

# អាមិសទាន & ធម្មទាន

## Āmisa-dāna & Dhamma-dāna


រៀបរៀងដោយ

**ឈុន_តឹមអៀត**


សម្រាប់ចែកជាធម្មទាន

# អាមិសទាន & ធម្មទាន

# Āmisa-dāna & Dhamma-dāna


រៀបរៀងដោយ

**ឈុន-តឹមអៀត**

ក្រុងឡុងប៊ីច, រដ្ឋកាលីហ្វ័រនីញ្ញា ស រ អ

ពិនិត្យនិងកែសម្រួលដោយ

ភិក្ខុ វិនយធរោ

មហា **យិន-សឿន**

ប្រធានពុទ្ធិកសមាគមខ្មែរទីក្រុងសានតាអាណា,
រដ្ឋកាលីហ្វ័រញ្ញា ស រ អ

ភិក្ខុមត្តេយោ

មហា **សុខ-សឿន**

វត្តសាមគ្គីធម្មារាម ក្រុងឡុងប៊ីច រដ្ឋកាលីហ្វ័រនីញ្ញា ស រ អ



បោះពុម្ពលើកទី១ចំនួន១០,០០០ច្បាប់

សម្រាប់ចែកជាធម្មទាន



រក្សាសិទ្ធិគ្រប់យ៉ាង



ព.ស.២៥៥៥ គ.ស.២០១១

# អារម្ភកថា

*សៀវភៅ* **អាមិសទាន** & **ធម្មទាន** *នេះជាស្នាដៃទីបីរបស់ខ្ញុំ បន្ទាប់ពីសៀវភៅ* **ទ្រឹស្តីកម្មផល** *និង សៀវភៅ* **ព្រះពុទ្ធដីកា** *ដែលបានទទួលការគាំទ្រយ៉ាងច្រើនបង្គួរ ពីសំណាក់សប្បុរសជន លោកអ្នកអានពីគ្រប់មជ្ឈដ្ឋាន ជាហេតុញ៉ាំងរូបខ្ញុំឱ្យកាន់តែមាន ទឹកចិត្តក្លាហាន មានវីរិយភាព និង មោទនភាពក្នុងកិច្ចការប្រមូល ចងក្រងជាសៀវភៅ ផ្នែកពុទ្ធសាសនាតទៅទៀត ។*

*វណ្ណកម្មថ្មីនេះ ខ្ញុំចងក្រងរៀបរៀងឡើង តាមសំណូមពររបស់ ឯកឧត្តម* **ហុង ទូហាយ** *សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី ២ ដែលលោកជាពុទ្ធមាមកជនមានចិត្តជ្រះថ្លាចេតនាមុតស្រួច ប្រាថ្នាបណ្តុះឧបនិស្ស័យទុកក្នុងថ្នាលព្រះពុទ្ធសាសនា ដូចខ្ញុំបាទផងដែរ ។*

*ក្នុងលោកសន្និវាសយើងនេះ មនុស្សម្នាក់ៗមានទស្សនៈ ជំនឿទិដ្ឋិ មិនដូចគ្នាទេ ហើយត្រូវបានគេចាត់ជាពីរប្រភេទ។ ប្រភេទទីមួយ ជាមនុស្សជឿកម្មផល បុណ្យបាប ចូលចិត្តធ្វើទាន រក្សាសីល ចំរើនភាវនា ។ ចំណែកប្រភេទទីពីរ ជាមនុស្ស មិនជឿកម្មផល កុសលាកុសល មិនចូលចិត្តធ្វើបុណ្យសុន្ទរទាន ថែមទាំងរិះគន់ទាយកទាយិកា ថាជាមនុស្សល្ងង់ខ្លៅ យកទ្រព្យសម្បត្តិខ្លួនឯង*

ទៅចែកចាយឱ្យគេទទេៗ ទៀតផង ។

ខ្ញុំសរសេរសៀវភៅនេះ ដោយច្រើនផ្អែកទៅលើគម្ពីរព្រះពុទ្ធសាសនា ដោយតិចបំផុតផ្អែកទៅលើទស្សនវិជ្ជា ក្នុងគោលបំណងជួយបំភ្លឺសប្បុរសជនប្រភេទទីមួយ ឱ្យបានយល់ច្បាស់ពីប្រភេទរបស់ទាន លក្ខណៈរបស់ទាន និង សិល្បៈបច្ចេកទេស នៃការធ្វើទានឱ្យបានត្រឹមត្រូវ តាមគន្លងព្រះពុទ្ធសាសនា មិនមានឆន្ទៈអន្ទងបញ្ចុះបញ្ចូលមនុស្សប្រភេទទីពីរ ឱ្យបរិច្ចាគទានឡើយ ហើយក៏រិតតែមិនមែន ដើម្បីចាក់ចេកចាក់ស្ករ ទាយក ទាយិកា ដែលមានសទ្ធាជ្រះថ្លាមកហើយនោះ ឱ្យជឿអានិសង្សទានផ្កាប់មុខ រហូតដាច់ចិត្តហ៊ានលក់ទ្រព្យសម្បត្តិ ស្រែចំការ ច្បារដំណាំ គោក្របី សេះដំរី យកមកធ្វើទានក៏ទេដែរ ។

គួរជ្រាបថា ព្រះពុទ្ធបរមគ្រូនៃយើង ថ្វីបើព្រះអង្គបានរកឃើញធម្មវិន័យ ដោយព្រះអង្គឯង ក៏ទ្រង់ពុំបានយកពុទ្ធភាពទៅគ្របសង្កត់ពួកសាវ័ក ឱ្យជឿនូវពុទ្ធវចនៈរបស់ព្រះអង្គ ទាំងងងឹតងងល់ ខ្វះការពិចារណារកហេតុផលឡើយ ។ ព្រះអង្គទ្រង់ដាស់តឿនក្រើនរំលឹកដល់ពុទ្ធសាសនិកជន ឱ្យប្រើវិចារណញ្ញាណ ឬសម្មាទិដ្ឋិ ការយល់ត្រឹមត្រូវមុននឹងជឿនូវអ្វីនីមួយៗ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនា ទុកក្នុងកាលាមសូត្រថា ៖

១- កុំប្រកាន់ជឿអ្វីដែលឮតៗ គ្នា មិនមានហេតុផល,

២- កុំប្រកាន់ជឿអ្វីដែលគេនិយាយតៗគ្នា មិនមានដើមចុង,

៣- កុំប្រកាន់ជឿអ្វីដោយការភ្ញាក់ផ្អើល,

៤- កុំប្រកាន់ជឿអ្វីដោយមើលឃើញសមតាមគម្ពីរខ្លួន,

៥- កុំប្រកាន់ជឿអ្វីដោយការនឹកដៅឬស្មានយក(អនុមាន),

៦- កុំប្រកាន់ជឿអ្វីដោយអាងការគ្នេរគ្នាន់ ឬ កាត់តម្រូវ,

៧- កុំប្រកាន់ជឿអ្វីដោយអាងការត្រិះរិះតាមអាការៈ,

៨- កុំប្រកាន់ជឿអ្វីដោយអាងថា ត្រូវនឹងទិដ្ឋិរបស់ខ្លួន,

៩- កុំប្រកាន់ជឿថា អ្នកនេះជាអ្នកប្រាជ្ញគួរជឿតាម ,

១០- កុំប្រកាន់ជឿថា សមណៈជាគ្រូយើង ។

ពាក្យប្រៀនប្រដៅនេះ ព្រះដ៏មានព្រះភាគទ្រង់ទេសនាទុកយូរយារណាស់មកហើយ ហើយស្ថិតនៅតាមសំណៅដើមដដែលឃើញហាក់ដូចជានៅថ្មីៗ ។ ពុទ្ធវចនៈនេះបញ្ជាក់ច្បាស់ថា ព្រះពុទ្ធសាសនា ជាសាសនាប្រគល់សេរីភាពឱ្យបុគ្គលម្នាក់ៗ ក្នុងការជឿ ការនិយាយ ការធ្វើ ការគិត ពុំព្រមឱ្យប្រើជំនឿឥតហេតុ ផលទេ សូម្បីតែក្នុងការធ្វើទានក៏ដោយ ។ ដូច្នេះហើយបានជាមានពុទ្ធភាសិតមួយថា "**វិចេយ្យ ទានំ សុគតប្បសត្ថំ** កាលពិចារណាហើយឱ្យ ជាអំពើដែលព្រះសុគតទ្រង់សរសើរ " ។

*ខ្ញុំសង្ឃឹមថា ស្នាដៃខ្ញុំនេះ គង់អាចបានជាប្រទីបតូចមួយ ជួយបំភ្លឺសប្បុរសជនមិត្តអ្នកអាន ឱ្យបានយល់ពីទានូបនិស្ស័យ ទានានិសង្ស និងសិល្បៈបច្ចេកទេសក្នុងការធ្វើទានឱ្យបានផលល្អ តាមគន្លងព្រះពុទ្ធោវាទ ។*

*ខ្ញុំសូមអភ័យទោសទុកជាមុន ពីសំណាក់អ្នកប្រាជ្ញ រាជ-បណ្ឌិត អត្ថកោវិទ ខាងព្រះពុទ្ធសាសនា ប្រសិនបើអស់លោកជួបប្រទះឃើញមានកំហុសឆ្គាំឆ្គងផ្នែកនិយមន័យ ពាក្យពេចន៍ ឃ្លាប្រយោគ ឬ អក្ខរាវិរុទ្ធ ដូចម្ដេចក្ដី សូមមេត្តាកែលំអ ដោយសន្ដានចិត្តអនុគ្រោះឱ្យទានខ្ញុំបាទផង ។ ខ្ញុំបាទ រង់ចាំទទួលនូវការរិះគន់ស្ថាបនា ដោយចិត្តស្មោះស រីករាយជាទីបំផុត ។*

*ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរៀបរាប់អំពីជីវប្រវត្តិសង្ខេបរបស់ខ្ញុំ ។ ខ្ញុំបាទកើតនៅឆ្នាំ ១៩៤៦ ( ថ្ងៃខែមិនប្រាកដ ) នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ លោកឪពុកឈ្មោះ* **ឈុន ហួយ** *អ្នកម្ដាយឈ្មោះ* **ពោ លន់** *។ ខ្ញុំបាទមានបងប្អូន ប្រាំនាក់ ប្រុសពីរនាក់ និង ស្រីបីនាក់ ហើយខ្ញុំជាកូនប្រុសច្បង ។*

*ជីវិតនៅមាតុភូមិក្នុងយុវវ័យ ការសិក្សារបស់ខ្ញុំ បានត្រឹមមធ្យមសិក្សា ។ ខ្ញុំបាទបានលាចាកការសិក្សានៅ ឆ្នាំ ១៩៦៦ មករកទទួលទានជាជនសាមញ្ញ ។ ក្រោយរបបប្រល័យពូជសាសន៍*

**ម៉ុល ពត** នាចុងឆ្នាំ ១៩៧៩ ខ្ញុំបានភៀសខ្លួនចូលមករស់នៅជំរំខាវអ៊ីដាងនៅក្នុងទឹកដីនៃប្រទេសថៃ ។ នៅខែសីហា ឆ្នាំ១៩៨១ ត្រូវបានរដ្ឋាភិបាលអាមេរិកកាំង អនុញ្ញាតឱ្យចូលមករស់នៅក្នុងទឹកដីសហរដ្ឋអាមេរិក ក្នុងនាមជាជនភៀសខ្លួន នៅក្រុងឡុងប៊ិច ( Long Beach រដ្ឋកាលីហ្វ័រញ៉ា ( California ) ។

ជីវិតក្នុងទឹកដីថ្មីនេះ ខ្ញុំឆ្លៀតឱកាសបន្តវិជ្ជា នៅមហាវិទ្យាល័យទីក្រុងឡុងប៊ិច អស់រយៈពេល ៣ ឆ្នាំ ។ នៅថ្ងៃទី ៨ ខែមិថុនា ១៩៨៤ ( June 8, 1984 ) ខ្ញុំបានទទួលអនុបរិញ្ញាប័ត្រផ្នែកអេលិចត្រូនិច ( The Degree of Associate in Science majoring Electronic Technology ) ។

ក្នុងឆាកជីវិតរបស់ខ្ញុំ ថ្វីបើខ្ញុំពុំបានសិក្សាខ្ពង់ខ្ពស់វែងឆ្ងាយ ប៉ុន្តែដោយខ្ញុំមានជំនឿជឿជាក់លើព្រះពុទ្ធសាសនា ដើរតាមគន្លងព្រះពុទ្ធោវាទ ប្រកាន់យកមាគ៌ាខ្លះ នៃមាគ៌ាទាំង ៨ គឺ ប្រកាន់នូវសម្មាវាយាមៈ (ការប្រឹងប្រែងព្យាយាមត្រូវ), សម្មាកម្មន្តៈ (ការងារត្រឹមត្រូវ) និង សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រឹមត្រូវ) ខ្សែជីវិតខ្ញុំបានជួបប្រទះសេចក្តីសុខចំរើន មានជីវភាពសមរម្យក្នុងទឹកដីថ្មី ។

☆ ✲ ☆

# សេចក្តីថ្លែងអំណរព្រះគុណ និង អរគុណ

*ខ្ញុំសូមថ្លែងអំណរព្រះគុណ និង អរគុណយ៉ាងជ្រាលជ្រៅបំពោះ ៖*

*-ភិក្ខុវិនយធរោ* **មហា យិន - ឡឿន** *ប្រធានពុទ្ធិកសមាគមខ្មែរ នៅទីក្រុងសាន់តាអាណា* ( Santa Ana, California ) *ដែលព្រះអង្គបានជួយកែសម្រួលវាក្យស័ព្ទ ភាសាបាលី និង អត្ថន័យ ព្រមទាំងបានផ្តល់ក្បួនច្បាប់ផ្សេងៗ សម្រាប់ដកស្រង់មកបញ្ចូល ក្នុងសៀវភៅនេះ ។*

*-ភិក្ខុធម្មត្ថេរោ* **មហា សុខ - សឿន** *គង់នៅវត្តសាមគ្គីធម្មារាម ក្រុងឡុងប៊ិច* ( Long Beach, California ) *ដែលព្រះអង្គបានជួយវាយអក្សរកុំព្យូទ័រ* ( *computer* ) *និងជួយពិនិត្យ អត្ថន័យ ឃ្លាល្បះ អក្ខរាវិរុទ្ធដោយអស់ពីសមត្ថភាពមិនខ្លាចនឿយព្រះកាយ ។*

*-លោក* **អ៊ុច -ឈាត** *ប្រធានវត្តខេមរពុទ្ធិការាម ក្រុងឡុង-ប៊ិច* ( Long Beach, California ) *ដែលលោកបានជួយផ្ទៀងផ្ទាត់កែសម្រួលឃ្លាល្បះ អក្ខរាវិរុទ្ធ និង ផ្តល់គំនិតដ៏ល្អៗ ធ្វើឱ្យសៀវភៅនេះមានអត្ថរូប អត្ថរស និង អត្ថន័យអាចទទួលយកបាន ។*

*-លោក* **គុជ - សុជាតិ** *ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ជួយរចនាក្របសៀវភៅនេះ ឱ្យមានសោភ័ណ-*

ភាព គួរជាទីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

-ឯកឧត្តម **ហុង -ទូហាយ** សមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជាអាណត្តិទី ២ ដែលលោកមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ផ្តួចផ្តើមគំនិត និង សំណូមពរឱ្យខ្ញុំសរសេរសៀវភៅនេះ ផ្សាយជាធម្មទាន ។

ប្រសិនបើគ្មានការឧបត្ថម្ភជួយជ្រោមជ្រែង ពីសំណាក់ព្រះសង្ឃ និង អស់លោកដូចបានជម្រាបខាងលើនេះទេ សៀវភៅ **អាមិសទាន & ធម្មទាន** នេះ ប្រាកដជាពុំបានលេចចេញជារូបរាង ជាសមិទ្ធិកម្មថ្លៃថ្លា សម្រាប់ព្រះពុទ្ធសាសនាឡើយ ។

## ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសបុណ្យកុសល ដែលបានកើតឡើងអំពីសេចក្តីព្យាយាមអត់ធន់ ដកស្រង់ប្រមូលរៀបរៀងជាសៀវភៅនេះ ជូនចំពោះមាតាបិតា គុណគ្រូឧបជ្ឈាយាចារ្យ ញាតិកាទាំង ៧ សន្តាន ដែលមានជីវិតរស់នៅសព្វថ្ងៃក្តី ដែលបានចែកឋានទៅហើយក្តី សូមអនុមោទនាកុសលផលបុណ្យ នៃធម្មទាននេះ ដោយចិត្តជ្រះថ្លា ហើយសូមឱ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺ សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

**អាមិសទាន & ធម្មទាន**

*ម្យ៉ាងទៀត ខ្ញុំសូមឱ្យអស់លោកមិត្តអ្នកអានបានជួបប្រទះ នូវពុទ្ធពរទាំងឡាយ បួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសាសនាព្រះសមណគោតមព្រះបរមគ្រូ មានអាយុយឺនយូរគ្រប់កំណត់៥០០០ព្រះវស្សា ដើម្បីជាម្លប់សាខាដ៏ត្រជាក់ត្រជុំដល់សត្វទាំងឡាយក្នុងត្រៃភព ។*

សូមឱ្យសេចក្តីបរិសុទ្ធិ ស្ថិតនៅក្នុងសន្តានចិត្តសត្តនិករ ជានិច្ចនិរន្តរ៍ ។

**សព្វេ សត្តា សុខី ហោន្តុ**

*សូមសព្វសត្វទាំងឡាយ បានសុខសប្បាយ ។*

***May all Beings be Happy .***

ឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក

*ថ្ងៃ ៣ រោច ខែអស្សុជ ព.ស. ២៥៥៤*

*ត្រូវនឹងថ្ងៃទី ២៦ ខែ តុលា គ.ស.២០១០*

**ឈុន -គឹមអៀត**

# មាតិកា


| ឈ្មោះអត្ថបទ | ទំព័រ |
|---|---|
| អារម្ភកថា របស់អ្នករៀបរៀង | ក |
| កំណាព្យសម្តេចព្រះសង្ឃរាជ ជួន ណាត | ជ |
| កំណាព្យសម្តេចព្រះសង្ឃរាជ ជួន ណាត | ថ |
| សេចក្តីផ្តើម | ១ |
| ធម្មទាន | ៧ |
| អាមិសទាន | ១៥ |
| ទានសង្គហៈ | ២៧ |
| ទានក្នុងអនុបុព្វីកថា | ២៩ |
| ទានក្នុងសប្បុរិសបញ្ញត្តិ | ៣១ |
| សប្បុរិសទាន | ៣៥ |
| សង្គហធម៌របស់មាតាបិតា | ៣៩ |
| សង្គហធម៌របស់បុត្រធីតា | ៤១ |
| សង្គហធម៌របស់ស្វាមី | ៤២ |
| សង្គហធម៌របស់ភរិយា | ៤៥ |
| សង្គហធម៌របស់ចៅហ្វាយនាយ | ៤៦ |
| សង្គហធម៌របស់ទាសកម្មករ | ៤៨ |

**អាមិសទាន & ធម្មទាន**


| | |
|---|---|
| ទានប្បភេទ | ៥០ |
| អភ័យទាន | ៥៤ |
| ទក្ខិណានុប្បទាន | ៥៦ |
| ទានលក្ខណៈ | ៧០ |
| ទានមានផលល្អ | ៨១ |
| ធម្មទ្ធទាន | ៨៦ |
| ទានានិសង្ស | ៩១ |
| ទានវិចារណកថា | ១០៥ |
| ធ្វើទានបានក្រឬ ? | ១១៤ |
| ភ័ព្វព្រេងសំណាង | ១២១ |
| រឿងតោទេយ្យព្រាហ្មណ៍ | ១៥១ |
| ព្រះបោបិលត្ថេរ | ១៥៧ |
| អវសានកថា | ១៦១ |
| សៀវភៅដែលខ្ញុំដកស្រង់ | ១៧១ |
| សេចក្ដីជូនដំណឹង | ១៧២ |
| បញ្ជីរាយឈ្មោះសប្បុរសជន | ១៧៣ |

# កាព្យពាក្យ ៧ ស្ដីពីអបាយមុខ

អបាយមុខជម្រុកហិន សង្កិនឱ្យក្ដៅដួងហឫទ័យ
ច្រើននាំអ្នកលេងឱ្យសន្ទៃ យប់ថ្ងៃដេកព្រួយនឹកស្ដាយក្រោយ។
កំពុងប្រព្រឹត្តងងឹតឈឹង លុះដល់រំពឹងឃើញញឹកញយ
ទើបបានយល់ច្បាស់ថាខ្លួនធ្លោយ ជួនក៏បណ្ដោយដេញដើងទៀត ។
ដេញដើងត្រាតែឃើញលិចលង់ រឹតតែល្ងង់ទ្រូងចង្អៀត
អ្នកខ្លះម៉្លឹងហើយនៅតែធ្មៀត អង្រៀតនឹងស្លាប់ទើបថយក្រោយ ។
ទំពាំភ្ញាក់ខ្លួនជួនអស់ទ្រព្យ ជួនកាលធ្លាក់ជាប់ដល់រូបខ្សោយ
កើតរោគឈឺចាប់ស្លាប់បណ្ដោយ គួរឱ្យព្រឺខ្លាចអបាយមុខ ។
ហេតុនោះយុវនៃយុវតី នាងអ្នកប្រុសស្រីគួរខ្លាចទុក្ខ
ឱ្យហើយពីក្មេងទាន់មានសុខ ត្រូវខំសម្រុកប្រឹងរៀនសូត្រ ។
នាងអ្នកចូររៀនកុំធុញទ្រាន់ ទាន់វ័យនៅក្មេងត្រូវខំស្រូត
ស្រូតរៀនឱ្យទាល់តែរហូត បានដល់កោះត្រើយសឹមសម្រាក។
វិទ្យាជាទ្រព្យដ៏ចម្បង កន្ទង់លើសលែងឥតទ្រព្យសាក
ជាទ្រព្យស្រាលផងមិនលំបាក វេចជាបង្វេចស្ពាយពុនរែក ។
ទៅមកយកជាប់ទៅជាមួយ វិទ្យាអាចជួយឃើញទាន់ភ្នែក
ចង់បានអ្វីៗវិទ្យាស្រែក ហៅទ្រព្យប្លែកៗឱ្យមូលមក ។

**( សម្ដេចព្រះសង្ឃរាជ ជ.ណ ជោតញ្ញាណោ )**

# កាព្យពោលពីញៀនដោយសង្ខេប
## បទភាគគតិ

ញៀនក្នុងលោកីយ៍ ពុំអាចដើម្បី ស្រដីពណ៌នា
ញៀនជក់បារី ញៀនជាប់ស៊ីស្វា ញៀនផឹកសុរា
ញៀនជក់អាភៀន ។

ញៀនល្បែងស៊ីសង ញៀនក្រេកន្ទង ញៀនខំសូត្ររៀន
ញៀនដើរលេងយប់ តាមច្រកតាមភៀន មួយយ៉ាងហៅញៀន
ជក់មើលមហោស្រព ។

ញៀនលេងចត្រង្គ ញៀនតែងរូបអង្គ ញៀនលាបទឹកអប់
ញៀនជក់កញ្ឆា និងញៀនទាំងគ្រប់ ពណ៌នាពុំចប់
សុទ្ធតែហៅញៀន ។

ញៀនអស់ទាំងនេះ មានញៀនខ្លះចេះ បំពេញការរៀន
ឱ្យមានចំណេះ វិជ្ជារបៀន បែបនេះហៅញៀន
បំពេញប្រយោជន៍ ។

ញៀនធ្វើការងារ ធ្វើស្រែចំការ មិនឱ្យខ្វះហោច
នេះត្រូវញៀនចុះ ព្រោះមានប្រយោជន៍ បើមានការហោច
កុំបីញៀនឡើយ ។

( **សម្តេចព្រះសង្ឃរាជ ជ.ណាត ជោតញ្ញាណោ** )

# សេចក្តីផ្តើម

*ពាក្យថា **ទាន** ជាភាសាបាលី ឬ សំស្ក្រឹត ជានាមស័ព្ទផង ជាកិរិយាស័ព្ទផង ។ **ទាន** ជានាមស័ព្ទ ប្រែថា អំណោយ (ការឱ្យ) អ្វីៗដែលគួរឱ្យ ។ រីឯ **ទាន** ជាកិរិយាស័ព្ទ ប្រែថា ឱ្យ ជូន ប្រគេន ថ្វាយ (តាមឋានានុក្រម) ។ ក៏ប៉ុន្តែ ខ្មែរយើងនិយមនិយាយថា ឱ្យទាន, ធ្វើទាន, បរិច្ចាគទាន, ចែកទាន, សូមទាន, ទូលទាន.....។*

*តើទានមានប្រវត្តិពីត្រឹមណា ? តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញខាង ប្រវត្តិវិទ្យា សាសនវិទ្យា សង្គមវិទ្យា និង ទស្សនវិជ្ជា គេបានព្រមព្រៀងគ្នារកឃើញថា ទានជាគុណធម៌មួយមានមកតាំងពីការកើតឡើងនៃពិភពលោក ឬ ការកើតឡើងនៃមនុស្សជាតិ ដែលអាស្រ័យលើទីបលោក ។*

*សក្ខីភាពច្បាស់ក្រឡែត គឺសមិទ្ធិសំណង់ ដែលសម្រេចរូបរាងបានទាំងក្នុងបុរាណកាល ទាំងបច្ចុប្បន្នកាល ក្នុងពិភពលោកទាំងមូលនេះ ដូចជាទួរអេហ្វែល* (Eiffel Tower)*នៅប្រទេសបារាំងប្រាសាទ ពីរ៉ាមីត* ( Pyramid ) *នៅប្រទេសអេហ្ស៊ីប* ( Egypt )*មហាកំផែង* ( Great Wall ) *នៅប្រទេសចិន អង្គរវត្តនៅប្រទេសខ្មែរជាដើម សុទ្ធសឹងតែកើតឡើងពីអំណោយរបស់មនុស្ស ។*

*ម្យ៉ាងទៀត មនុស្សគ្រប់ជាតិសាសន៍ ដែលរស់នៅ រងោក*

វណ្ណករណែល លើពិភពលោកយើងនេះ ក៏ជាសមិទ្ធិរបស់មនុស្ស ក្នុងសម័យបូរាណតគ្នាតាមលំដាប់រៀងមកដល់សព្វថ្ងៃ ។ ចំណុច នេះសបញ្ជាក់ថា មនុស្សកើតមករស់នៅ រីកចំរើន ព្រោះតែមាន អំណោយរបស់មនុស្ស គឺ មាតាបិតា ចិញ្ចឹមបុត្រធីតា បុព្វជន ចិញ្ចឹមអនុជនតៗគ្នាមក ។ ការចិញ្ចឹមនេះ គេនិយមយកមកប្រើ ជាពាក្យថា ទំនុកបំរុង ថាផ្គុំផ្គើម ថាថែរក្សា ។ លុះព្រះពុទ្ធបរម គ្រូបានត្រាស់ដឹងក្នុងលោក ទ្រង់បានយកពាក្យនេះ មកប្រើជា **ទាន** ដែលមានន័យច្រើនយ៉ាងគួរឱ្យកត់សំគាល់ ។

ធម្មទេសនាក្នុង **គម្ពីរមង្គលត្ថទីបនី** ព្រះសព្វញ្ញុពុទ្ធទ្រង់ ត្រាស់អំពីទាន មានន័យ ៣ យ៉ាង ដោយអំណាចនៃចាគចេតនា វិរតិ និង ទេយ្យធម៌ ។ ន័យ ៣ យ៉ាងនោះ គឺ ៖

១- **ចាគចេតនា ទានំ** ចេតនាដែលលះទេយ្យវត្ថុឱ្យដល់ បុគ្គលដទៃ ឈ្មោះថា ទាន ។

២- **វិរតិ ទានំ** ចេតនាដែលវៀរចាកអកុសលកម្ម មាន បាណាតិបាត ជាដើម ឈ្មោះថា ទាន ។

៣- **ទេយ្យធម្មោ ទានំ** ទេយ្យធម៌គឺវត្ថុដែលគេត្រូវលះឱ្យ ដល់បុគ្គលដទៃ ឈ្មោះថា ទាន ។

ទន្ទឹមគ្នានេះផងដែរ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់សំដែង

*ពន្យល់ជារឿយៗ អំពីន័យខុសគ្នា រវាង* **ទាន** *និង* **ចាគ** *ឱ្យពុទ្ធបរិស័ទយល់ច្បាស់ ហើយមានសទ្ធាជ្រះថ្លា បំពេញឧបនិស្ស័យក្នុងការធ្វើទាន ។ ព្រះទសពល ទ្រង់អធិប្បាយពីន័យ ៤ យ៉ាងផ្សេងទៀត របស់ទាន និង ន័យ ៤ យ៉ាង របស់ចាគៈ ។*

## ន័យ ៤ យ៉ាង របស់ទាន គឺ៖

*១-* **ទាន** *អំណោយណាមួយ ដែលនៅជាប់ជំពាក់ដោយមច្ឆរិយៈ (សេចក្ដីកំណាញ់) ឬ ឱ្យដោយស្ទាក់ស្ទើរ មិនជ្រះស្រឡះចាកមច្ឆរិយៈ ឬក៏ ជាអំណោយតាមទំនៀមទម្លាប់នៃវង្សត្រកូល ។*

*២-* **ទាន** *អំណោយដែលជាប់ដោយតណ្ហា គឺ ទាយកអ្នកឱ្យទានប្រាថ្នាយកសេរីសួស្ដី និង ផលប្រយោជន៍ មកខ្លួនវិញ ចំពោះអាមិសសុខ ក្នុងភពនេះ ឬ ភពខាងមុខ ។*

*៣-* **ទាន** *អំណោយមិនសមគួរ គឺ បុគ្គលណា មានទ្រព្យសម្បត្តិច្រើន មានវត្ថុថ្លៃថ្លាច្រើន លុះត្រូវការចាត់ចែងទាន បុគ្គលនោះ ក៏ចាត់ចែងដោយរលីបរលោបស្ដួចស្ដើង ដោយវត្ថុថោកទាបធម្មតា មិនសមតាមសក្តិតាមកម្លាំង នៃទ្រព្យសម្បត្តិរបស់ខ្លួន ។*

*៤-* **ទាន** *អំណោយចំពោះមុខបដិគ្គាហកៈអ្នកទទួលផ្ទាល់ ដែលជាបុគ្គលខ្សត់ខ្សោយដោយគុណធម៌ និង ទ្រព្យសម្បត្តិ ឬ មានគុណធម៌ខ្ពង់ខ្ពស់ ។*

## ន័យរបស់ចាគៈ ៤ យ៉ាង គឺ៖

១- **ចាគ** ការលះវត្ថុណាមួយចំពោះបដិគ្គាហកៈដើម្បីលះបង់ ឬ សង្កត់សង្កិន លោភៈ និង មច្ឆរិយៈ ឱ្យស្រាលស្តើងពីសន្តាន គឺ ចំណាយទ្រព្យធន ដើម្បីទុកជាអលង្ការ ឬ ជាកល្យាណវត្ថុរបស់ចិត្ត មិនបណ្តោយឱ្យចិត្តជ្រលក់ជាប់នៅក្នុងកិលេស ។

២- **ចាគ** ការឱ្យដោយមិនជាប់ជំពាក់ដោយតណ្ហា គឺ ឱ្យដោយបំណងចំពោះនិរាមិសសុខ ដើម្បីធ្វើចិត្តឱ្យបរិសុទ្ធ ឱ្យបញ្ញារបស់ខ្លួនមានកំម្លាំងលូតលាស់ឡើងផង ដើម្បីជាប្រយោជន៍ និងសេចក្តីចុំចម្រើង ជាតម្រាប់ដល់បច្ឆាជនជំនាន់ក្រោយផង ដូចយ៉ាងការចំណាយទ្រព្យសម្បត្តិ ជួយឧបត្ថម្ភព្រះពុទ្ធសាសនា កសាងសេនាសនៈ ថ្នល់ស្ពាន អណ្តូងទឹក សាលារៀន មន្ទីរពេទ្យ មជ្ឈមណ្ឌលវិបស្សនា សម្រាប់ជាសាធារណប្រយោជន៍ ។

៣- **ចាគ** ការលះឱ្យវត្ថុដ៏ច្រើនក្រៃលែង ឬ ខ្ពង់ខ្ពស់លើសវិស័យរបស់មនុស្សសាមញ្ញក្នុងលោកគួរឱ្យស្ញើច ដែលរាប់ថាជាការបរិច្ចាគយ៉ាងខ្ពង់ខ្ពស់បំផុត កម្រអ្នកផងលះបាន ដូចជាមហាបរិច្ចាគនៃព្រះពោធិសត្វ ។

៤- **ចាគ** ការលះកាត់អាល័យក្នុងជីវិត និង សេចក្តីសុខក្នុងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដើម្បីស្វះស្វែងរកឧបាយ ជួយជ្រោមជ្រែង

*មនុស្សក្នុងលោក ឬ លះបង់ទ្រព្យសម្បត្តិ ចែកចាយជាប្រយោជន៍ផ្ដល់សេចក្ដីសុខចំរើនរុងរឿង ដល់មហាជនទុកជាកេរ្ដិ៍ដំណែល ។*

*តាមរយៈន័យផ្សេងគ្នា ដូចដែលបានពិពណ៌នា មកនេះ គេអាចសង្កេតមើលឃើញច្បាស់ថា* **ចាគ** *មានកម្លាំងជាង* **ទាន** *ឬថាជាធម៌ខ្ពង់ខ្ពស់ផ្សាយរស្មីរុងរឿងទូលំទូលាយល្អជាង* **ទាន** *។ ប៉ុន្តែ* **ទាន** *និង* **ចាគ***នេះ បើពោលតាមលក្ខណៈរួបរួមមានន័យជាអំណោយ ការចែករំលែកទ្រព្យសម្បត្តិចំពោះសត្វ ឬ បុគ្គលដទៃប៉ុណ្ណោះ ។ តែបើនិយាយតាមហេតុផលវិញ* **ទាន** *ជាឈ្មោះបរិក្ខារវត្ថុដែលគេត្រូវឱ្យ ។* **ចាគ** *ជាឈ្មោះ ចេតនា ដែលជាចេតសិកសម្រាប់លះ ។ ចាគ ចាត់ជាហេតុ រីឯ ទាន ចាត់ជាផលអាស្រ័យគ្នាទៅវិញទៅមក គឺថាបើមានតែ ចាគចេតនា ប៉ុន្តែខ្វះទេយ្យវត្ថុ ឬក៏មានទេយ្យវត្ថុ ប៉ុន្តែខ្វះចាគចេតនា ទានមិនអាចកើតឡើងបាន ឬ ប្រព្រឹត្តទៅបានឡើយ ។*

*គម្ពីរ* **អង្គុត្តរនិកាយទុកនិបាត** *អធិប្បាយទុកជាគោលដើមតាមលំអានពុទ្ធភាសិតថា:* " **ទ្វេមានិ ភិក្ខវេ ទានានិ ។ កតមានិ ទ្វេ ។ អាមិសទានញ្ច ធម្មទានញ្ច ។ បេ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ** "(១) ។

---

(១)- សុត្តន្តបិដក អង្គុត្តរនិកាយ ភាគ ៤០ ទំព័រ ២០៥

**អាមិសទាន & ធម្មទាន**

*ប្រែថា: ម្នាលភិក្ខុទាំងឡាយ ទានមាន២ ប្រការ ទានទាំង ២ ប្រការ តើដូចម្តេចខ្លះ ? ( ទានទាំង២ ប្រការនោះ ) គឺ៖*

១- **អាមិសទាន** *ការឱ្យអាមិសជាទាន,*

២- **ធម្មទាន** *ការឱ្យធម៌ជាទាន ។*

*ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ ប្រការនេះ គឺធម្ម-ទាន ជាទានប្រសើរជាងអាមិសទាន ។*

*តាមរយៈការសិក្សាស្វែងយល់លំអិត អំពីទាន គេបានដឹងថា* **អាមិសទាន** *និង* **ធម្មទាន** *ត្រូវបានបុរាណាចារ្យ លោកចាត់ជាទានចម្បងពីរក្នុងបណ្តាទាននានាក្នុងពុទ្ធសាសនា ព្រោះថាប្រភេទទានដទៃផ្សេងទៀត រមែងត្រូវសង្គ្រោះចូល ក្នុងអាមិសទាន ឬ ក្នុងធម្មទាន ណាមួយដោយចៀសមិនរួច។ ហេតុនេះទើបខ្ញុំលើកយកទានចម្បងពីរនេះ មកធ្វើជាប្រធានបទ ព្រមទាំងចំណងជើងនៃសៀវភៅខ្ញុំនេះថា* **អាមិសទាន** *និង* **ធម្មទាន** *។*

*ម្យ៉ាងវិញទៀត ព្រះពុទ្ធបរមគ្រូនៃយើង មុននឹងព្រះអង្គបានត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ព្រះអង្គទ្រង់បានបំពេញទានបារមី ទានឧបបារមី និង ទានបរមត្ថបារមីជាច្រើនតំណជាតិ ។*

# ធម្មទាន

**ធម្មទាន** *មកពីពាក្យថា* **ធម្ម** + **ទាន** = **ធម្មទាន** *ប្រែថា ឱ្យធម៌ជាទាន ។ ការឱ្យធម៌ជាទានដល់អ្នកដទៃ ដូចជាការពន្យល់ ណែនាំបង្ហាត់បង្រៀនធម៌ សំដែងធម៌ ស្តាប់ធម៌ ការកសាងគម្ពីរ ដែលជាព្រះពុទ្ធដីកា និង ការឱ្យសៀវភៅក្បួនច្បាប់ សម្រាប់អាន ទន្ទេញ រៀនសូត្រ ចេះចាំ យល់ដឹងពីព្រះធម៌ ហៅថា ធម្មទាន ។ ធម្មទាន ចែកចេញជា ២ ប្រភេទ គឺ ៖*

១- **លោកិយធម្មទាន**

២- **លោកុត្តរធម្មទាន**

**លោកិយធម្មទាន** *ប្រែថាឱ្យធម៌សម្រាប់លោក ដោយន័យថា ឱ្យបញ្ញា ចំណេះវិជ្ជា សម្រាប់ធ្វើឱ្យបានចំរើន ក្នុងឥធលោក (លោកបច្ចុប្បន្ន) និង បរលោក (លោកខាងមុខ) បានដល់ វិជ្ជាពុទ្ធសាសនា* (១) *ថ្នាក់ដំបូង ថ្នាក់កណ្តាល វិជ្ជាអក្សរសាស្ត្រ*

---

១)- វិជ្ជាពុទ្ធសាសនា ចែកជាបី ថ្នាក់គឺ ថ្នាក់ដំបូង ( ថ្នាក់ទី១ ) ថ្នាក់កណ្តាល ( ថ្នាក់ទី២ ) ថ្នាក់បំផុត (ថ្នាក់ទី៣)។ ថ្នាក់ដំបូងបានដល់ទិដ្ឋធម្មិកត្ថប្រយោជន៍(ប្រយោជន៍បច្ចុប្បន្ន) មាន៤យ៉ាងគឺ៖ *ឧដ្ឋានសម្បទា១, អារក្ខសម្បទា១,កល្យាណមិត្តតា១,សមជីវិតា១ ។* ថ្នាក់កណ្តាលបានដល់ សម្បរាយិកត្ថប្រយោជន៍ (ប្រយោជន៍បរលោក) មាន៤យ៉ាងគឺ៖ *សទ្ធាសម្បទា១,សីលសម្បទា១,ចាគសម្បទា១,បញ្ញាសម្បទា ១ ។* ថ្នាក់ទីបំផុតបានដល់បរមត្ថប្រយោជន៍ ប្រយោជន៍ដ៏ល្អិតសុខុម ឯកន្តបរមសុខ (សុខក្នុងព្រះនិព្វាន) មាន ៣ យ៉ាងគឺ៖ *សីល១, សមាធិ១, បញ្ញា១* ទាំងបីនេះហៅថា ត្រៃសិក្ខា ។

គណិតវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា វិទ្យាសាស្ត្រសេដ្ឋកិច្ច.....។

**លោកុត្តរធម្មទាន** ប្រែថា ឱ្យវិជ្ជា ឱ្យបញ្ញា ( វិបស្សនាបញ្ញា ឬ វិបស្សនាញាណ ) សម្រាប់វែកញែក អំពី សង្ខារធម៌ ត្រៃលក្ខណធម៌ សច្ចធម៌ សម្រាប់រំដោះ មនុស្ស សត្វ ចេញចាកត្រៃលោក បានដល់វិជ្ជាពុទ្ធសាសនា ថ្នាក់ទីបំផុត ឬ ថ្នាក់បរមត្ថវិជ្ជា ។ **លោកុត្តរធម្មទាន**នេះជួនកាលលោកហៅថា **សិប្បត្តធម្មទាន**។

ដើម្បីឱ្យសប្បុរសជន បានយល់ច្បាស់ អំពីការបរិច្ចាគផ្សព្វផ្សាយ ចំណាយធម្មទាន បុរាណាចារ្យបានសំដែងពីរបៀបធ្វើធម្មទាន ដោយចែកចេញជា ៣ ប្រការ ។

**ធម្មទានចែកចេញជា ៣ ប្រការនោះ គឺ ៖**

១- **កថនំ** ពោលពាក្យពន្យល់,

២- **វាចនំ** បង្រៀន,

៣- **ធម្មទេសនំ** សម្ដែងធម្មទេសនា ។

**កថនំ** ( ពោលពាក្យពន្យល់ ) បានន័យថា ពោលពាក្យពន្យល់ណែនាំ ធ្វើអត្ថាធិប្បាយព្រះធម៌ដោយតាំងចិត្តឱ្យអ្នកស្ដាប់ចេះដឹងយល់ចូលចិត្តពីអត្ថន័យ និង ជម្រៅរបស់ព្រះធម៌ ដូចជា កុសល អកុសល បាប បុណ្យ គុណទោស ខុសត្រូវ មិច្ឆាទិដ្ឋិ សម្មាទិដ្ឋិ ធម៌ណាគួរប្រតិបត្តិ ធម៌ណាគួរវៀរចាក ធម៌ណាអាច

ជួយកំចាត់បង់នូវកិលេសក្នុងសន្តានបានដាច់ដាច់ មានជាអាទិ៍ ធ្វើទាន រក្សាសីល ចំរើនភាវនាជាដើម។ អកុសលធម៌មានលោភៈ ទោសៈមោហៈ អហិរិកៈ អនោត្តប្បៈ ដែលជាធម៌ប្រព្រឹត្តទៅនាំមក នូវសេចក្តីទុក្ខសៅហ្មងចិត្ត នាំមកនូវក្តីវិប្បដិសារីក្តៅក្រហល់ក្រហាយ ត្រូវលះបង់ចោលជាដាច់ដាច់ ។ ល ។

**វាចនំ** ( ការបង្រៀន ) បានន័យថា បង្រៀនធម៌ ដល់អ្នក ដែលមានចិត្តប្រាថ្នា ចង់ចេះ ចង់ដឹង ដោយវិធីផ្សេងៗ ដូចជាការ បង្រៀនផ្ទាល់មាត់ សរសេរជាសៀវភៅ អាត់ជាខ្សែអាត់ ជា ស៊ីឌី ( CD )ជា ឌីវីឌី ( DVD ) ឱ្យដល់អ្នកទទួលបានអាន ស្តាប់ រៀន ទន្ទេញ សូត្រ រហូតបានចេះចាំយល់អត្ថន័យរបស់ព្រះធម៌ ។

**ធម្មទេសនំ** (សំដែងធម៌ទេសនា) បានន័យថា ធម្មាចារ្យ ដែលជាពហុស្សូត មានប្រាជ្ញា បានសិក្សាគម្ពីរព្រះត្រៃបិដក ចេះ ចាំ ដឹងយល់ ជម្រៅនៃអត្ថន័យព្រះធម៌ មានសំនួនវោហារស័ព្ទ ល្បី ល្បាញ មានថ្វីមាត់ អាចសម្តែងលើធម្មាសនៈក្តី ពោលសម្តែងជា ទូទៅក្តី ធ្វើឱ្យអ្នកស្តាប់ចាប់អារម្មណ៍ អំពីរសរបស់ព្រះធម៌ ដូចជា សម្តែងអំពី ទាន សីល ភាវនា ជាលោកិយធម្មទានក្តី សម្តែងពី អរិយសច្ច ៤ ជាសិប្បត្តធម្មទានក្តី ។

គួរជ្រួតជ្រាប និង កត់សម្គាល់ផងដែរថា ការសម្តែងធម្ម-

*ទេសនា ដល់ជនដទៃ មិនមែនចេះតែធ្វើទៅបានងាយៗទេ ។ ជាការពិត ធម្មាចារ្យ ឬ ធម្មកថិក កាលនឹងសម្ដែងធម៌ គប្បីដម្កល់ធម៌៥ យ៉ាងទុកក្នុងខ្លួនឱ្យបាន ។ សមដូចជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុក ក្នុងបឋមវគ្គ នៃចតុត្ថបណ្ណាសកៈ ក្នុងបញ្ចកនិបាត អង្គុត្តរនិកាយ ( ព្រះត្រៃបិដក ភាគទី ៤៥ ទំព័រ ១១១ ) ថា៖*

*ម្នាលអានន្ទ ការសំដែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ,ម្នាលអានន្ទ កាលភិក្ខុសំដែងធម៌ដល់ជនដទៃគប្បីតម្កល់ធម៌ ៥ យ៉ាង ឱ្យមានក្នុងខ្លួនសិន ទើបគួរសំដែងធម៌ដល់ជនដទៃ, ធម៌ ៥ យ៉ាងនោះដូចម្ដេចខ្លះ ? ។ គឺភិក្ខុត្រូវសំដែងធម៌ដល់ជនដទៃ ដោយតាំងចិត្តថា៖*

*"អាត្មាអញនឹងសំដែងនូវអនុបុព្វីកថា១ "*

*"អាត្មាអញនឹងសំដែងពាក្យ លើកអាងហេតុផល១"*

*"អាត្មាអញនឹងសំដែងនូវពាក្យ ដោយអាស្រ័យនូវសេចក្ដីអាណិត ( ដល់អ្នកស្ដាប់ )១"*

*"អាត្មាអញនឹងមិនអាស្រ័យអាមិសជាហេតុ សំដែងធម៌១"*

*"អាត្មាអញនឹងសំដែងធម៌ ដោយមិនបានបៀតបៀនខ្លួនឯង និង បុគ្គលដទៃ១" ។*

*ធម្មទានជាអាយុនៃព្រះពុទ្ធសាសនា អាចលើកស្ទួយពុទ្ធ-*

សាសនា ឱ្យមានពន្លឺរស្មីរុងរឿង ស្ថិតស្ថេរជរាបដល់គ្រប់ ៥០០០ ព្រះវស្សា ។ ធម្មទានជាប្រធាននៃទានទាំងពួង រមែងបានផល្លា និសង្សទាំងអ្នកសម្តែងទាំងអ្នកស្តាប់ ។ ក្នុងគម្ពីរអដ្ឋកថាធម្មបទ ព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ សរសើរ អ្នកបំពេញធម្មទានដូចនេះ ថា: ទាយកទាយិកាមានសទ្ធាជ្រះថ្លា បានថ្វាយប្រគេនសំពត់ចីវរ ដែលមានសាច់ម៉ដ្ឋរលើបរលោង ចង្ហាន់បិណ្ឌបាតដែលមានក្លិន ក្រអូបឈ្ងុយឈ្ងប់មានរសជាតិដ៏ឆ្ងាញ់ពិសា ព្រមទាំងសេនាសនៈ គិលានភេសជ្ជៈ យ៉ាងប្រណីតចំពោះព្រះសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអរហន្តាខីណាស្រព ដែលគង់នៅមីរដេរដាស ក្នុងចក្រវាឡ នេះ រហូតដល់ព្រហ្មលោក ក៏ពុំប្រសើរស្មើដល់ការអនុមោទនា ដោយគាថាបួនបាទរបស់លោកទាំងនោះក្នុងសមាគមនោះទេ ។ កិរិយាអនុមោទនាដែលព្រះពុទ្ធជាដើម ទ្រង់បានធ្វើហើយ ដោយ ព្រះគាថាប្រកបដោយ ៤ បាទ ក្នុងសមាគមនោះឯង ប្រសើរ បំផុត ។ ព្រោះថា ទាននោះ ( ចីវរ, បិណ្ឌបាត, សេនាសនៈ និង គិលានភេសជ្ជទាន ) រមែងមិនដល់តម្លៃនូវចំណែកទី ១៦ នៃព្រះ គាថានោះទេ ។

ទានទាំងឡាយក្នុងព្រះពុទ្ធសាសនា រមែងមានធម្មទានជា បទដ្ឋាន ព្រោះថា បុគ្គលដែលបំពេញទាននានា ឱ្យបានត្រឹមត្រូវ

តាមគន្លងព្រះពុទ្ធសាសនា លុះត្រាតែបុគ្គលនោះ ព្យាយាមត្រង់ត្រាប់ស្ដាប់ រៀន ពីសំណាក់ធម្មកថិក ឬ ធម្មាចារ្យ ដែលមានទេពកោសល្យ ក្នុងការបង្ហាត់ សម្ដែង ពន្យល់ណែនាំ បើពុំនោះសោតទេ គេនឹងបរិច្ចាគទានប្រកបដោយ សោមនស្សសហគតចិត្ត និងទោមនស្សសហគតចិត្ត បានន័យថា ចិត្តប្រកបដោយសោមនស្ស និងទោមនស្ស គឺ ជាចិត្តមានកំណើតពីធម្មជាតិ ។ មានចិត្តម្យ៉ាងទៀត ដែលព្រះសម្មាសម្ពុទ្ធទ្រង់សរសើរ គឺ ឧបេក្ខាសហគតចិត្ត បានន័យថា ចិត្តប្រកបព្រមដោយភាពកណ្ដាល ចិត្តឃើញយល់ច្បាស់តាមសេចក្ដីពិតដែលមិនឃ្លេងឃ្លោងតាមសោមនស្ស និងទោមនស្សចិត្ត ។ ឧបេក្ខាចិត្តនេះ មិនមែនជាចិត្តកើតពីធម្មជាតិទេ គឺជាចិត្តដែលកើតឡើងពីការអប់រំ ដោយចំរើន សមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋាន ឬ សតិបដ្ឋាន ។

អ្នកដែលបានស្ដាប់ព្រះធម៌ យល់ន័យព្រះធម៌ពិត ហើយព្យាយាមប្រតិបត្តិ រហូតដល់កើតមានឧបេក្ខាសហគតចិត្ត តែងតែបំពេញទាន ដែលហូរចេញមកពីប្រភព ៣ យ៉ាងគឺ ៖

១- **បសាទោ** មានចិត្តជ្រះថ្លាស្អាតបរិសុទ្ធ ចំពោះគុណធម៌នៃបដិគ្គាហកៈ ( អ្នកទទួល ) មានមេត្តាចិត្តអាណិត ដល់អ្នកទទួល ជួយឱ្យរួចផុតពីទុក្ខកង្វល់ និង កង្វះខាតទាំងឡាយ ។

២- **សទ្ធេនោ** មានចិត្តស្វែងគពីរូប និង សង្ខារ តក់ស្លុតពីបញ្ហាទុក្ខទោសក្នុងលោក ខិតខំប្រឹងប្រែងធ្វើទាន ដើម្បីរំដោះខ្លួនអំពីសង្សារវដ្ត ។

៣- **តេសុចរិតោ** ព្យាយាមជំរះកាយ វាចា ចិត្ត របស់ខ្លួនឱ្យបានស្អាតបរិសុទ្ធផូរផង់ ដោយដាក់កាយឱនលំទោន គោរពចំពោះបដិគ្គាហកៈអ្នកទទួល ទោះបីអ្នកទទួលនោះ ជាបុគ្គលប្រភេទណាក៏ដោយ ព្រមទាំងគោរពចំពោះទេយ្យវត្ថុ ដែលខ្លួនត្រូវលះបង់ ដោយការសំអិតសំអាងសម្រិតសម្រាំង តាមបច្ចេក-ទេស សិល្បៈ ជាមុនទើបលះឱ្យ ។

បន្ថែមទៀតនោះ បុគ្គលដែលមានភោគសម្បត្តិស្តុកស្តម្ភទទួលដំណែងឋានន្តរសក្តិ គ្រប់ជាន់ថ្នាក់ ក្នុងស្ថាប័ននៃរដ្ឋ ឬប្រទេសនីមួយៗក្តី បុគ្គលដែលបានរំដោះខ្លួនពីបុថុជ្ជន ឆ្ពងទៅកាន់អរិយជន មានសោតាបន្ន សកទាគាមី អនាគាមី និង ព្រះអរហន្តជាដើមក្តី សុទ្ធតែបានមក អំពីការរៀនសូត្រ ការស្តាប់ ការប្រតិបត្តិទាំងអស់ និយាយរួមទៅ បានមកអំពីធម្មទាននេះឯង ។ អាស្រ័យហេតុនេះ ទើបព្រះលោកនាថ ពោលនូវពុទ្ធភាសិតថាៈ

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទាន រមែងឈ្នះអស់ទានទាំងពួង ។

*សូមជឿជាក់ថា ការបំពេញធម្មទាន ឱ្យមានផលានិសង្ស ច្រើនដូចដែលព្រះភគវាមានពុទ្ធដីកានោះ ពុទ្ធបរិស័ទមិនចាំបាច់ចេះសំដែងធម៌អាចំ សរសេរ ចារជាសៀវភៅធម៌ ពន្យល់បង្រៀនអ្នកដទៃឱ្យយល់ចូលចិត្តឡើយ ។ គ្រាន់តែមានសទ្ធាជ្រះថ្លា ចែកចាយ ផ្សព្វផ្សាយព្រះធម៌ តាមរយៈការកសាងគម្ពីរពុទ្ធសាសនា ដូចជា ជាវព្រះត្រៃបិដក បោះពុម្ពសៀវភៅធម៌ ថតសម្លេងព្រះធម៌ទេសនា នៃលោកអ្នកប្រាជ្ញ ពហុស្សូត ធម្មកថិក ធម្មាចារ្យ ដែលមានវោហាសំដីថ្វីមាត់ ក្នុងការសំដែង បញ្ចូលក្នុងបន្ទះ ស៊ីឌី (CD)ឬ ឌីវីឌី (DVD)ទុកចែកចាយផ្សាយឱ្យដល់អ្នកទទួលយកទៅហាត់ រៀន ស្តាប់ អាន រហូតដល់ ចេះចាំ ដឹងយល់ពីអត្ថន័យរបស់ព្រះធម៌ ព្យាយាមប្រតិបត្តិឱ្យបានទៅជាគុណប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ឈ្មោះថាជាអ្នកបានបំពេញធម្មទានដោយពិតប្រាកដ ។*

**"សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ " ។**

*អ្នកណាឱ្យទីអាស្រ័យ អ្នកនោះឈ្មោះថាឱ្យរបស់ទាំងពួង, អ្នកណាប្រៀនប្រដៅធម៌ អ្នកនោះ ឈ្មោះថាឱ្យអម្រឹត ។*

# អាមិសទាន

**អាមិសទាន** មកពីពាក្យ **អាមិស** + **ទាន** = **អាមិសទាន** ប្រែថា: ឱ្យអាមិសជាទាន ។ **អាមិស** ប្រែថា នុយគ្រឿងបញ្ឆោតចិត្ត ឬ អន្ទាក់របស់ចិត្ត ឬក៏ ថាជារបស់ដែលគេគប្បីប៉ះពាល់ត្រូវដោយកិលេសមានតណ្ហាជាដើម ។ ប៉ុន្តែក្នុងន័យនេះ **អាមិស** បានដល់បច្ច័យ៤ យ៉ាង ( ចតុប្បច្ច័យ )និង ទានវត្ថុ១០ យ៉ាង ។

ពាក្យ **បច្ច័យ** ប្រែថា គ្រឿងអាស្រ័យរបស់សត្វលោក ឬ ថាគ្រឿងទ្រទ្រង់ជីវិតសព្វសត្វឱ្យប្រព្រឹត្តទៅបានក្នុងលោក ។

**បច្ច័យ ៤ យ៉ាងគឺ ៖**

១- **ចីវរប្បច្ច័យ** បានដល់ត្រៃចីវរ ស្បង់ សង្ឃាដីជាដើម,

២- **បិណ្ឌបាតប្បច្ច័យ** បានដល់ចង្ហាន់បិណ្ឌបាត និង ភោជនាហារជាដើម ,

៣- **សេនាសនប្បច្ច័យ** បានដល់ទីសម្រាប់ដេក អង្គុយ មានកុដិ សាលា ព្រះវិហារជាដើម,

៤- **គិលានភេសជ្ជប្បច្ច័យ** បានដល់ថ្នាំសម្រាប់ព្យាបាលរោគផ្សេងៗ មានថ្នាំលាប ថ្នាំលេប ថ្នាំផឹកជាដើម ។

ពាក្យថា បច្ច័យ ដូចពិពណ៌នាមកនេះ ស្តាប់ទៅហាក់បីដូចជាពាក្យសម្រាប់ប្រើចំពោះតែព្រះសង្ឃ ប៉ុន្តែពុំមែនដូច្នោះទេ

ពាក្យនេះសម្រាប់ប្រើទូទៅ ព្រោះមនុស្សសត្វរមែងត្រូវការបច្ច័យទាំងបួននេះណាមួយ មិនអាចខ្វះខាតបានឡើយ គ្រាន់តែប្រើពាក្យសំដីផ្សេងពីព្រះសង្ឃ ដូចជាសំពត់អាវសារស្បៃសម្រាប់ស្លៀកដណ្តប់បិទបាំងរាងកាយ ទីជម្រកសម្រាប់ជ្រកអាស្រ័យនៅបាយទឹក នំចំណី ត្រីសាច់សម្រាប់បរិភោគ និង ឱសថសម្រាប់ព្យាបាលរោគផ្សេងៗជាដើម ។

## ទានវត្ថុ១០ យ៉ាងគឺ ៖

១- **អន្នំ** គ្រឿងបរិភោគ មានបង្អែមចំអាបគ្រប់មុខ,

២- **បានំ** ទឹកអដ្ឋបាន ៨ យ៉ាង មានទឹកដែលគេធ្វើពីផ្លែស្វាយ ក្រឱឈូកជាដើម ( បិដកភាគ ៦៦ ទំព័រ ៦១ ),

៣- **វត្ថំ** សំពត់ស្លៀកដណ្តប់ បិទបាំងរាងកាយ,

៤- **យានំ** យានជំនិះដែលញ៉ាំងដំណើរឱ្យសម្រេច មានទោចក្រយានយន្តជាដើម មានស្បែកជើងជាទីបំផុត ,

៥- **មាលា** ផ្កាឈើគ្រប់យ៉ាងដែលគេដោតក្រង ចងជាភួងមាល័យឬ មិនទាន់ក្រងចងជាភួងមាល័យ,

៦- **គន្ធំ** គ្រឿងក្រអូបដែលជាគន្ធជាតិមានក្លិន និង គ្រឿងផ្សែផ្សំដល់គ្រឿងក្រអូប ដែលគេកិនក្តី ឬ មិនទាន់កិនក្តី,

៧- **វិលេបនំ** គ្រឿងលាប គឺវត្ថុសម្រាប់លាបស្បែកខាង

ក្រៅ ឱ្យគួរជាទីត្រេកអរពេញចិត្ត,

៨- **សយនំ** ទីដេកកន្លែងសម្រាប់ដេក អង្គុយមានគ្រែតាំង រាំងនន ចៀមព្រំជាដើម,

៩- **អាវសថំ** ទីលំនៅ មានផ្ទះសម្បែង ភូមិគ្រឹះ វិមាន សម្រាប់ការពារព្យុះ ភ្លៀង ខ្យល់ កំដៅថ្ងៃជាដើម,

១០- **បទីបេយ្យំ** ប្រទីបជ្វាលា មានប្រេង ខ្លាញ់ ចង្កៀង គោមជាដើម ។

អាមិសទាន ដូចបានពោលមកនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងញែកឈ្មោះតាមលក្ខណៈ ឬតាមកិច្ចរបស់ទាននោះ មានច្រើនប្រការ ប៉ុន្តែសូមលើកយកត្រឹមតែទាន ២ ប្រភេទ គឺ **បាដិបុគ្គលិកទាន** និង **សង្ឃទាន** មកអធិប្បាយមុន ព្រោះទានទាំងពីរប្រភេទនេះ ពុទ្ធសាសនិកទាំងឡាយ ត្រូវការធ្វើជាញឹកញាប់ជាងទានឯទៀតៗ ។ រីឯទានផ្សេងៗ ទៀតនឹង ពិពណ៌នាក្នុង **ទានប្បភេទ** នៅទំព័រខាងក្រោយ ។

## បាដិបុគ្គលិកទាន

**បាដិបុគ្គលិកទាន** ប្រែថា ទានដែលគេឱ្យចំពោះរូបបុគ្គលមួយៗ ដោយតាំងចិត្តថា លោកនេះ ជាគ្រូអាចារ្យ អ្នកនេះ ជាញាតិមិត្តសាច់សាលោហិត ជាមាតាបិតា ជាស្វាមី ភរិយា

ជននេះជាទីស្រឡាញ់រាប់អាន ជននោះមិនមែនជាទីរាប់អាន ហើយក៏មានចិត្តបំពេញទានចំពោះតែជននោះៗ ឬ ការសាងសង់អ្វីមួយសម្រាប់តែក្នុងវង្សផ្គត់គ្រួសាររបស់ខ្លួន ឬក៏ ឧទ្ទិសជូនចំពោះតែបុគ្គលជាទីរាប់អានស្រឡាញ់ពេញចិត្ត ហៅថា **បាដិបុគ្គលិក-ទាន** ឬ **បុគ្គលិកទាន** ឬ **អសាធារណទាន** ។

**បាដិបុគ្គលិកទាន** មានបុគ្គលអ្នកទទួល ១៤ បែប គឺៈ

១- ព្រះសព្វញ្ញុពុទ្ធ,

២- ព្រះបច្ចេកពុទ្ធ,

៣- អរហត្តផលបុគ្គល,

៤- អរហត្តមគ្គបុគ្គល,

៥- អនាគាមិផលបុគ្គល,

៦- អនាគាមិមគ្គបុគ្គល,

៧- សកទាគាមិផលបុគ្គល,

៨- សកទាគាមិមគ្គបុគ្គល,

៩- សោតាបត្តិផលបុគ្គល,

១០ សោតាបត្តិមគ្គបុគ្គល,

១១- បុគ្គលក្រៅសាសនាតែមានសេចក្តី
នឿយណាយចាកកាម,

*១២- មនុស្សមានសីល,*

*១៣- មនុស្សទ្រុស្តសីល,*

*១៤- សត្វតិរច្ឆាន*

## សង្ឃទាន

**សង្ឃទាន** *ប្រែថា "ប្រគេនសង្ឃ" ។ ទានដែលទាយកប្រគេនចំពោះព្រះសង្ឃដោយគោរព និង ដោយតាំងចិត្តជ្រះថ្លា មិនគិតប្រកាន់ថា ភិក្ខុដែលគេនិមន្តពីសំណាក់ភិក្ខុសង្ឃ ជាភិក្ខុប្រភេទណាមានសីល ឬ ទ្រុស្តសីលហៅថា* **សង្ឃទាន** *ឬ* **សង្ឃគតាទក្ខិណាទាន** *ឬ* **សង្ឃគតាទាន** ។

**សង្ឃទាន** *បែកតាមប្រភេទបុគ្គលអ្នកទទួលមាន៧ គឺៈ*

*១- ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន,*

*២- ភិក្ខុនីសង្ឃមានព្រះពុទ្ធជាប្រធាន,*

*៣- ភិក្ខុសង្ឃ និង ភិក្ខុនីសង្ឃមានព្រះពុទ្ធជាប្រធាន,*

*៤- ភិក្ខុសង្ឃ និង ភិក្ខុនីសង្ឃ,*

*៥- ភិក្ខុសង្ឃ,*

*៦- ភិក្ខុនីសង្ឃ,*

*៧- សមណេរ ។*

*ពាក្យថា* **សង្ឃ** *មានន័យ ២ យ៉ាង គឺ សង្ឃក្នុងព្រះធម៌*

និង សង្ឃក្នុងព្រះវិន័យ ។

១- **សង្ឃក្នុងព្រះធម៌** បានដល់សង្ឃរតនៈសំដៅយកព្រះអរិយបុគ្គល ៤ ពួក ដែលបានសម្រេចសោតាបត្តិមគ្គ១, សោតា - បត្តិផល១, សកទាគាមិមគ្គ១, សកទាគាមិផល១, អនាគាមិមគ្គ១, អនាគាមិផល១, អរហត្តមគ្គ១, អរហត្តផល១, ដែលជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធបរមនាថ អ្នកប្រតិបត្តិល្អ អ្នកប្រតិបត្តិត្រង់ អ្នកប្រតិបត្តិដោយប្រពៃ ប្រតិបត្តិដើម្បីដឹងច្បាស់នូវអរិយសច្ចធម៌ ប្រតិបត្តិដើម្បីគួរដល់ការថ្វាយបង្គំ ការបូជាជាដើម ។

២- **សង្ឃក្នុងព្រះវិន័យ** សំដៅយកពួកនៃបព្វជិត គឺ ភិក្ខុតាំងពី ៤ រូបឡើងទៅ ។

ក្នុងវចនានុក្រមខ្មែរ ពាក្យថា **សង្ឃ** តាមលទ្ធិពុទ្ធសាសនាសំដៅចំពោះភិក្ខុតាំងពី៤ឡើងទៅ ។ តាមសេចក្តីពន្យល់ របស់ភិក្ខុធម្មបាលោ **ខៀវ ជុំ** ថាភិក្ខុសង្ឃ ឬ ភិក្ខុនីសង្ឃ ឬ សាមណេរទាំងនៅបុថុជ្ជនទាំងបានសម្រេចអរិយមគ្គ អរិយផលហើយ ត្រូវមានចំនួនយ៉ាងតិច ៤ អង្គឡើងទៅ ទើបហៅថាសង្ឃ ។ ពាក្យថា **សង្ឃ** ក្នុងវិន័យ ហៅបានតែចំពោះ **ភិក្ខុសង្ឃ** និង **ភិក្ខុនីសង្ឃ** ចំណែកសាមណេរ មិនឃើញមាន ហៅថា **សាមណេរសង្ឃ** ទេ ព្រោះសមណេរប្រើប្រាស់បានចំពោះតែសង្ឃចតុវគ្គ សម្រាប់

ទាយកទាយិកាធ្វើបុណ្យសង្ឃទាន ។ ឯសង្ឃបញ្ចវគ្គ សម្រាប់ធ្វើសង្ឃកម្ម ( កិច្ចការរបស់សង្ឃដែលប្រជុំគ្នាក្នុងសីមា ) នានា មិនឃើញមានសាមណេរឡើយ ។

មកដល់ចំណុះនេះ បញ្ហាមួយចោទឡើង ថាដើម្បីបំពេញសង្ឃទានចាំបាច់ត្រូវតែមានភិក្ខុសង្ឃ ចាប់ពី ៤ អង្គឡើងទៅ ឬ ? តើការកំណត់ចំនួនភិក្ខុសង្ឃនេះ ជាពុទ្ធបញ្ញត្តិ ឬ អ្វី ? ។

ខ្ញុំសូមមិនឆ្លើយតបសំនួរទាំងនេះទេ ប៉ុន្តែខ្ញុំសូមលើកយកអត្ថបទវិភាគរបស់ព្រះតេជៈព្រះគុណបណ្ឌិត **ហុក សាវណ្ណ** ក្រោមប្រធានបទ " ការវេរចង្ហាន់ " មកពិចារណាទាំងអស់គ្នា ។

## ការវេរចង្ហាន់

ការវេរចង្ហាន់ជាពិធីកម្មមួយដ៏ល្អដែរ ។ រាល់ពេលធ្វើបុណ្យកុសល នៅវេលាថ្ងៃជិតត្រង់ពុទ្ធបរិស័ទតែងធ្វើការវេរចង្ហាន់ ។ ការវេរចង្ហាន់ទុកដូចជាសុន្ទរកថា ទូលព្រះសង្ឃឱ្យបានជ្រាប និង តាំងចិត្តរបស់ខ្លួនក្នុងការបំពេញទាននេះ ។ ក្នុងការវេរនោះ មានពាក្យថា ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ។ បានសេចក្តីថារបស់ដែលបានយកមកធ្វើទាននេះពុំមែនបានពីការលួចប្លន់ ឬ សម្លាប់

សត្វយកមកធ្វើបុណ្យទេ គឺបានមកប្រកបដោយធម៌ ។ ការពោលដូច្នេះ ដើម្បីកុំឱ្យព្រះសង្ឃមានសេចក្តីសង្ស័យ អំពីចង្ហាន់ដែលយកមកប្រគេននេះ ព្រោះព្រះសង្ឃអាចឆាន់សាច់បានមិនត្រូវអាបត្តិ ដោយការបរិសុទ្ធិដោយហេតុ៣យ៉ាង គឺ មិនឃើញគេសម្លាប់ មិនបានឮសត្វស្រែកពេលដែលគេសម្លាប់ និងមិនបានសង្ស័យថាគេសម្លាប់ដើម្បីខ្លួន ។ ក្នុងធម៌វេរនោះ បានបន្តទៀតថា ខ្ញុំព្រះករុណាសូមឧទ្ទិសកុសលជូនក្រុមគ្រួសារ ដែលចែកស្ថានទៅមានមាតាបិតាជាដើម ។ នេះចាត់ជាការប្រគេនដោយវាចា និង បញ្ជាក់អំពីគោលបំណងនៃការធ្វើកុសលនេះ ។ ប៉ុន្តែបើគេប្រគេនមិនវេរក៏គ្មានទាស់អ្វីដែរ ព្រោះបុណ្យកុសលមានការធ្វើទានជាដើម កើតឡើងពីចេតនាលះបង់ នូវមច្ឆរិយៈក្នុងផ្លូវចិត្ត ។

ក្នុងការវេរនេះ មានបញ្ហាមួយដែលពុទ្ធបរិស័ទ អនុវត្តតៗគ្នាមកដោយសារសៀវភៅ"គិហិប្រតិបត្តិ"សរសេរថាភិក្ខុ១ អង្គវេរជាបុគ្គល ពី២ អង្គទៅ ៣ អង្គ វេរជាគណៈ ពី៤អង្គឡើងទៅទើបវេរជាសង្ឃ ។ នេះជាការភាន់ច្រឡំ ព្រោះការធ្វើទាននេះ កើតពីចេតនាកម្មពុំមែនបញ្ញត្តិកម្មទេ ។ ពាក្យថាធ្វើទានចំពោះព្រះសង្ឃមានន័យថា ក្រាលចិត្តទូទៅមិនចំពោះអង្គណាមួយ ។ ដូចជាការ

ដាក់បាត្រចំពោះព្រះសង្ឃ ១ អង្គដែលនិមន្តមកបិណ្ឌបាត ក្រាលចិត្តទូទៅមិនចំពោះអង្គណា ជាព្រះសង្ឃដែលនិមន្តមកអំពីទិសទាំង ៤ ។ ការក្រាលចិត្តបែបនេះ ជាការធ្វើទានចំពោះព្រះសង្ឃហើយ មិនគិតពីចំនួនព្រះសង្ឃឡើយ ទោះបីភិក្ខុមានចំនួនប៉ុន្មានក៏ដោយ ។ ត្រង់ចេតនាបែបនេះ ភិក្ខុប៉ុន្មានអង្គក៏ចាត់ថាជាសង្ឃដែរ ។ មានអ្នកខ្លះនិមន្តចំពោះភិក្ខុមួយអង្គៗ ជាច្រើនវត្តមកផ្តុំគ្នាធ្វើជាសង្ឃ ពុំអាចទៅជាសង្ឃកើតទេ ពីព្រោះមានចិត្តចំពោះបុគ្គលរួចទៅហើយ ។

ចំពោះព្រះសង្ឃ ៤ អង្គ ឬ ៤ អង្គឡើងទៅ ជាបញ្ញត្តិកម្មដែលព្រះពុទ្ធបានបញ្ញត្តិចំពោះព្រះសង្ឃ សម្រាប់បំពេញកិច្ចការរបស់សង្ឃដែលហៅថា សង្ឃកម្ម ។ ឧទាហរណ៍ ព្រះសង្ឃ ៤ អង្គអាចធ្វើឧបោសថសំដែងបាតិមោក្ខបាន។ ព្រះសង្ឃ ៥ អង្គអាចធ្វើកឋិនកម្មបាន ។ ព្រះសង្ឃ ២០ អង្គ ក្នុងមជ្ឈិមប្រទេសដែលសំបូរព្រះសង្ឃ អាចបំបួសកុលបុត្រជាភិក្ខុបានជាដើម ។ ហេតុដែលសង្ឃកម្មមានចំនួនព្រះសង្ឃតិចជាងគ្នានេះ គឺ យោលទៅតាមទំហំការងារ ។ បើការងារនោះមានទំហំតូច ត្រូវការព្រះសង្ឃក៏មានចំនួនតិច ដូចជាការធ្វើឧបោសថកម្ម ការសំដែងបាតិមោក្ខជាដើម ។ បើការងារនោះសំខាន់ខ្លាំង ក៏ត្រូវការព្រះភិក្ខុសង្ឃជា

សមាជិកអង្គប្រជុំមានចំនួនច្រើនអង្គ ហើយត្រូវពិគ្រោះ ពិភាក្សាគ្នាឱ្យបានល្អិតល្អន់ ដូចជាការបំបួសកុលបុត្រជាដើម ។

ដូច្នេះបញ្ជាក់ថា ចំនួនព្រះសង្ឃចាប់ពី ៤ អង្គ និង ៤ អង្គឡើងទៅនោះ សម្រាប់ធ្វើជាអង្គប្រជុំ ដើម្បីបំពេញកិច្ចការរបស់ព្រះសង្ឃ ពុំមែនសម្រាប់សង្ឃទាននោះឡើយ ។ នេះជាបញ្ញត្តិកម្ម ដែលព្រះពុទ្ធបានបញ្ញត្តិ ដើម្បីឱ្យព្រះសង្ឃអនុវត្តសម្រាប់បំពេញកិច្ចការ របស់សង្ឃ ។ ចំណែកសង្ឃទាន គឺទានចំពោះព្រះសង្ឃនោះ គឺ ចេតនាកម្ម ជាចេតនារបស់អ្នកធ្វើទាន ក្រាលចិត្តទូទៅមិនចំពោះភិក្ខុអង្គណាមួយ ។ ព្រះពុទ្ធមិនបានសំដែងថាធ្វើទានឱ្យកើតជាសង្ឃទាន ត្រូវតែមានភិក្ខុចំនួនប៉ុណ្ណេះប៉ុណ្ណោះឡើយ ។ ដោយសារការភ័ន្តច្រឡំ យកបញ្ញត្តិកម្មរបស់សង្ឃកម្មមកធ្វើជាចេតនាកម្មរបស់សង្ឃទាននេះហើយ បានជាសៀវភៅ "គិហិប្រតិបត្តិ" សរសេរដូចបានពោលមកហើយ ។ ពុទ្ធសាសនាបានបើកសិទ្ធិសេរីភាព ទោះបីអ្នកធ្វើទាន ដោយការស្រឡាញ់ពេញចិត្តក្តី ដោយក្រាលចិត្តទូទៅ ដែលហៅថា សង្ឃទានក្តី ក៏ស្រេចតែទឹកចិត្តពុទ្ធបរិស័ទ ធ្វើទៅតាមសទ្ធារបស់គេ ។

វិភាគកថា ដែលបានដកស្រង់មកពិពណ៌នាហើយនេះ ចាត់ទុកជាប្រទីប ឆ្លុះបញ្ចាំងសម្រាប់ទាយក ទាយិកា ពិចារណា

ស្វែងយល់អំពីភាពខុសគ្នា រវាងបាដិបុគ្គលិកទាន និង សង្ឃទាន ព្រមទាំងអានិសង្សនៃទានទាំងពីរនេះផង ។ ព្រះបរមសាស្តា សំដែងថា: "**វិចេយ្យ ទានំ សុគតប្បសត្ថំ** ប្រែថា កាល ពិចារណាហើយឱ្យ ជាអំពើដែលព្រះសុគតទ្រង់សរសើរ " ។

រវាងទានទាំងពីរប្រភេទនេះគឺ បាដិបុគ្គលិកទាន និងសង្ឃ ទាន បុរាណាចារ្យលោកពោលថា សង្ឃទាន មានផលានិសង្ស ច្រើនជាងបាដិបុគ្គលិកទាន ។ ប៉ុន្តែបើទាយកទាយិកាធ្វើដល់ពួក ច្រើន ចាប់តាំងពី ៤ រូបឡើងទៅ ទានរបស់គេក៏មានផលានិសង្ស ច្រើនមិនចាញ់សង្ឃទានប៉ុន្មានទេ ដូចជាចំណាយធនធានដែល ខ្លួនមាន ដើម្បីកសាងសម្បត្តិជាតិ សាសនា ជាសាធារប្រយោជន៍ ឬ បង្កើតជាអង្គការសមាគមអ្វីមួយ រៃអង្គាស ដើម្បីជួយសង្គ្រោះ ដល់ជនក្រីក្រ អត់ឃ្លានខ្វះខាត ឬ ជនពិការ កុមារកំព្រារហូតដល់ ធ្វើផ្លូវ ជីកស្រះ អណ្តូងទឹក សង់ស្ពាន សាលារៀន មន្ទីរពេទ្យ ផ្សារ កសាងវត្តអារាម មានកុដិ សាលា ព្រះវិហារ សួនច្បារឧទ្ទិស ជូនចំពោះសាសនាជាដើម ។ ទានទាំងអស់នេះពិតមែនតែឱ្យ ឈ្មោះថាសង្ឃទានមិនបាន ប៉ុន្តែគេអាចហៅថា **សាធារណទាន** បានព្រោះពាក្យថា " សង្ឃ " ជាពាក្យបច្ចេកទេស សម្រាប់ព្រះ វិន័យ និង ពាក្យសាធារណ: មានន័យថា ទូទៅទាំងអស់ដូចគ្នា ។

**អាមិសទាន & ធម្មទាន**

សរុបសេចក្តីមក ឃើញថាទានមានច្រើនប្រភេទ ច្រើនយ៉ាង ឯការបរិច្ចាគទាន ក៏មានច្រើនបែបបទតាមលក្ខណៈរបស់ទាន ។ ហេតុនេះ ពុទ្ធបរិស័ទចូរពិចារណាយល់ដឹងឱ្យបានល្អិតល្អន់អំពីទានណាមួយ ដែលខ្លួនបំរុងនឹងធ្វើ ដើម្បីបង្កើនសទ្ធាឱ្យកើតខ្លាំងក្លាក្នុងសន្តាន រួចហើយលះមច្ឆរិយៈ សំរួចចិត្តជ្រះថ្លាបំពេញទាននោះ ដោយគោរពតាមគន្លងព្រះពុទ្ធសាសនា ទើបពុទ្ធបរិស័ទបានទទួលផលានិសង្សច្រើនជាទីពេញចិត្ត ដែលជាឧបនិស្ស័យព្រេងវាសនាសម្រាប់អនាគតជាតិ ។

**នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា**

កាលបើចិត្តជ្រះថ្លាហើយ ទក្ខិណាទានមិនឈ្មោះថាបានផលតិចតួចឡើយ ។

ទក្ខិណាទាន ដែលនឹងមានផលបរិបូណ៌ទៅបាន ត្រូវអាស្រ័យលើចិត្តសទ្ធាជ្រះថ្លា ចេតនា មុតស្រួចនៃទាយកនោះ ។ បើចិត្តជ្រះថ្លាខ្លាំង ផលក៏បានច្រើន បើចិត្តជ្រះថ្លាមានកម្លាំងតិចផលដែលត្រូវបានក៏តិចដែរ ។ ដូចនេះ ជនអ្នកបរិច្ចាគទាននានាដែលប្រាថ្នាឱ្យបានអានិសង្សច្រើននោះ គួរតាំងចិត្តជ្រះថ្លាបរិសុទ្ធស្អាតនៅពេលមុនធ្វើ កំពុងធ្វើ និង ក្រោយពេលធ្វើរួចហើយ ។

# ទានសង្គហៈ

**ទានសង្គហៈ** *មកពីពាក្យ* **ទាន** + **សង្គហៈ**= *ប្រែថា ការដកស្រង់សេចក្តីចេញអំពីទាន យកមកដោយសង្ខេប ។ ទានក្នុងព្រះពុទ្ធសាសនា មានមកចាកប្រភពនៃធម៌ច្រើនពួក ហេតុនេះហើយ ទើបលោកសង្គ្រោះចូលក្នុងធម៌ទាំងឡាយ ដែលព្រះពុទ្ធបរមគ្រូទ្រង់ធ្លាប់សំដែងមានដូចតទៅនេះ ៖*

*ក-* **បុញ្ញកិរិយា ១០** *ហៅថា* **ទានមយៈ** *បានន័យថា បុណ្យសម្រេចអំពីធ្វើទាន ។*

*ខ-* **អរិយទ្រព្យ ៧**(១) *ហៅថា* **ចាគធនំ** *បានន័យថាទ្រព្យគឺការឱ្យទានជាទ្រព្យដ៏ប្រសើរ ។*

*គ-* **ទសពិធរាជធម៌ ១០** *ហៅថា* **ទាន** *បានន័យថា ការចិញ្ចឹមទំនុកបំរុងឱ្យអភ័យ ។*

*ឃ-* **ប្រយោជន៍បរលោក ៤** *ហៅថា* **ចាគ** *បានន័យថា លះបង់ទ្រព្យសម្បត្តិកសាង ។*

*ង-* **បារមីធម៌១០** *ហៅថា* **ទាន** *បានន័យថាការកសាងកម្លាំងត្រាស់ដឹងដោយទ្រព្យ ។*

---

(១)- អរិយទ្រព្យ ៧ យ៉ាង គឺ សទ្ធាធនំ១, សីលធនំ១, ហិរិធនំ១, ឱតប្បធនំ១, សុតធនំ១, ចាគធនំ១, បញ្ញាធនំ១, ។

*ច-* **មង្គល ៣៨** *ហៅថា* **ទាន** *បានន័យថា ការបំពេញទាន ជាគុណធម៌នាំឱ្យចំរើន ។*

*ឆ-* **សង្គហធម៌ ៤** *ហៅថា* **ទាន** *បានន័យថា ការបរិច្ចាគទាន ជាគុណធម៌ធ្វើឱ្យសង្គមមនុស្សមានសាមគ្គីធម៌ ។*

*ជ-* **អនុបុព្វិកថា ៥** (១) *ហៅថា* **ទានកថា** *បានន័យថា ធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងប្រចាំថ្ងៃ ។*

*ឈ-* **សប្បុរិសបញ្ញត្តិ** *ហៅថា* **ទាន** *បានន័យថា ធម៌ដែលសប្បុរសទាំងឡាយ បញ្ញត្តិសម្រាប់លោក ។*

*ញ-* **សប្បុរិសធម៌** *ហៅថា* **សក្កច្ចំ ទានំ ទេតិ** *បានន័យថា សប្បុរសឱ្យទានដោយគោរព ។*

*យើងឃើញថា ទានក្នុងពុទ្ធសាសនា មានមកពីប្រភពនៃធម៌ច្រើនពួក គួរឱ្យយើងចង់ដឹងថា តើទានដែលមានមកក្នុងពួកធម៌នោះៗ មានសេចក្តីអធិប្បាយយ៉ាងណា ? មានគុណសារ-ប្រយោជន៍ខុសគ្នាដូចម្តេច ? ។*

*ខ្ញុំសូមមិនអធិប្បាយអំពីទានទាំងអស់ ក្នុងសៀវភៅដ៏តូចស្តើងនេះទេ ព្រោះក្នុងធម៌ខ្លះ លោកអ្នកអានបានចេះចាំរួចហើយ ខ្ញុំអធិប្បាយខ្លះ ចំពោះតែរឿងពិបាកយល់ប៉ុណ្ណោះ ។*

---

(១)- អនុព្វិកថា ៥ គឺ ៖ ទានៈ, សីលៈ, សគ្គៈ, កាមាទីនវៈ, នេក្ខម្មានិសំសៈ ។

# ទានក្នុងអនុបុព្វិកថា

ពុទ្ធបរិស័ទធ្លាប់បានដឹងរួចមកហើយថា ក្នុងពោធិសម័យ ៤៥ ព្រះវស្សា ព្រះពុទ្ធទ្រង់បំពេញពុទ្ធកិច្ច ៥ យ៉ាង ដោយគ្មាននឿយណាយព្រះកាយពល ។ ក្នុងពុទ្ធកិច្ច៥យ៉ាងនោះបានពោលថា ពេលថ្ងៃរសៀលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះធម៌ ។ ក្នុងពេលនោះ ព្រះអង្គទ្រង់ចាប់ផ្តើមសំដែងអំពីទានទុកជាមុន ហើយទ្រង់សំដែងអំពីសីល ឋានសួគ៌ កាមាទីនវៈ និង នេក្ខមៈ តាមលំដាប់ ។ ដូចម្តេច ទើបទ្រង់សំដែងអំពីទានជាមុន ? ព្រោះទ្រង់ទតឃើញនិស្ស័យសន្តានរបស់មនុស្ស ដែលចាប់អារម្មណ៍ លើទ្រព្យសម្បត្តិ ដែលសុខចិត្តរស់នៅជាមួយទ្រព្យ ដែលទឹកថាជីវិតខ្ពង់ខ្ពស់ដោយសារទ្រព្យ ដែលប្រើកម្លាំងទ្រព្យជិះជាន់អ្នកដទៃ ដែលគិតតែពីរស់យករួចខ្លួនតែម្នាក់ឯង មិនអើពើដល់ការរស់នៅរបស់អ្នកដទៃ ។ ល ។ ក្នុងធម៌ទេសនានោះ ព្រះអង្គទ្រង់ណែនាំឱ្យមនុស្សលះបង់ទ្រព្យសម្បត្តិ ធ្វើអំណោយដល់មនុស្សដែលត្រូវធ្វើអំណោយ មានអ្នកទីទាល់ក្រកំសត់ទុគ៌ត និង អ្នករងគ្រោះដោយគ្រោះថ្នាក់ធម្មជាតិជាដើម ចិញ្ចឹមមនុស្សដែលត្រូវចិញ្ចឹម មានមាតាបិតា ភរិយា ស្វាមី បុត្រធីតាជាដើម ។

ជាពិសេសជាងនេះទៅទៀតព្រះអង្គទ្រង់ពន្យល់ថា ទ្រព្យ

*សម្បត្តិ គេមិនត្រូវស្រឡាញ់ជាប់ចិត្ត ទាល់តែចាយមិនកើតទេ ។ ទ្រព្យសម្បត្តិគេមិនត្រូវសន្សំទុកដាក់ប្រើប្រាស់ ដាក់ម្ចាំងជិះជាន់អ្នកដទៃទេ ។ ក្នុងនាមជាមនុស្សមិនត្រូវធ្វើខ្លួនឱ្យធ្លាក់ជុនជាបទៅជាអ្នកគោរពបូជាទ្រព្យសម្បត្តិទេ ។ ជាមនុស្សត្រូវតែជាចៅហ្វាយរបស់ទ្រព្យសម្បត្តិ ហើយត្រូវបំពេញមុខងាររបស់ខ្លួនដោយទ្រព្យសម្បត្តិ ព្រោះបុគ្គលគ្រប់រូប មិនអាចពាំនាំយកទ្រព្យសម្បត្តិទៅជាមួយខ្លួនបានទេ ពេលអត្តភាពបែកធ្លាយចាកលោកនេះទៅ ។ នេះសបញ្ជាក់ឱ្យយើងឃើញយ៉ាងច្បាស់ថា ព្រះពុទ្ធបរមគ្រូទ្រង់បានគិតដល់ជីវភាពរបស់មនុស្សជាដំបូង ទើបព្រះអង្គសំដែងអំពីទានមុនអនុពុីកថាដទៃៗ ។*

*អាស្រ័យដោយញាណទស្សនៈ បែបនេះហើយ ទើបព្រះសាស្តា ទ្រង់ប្រទានពុទ្ធភាសិតថាៈ*

**អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ តំ**
**តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឧយ្ហតិ ។**
**ឯវមេទិត្តោ លោកោ ជរាយ មរណេន ច**
**និហរេថេវ ទានេន ទិន្នំ ហោតិ សុនីភតំ ។**

*( សេចក្តីថា ) កាលភ្លើងឆេះផ្ទះ បុគ្គលនាំយកភាជនៈណាចេញបាន ភាជនៈនោះរមែងជាប្រយោជន៍របស់គេ ។ ចំណែកភាជនៈដែលនាំចេញមិនបាន ក៏ត្រូវភ្លើងឆេះក្នុងផ្ទះនោះ យ៉ាង*

ណា, សត្វលោកដែលត្រូវ(ភ្លើង) ជរា និងមរណៈឆេះក៏យ៉ាងនោះ បុគ្គលគួរនាំយករបស់ខ្លួនចេញ ដោយការឱ្យទាន របស់ដែលគេបានឱ្យទានហើយ ឈ្មោះថា គេបាននាំចេញទៅដោយល្អ ។

សេចក្ដីនេះបំភ្លឺថា រូបកាយមនុស្សយើងប្រៀបដូចផ្ទះ ចិត្តរបស់មនុស្សយើងប្រៀបដូចបុគ្គលដែលនៅក្នុងផ្ទះ ទ្រព្យសម្បត្តិរបស់យើងប្រៀបដូចជាភាជនៈនៅក្នុងផ្ទះ ។ កាលភ្លើងឆេះផ្ទះ ម្ចាស់ផ្ទះជញ្ជូនចេញនូវរបស់ណាបាន របស់នោះក៏ជាប្រយោជន៍របស់គេ ។ ចំណែករបស់ដែលយកមិនបាន ក៏ត្រូវជាចំណីភ្លើង ។ យ៉ាងណាមិញ ទ្រព្យសម្បត្តិរបស់យើង កាលណារូបកាយរបស់យើងត្រូវភ្លើង គឺជរា និង មរណៈឆេះ ប្រសិនបើយើងមិនបាននាំចេញដោយការឱ្យទានទេ ទ្រព្យសម្បត្តិនោះក៏មិនមានប្រយោជន៍ដល់យើងនៅក្នុងជាតិខាងមុខ ដូចជាភាជនៈដែលត្រូវភ្លើងឆេះអស់ មិនមានប្រយោជន៍ដល់ម្ចាស់ផ្ទះ ។ ចំណែកទ្រព្យសម្បត្តិដែលយើងបានធ្វើទានជាស្រេចហើយនោះ រមែងជាប្រយោជន៍ដល់យើងទៅអនាគត ដូចជាភាជនៈដែលគេយកចេញពីផ្ទះភ្លើងឆេះបានដូច្នោះ ។

## ទានក្នុងសប្បុរិសបញ្ញត្តិធម៌

**សប្បុរិសបញ្ញត្តិធម៌** មានន័យថា ធម៌ដែលសប្បុរស

ប្រកាសឱ្យមនុស្សលោកដឹង ឬ ធម៌ដែលសប្បុរសបញ្ញត្តិ ទុកមកក្នុងលោក ។

## សប្បុរិសបញ្ញត្តិធម៌មាន ៣ យ៉ាងគឺ ៖

១- **ទាន** ការបរិច្ចាគ,

២- **បព្វជ្ជា** ការបួសជាភិក្ខុ សាមណេរ,

៣- **មាតាបិតុឧបដ្ឋាន** ការបំរើមាតាបិតា ។

ពាក្យថា **សប្បុរស** បានដល់អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម។ ប៉ុន្តែធម៌ ៣ យ៉ាងខាងលើនេះ ពុំមែនជាពុទ្ធបញ្ញត្តិទេ ជាបញ្ញត្តិរបស់អ្នកប្រាជ្ញបុរាណាចារ្យទាំងឡាយ ជាយូរយាណាស់មកហើយ ។ លុះព្រះពុទ្ធបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ទ្រង់យល់ឃើញថា ធម៌នេះល្អ ទើបទ្រង់ដាក់ចូល ក្នុងសាសនារបស់ព្រះអង្គ ដោយឥតមានកែប្រែសូម្បីបន្តិចបន្តួច ។ ព្រះពុទ្ធអង្គទ្រង់ធ្វើយ៉ាងនេះ ក៏ព្រោះព្រះអង្គទ្រង់រក្សាទុកនូវធម៌បរមបុរាណនៃសប្បុរសទាំងឡាយ ក្នុងអតីតកាលដើម្បីឱ្យសមដល់កិត្តិយស របស់ព្រះអង្គជាអ្នកស្វែងរកត្រូវ មិនមែនស្វែងរកកេរ្តិ៍ឈ្មោះឡើយ ។

សប្បុរិសបញ្ញត្តិធម៌ មានប្រយោជន៍ដល់សង្គមមនុស្ស ជាច្រើនណាស់ បើយើងស្គាល់ន័យ ស្គាល់បំណងពិតរបស់ធម៌នេះ

ហើយនាំគ្នាគោរពប្រតិបត្តិឱ្យបានត្រូវគ្រប់ទាំង ៣ យ៉ាង ។

ន័យរបស់ **ទាន** ពុំមែនដោយកតែត្រឹមបាដិបុគ្គលិកទាន ឬ សង្ឃទាន មានដាក់បាត្រ វេរដារបង្សុកូល...ប៉ុណ្ណោះទេ គឺដោយកការរួមរស់ដ៏មានសីលធម៌ក្នុងសង្គម មានការលះបង់នូវទ្រព្យសម្បត្តិ សាងសាធារណប្រយោជន៍ឱ្យសង្គម មានការសង់ស្ពាន សាលារៀន មន្ទីរពេទ្យ វត្តអារាម មជ្ឈមណ្ឌលវិបស្សនា.... ។

ន័យរបស់ **បញ្ញា** មិនមែនដោយកត្រឹមតែការបួស ភិក្ខុសាមណេរប៉ុណ្ណោះទេ គឺដោយកការលែងបៀតបៀនគ្នា ដោយប្រើកម្លាំងយសសក្តិ វណ្ណៈ ផៅពង្ស ពិសេសគឺមនុស្សម្នាក់ៗ ត្រូវរៀបចំខ្លួនឱ្យមានសីលធម៌ សម្រាប់ក្រុមគ្រួសារឱ្យមានមនុស្សធម៌ សម្រាប់មនុស្សជាតិក្នុងពិភពលោក ។

ន័យរបស់ **មាតាបិតុឧបដ្ឋាន** មិនមែនដោយកតែការបំរើមាតាបិតាទេ គឺដោយកការបំរើបុព្វបុរសទាំងអស់ នៃពិភពលោក ព្រោះពិភពលោកកើតមានវត្ថុផ្សេងៗ សម្រាប់ឱ្យបច្ឆាជន រស់នៅបានសុខសប្បាយក្នុងបច្ចុប្បន្ននេះ ដោយស្នាដៃរបស់លោក ។

ន័យរបស់ទាន ទូលំទូលាយណាស់តាមការសង្កេតពិចារណាកន្លងមកនេះ ។ ផ្ទុយទៅវិញ ចិត្តរបស់មនុស្សគ្រប់ជាន់ថ្នាក់រមែងចង្អៀតក្នុងការធ្វើទាន ព្រោះចិត្តរបស់គេលុះក្រោមអំណាច

**អាមិសទាន & ធម្មទាន**

*របស់មច្ឆរិយៈ ( សេចក្តីកំណាញ់ ) ច្រើនជាងក្រោមអំណាចរបស់សទ្ធា ។ ដូចនេះហើយ បានជាមានពុទ្ធភាសិតមួយពោលថាៈ*

**"ទានញ្ច យុទ្ធញ្ច សមានមាហុ**
**អប្បាបិ សន្តា ពហុកេ ជិនន្តិ**
**អប្បម្បិ ចេ សទ្ធហានោ ទទាតិ**
**តេនេវ សោ សុខី បរត្ថ " ។**

*ប្រែថាៈ អ្នកប្រាជ្ញទាំងឡាយ ពោលថា ការឱ្យទាន និងការច្បាំងជារបស់ស្មើគ្នា អ្នកច្បាំងប្រថុយលះបង់ជីវិត សូម្បីមានគ្នាតិច ក៏អាចឈ្នះសត្រូវមានគ្នាច្រើន, អ្នកឱ្យទានសូម្បីតែមានទ្រព្យសម្បត្តិតិចតួច តែមានសទ្ធាក៏អាចឱ្យទានបាន សេចក្តីសុខនឹងមានក្នុងលោកខាងមុខ ដោយផលនៃចេតនាទាន ។*

*សេចក្តីនេះ អធិប្បាយថា ជាធម្មតា បុគ្គលដែលខ្លាចអស់ទ្រព្យសម្បត្តិរមែងឱ្យទានមិនកើត អ្នកខ្លាចស្លាប់ក៏ច្បាំងមិនកើត។ បុគ្គលកាត់ក្តីអាល័យ ក្នុងជីវិតរបស់ខ្លួនបាន ទើបអាចទៅជាអ្នកច្បាំងបាន បុគ្គលកាត់អាល័យក្នុងទ្រព្យសម្បត្តិរបស់ខ្លួនបាន ទើបអាចទៅជាអ្នកធ្វើទានបាន ។ ដូច្នេះ ទើបអ្នកប្រាជ្ញលោកពោលថា ការធ្វើចំបាំង និង ការធ្វើទានមានទំហំប៉ុនគ្នា ។*

*អ្នកច្បាំងសូម្បីពួកខ្លួនមានគ្នាតិច មានអាវុធតិច តែហ៊ានប្រថុយលះបង់ជីវិត ដើម្បីបុព្វហេតុអ្វីមួយ អ្នកចំបាំងដែលមាន*

*សេចក្តីក្លាហានបែបនេះ ត្រូវតែមានជ័យជំនះក្នុងចំបាំងរបស់គេ។*

*អ្នកធ្វើទាន សូម្បីខ្លួនមានទ្រព្យសម្បត្តិត្រឹមតែបន្តិចបន្តួច តែមានចិត្តចង់ឱ្យទាន មានសទ្ធាខ្លាំងក្លា មានឥន្ទ្រីយ៍ធម៌ ប្រកប ព្រមដោយកម្លាំងមាំមួន គេត្រូវតែឱ្យទានបាន ហើយគេនឹងបាន សេចក្តីសុខចំរើន ក្នុងលោកខាងមុខ ។*

## សប្បុរិសទាន

**សប្បុរិសទាន** *ប្រែថា អំណោយរបស់ជនសប្បុរស ឬ អំណោយរបស់ជនអ្នកមានចិត្តស្ងប់ចាកបាប ។ សប្បុរសធ្វើទាន ដោយស្មារតីខ្ពស់ក្នុងរបៀប ៥ យ៉ាងគឺ៖*

*១-* **សទ្ធា ទានំ ទេតិ** *ឱ្យទានដោយសទ្ធាគឺឱ្យដោយចិត្ត ជឿកម្ម និង ផលវិបាករបស់កម្ម ជឿថាសត្វទាំងឡាយ មានកម្ម ដែលខ្លួនបានធ្វើហើយជារបស់ខ្លួន...។*

*២-* **សក្កច្ចំ ទានំ ទេតិ** *ឱ្យទានដោយគោរព គឺគោរព ទេយ្យវត្ថុផង គោរពបដិគ្គាហកៈ អ្នកទទួលផង ។ គោរពទេយ្យវត្ថុ គឺ សំអាតទានវត្ថុដោយផ្ចិតផ្ចង់ មិនខ្ជីខ្ជាតាមតែបាន ។ ឯគោរព បដិគ្គាហកៈ គឺ សំដែងសេចក្តីរាប់អានដ៏ខ្លង់ខ្ពស់ ចំពោះអ្នកទទួល ទានមិនរើសមុខ រើសវណ្ណៈ ។*

*៣-* **កាលេន ទានំ ទេតិ** *ឱ្យទានតាមកាលគួរ គឺឱ្យតាម*

*កាលតាមរដូវដែលគេត្រូវធ្វើ ត្រូវឱ្យ ដូចជាចូលវស្សា ចេញវស្សា រដូវរងាឱ្យគ្រឿងស្លៀកដណ្ដប់ រដូវក្ដៅឱ្យទឹក ឬ ក៏ពេលមានវត្ថុថ្មីថ្មោងមានផ្លែឈើជាដើម ។*

៨- **អនុគ្គហិតចិត្តោ ទានំ ទេតិ** *ឱ្យទានដោយសេចក្ដីអនុគ្រោះគឺឱ្យដោយចិត្តមេត្តាអាណិតអាសូរយ៉ាងទោរទន់ចំពោះសមណៈ ឬ ជនក្រីក្រលំបាកដែលរងទុក្ខវេទនា ដោយសេចក្ដីស្រេកឃ្លានជាដើម ឱ្យបានសុខស្រួលផុតអំពីទុក្ខព្រួយ ហើយឥតតាំងចិត្តថា នឹងទារយកគុណបំណាច់អ្វី អំពីបដិគ្គាហកៈនោះមកវិញឡើយ ។*

៩- **អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ** *ឱ្យទានដោយមិនបានតាំងចិត្តបៀតបៀនខ្លួនឯង និង អ្នកដទៃ គឺឱ្យដើម្បីបន្ទោបង់លោភៈ និង មច្ឆរិយៈ ព្រមទាំងអាសវកិលេស ដែលនាំឱ្យវិលវល់ក្នុងសង្សារវដ្ដតែប៉ុណ្ណោះ មិនអួតអាងឱ្យអ្នកដទៃស្ញើចសរសើរ ។ ដែលថាមិនបៀតបៀនខ្លួន គឺ មិនឱ្យអ្នកដទៃសរសើរខ្លួន មិនបៀតបៀនអ្នកដទៃ គឺ មិនបង្អាប់បន្ទាបអ្នកដទៃ ។*

## សប្បុរសធ្វើទានក្នុងរបៀបថ្លៃថ្នូរ ៥ យ៉ាងទៀត គឺ ៖

១- **សទ្ធច្ចំ ទេតិ** *ឱ្យទានដោយសេចក្ដីគោរព ចំពោះវត្ថុដែលត្រូវឱ្យ ។*

២- **ចិត្តីំ កត្វា ទេតិ** ឱ្យទានដោយតាំងចិត្តគោរព ចំពោះទេយ្យវត្ថុ និង បដិគ្គាហកៈ ។

៣- **សហត្ថា ទេតិ** ឱ្យទានដោយដៃខ្លួនឯង ។

៤- **អនបវិដ្ឋំ ទេតិ** ឱ្យទានដោយមិនបោះឱ្យ ។

៥- **អាគមនទិដ្ឋិកោ ទេតិ** ឱ្យទានដោយចិត្តជឿថា នឹងទទួលផលដោយពិត ។

សប្បុរសធ្វើទាន លោកពុំបានរើសបដិគ្គាហកៈអ្នកទទួលទេ មនុស្សល្អ ក៏លោកជួយសង្គ្រោះ មនុស្សអាក្រក់ ក៏លោកជួយសង្គ្រោះ ។ លោកជួយសង្គ្រោះមនុស្សអាក្រក់ ក្នុងន័យថា លោកមានចិត្តអាណិត ព្រោះមនុស្សយើងកាលណាមានទុក្ខ ឬ មានគ្រោះថ្នាក់កើតឡើង រមែងបួងសួងសុំជំនួយពីអ្នកដទៃ ។ ចរិយាល្អរបស់សប្បុរសក្នុងផ្នែកទាននេះ អាចធ្វើឱ្យមនុស្សអាក្រក់ ប្រែចិត្តមកជាមនុស្សល្អវិញក៏មាន ។

សប្បុរសមួយពួកទៀត វេលាធ្វើទានលោកពុំបាននឹកនាដល់កិរិយាប្រព្រឹត្តិ ជំនឿ ទិដ្ឋិ ជាតិសាសន៍ លទ្ធិ និង សាសនារបស់មនុស្សឡើយ ។ លោកលះបង់ចិត្តធម្មតា គឺ ចិត្តដែលសហគត ជាមួយសោមនស្សវេទនាអស់ហើយ លោកអាស្រ័យតែជាមួយចិត្ត ដែលសហគតដោយឧបេក្ខាវេទនា ។ ដូចធ្លាប់បានជំរាប

ខាងដើមមកហើយថា សោមនស្សវេទនា ជាវេទនាមានមកឯងជាមួយធម្មជាតិ វេទនានេះមានគូជាមួយទោមនស្សវេទនា។ចំណែកឧបេក្ខាវេទនា ជាវេទនាកើតឡើងពីការអប់រំ ( តាមរយៈសមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋាន ) ជាវេទនាមិនមានគូ ។ មនុស្សធម្មតាធ្វើទានបានចំពោះតែវត្ថុដែលខ្លួនចូលចិត្ត មនុស្សដែលខ្លួនរាប់អានសាសនាដែលខ្លួនកាន់ លទ្ធិនិកាយដែលខ្លួនស្រឡាញ់ ព្រោះចិត្តរបស់គេអាស្រ័យជាមួយសោមនស្សវេទនា ហើយច្រើនធ្លាក់ទៅជាបាដិបុគ្គលិកទាន ។ ទានដែលគេធ្វើដោយអាស្រ័យ ឧបេក្ខាវេទនាច្រើនតែជាសង្ឃទាន ឬ សាធារណទាន ។

**អសប្បុរស** ធ្វើទានដោយស្មារតីទាប ខ្វះសេចក្តីថ្លៃថ្នូរ និង ដោយសេចក្តីប្រមាទ ផ្ទុយស្រឡះអំពីសប្បុរស ។ ទានដែលអសប្បុរសធ្វើ ហៅថា **អសប្បុរិសទាន** ដែលមានន័យផ្ទុយគ្នា និង សប្បុរិសទាន ដែលបានពោលរួចមកហើយនេះ ។

## សង្គហធម៌

**សង្គហធម៌** ប្រែថា ធម៌សម្រាប់សង្គ្រោះគ្នា គឺ ធម៌សម្រាប់សង្គ្រោះរវាងមាតាបិតា និង បុត្រធីតា ស្វាមី និង ភរិយា គ្រូបាអាចារ្យ និង សិស្ស ចៅហ្វាយនាយ និង កម្មករ...។

សង្គហធម៌ជាគ្រឹះរបស់សង្គម ។ សង្គហធម៌មានទីតាំង ឬ

អង្គនៃសេចក្តីសង្គ្រោះ ៤ ប្រភេទ ហៅថា សង្គហវត្ថុ គឺ ៖

១- **ទាន** ការឱ្យទេយ្យវត្ថុ,

២- **បិយវាចា** ការពោលវាចាគួរឱ្យចង់ឮ ចង់ស្តាប់ ,

៣- **អត្ថចរិយា** ការប្រព្រឹត្តិអំពើជាប្រយោជន៍ដល់គ្នា,

៤- **សមានត្តតា** ការតាំងខ្លួនស្មើៗដោយគុណធម៌ ។

## សង្គហធម៌របស់មាតាបិតា

### មាតាបិតាសង្គ្រោះបុត្រធីតាដោយធម៌ ៥ យ៉ាងគឺ ៖

១- **បាបា និវារេន្តិ** មាតាបិតា តែងតែហាមប្រាមកូនឱ្យវៀរចាកអំពើបាបទាំងឡាយទាំងពួងដែលសង្គមស្អប់ខ្ពើម ពោលគឺវៀរចាកការសម្លាប់សត្វ បៀតបៀនព្យាបាទអ្នកដទៃ លួចឆក់ប្លន់កេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃការប្រព្រឹត្តិល្មើសរំលោភប្រពៃណីលើប្រពន្ធកូនអ្នកដទៃ ការនិយាយកុហក ឆបោកអ្នកដទៃ ព្រមទាំងវៀរចាកការសេពគ្រឿងស្រវឹង ឬ គ្រឿងញៀនផ្សេងៗ មានអាភៀន យ៉ាម៉ា មួយអន្ទើដោយល្បែងពាលា អាវាសែគ្រប់ប្រភេទដែលនាំមកនូវសេចក្តីវិនាសអន្តរាយដល់ខ្លួន និង សង្គមជាតិ ។

២- **កល្យាណេ និវេសេន្តិ** មាតាបិតា តែងតែដឹកនាំកូនឱ្យធ្វើអំពើបុណ្យកុសល អំពើសុចរិតយុត្តិធម៌ ដូចជាការធ្វើទាន រក្សាសីល ការចេះគោរពម្តាយឪពុក ព្រះសង្ឃ ចាស់ទុំ ឧត្តមគ្រូទ្ធាចារ្យ

ត្រកូលរៀមច្បងជាដើម ។

៣- **សិប្បំ សិក្ខាបេន្តិ** កាលបើកូនមានវ័យល្មមសមនឹងសិក្សា ឪពុកម្ដាយ តែងតែខ្នះខ្នែងបញ្ជូនកូនឱ្យទៅរៀនសូត្រតាមសាលានានា និង ជួយជំរុញលើកទឹកចិត្តឱ្យកូនស្រឡាញ់ពេញចិត្តចំពោះការសិក្សា ទាំងផ្នែកពុទ្ធចក្រ និង អាណាចក្រ ជាពិសេស មុខវិជ្ជាដែលសង្គមត្រូវការនាបច្ចុប្បន្ននេះ ។ មិនតែប៉ុណ្ណោះគាត់ថែមទាំងពន្យល់អំពីផលវិបាកនៃភាពល្ងង់ខ្លៅ ដែលជាមាគ៌ាមួយឈានទៅរកឱនភាព ភាពថោកទាប មិនអាចថែរក្សា ឬ លើកស្ទួយជីវភាពគ្រួសារ ឱ្យរុងរឿងថ្កុំថ្កើងបានឡើយ ។ មានតែចំណេះចេះដឹងប៉ុណ្ណោះ ដែលធ្វើឱ្យយើងមានកិត្តិយសថ្លៃថ្លា មានគេគោរពរាប់អាន និង អាចជួយលើកស្ទួយវង្សត្រកូលជាតិ សាសនា ឱ្យបានរុងរឿង ចំរើនជាភិយ្យោភាព ។

៤- **បដិរូបេន ទារេន សញ្ញោជេន្តិ** មាតាបិតា កាលបើដឹងថា កូនរបស់ខ្លួនចំរើនវ័យធំល្មមមានគូស្រករហើយ គាត់តែងតែរៀបចំទុកដាក់កូនចៅឱ្យមានភរិយា ស្វាមី ទៅតាមសមត្ថភាពធនធានពូជពង្សវង្សត្រកូល និង តាមប្រពៃណីរបស់ខ្លួន ។

៥- **សមយេ ទាយជ្ជំ និយ្យាទេន្តិ** មាតាបិតា តែងចែកចាយទ្រព្យសម្បត្តិកេរមត៌ក របស់ខ្លួនតាមសម័យកាល គឺ ចែកឱ្យ

កូនជានិច្ច និង ជារឿយៗមិនដែលខាន ។ កាលសម័យ គឺ មាតាបិតា ចែកទ្រព្យឱ្យកូនតាមកាល នៅពេលដែលកូនបែកមានក្រុមគ្រួសារហើយ ។

សូមចាំជាក់ក្នុងចិត្តថា មាតាបិតា ជាអ្នកមានព្រហ្មវិហារធម៌ ៤ និង សង្គហធម៌ ៥ ចំពោះបុត្រធីតាគ្រប់រូប ព្រោះថាលោកទាំងទ្វេបានចិញ្ចឹមបីបាច់ថែរក្សា ជាអ្នកមានឧបការគុណដ៏ធំធេងពុំអាចគណនាបានឡើយ គឺមានអនន្តគុណ គុណធ្ងន់ដ៏ក្រៃលែង អនេកប្បគុណ គុណច្រើនរាប់មិនអស់ អសមគុណ គុណប្រៀបស្មើពុំបាន អប្បមាណគុណ គុណប្រមាណមិនបាន ។

## សង្គហធម៌របស់បុត្រធីតា

ក្នុងព្រះពុទ្ធសាសនា ដើម្បីឱ្យបានជាអ្នកមានកតញ្ញូកតវេទីតាធម៌ចំពោះមាតាបិតា បុត្រធីតាត្រូវតបស្នងសងគុណមាតាបិតាវិញ ដោយសង្គហធម៌ ៥ យ៉ាង និង សម្បទា ៤ យ៉ាង ។

## សង្គហធម៌ ៥ យ៉ាង គឺ ៖

១- **ភតោ នេសំ ភរិស្សាមិ** បុត្រធីតា គប្បីចិញ្ចឹមថែរក្សាមាតាបិតាវិញ ដោយផ្គត់ផ្គង់ ទំនុកបំរុងនូវបច្ច័យទាំងឡាយ ៤ មានជូនសំលៀកបំពាក់ បាយទឹក នំចំណី ត្រីសាច់ សំពត់អាវសាវស្បៃ កន្ទេលខ្នល់ខ្នើយ ពូកគ្រែ ព្រៃព្រំ មុងក្ឋយសម្រាប់បិទបាំង

*រាងកាយ និង ថ្នាំកែរោគ...។*

២- **កិច្ចំ នេសំ ករិស្សាមិ** *បុត្រធីតា គប្បីជួយធ្វើការងារមាតាបិតា បើសិនជាលោកមានធុរៈពឹងពាក់យើង ។ ធម្មតាកូនតែងមានកិច្ចការផ្ទាល់ខ្លួនច្រើនណាស់ ប៉ុន្តែបើសិនជាលោកទាំងពីរមានធុរៈត្រូវពឹងពាក់នោះ កូនត្រូវបញ្ឈប់ការងាររបស់ខ្លួនសិនទោះបីជារវល់យ៉ាងណាក៏ដោយ មិនត្រូវធ្វើព្រងើយកន្តើយ ឬធ្វើមិនដឹងមិនឮនោះទេ ។*

៣- **កុលវំសំ ឋបេស្សាមិ** *បុត្រធីតា គប្បីថែរក្សា វង្សត្រកូលឱ្យបានល្អ ត្រូវការពារកេរ្តិ៍ឈ្មោះមាតាបិតារបស់ខ្លួន និងតំកើងវង្សត្រកូលឱ្យមានកេរ្តិ៍ឈ្មោះ ពិរោះ ក្រអូបសុះសាយក្នុងសង្គម ព្រមទាំងរៀបចំឥរិយាបថ អាកប្បកិរិយា ឬកពា មារយាទឱ្យបានថ្លៃថ្នូរ ត្រូវដឹងស្គាល់ឋានៈរៀមច្បង ខ្ពស់ទាបរបស់មនុស្សកុំឱ្យត្រូវដូចបូរាណពោលថា" ដឹងឆ្លើយត្បិតដង កូនសោតវែងឆ្គងត្បិតមេបា" ។ បុត្រធីតាត្រូវមានសីលធម៌ សុជីវធម៌ជានិច្ច ហើយប្រព្រឹត្តតែអំពើដែលមានប្រយោជន៍ដល់ខ្លួន និង សង្គម ។*

៤- **ទាយជ្ជំ បដិបជ្ជាមិ** *បុត្រធីតា គប្បីគោរពប្រតិបត្តិមាតាបិតាឱ្យបានល្អ ដោយត្រៃបណាម គឺ ការគោរពប្រណិប័តន៍ដោយទ្វារទាំង បី ជាពិសេសពេលដែលគាត់មានវ័យចាស់ជរា ។*

មិនត្រូវធ្វើមុខ ក្រញូវ ចងចិញ្ចើម ពោលពាក្យទ្រគោះបោះបាក ឬ មានកាយវិការ ប្រវេងប្រវាង ប្រឡេងខាម ពាក្យសំដី រមុាំង រមោក បញ្ឆួសបញ្ឆោក តបតពាក្យសំដី ឱ្យមាតាបិតាចុកណែន ដើមទ្រូងស្រក់ទឹកភ្នែក ។

៥- **ទក្ខិណាំ អនុប្បទស្សាមិ** បុត្រធីតា គប្បីដឹងថា ពេល មាតាបិតា ធ្វើមរណកាលទៅកាន់លោកខាងមុខ យើងជាកូនត្រូវ ធ្វើបុណ្យឈាបនកិច្ច ព្រមទាំងធ្វើបុណ្យឱ្យបានញឹកញាប់ ហើយ ជារឿយៗ ដើម្បីឧទ្ទិសកុសលជូនចំពោះលោកទាំងពីរ គឺមាតាបិតា ព្រមទាំងញាតិកាទាំងប្រាំពីរសន្តាន ។

## សម្បទាធម៌ ៤ យ៉ាងគឺ៖

១- **សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា ។ ប្រសិនបើមាតា បិតា ជាអ្នកគ្មានសទ្ធា ជឿលើកម្មផលទេ បុត្រធីតា គប្បីដឹកនាំ គាត់ទាំងពីរនាក់ ឱ្យមានសទ្ធាជ្រះថ្លាឡើង ។

២- **សីលសម្បទា** ដល់ព្រមដោយសីល ។ ប្រសិនបើមាតា បិតា ជាអ្នកទ្រុស្តសីល មានការសម្លាប់សត្វជាដើម បុត្រធីតា គប្បី ពន្យល់ណែនាំលោកទាំងទ្វេឱ្យរក្សាសីលឡើង ។

៣- **ចាគសម្បទា** ដល់ព្រមដោយការលះ ។ ប្រសិនបើ មាតាបិតាជាមនុស្សកំណាញ់ស្វិតស្វាញ មិនចេះចំណាយធនធាន

ធ្វើទាននោះទេ បុត្រធីតាគប្បីពន្យល់ណែនាំ កុំឱ្យគាត់លុះក្រោមអំណាចមច្ឆរិយៈធ្វើជាទាសករនៃទ្រព្យសម្បត្តិ ឱ្យគាត់ចេះបរិច្ចាគធនធានធ្វើជាទានឡើង ។

៤- **បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា ។ ប្រសិនបើមាតា បិតាជាអ្នកមិនចូលចិត្តស្តាប់ធម៌ទេសនា ឬ សិក្សារៀនសូត្រធម៌អាថ៌ ចំរើនមេត្តាភាវនាទេនោះ បុត្រធីតា គប្បីពន្យល់ណែនាំគាត់ឱ្យចេះស្តាប់ធម៌ សិក្សាអត្ថន័យរបស់ព្រះធម៌ ហើយតាំងចិត្តចំរើននូវកម្មដ្ឋាន ដើម្បីឱ្យកើតបញ្ញាចាក់ធ្លុះឡើង ។

កុលបុត្រកុលធីតា កាលបើបានអនុវត្តនូវសង្គហធម៌ទាំង ៥ យ៉ាង និង សម្បទា ៤ យ៉ាង ដូចបានពោលមកខាងលើដោយម៉ត់ចត់មិនធ្វេសប្រហែស ចំពោះលោកអ្នកដ៏មានគុណ គឺ មាតាបិតានឹងមានឈ្មោះថាបានបំពេញ **បូជាទាន** ឬ **បដិការទាន** ព្រមទាំងមានឈ្មោះថា **កតញ្ញូកតវេទីបុគ្គល** ផង ។

## សង្គហធម៌របស់ស្វាមី

ស្វាមីគប្បីសង្គ្រោះភរិយា ដោយសង្គហធម៌ ៥ យ៉ាង គឺ ៖

១- **សម្មាននាយ** ស្រឡាញ់រាប់អានថា ជាភរិយារបស់ខ្លួន ។ យើងជាស្វាមីរបស់ស្ត្រីណា គប្បីសង្គ្រោះស្ត្រីនោះ ដោយចិត្តស្មោះត្រង់ គឺ លើកតំកើងជាភរិយាពេញសិទ្ធិ ។

២- **អទិមាននាយ** មិនប្រមាថមើលងាយ ភរិយាដូចជាខ្ញុំកំដរបាវព្រាវ ។ ខណៈពោលទៅកាន់ភរិយា គប្បីពោលពាក្យសំដីផ្អែមល្ហែម ពិរោះពិសា មិនពោលពាក្យរោយរាយ ឥតប្រយោជន៍ បើភរិយាមានកំហុសខុសត្តង់បន្តិចបន្តួច ក៏គួរអត់ឱនឱ្យ ហើយទូន្មានប្រៀនប្រដៅស្វាត់ៗ ដោយសេចក្តីល្អ ។

៣- **អនតិចរិយាយ** មិនប្រព្រឹត្តកន្ធងចិត្តភរិយា គឺមិនប្រព្រឹត្តក្បត់ព្រំដែនជាប្តី យកបេះដូងរបស់ខ្លួនដែលមានម្ចាស់ហើយទៅបូជាដល់ស្ត្រីដទៃ សមដូចពាក្យបុរាណាចារ្យលោកបានពោលថា "ត្រីឆ្អើតឆ្អៀតពង" ។

៤- **ឥស្សរិយវោស្សគ្គេន** ប្រគល់អំណាចជាធំ ចំពោះភរិយាជាស្ត្រីមេផ្ទះ រៀបចំទុកដាក់ទ្រព្យសម្បត្តិ រក្សាថែទាំ លំអគេហដ្ឋានឱ្យមានសិរីសួស្តី ។

៥- **អលង្ការានុប្បទានេន** ក្នុងនាមជាស្វាមី គប្បីរៀបចំឱ្យមានគ្រឿងអលង្ការដល់ភរិយាគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់តាមកាលៈទេសៈ តាមសម័យនិយម និង តាមសមត្ថភាព ។

## សង្គហធម៌របស់ភរិយា

ភរិយាគប្បីសង្គ្រោះស្វាមី ដោយសង្គហធម៌ ៥យ៉ាងគឺ ៖

១- **សុសំវិហិតកម្មន្តា** ភរិយាគប្បីចាត់ចែងការងារមាន

ម្ហូបចំណីអាហារជាដើម ដោយផ្ចិតផ្ចង់សម្រាប់ស្វាមី ឱ្យត្រឹមត្រូវតាមពេលវេលា ។

២- **សុសង្គហិតបរិជនា** ភរិយា គប្បីសង្គ្រោះញាតិខាងស្វាមី និង ខាងខ្លួនដោយប្រពៃ ។

៣- **អនតិចារិនី** ភរិយា មិនគប្បីប្រព្រឹត្តកន្លងចិត្តប្តី គឺមិនត្រូវយកបេះដូងរបស់ខ្លួន ដែលជាកម្មសិទ្ធិរបស់ស្វាមី ទៅប្រគល់ឱ្យបុរសដទៃក្រៅពីស្វាមីខ្លួនឡើយ ។

៤- **សម្ភតំ អនុរក្ខតិ** ភរិយា គប្បីថែទាំទ្រព្យសម្បត្តិ ដែលប្តីរកបានមកហើយ មិនឱ្យវិនាសបាត់បង់ខូចខាតទៅវិញ ដោយហេតុការណ៍ណាមិនគួរ ។

៥- **ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ** ភរិយា គប្បីឈ្លាសវៃក្នុងការងារទាំងឡាយ មានការចាត់ចែងម្ហូបចំណី ជាដើម ដោយល្អ មិនខ្ជិលច្រអូស ហើយកិច្ចការស្ត្រីទាំងប៉ុន្មាន ក្នុងផ្ទះ ត្រូវធ្វើដោយផ្ចិតផ្ចង់ ឱ្យបានសម្រេចល្អជាទីបំផុត ។

## សង្គហធម៌របស់ចៅហ្វាយនាយ

ចៅហ្វាយនាយ ត្រូវមានសន្តានចិត្តសន្តោស សង្គ្រោះដល់ទាសកម្មករ ដោយសង្គហកិច្ច ៥ យ៉ាង គឺ៖

១- **យថាពលំ កម្មន្តំ សំវិធានេន** ចាត់ចែងការងារឱ្យធ្វើ

*តាមសមគួរដល់កម្លាំង ។ ចៅហ្វាយនាយ កាលប្រើកម្មករឱ្យធ្វើការងារណាមួយ គប្បីប្រមើលមើលសមត្ថភាពទាសកម្មករសិន បើកម្មករនោះមានប្រាជ្ញាស្មារតី មានកម្លាំងមាំមួនល្មមទទួលការងារធ្ងន់ស្រាលបាន ទើបចាត់ចែងឱ្យធ្វើតាមសមត្ថភាព ។*

*២-* **ភត្តវេត្តនានុប្បទានេន** *ឱ្យភោជនាហារ និង រង្វាន់ ។ ចៅហ្វាយនាយគប្បីទំនុកបំរុង ភោជនាហារសម្រាប់ទាសកម្មករបរិភោគឱ្យបានគ្រប់គ្រាន់តាមកាល តាមវេលាមិនឱ្យខ្វះខាត ។*

*៣-* **គិលានុបដ្ឋានេន** *ព្យាបាលក្នុងពេលមានជម្ងឺ ។ កាលបើទាសកម្មករមានជម្ងឺដំកាត់ផ្សេងៗកើតឡើង ចៅហ្វាយនាយគួរប្រញាប់ប្រញាល់ទិញថ្នាំសង្កូវសម្រាប់ព្យាបាលរោគ ឬ អញ្ជើញពេទ្យហ្ម មកពិនិត្យព្យាបាល ថែទាំសុខភាព ជម្ងឺទាសកម្មករ ឬបាវព្រាវ រហូតបានជាសះស្បើយ ។*

*៤-* **អច្ឆរិយានំ រសានំសំវិភាគេន** *ចែកភោជនាហារដែលមានរសជាតិប្លែកៗឱ្យបរិភោគ ។ ដូចជាចំណីដែលគាប់ប្រសើរ ឬផ្លែឈើណាដែលពុំសូវមាន ជួនជាបានម្តងម្កាល ចៅហ្វាយនាយត្រូវតែចែករំលែកដល់ទាសកម្មករឱ្យបានបរិភោគខ្លះៗផង ។*

*៥-* **សមយេ វោស្សគ្គេន** *បើកឱកាសឱ្យសប្បាយក្នុងកាលដ៏សមគួរ ។ ដូចជាមានពិធីបុណ្យទានអ្វីមួយ មានល្បែងរបាំ*

*មហោស្រព ឬ ក្នុងពេលបុណ្យចូលឆ្នាំជាដើម ចៅហ្វាយនាយត្រូវបើកឱកាសឱ្យកម្មករបានទៅលេង កំសាន្ត សប្បាយនឹងគេ ព្រមទាំងបើករង្វាន់ប្រាក់កាសសម្រាប់ចាយវាយខ្វះៗផង ។*

## សង្គហធម៌របស់ទាសកម្មករ

*ទាសកម្មករ ត្រូវគោរពប្រតិបត្តិ តាមតួនាទីរបស់ខ្លួនក្នុងសង្គហធម៌ ៥ យ៉ាងគឺៈ*

១- **បុព្វុដ្ឋាយិនោ ច ហោន្តិ** *ក្រោកឡើងធ្វើការមុនចៅហ្វាយនាយ ។ កិច្ចការណាដែលចៅហ្វាយនាយ ចាត់ចែងដាក់ឱ្យធ្វើនោះ គប្បីស្ទុះស្ទារប្រញាប់ប្រញាល់ ធ្វើឱ្យបានមុនចៅហ្វាយនាយរបស់ខ្លួន ។*

២- **បច្ឆានិបាតិនោ** *លែងធ្វើការក្រោយចៅហ្វាយនាយ ។ កាលបើប្រកបការងាររបស់ចៅហ្វាយនាយ ត្រូវធ្វើឱ្យដល់ទីបំផុតដល់ពេលវេលា មិនត្រូវឈប់ខុសពេលវេលា បើចៅហ្វាយនាយឈប់ហើយ ចាំឈប់តាមក្រោយទើបគួរ ។*

៣- **ទិន្នាទាយិនោ** *របស់ណា ដែលចៅហ្វាយនាយឱ្យទើបកាន់យក ។ ទាសកម្មករត្រូវមានសច្ចៈទៀងត្រង់នឹងចៅហ្វាយនាយ មិនត្រូវមានចិត្តគំនិត ប្រព្រឹត្តលួចលាក់យករបស់ទ្រព្យចៅហ្វាយនាយឡើយ ។*

៨- **សុភតកម្មករា** ធ្វើការងារដោយយកចិត្តទុកដាក់ ។ ការងារណាដែលចៅហ្វាយនាយបញ្ជាឱ្យធ្វើ គប្បីមានសុឆន្ទៈខិតខំប្រឹងប្រែងធ្វើដោយផ្ចិតផ្ចង់ មិនធុញទ្រាន់មិនខ្ជិលខ្ជាឱ្យរួចតែពីដៃ ចេះសំអិតសំអាងដូចជារបស់ខ្លួន ខិតខំខ្មីឃ្មាតធ្វើឱ្យទាល់តែបានសម្រេចជាទីបំផុត ។

៩- **កិត្តិវណ្ណហារា** នាំកិត្តិគុណចៅហ្វាយនាយ ទៅពោលសរសើរក្នុងទីដទៃ ។ កិត្តិគុណ គឺគុណសម្បត្តិ ចរិយាសម្បត្តិ ដ៏ល្អសុភាពស្លូតបូតទៀងត្រង់ ឬ គុណសម្បត្តិដែលល្បីខ្ចរខ្ចាយ ។ ទាសកម្មករ គប្បីនាំគុណវិសេសនេះ ទៅពោលប្រាប់ជនដទៃសរសើរថា ចៅហ្វាយនាយរបស់ខ្លួនល្អណាស់ លោកចេះសង្គ្រោះមិនប្រកាន់វណ្ណៈ ឬ ចេះពោលពាក្យផ្អែមល្ហែម ទៅកាន់កម្មករមិនប្រមាថមើលងាយដល់ជនដទៃជាដើម ដើម្បីលើកកិត្តិយសរបស់ចៅហ្វាយនាយ ។

សង្គហធម៌ជាគ្រឹះស្ថានមួយ ដ៏សំខាន់របស់សង្គមជាតិ ។ សង្គហធម៌នេះ កាលបើកើតមានរីកដុះដាល់ដល់សង្គមជាតិណាហើយ សង្គមជាតិនោះរមែងជួបប្រទះនូវសុខុមាលភាព វឌ្ឍនភាព ភាតរភាព សមភាពជាស្ថាពរ ។

# ទានប្បភេទ

**ទានប្បភេទ** *ប្រែថា ប្រភេទរបស់ទាន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ស្រាវជ្រាវ សំដែងពន្យល់ពុទ្ធបរិស័ទ អំពីទានមានច្រើនប្រភេទ មិនអាចបរិយាយឱ្យអស់បានទេ ។ ក្រៅអំពីប្រភេទទានដែលបានអធិប្បាយខាងដើមរួចមកហើយនោះ ខ្ញុំសូមលើកយកទានក្នុងព្រះវិន័យ, ទានក្នុងព្រះសូត្រ, ទានក្នុងព្រះអភិធម្ម, ករុណាទាន, បូជាទាន ឬ បដិការទាន, សង្គហទាន ឬ អនុគ្គហទាន , កាលទាន, អសម្មតទាន, អភ័យទាន, ទក្ខិណានុប្បទាន និង កឋិនទានមកពិពណ៌នា ដោយសង្ខេប ។*

## ទានក្នុងព្រះវិន័យ

*ទាននៅក្នុងព្រះវិន័យមាន ៤ យ៉ាង គឺ ចីវរប្បច្ច័យ, បិណ្ឌបាតប្បច្ច័យ, សេនាសនប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ។ សូមអាន សេចក្តីពន្យល់នៅក្នុងអាមិសទានខាងដើម ។*

## ទានក្នុងព្រះសូត្រ

*ទានក្នុងព្រះសូត្រមាន ១០ យ៉ាង គឺ អន្នំ បាយ, បានំ ទឹក, វត្ថំ សំពត់, យានំ យាន, មាលា ផ្កា, គន្ធំ គ្រឿងក្រអូប, វិលេបនំ គ្រឿងលាប, សេយ្យំ ទីដេក, អាវសថំ ទីនៅ, និង បទីបេយ្យំ គ្រឿងប្រទីប ។ សូមអានសេចក្តីពន្យល់នៃទានវត្ថុ ១០ យ៉ាង ក្នុង*

អាមិសទានខាងដើម ។

## ទានក្នុងព្រះអភិធម្ម

ទានក្នុងព្រះអភិធម្ម មាន ៦ យ៉ាងគឺ ៖

១- **រូបទាន** ឱ្យរូបជាទាន,

២- **សទ្ទទាន** ឱ្យសម្លេងជាទាន,

៣- **គន្ធទាន** ឱ្យក្លិនជាទាន,

៤- **រសទាន** ឱ្យរសជាទាន,

៥- **ផោដ្ឋព្វទាន** ឱ្យសម្ផស្សជាទាន,

៦- **ធម្មារម្មណ៍** ឱ្យធម៌ជាទាន ( កើតតាមមនោទ្វារ ) ។

## ករុណាទាន

មនុស្សខ្លះក្នុងលោកនេះ ជាអ្នកមានសន្តានចិត្ត អាណិតអាសូរទោរទន់ទៅរកមនុស្សសត្វដទៃ ហើយបានឱ្យគ្រឿងបរិភោគដោយសេចក្តីអាណិតតែម្យ៉ាង មិនអាស្រ័យយកកម្លាំងប្រើប្រាស់ការឱ្យទានដូច្នេះ ហៅថា **ករុណាទាន** ។

## បូជាទាន ឬ បដិការទាន

មនុស្សខ្លះ យល់ច្បាស់ពីគុណូបការៈ ឬ គុណសម្បត្តិណាមួយ របស់លោកអ្នកដ៏មានគុណ មានមាតាបិតា គ្រូអាចារ្យ ឬលោកអ្នកទ្រទ្រង់ នូវសីលគុណខ្ពង់ខ្ពស់ជាដើម ហើយបានធ្វើទាន

ចំពោះលោកអ្នកដ៏មានគុណនោះ ការឱ្យទានបែបនេះ ហៅថា **បូជាទាន** ឬ **បដិការទាន** ។

## សង្គហទាន ឬ អនុគ្គហទាន

មនុស្សខ្លះ មានសន្តានចិត្តធូរទូលំទូលាយ ចង់ឱ្យសេចក្តីសុខចំរើន និង ប្រយោជន៍ដល់អ្នកដទៃ ដែលជាញាតិមិត្រ សាច់សាលោហិតក្តី ឬជាមនុស្សរួមសង្គមជាតិក្តី ដែលល្មមសមគួរដល់ការទទួលអំណោយសង្គ្រោះ ហើយក៏ចែកទ្រព្យសម្បត្តិជាដើមទុនក្តី គ្រឿងបរិភោគប្រើប្រាស់ក្តី ដើម្បីទំនុកបំរុងជួយជាកម្លាំងសង្គ្រោះឱ្យកើតមានប្រយោជន៍ស្មើមុខគ្នាឡើង ការឱ្យទានដូច្នេះ ហៅថា **សង្គហទាន** ឬ **អនុគ្គហទាន** ។

## កាលទាន

**កាលទាន** ប្រែថា ការឱ្យទានតាមកាលវេលា ។ កាលទាន មាន ៥ យ៉ាងគឺ ៖

១- **អាគន្តុកទានំ** ទានចំពោះអ្នកទើបនឹងមកដល់ថ្មី,

២- **គមិកទានំ** ទានចំពោះអ្នកដែលរៀបចំ ធ្វើដំណើរទៅកាន់ទីឆ្ងាយ,

៣- **គិលានទានំ** ទានចំពោះអ្នកជម្ងឺ,

៤- **ទុព្ភិក្ខទានំ** ទានក្នុងពេលវេលា ដែលកំពុងអត់ឃ្លាន,

*៥- **នវទានំ** ទានផ្លែឈើ ឬ វត្ថុដែលទើបនឹងមានដំបូង ។*

## អសម្មតទាន

***អសម្មតទាន** ប្រែថា ទានដែលលោកអ្នកប្រាជ្ញ មិនសន្មត ថាជាទាន ព្រោះថាទាននោះ មិនបានបុណ្យ កុសល និង ផល្លា-និសង្សទេ ។ អសម្មតទាន មាន ៥ យ៉ាង គឺ ៖*

*១- **ឥត្ថីទានំ** ឱ្យស្ត្រីដល់បុរស ឱ្យបុរសដល់ស្ត្រី,*

*២- **ឧសភទានំ** បើកលែងគោឧសភ គឺ គោបា ឬ គោឈ្មោលដល់មេគោ ឱ្យមេគោដល់គោឧសភ,*

*៣- **មជ្ជទានំ** ឱ្យទានទឹកស្រវឹង ឬ ថ្នាំញៀន,*

*៤- **សមជ្ជទានំ** រាំ និង ច្រៀងឱ្យជាទាន ឬ ឱ្យទានរបាំរាំច្រៀងកំប្លុក កំប្លែង ក្រមាប់ក្រមើម,*

*៥- **ចិត្តកម្មទានំ** ឱ្យទានរូបគំនូរស្ត្រី និង បុរសដែលជារូបនាំឱ្យកើតតំរេកត្រេកត្រអាល ទៅរកកាមគុណ ។*

*អសម្មតទាននេះ សាធុជនជាសប្បុរស មិនគួរគប្បីនាំគ្នាធ្វើឡើយ ព្រោះថាទាននេះ បុរាណលោកមិនបានសន្មតថាជាទានបានផល្លានិសង្សដូចទានដទៃទៀតទេ គួរនាំគ្នាខ្វល់ខ្វាយធ្វើសង្ឃទាន ឬ សាធារណទាន ទើបបានផលកម្រៃច្រើន ទុកជាបុញ្ញនិធិទៅអនាគតជាតិ ។*

**អាមិសទាន & ធម្មទាន**

*សព្វថ្ងៃនេះ គេសង្កេតឃើញពេលមានពិធីបុណ្យទានធំៗ ក្នុងវត្តអារាមម្តងៗ ម្ចាស់ដើមទានប្រធានដើមបុណ្យ តែងតែជួល ល្បែងរបាំ កុន ល្ខោន យីកេ ការ៉ាអូខេ ឆាកកំប្លែង មកសំដែងចែក ជូនអ្នកស្រុក អ្នកភូមិ កំសាន្តសប្បាយ ដោយសន្មតិថាជាទាន មានអានិសង្ស ហើយក៏ចេះតែនាំគ្នាធ្វើតៗគ្នារៀងមក ។*

## អភ័យទាន

**អភ័យទាន** *ប្រែថាឱ្យអភ័យដល់មនុស្ស សត្វ ឬធ្វើមនុស្ស សត្វឱ្យអស់ភ័យ ។ អភ័យទានចែកចេញជា ២ ប្រភេទ គឺអភ័យ ទានផ្លូវចិត្ត និង អភ័យទានផ្លូវសម្ភារៈ ។*

១- **អភ័យទានផ្លូវចិត្ត** *អភ័យទានដែលបុគ្គលធ្វើខាងផ្លូវ ចិត្ត បានដល់ការអត់ឱន បទល្មើស កោងកាច ដែលបុគ្គលដទៃ ប្រព្រឹត្តមកលើខ្លួន ។*

២- **អភ័យទានផ្លូវសម្ភារៈ** *អភ័យទាន ដែលបុគ្គលធ្វើ ខាងផ្លូវវត្ថុ បានដល់អំណោយផ្សេងៗ ដែលគេធ្វើឡើងឱ្យមនុស្ស អស់ភ័យ ដើម្បីការពារភ័យរបស់មនុស្សសត្វទាំងឡាយ ។*

*ក្នុងព្រះពុទ្ធសាសនា លោកពោលថា ភ័យចែកចេញជា ៨ យ៉ាងគឺ ៖*

១- **ឧទកភ័យ** *ភ័យកើតអំពីទឹក,*

២- **អគ្គិភ័យ** ភ័យកើតអំពីភ្លើង,

៣- **ចោរភ័យ** ភ័យកើតអំពីចោរកម្ម,

៤- **រាជភ័យ** ភ័យកើតអំពីអំណាច អ្នកគ្រប់គ្រង,

៥- **ជាតិភ័យ** ភ័យអំពីកើត,

៦- **ជរាភ័យ** ភ័យអំពីចាស់,

៧- **ព្យាធិភ័យ** ភ័យកើតអំពីឈឺ,

៨- **មរណភ័យ** ភ័យកើតអំពីស្លាប់ ។

ក្នុងបណ្តាភ័យទាំង ៨ យ៉ាងខាងលើនេះភ័យ ៤ យ៉ាងខាងដើម ជាភ័យមាននៅប្រចាំបច្ចុប្បន្នភព ។ រីឯភ័យ ៤យ៉ាងខាងចុងជាភ័យមានប្រចាំត្រៃភព ។ អាស្រ័យហេតុនេះ ទើបបុរាណាចារ្យលោកចែកអភ័យទានជាពីរផ្នែកទៀត គឺ **អភ័យទានខាងផ្លូវលោកិយ** និង **អភ័យទានខាងផ្លូវលោកុត្តរៈ** ។

**អភ័យទានខាងផ្លូវលោកិយ** បានដល់អំណោយដោយស្ថាបនាព្រៃក ទំនប់ទឹក ប្រឡាយ ស្រះ អណ្តូង ស្ថាបនាបន្ទាយការពារចោរខ្មាំងសត្រូវ ស្ថាបនាគ្រឿងរំលត់ភ្លើង ជួយសង្គ្រោះសត្វដែលត្រូវគេចាប់ដាក់ទ្រុង ដាល ឱ្យបានរួចភ័យដោយបង់តម្លៃជំនួស ឬ ជួយថែរក្សាការពារជីវិតសត្វព្រៃជាដើម ។

**អភ័យទានខាងផ្លូវលោកុត្តរៈ** បានដល់ការសាងធម៌ ឬ

ឱ្យទានធម៌ ដោយបង្រៀន ដោយសំដែងធម្មទេសនា ដោយបាន សាងគម្ពីរ ក្បួនខ្នាត ដើម្បីធ្វើឱ្យមនុស្សមានបញ្ញា ជាសម្មាទិដ្ឋិ មើលឃើញអរិយសច្ចធម៌ បានសម្រេចមគ្គ ផល និព្វាន អស់ភ័យ អំពីសេចក្ដីកើត ចាស់ ឈឺ ស្លាប់ ។ អាស្រ័យហេតុនេះហើយ បាន ជាព្រះសមណគោត្តមបរមគ្រូ ទ្រង់សង្គ្រោះអភ័យទាននេះចូល ទៅក្នុងធម្មទាន ។

## ទក្ខិណានុប្បទាន

**ទក្ខិណានុប្បទាន** មកពីពាក្យ **ទក្ខិណា** + **អនុប្បទាន** = **ទក្ខិណានុប្បទាន** ។ **ទក្ខិណា** ប្រែថា ខាងត្បូង, ខាងស្ដាំក៏បាន ប៉ុន្តែនៅទីនេះ **ទក្ខិណា** ប្រែថា អំណោយដែលទាយក ទាយិកា ជឿកម្ម ជឿផលច្បាស់លាស់ ហើយទើបគេលះឱ្យ ឬ អំណោយ ដែលគេឱ្យដល់ទក្ខិណេយ្យបុគ្គល ។ **អនុប្បទាន** ប្រែថា តាម ឧទ្ទិសឱ្យ ។ ដូច្នេះហើយពាក្យថា **ទក្ខិណានុប្បទាន** ប្រែថា ទក្ខិណាទាន ដែលបុគ្គលតាមឧទ្ទិសឱ្យដល់បុគ្គលដែលស្លាប់ទៅ ហើយ ឬ អំណោយដែលគេឧទ្ទិសទក្ខិណាទាន ចំពោះបុគ្គល ដែលចែកឋានទៅកាន់បរលោកហើយ ។

ឧបការជន មានជីដូនជីតា មាតាបិតា គ្រូអាចារ្យ ញាតិ សាច់សាលោហិត មិត្រសម្លាញ់ជាដើម ដែលបានចែកឋានទៅ

*ហើយ យើងពុំបានដឹងថា លោកទាំងនោះ យោនយកកំណើត ជាទេវតា ជាមនុស្ស ឬ ជាប្រេតវិស័យ ។ ដូច្នេះហើយ យើងជា កុលបុត្រកុលធីតា គួរគប្បីនាំគ្នាធ្វើទក្ខិណានុប្បទាន ឧទ្ទិសជូន ចំពោះអ្នកដ៏មានគុណទាំងនោះ ឱ្យបានញឹកញាប់ ។*

*ព្រះពុទ្ធបរមសាស្តាទ្រង់បានត្រាស់ដឹង និង ឃើញច្បាស់ នូវទុក្ខ និង ការស្រេកឃ្លានដ៏ខ្លាំងក្លា របស់ពួកប្រេតក្នុងបេតភូមិ ( ភូមិរបស់ពួកប្រេត ) ព្រោះពពួកប្រេតទាំងនោះ អាចញ៉ាំងជីវិត ឱ្យរស់នៅបាន ដោយសារផលនៃទាន ដែលញាតិមិត្រសម្លាញ់ ឧទ្ទិសឱ្យអំពីលោកនេះប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពួកប្រេតទាំងនោះ ទោះបីជាដើរត្រាច់ស្វែងរកជួបជនជាញាតិមិត្រ បងប្អូនកូនចៅ ហើយក៏ដោយក៏មិនអាចសុំអង្វរនូវបច្ច័យ ៤ យ៉ាង មានសំពត់ខោ អាវ អាហារបិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈបានឡើយ ។ អាស្រ័យហេតុនេះ ទើបព្រះដ៏មានព្រះភាគ ទ្រង់សំដែងទុកក្នុង តិរោកុឌ្ឌសូត្ររំលឹកជនជាញាតិ ថា ៖*

*"បុគ្គលកាលរឭកនឹកឃើញ នូវឧបការគុណ ដែលលោក ធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងនោះជាញាតិមិត្តរបស់ អញ ដូច្នេះគួរឱ្យទក្ខិណាទានចំពោះប្រេតទាំងឡាយនោះ " ។*

*សូមជ្រាបថាដើម្បីឧទ្ទិសនូវផលទាន ( ទក្ខិណានុប្បទាន ) ដែលយើងបានធ្វើនោះ ឱ្យបានសម្រេចប្រយោជន៍ ដល់ពួកប្រេតទាំងនោះបាន ទាល់តែយើងធ្វើប្រកបដោយអង្គ ៣ ។*

## ទក្ខិណានុប្បទានប្រកបដោយអង្គ ៣ យ៉ាង គឺ៖

*១-* **ទក្ខិណេយ្យសម្បទាយ** *ដល់ព្រមដោយ ទក្ខិណេយ្យបុគ្គល ។ ទក្ខិណេយ្យបុគ្គល គឺ បុគ្គលអ្នកញ៉ាំងទក្ខិណាទានឱ្យបានផលច្រើន បានដល់ព្រះសង្ឃ និង លោកអ្នកមានសីលមានគុណធម៌ខ្ពស់ ។ ព្រះសង្ឃមានអានុភាពចំពោះទក្ខិណាទាន ២ យ៉ាងគឺ៖*

**ក**- *ព្រះសង្ឃជាបុញ្ញខេត្ត ( ស្រែបុណ្យដ៏ប្រសើរ ) ដែលអាចញ៉ាំងទាយកទាយិកា អ្នកមានពូជស្រូវ គឺ ទេយ្យធម៌ សូម្បីតែតិចតួចក៏អាចសម្រេចបុណ្យកុសលដ៏ច្រើនបាន។ បើមិនមានព្រះសង្ឃមកធ្វើជាបដិគ្គាហកៈ នៃទក្ខិណានុប្បទាននោះទេ ទាយកធ្វើដូចម្ដេចនឹងបានសម្រេចបុណ្យកុសល ឧទ្ទិសដល់ពួកប្រេតជាញាតិមិត្របាន ព្រោះព្រះសង្ឃជាស្រែបុណ្យរបស់ទាយកទាយិកា មិនមានស្រែបុណ្យឯណាឱ្យប្រសើរជាងបានឡើយ ។*

**ខ**- *ព្រះសង្ឃជាអ្នកមានសីល មានវត្តប្រតិបត្តិល្អ មានការប្រព្រឹត្តិទៅតាមគន្លងនៃព្រះនព្វលោកុត្តរធម៌ជាដើម អាចញ៉ាំង*

ចិត្តរបស់ពួកប្រេតឱ្យជ្រះថ្លាត្រេកអរបាន ។

២- **ទាយកានំ ឧទ្ទិស្សេន** ទាយកដែលជាញាតិ បាន ឧទ្ទិសចំណែកបុណ្យឱ្យ ។ ទាយកដែលជាអ្នកឱ្យទាន គប្បីតាំងចិត្តឧទ្ទិសបុណ្យកុសល ចំពោះឈ្មោះលោកអ្នកដ៏មានគុណ មានមាតាបិតា ព្រមទាំងញាតិកាទាំង ៧ សន្តានដូចជាឈ្មោះ សុខ សៅ ចាន់ ចែមជាដើម ដើម្បីឱ្យអស់លោកទាំងនោះមកទទួលយកចំណែកបុណ្យ ដែលបងប្អូន កូនចៅ ញាតិមិត្របានធ្វើក្នុងឱកាសនេះ ។ ប៉ុន្តែបើសិនជាទាយក អ្នកឱ្យទានមិនបានឧទ្ទិសចំណែកបុណ្យកុសលនោះឱ្យទេ ពពួកប្រេតដែលជាញាតិមិត្រ ក៏មិនអាចទទួលចំណែកបុណ្យបានដែរ លុះត្រាតែជនជាញាតិមិត្រសម្លាញ់ ឧទ្ទិសទៅឱ្យ ទើបទទួលបាន ។

៣- **បេតានំ អត្តនោ អនុមោទនេន** ប្រេតមកអនុមោទនាដោយខ្លួនឯង ។ ពួកញាតិដែលយកកំណើតជាប្រេតវិស័យ កាលបើបានដឹង បានឮថា ញាតិមិត្រ បងប្អូន កូនចៅ របស់ខ្លួនគេបានធ្វើបុណ្យកុសលឧទ្ទិសផលទៅឱ្យ ត្រូវបេះអនុមោទនាទទួលយកដោយខ្លួនឯង នូវចំណែកបុណ្យកុសលនោះ បើមិនបេះអនុមោទនាទេប្រាកដជាមិនអាចសម្រេចផលឡើយ ។

ពុទ្ធបរិស័ទ តាមការរៀបរាប់ដោយសង្ខេបមកនេះ ក៏ល្មម

យល់ដឹងហើយថា ទក្ខិណានុប្បទាននេះ ទាយកធ្វើឡើងសម្រាប់អ្វី ? ធ្វើយ៉ាងណាទើបបានអានិសង្សប្រសើរក្រៃលែង ? តាមការពិត ការធ្វើទានតម្រូវឱ្យទាយកប្រើវិចារណញ្ញាណ សំរិតសម្រាំងទេយ្យវត្ថុ ជ្រើសរើសបដិគ្គាហកៈអ្នកទទួល សម្រួចចេតនាជ្រះថ្លាព្រមទាំងគោរព ទាំងវត្ថុទានទាំងអ្នកទទួលទាន ទើបម្ចាស់ដើមទានបានទទួលផលកម្រៃគាប់ប្រសើរ ។ ដូច្នេះហើយទើបព្រះពុទ្ធបរមគ្រូទ្រង់ពោលភាសិតថា៖

**"វិចេយ្យ ទានំ សុគតប្បសត្ថំ**
**យេ ទក្ខិណេយ្យា ឥធ ជីវលោកេ**
**ឯតេសុ ទិន្នានិ មហប្ផលានិ**
**ពិជានិ វុត្តានិ យថា សុខេត្តេ "** ។

ប្រែថា ទានដែលបុគ្គលជ្រើសរើសឱ្យ ជាទានដែលព្រះសុគតទ្រង់សរសើរ បុគ្គលទាំងឡាយឯណា ជាបុគ្គលគួរដល់ទក្ខិណាទានក្នុងលោកនេះ ទានដែលគេឱ្យដល់បុគ្គលពួកនេះ ជាទានមានផលច្រើន ដូចជាពូជដែលគេដាំក្នុងស្រែល្អដូច្នោះឯង ។

## បុណ្យកឋិនទាន

បុណ្យកឋិនទាន ដែលប្រជាជនធ្វើក្នុងប្រទេសខ្មែរយើងសព្វថ្ងៃនេះ គេចាត់ថាជាបុណ្យមួយធំបំផុត ខាងអាមិសទាន ។ ពាក្យកឋិនទាននេះ មានពីរបទគឺ **កឋិន** + **ទាន** = **កឋិនទាន** ។

**កឋិន** ប្រែថា សំពត់ដែលទាយកប្រគេនដល់ភិក្ខុសង្ឃក្នុងកឋិនកាល គឺ តាំងពីថ្ងៃ ១ រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើត ខែកត្តិក ។ បុណ្យកឋិនទាន គឺជាបុណ្យប្រគេនសំពត់នេះឯង ។

**កឋិន** មានន័យលំអិតផ្សេងទៀត គឺពាក្យថា **កឋិន** មកពី **កឋ:** ធាតុប្រែថា កម្រ ឬ រស់នៅដោយកម្រ, ពោលសរសើរ, ប្រជុំរួបរួមនូវរូបធម៌ និង នាមធម៌, ស្អិតស្អួរភ្ជាប់ខ្លួន, សង្គ្រោះទុក ឬអោបក្រសោបទុក ។

ប្រែថា **កម្រ** មានន័យថា ក្រនឹងធ្វើឱ្យកើតឡើងជាកឋិនពេញអង្គ សមដូចបទវិគ្គហ:ថា **កឋតិ កិច្ឆេន ជីវតីតិ** > **កឋិនោ** សភាវៈឯណាដែលរស់នៅបានដោយកម្រ សភាវៈនោះឯងហៅថា **កឋិន** ព្រោះលោកមានសេចក្តីប្រៀបធៀបទៅនឹងឈើស្នឹង ដែលបុគ្គលកាត់ចេញអំពីដើម ហើយយកទៅបោះភ្ជាប់ទៅនឹងផែនដី ឈើស្នឹងនោះឯង រមែងដុះលូតលាស់បានយ៉ាងណា ឬ ក៏រស់នៅបានដោយកម្រយ៉ាងណា វីកិច្ចដែលកើតឡើង តាំងឡើងជាកឋិនពេញទីនោះ បានដោយកម្រពន់ពេកក៏យ៉ាងនោះដែរ ។

ប្រែថា **ពោលសរសើរ** ពីព្រោះចីវរទាន ដែលពុទ្ធបរិស័ទយកមកធ្វើកឋិននោះ ជាទានវិសេសជាងទានដទៃ ដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម តែងពោលសរសើរ

*ចំពោះកឋិនទាន ដែលបុគ្គលបានធ្វើហើយ ដោយសទ្ធាជ្រះថ្លា ព្រោះតែបុគ្គលនោះ បានឱ្យសេចក្ដីសុខស្រួល ដល់ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ដែលបានទទួលនូវអានិសង្ស ៥ ប្រការ នោះដែរ ។*

*ប្រែថា* **ប្រជុំរូបធម៌** *និង* **នាមធម៌** *គឺ* **រូបធម៌** *បានដល់ភិក្ខុសង្ឃ ដែលលោកបានកាន់ព្រះវស្សា ព្រមទាំងត្រៃចីវរ ដែលកើតឡើងប្រកបដោយចីវរកាល ។ ឯនាមធម៌ បានដល់វស្សា បីខែ អត្ថារៈ គឺការក្រាលគ្រងប្រកបដោយធម៌ និង អនុមោទនាញត្តិប្រគល់សំពត់កឋិន ។*

*ប្រែថា* **ស្ថិតស្ថេរភ្ជាប់ខ្លួន** *វិគ្គហៈថា* **ចិរត្ថេន កថិនំ** *កឋិន គឺ ការតាំងនៅស្ថិតស្ថេរភ្ជាប់ខ្លួនអស់រយៈកាល ៥ ខែ ដោយអំណាចកឋិនទាននោះឯង ។*

*ប្រែថា* **សង្គ្រោះទុក ក្រសោបទុក** *គឺ អោបក្រសោបនូវអានិសង្ស ៥ មិនឱ្យឃ្លាតទៅទីដទៃបាន ។ កឋិនអាចឱ្យសម្រេចផលដល់បុគ្គលពីរផ្នែក គឺទាយកទាយិកា ក៏បានទទួលអានិសង្ស រីឯបដិគ្គាហកៈភិក្ខុអ្នកក្រាលគ្រង និង អនុមោទនា ក៏បានទទួលអានិសង្ស ។ បើនិយាយឱ្យខ្លីកឋិនជាកិច្ចមួយក្នុងព្រះពុទ្ធសាសនា ដែលកើតតាមពុទ្ធានុញ្ញាតសម្រាប់ហ៊ុំទុក គ្រៀកទុក នូវអានិសង្ស*

៥ របស់ភិក្ខុ ។

កឋិនទាននេះកើតមានឡើងក្នុងបឋមពោធិកាលដែលព្រះបរមសាស្តា ទ្រង់អនុញ្ញាតឱ្យភិក្ខុសង្ឃប្រើប្រាស់តែសំពត់បង្សុកូលចីវរ ពុំទាន់បានទ្រង់អនុញ្ញាត្តឱ្យប្រើគហបតីចីវរនៅឡើយ ។

សម័យមួយ កាលដែលព្រះដ៏មានព្រះភាគ ទ្រង់គង់ចាំវស្សានៅវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី មានភិក្ខុ ៣០ អង្គឈ្មោះថា ភទ្ទវគ្គិយត្ថេរ ក្នុងដែនបាឋេយ្យ ជាអ្នកប្រព្រឹត្តធម៌នៅក្នុងព្រៃ ក៏នាំគ្នាចេញពីទីនោះមកកាន់ក្រុងសាវត្ថី ដើម្បីនឹងគាល់បំរើព្រះលោកនាថ ។ ទើបតែមកដល់ពាក់កណ្តាលផ្លូវ ជួនជាដល់ថ្ងៃចូលវស្សា នឹងស្រូតមកទៀតមិនទាន់ក៏នាំគ្នាស្វែងរកទីសេនាសនៈនៅចាំវស្សាទៀបក្រុងសាកេត នាពាក់កណ្តាលផ្លូវនោះទៅ ។ ភិក្ខុទាំងឡាយនោះមានសេចក្តីអផ្សុកជាខ្លាំងដោយគិតឃើញថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅទីជិតចម្ងាយ ៦ យោជន៍ទៀតសោះ មិនសមបើយើងទាំងឡាយមកស្កុនដំណើរមិនបានទៅគាល់បំរើព្រះអង្គ ។

លុះដល់ថ្ងៃចេញព្រះវស្សា បវរណាស្រេចហើយ លោកក៏នាំគ្នាស្រូតចេញដំណើរ ពីទីនោះមកទៀត ទទួលរដូវនោះមានភ្លៀងរលឹមជោកជាំនៅឡើយ តាមផ្លូវដែលទៅមក ពោរពេញទៅ

*ដោយទឹក និង ភក់រអិលប៉ប៉ិចប៉បាច់ ។ កាលមកដល់ក្រុងសាវត្ថី ហើយក៏ចូលទៅកាន់វត្តជេតពន ក្រាបថ្វាយបង្គំព្រះបរមសាស្តារួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លំដាប់នោះព្រះដ៏មានប្រាជ្ញាញាណទ្រង់មានព្រះបន្ទូលរាក់ទាក់ទៅរកភិក្ខុទាំងនោះថាៈ ម្នាលភិក្ខុទាំងឡាយ ! សរីរយន្តរបស់អ្នកទាំងឡាយ ល្មមអត់សង្កត់បានឬទេ? ល្មមប្រព្រឹត្តទៅបានឬទេ ? អ្នកទាំងឡាយមានសេចក្តីព្រមព្រៀង ស្មោះស្មើ ឥតមានវិវាទទាស់ទែងគ្នាឬទេ ? អ្នកទាំងឡាយនៅចាំព្រះវស្សានោះសោត ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតឬទេ ? ភិក្ខុទាំងឡាយក៏ក្រាបថ្វាយបង្គំទូលតាមដំណើរនោះរួចហើយ ក៏ក្រាបថ្វាយបង្គំទូលសេចក្តីលំបាករបស់ខ្លួន ដែលមានមកតាមផ្លូវ ដោយសព្វគ្រប់តាមដំណើរ ។*

*លំដាប់នោះព្រះជិនស្រី ទ្រង់សំដែងធម្មីកថា ប្រារព្ធអំពីសង្សារវដ្តមិនមានទីបំផុត ប្រោសប្រទានដល់ភិក្ខុទាំងនោះ ។ លុះចប់ធម្មទេសនាហើយភិក្ខុទាំងនោះ ក៏បានសម្រេចព្រះអរហន្តទាំងអស់អង្គ ។ បន្ទាប់ពីនោះមកព្រះអង្គទ្រង់ព្រះតម្រិះថា បើសិនជាតថាគតបានអនុញ្ញាត* **កឋិនត្ថារកិច្ច** (១) *ទុកអំពីគ្រាមុនមកម្ល៉េះសមភិក្ខុទាំងឡាយនោះ នឹងបានលះចីវរមួយទុកនៅនឹង*

(១)- សូមអាន វិន័យបិដក មហាវគ្គ តតិយភាគ កឋិនក្ខន្ធកៈ ភាគ ៨ ទំព័រទី ១

កន្ទេលយកមកតែស្បង់ និង ចីវរ ប៉ុណ្ណោះមានអត្តភាពស្រាល មិនលំបាកយ៉ាងនេះសោះឡើយ ហើយកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងពាល់ព្រះអង្គ ក៏តែងតែអនុញ្ញាតទុកដល់សាវ័កពុំដែលលះផង ។ ព្រះដ៏មានជោគទ្រង់ព្រះតម្រិះយ៉ាងដូច្នេះហើយ ទើបទ្រង់ត្រាស់ហៅ ភិក្ខុទាំងឡាយមក ។ ព្រះអង្គទ្រង់អនុញ្ញាតកឋិនត្ថារកិច្ចនេះដោយព្រះពុទ្ធដីកាថា ៖

"ម្នាលភិក្ខុទាំងឡាយ ! តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយដែលបានចាំព្រះវស្សារួចហើយ ក្រាលកឋិនបាន ។ ម្នាលភិក្ខុទាំងឡាយ ! កាលបើអ្នកទាំងឡាយ បានក្រាលកឋិនហើយ នឹងបានសម្រេចនូវអានិសង្ស ៥ ប្រការ " ។

## កឋិនប្លែកពីចីវរទាន ដោយហេតុ ៥ យ៉ាង គឺ ៖

១- **ប្លែកដោយកាល** កាលដែលព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឱ្យធ្វើកឋិននោះ គឺមានរយៈពេលតែ ២៩ ថ្ងៃ រាប់ពីថ្ងៃ ១ រោច ខែ អស្សុជ រហូតដល់ថ្ងៃ ១៥ កើត ខែកត្តិក ។ រយៈពេលនេះហៅថាកឋិនកាល ពាក្យសាមញ្ញលោកហៅថា រដូវកឋិន។ ក្នុងរដូវនេះបើសិនជាពុទ្ធបរិស័ទ ប្រាថ្នាចង់ធ្វើបុណ្យកឋិន គឺ អាចធ្វើបាន ប៉ុន្តែបើសិនជាធ្វើក្រៅអំពីថ្ងៃទាំង២៩ នេះពុំបានឡើយ ហើយតាមបណ្តាវត្តនីមួយៗទទួលបានតែម្តង ចំណែកភិក្ខុវិញក៏ទទួលក្រាល

គ្រង់កឋិន និង អនុមោទនា បានតែម្តងដែរ ។

២- **ប្លែកដោយវត្ថុ** សំពត់ដែលយកមកធ្វើអង្គកឋិននោះ គឺបានតែស្បង់ ចីពរ សង្ឃាដី ដែលគេយកសំពត់នោះធ្វើឱ្យត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ។សំពត់ក្រៅពីនោះពុំបានឡើយ ហើយសំពត់ទាំងបីមុខនេះទៀតសោត នឹងយកទាំងអស់ជាអង្គកឋិនពុំបាន គឺបានតែមួយមុខទោះបីជាទាយកវេរប្រគេនចីវរមួយត្រៃក៏ដោយ ។ ភិក្ខុអ្នកក្រាលគ្រង់ ត្រូវជ្រើសរើសយកតែវត្ថុមួយមកធ្វើជាកឋិន បើសិនជាលោកចង់ក្រាលគ្រង់ ស្បង់តែមួយក៏បាន, ចីពរក៏បាន, សង្ឃាដីក៏បាន ឱ្យតែរើសយកតែមួយ ដើម្បីក្រាលគ្រង់ឱ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ។

៣- **ប្លែកដោយអំពើ** ទាយកទាយិកា គប្បីធ្វើឱ្យត្រឹមត្រូវតាមព្រះវិន័យ ហើយភិក្ខុអ្នកក្រាលគ្រង់ និង អនុមោទនា ឱ្យត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាត ទើបឡើងជាកឋិនពេញលក្ខណៈបាន ។

៤- **ប្លែកដោយបដិគ្គាហកៈ** អ្នកដែលទទួលកឋិនបានតែភិក្ខុក្រៅអំពីភិក្ខុពុំបានឡើយ ហើយភិក្ខុនោះសោតទៀតលុះត្រាតែបានគង់ចាំព្រះវស្សាគ្រប់ ៣ ខែ ក្នុងវត្តណាមួយ ទើបទទួលក្រាលគ្រង់អនុមោទនាកឋិនក្នុងវត្តនោះបាន ។ បើភិក្ខុពុំបានចាំ

វស្សា ឬ បានចាំវស្សាដែរ ប៉ុន្តែដាច់វស្សាក៏ពុំអាចទទួលក្រាលគ្រង់កឋិនបានដែរ ។

៥- **ម្លែកដោយអានិសង្ស** ទាយកទាយិកា ក៏បាននូវអានិសង្ស ៥ ភិក្ខុអ្នកក្រាលគ្រង់ អនុមោទនា ក៏បាននូវអានិសង្ស ៥ អស់រយៈពេល ៥ ខែ ។

## អានិសង្សរបស់ភិក្ខុមាន ៥ យ៉ាងគឺ ៖

១- **អនាមន្តចារោ** ភិក្ខុត្រាច់ទៅកាន់ស្រុកភូមិនិគមជនបទបានដោយសេរីមិនចាំបាច់ត្រូវលាភិក្ខុផង់គ្នា ( ដោយមិនត្រូវអាបត្តិក្នុងចារិតសិក្ខាបទ ) ,

២- **អសមាទានចារោ** ភិក្ខុត្រាច់ទៅកាន់ទីដទៃ ដោយមិនចាំបាច់យកចីវរ ជាប់ទៅជាមួយខ្លួនទាំងអស់ ( ដោយមិនត្រូវអាបត្តិក្នុងបឋមកឋិនសិក្ខាបទ ) ,

៣- **គណភោជនំ** ភិក្ខុឆាន់អាហារ ដោយរួមវង់គ្នាបាន ( ដោយមិនត្រូវ អាបត្តិក្នុងគណភោជនសិក្ខាបទ ) ,

៤- **យាវទត្ថចីវរំ** ភិក្ខុទុកដាក់ចីវរ ដែលមិនត្រូវការប្រើប្រាស់បាន ( ដោយមិនត្រូវ អាបត្តិ ក្នុងបឋមកឋិនសិក្ខាបទ ) ,

៥- **យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** សង្ឃលាភផ្សេងៗ ដែលកើតឡើងត្រូវបានភិក្ខុ ដែលគង់ចាំវស្សាក្នុងវត្ត

*ដែលលោកបានក្រាលគ្រង់កឋិននោះ ។*

**អានិសង្សរបស់ទាយក ៥ យ៉ាង គឺ ៖**

១- **តិក្ខបញ្ញោ វិសារទោ** *រមែងជាអ្នកបរិបូណ៌ ប្រកបព្រមទៅដោយបញ្ញា ,*

២- **សុរូបតា** *រមែងជាអ្នកមានរូបល្អ ,*

៣- **សុវណ្ណតា** *ជាអ្នកមានពណ៌សម្បុរកាយស្អាតល្អ ,*

៤- **សុសណ្ឋានតា** *ជាអ្នកមានសណ្ឋានទ្រង់ទ្រាយស្អាតល្អ ,*

៥- **ចក្កវត្តិ រាជា ហោតិ** *រមែងបានកើតជាស្តេចចក្រពត្តិក្នុងជាតិណាមួយមិនខាន ។*

*អានិសង្សកឋិនទានទាំង ២ យ៉ាង គឺ អានិសង្សសម្រាប់ទាយក អ្នកថ្វាយសំពត់ និង អានិសង្សសម្រាប់ភិក្ខុអ្នកក្រាលគ្រង់អនុមោទនា ដែលបានពោលមកខាងលើនេះ សូមលោកអ្នកអានពិចារណាវិភាគថ្លឹងថ្លែង ប្រៀបធៀបទៅនឹងអានិសង្ស នៃអាមិសទានដទៃ ដោយខ្លួនឯងចុះ ។*

*អានិសង្សសម្រាប់ ទាយក ទាយិកា មិនឃើញមាននៅក្នុងវិនយបញ្ញត្តិទេ ប៉ុន្តែអានិសង្សសម្រាប់បដិគ្គាហកៈ មាននៅក្នុងព្រះវិន័យ ។ ដូច្នេះយើងមិនអាចសម្រេចសេចក្តីថា អ្នកធ្វើកឋិនទាន បានផលតិចច្រើនប៉ុណ្ណាឡើយ ព្រោះព្រះវិន័យក៏មិនបាន*

និយាយ ព្រះសូត្រក៏មិនបាននិយាយ ។

ក៏ប៉ុន្តែកឋិនជាសង្ឃកម្មដ៏ពិសេសមួយ ។ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់ចាត់កឋិនកម្មថាជាសង្ឃកម្មពិសេស ព្រោះព្រះអង្គទ្រង់ធ្លាប់ ចូលរួមការក្រាលកឋិនផ្ទាល់ព្រះអង្គ រហូតដល់ទ្រង់ជួយចាត់ចែងធ្វើចីវរ ប្រសិនបើចីវរពុំទាន់សំរេចរូប។ ទ្រង់ជួយចាត់ចែងក្នុងបុព្វករណ៍ខ្លះ ប្រសិនបើចីវរមានរូបសម្រេចហើយ ។ ព្រះអង្គទ្រង់ទុកដាក់កឋិនកម្មថាជាមុខងារល្អប្រពៃ របស់ព្រះសង្ឃ រហូតដល់ទ្រង់បានអនុញ្ញាតឱ្យផ្អាកប្រតិបត្តិវិន័យ ៥ខ អស់រយៈ៥ ខែ ។

សូមជ្រាបថា បច្ចុប្បន្នកាលនេះ ជាសម័យសម្ភារៈនិយម ភិក្ខុមិនចាំបាច់ចាត់ចែងធ្វើចីវរ ចាត់ចែងក្នុងបុព្វករណ៍ ដូចភិក្ខុក្នុងពោធិសម័យ ដែលមានការខ្វះខាតសំពត់ចីវរឡើយ ។ ដូច្នេះហើយបានជាពាក្យកឋិន មានន័យថា កម្រ គឺ ក្រទាំងសំពត់ចីវរ ក្រទាំងធ្វើឱ្យកើតឡើងជាកឋិនពេញអង្គ តាមពុទ្ធានុញ្ញាត និងពុទ្ធប្បញ្ញត្តិ ។

**វត្ថទោ ហោតិ វណ្ណទោ**

ការឱ្យសំពត់ជាទាន បានឈ្មោះថា ឱ្យពណ៌សម្បុរជាទាន គឺ បានឈ្មោះថា ឱ្យវណ្ណទាន ។

# ទានលក្ខណៈ

**ទានលក្ខណៈ** *ប្រែថា គ្រឿងចំណាំ ឬសំគាល់របស់ទាន ។ វត្ថុទាំងអស់ក្នុងពិភពលោក ទោះមានរូបក្តី ( រូបនាម ) ឥតរូបក្តី ( អរូបនាម ) សុទ្ធតែមានលក្ខណៈ សម្រាប់សំគាល់ ឬ សម្រាប់ចំណាំដើម្បីកុំឱ្យច្រឡំគ្នា ។ លក្ខណៈនោះបានដល់ពាក្យថា ខ្ពស់ ទាប ស ខ្មៅ ថ្លាត ល្វឹង ស្ងួត កាច ល្អ អាក្រក់ ត្រូវ ខុស ធំ តូច ច្រើន តិច ។ ល ។ ទានក៏មានលក្ខណៈដូចរូបធាតុ និង អរូបធាតុទាំងឡាយនោះដែរ ។*

*លក្ខណៈរបស់ទាន កើតឡើងបានដោយអាស្រ័យចិត្ត (ចេតនា ) ក៏មាន កាយក៏មាន វាចាក៏មាន ទេយ្យទានក៏មាន ។ អ្នកធ្វើទាន មានកាយ វាចា ចិត្ត ឬ ទេយ្យទាន ទាបថោក ទានរបស់គេក៏មានលក្ខណៈទាបថោក ហៅថា* **ហីនទាន** *។ អ្នកធ្វើទានមានកាយ វាចា ចិត្ត ឬ ទេយ្យទានមធ្យម កណ្តាល ទានរបស់គេក៏មានលក្ខណៈមធ្យម កណ្តាល ហៅថា* **មជ្ឈិមទាន** *។ អ្នកធ្វើទានមានកាយ វាចា ចិត្ត និង ទេយ្យទានខ្ពង់ខ្ពស់ ទានរបស់គេក៏មានលក្ខណៈខ្ពង់ខ្ពស់ ហៅថា* **ឧត្តមទាន** *។*

*ចិត្តទាបមានន័យថា ចិត្តរបស់បុគ្គលមានឥន្ទ្រីយ៍ទាំង ៥ គឺសទ្ធា,វីរិយ,សតិ,សមាធិ,បញ្ញាទន់ខ្សោយ ។ ចិត្តមធ្យមកណ្តាល*

មានន័យថា ចិត្តរបស់បុគ្គលមានឥន្ទ្រីយ៍ មធ្យម កណ្តាល ។ ចិត្តខ្ពស់ គឺចិត្តរបស់បុគ្គលមានឥន្ទ្រីយ៍ខ្ពស់ ។ កាយ វាចាខ្ពស់ គឺកាយវាចា ដែលគេបានអប់រំដោយចរិយាសាកល ហើយតម្កល់ទុកនៅក្នុង **គារវៈ** ៦ យ៉ាង គឺ ៖

១- **ពុទ្ធគារវៈ** គោរពចំពោះព្រះពុទ្ធ ,

២- **ធម្មគារវៈ** គោរពចំពោះព្រះធម៌ ,

៣- **សង្ឃគារវៈ** គោរពចំពោះព្រះសង្ឃ,

៤- **សិក្ខាគារវៈ** គោរពចំពោះសិក្ខាបទ,

៥- **អប្បមាទគារវៈ** គោរពចំពោះអប្បមាទធម៌,

៦- **បដិសណ្ឋារគារវៈ** គោរពទទួលបដិសណ្ឋារកិច្ច ។

សូមកុំភ្លេចថា កាយ វាចានេះ អាចមានចរិយាប្រព្រឹត្តទាប កណ្តាល ខ្ពស់ ទៅតាមការអប់រំច្រើន ឬ តិចផ្នែកខាងសីលធម៌ និងការប្រតិបត្តិធ្ងន់ ស្រាល ក្នុងគារវធម៌ ។ ចំណែកទេយ្យទាន ទាប កណ្តាល ខ្ពស់ លោកសំដៅយកសម្បត្តិផង សំដៅយកចិត្តផង ព្រោះថា មានអ្នកធ្វើទានខ្លះមានទេយ្យវត្ថុអន់ទេ ប៉ុន្តែមានចិត្តខ្ពស់ មានកាយ វាចា ប្រកបដោយសេចក្តីគោរព ។ មានអ្នកធ្វើទានខ្លះ មានទេយ្យវត្ថុថ្លៃថ្នូរ ប៉ុន្តែមានចិត្តទាប មានកាយ វាចា មិនប្រកបដោយសេចក្តីគោរព ។

**អាមិសទាន & ធម្មទាន**

និយាយតាមការពិត ជីវភាពរបស់មនុស្សក្នុងលោកនេះ បើយើងចែកឱ្យល្អិតទៅមាន ៤ ពួក គឺ ៖

១- **ពួកគ្មាន** ,

២- **ពួកក្រ** ,

៣- **ពួកមានគ្រប់គ្រាន់**,

៤- **ពួកមានសល់ទុក** ។

ពួកទាំង ៤ នេះមានអារម្មណ៍ខុសៗគ្នា ក្នុងការបំពេញទាន គឺ ពួកគ្មានខំប្រឹង ស៊ីឈ្នួលគេ ធ្វើកម្មករលីសែងដើម្បីយកលុយកាក់មកចាត់ចែងធ្វើទាន ។ ពួកក្រខំប្រឹងធ្វើការ ប្រកបអាជីវកម្មនានាជាងធម្មតា ដើម្បីសន្សំទុកឱ្យបានល្មម ហើយធ្វើទានក្នុងពេលណាមួយ ។ អ្នកមានគ្រប់គ្រាន់ខំប្រឹងបន្ថយថវិកា ស៊ីចាយរបស់ខ្លួនគ្រប់ពេលដើម្បីយកសំណល់មកធ្វើទាន។ អ្នកមានទ្រព្យសល់ទុក នឹកចង់ធ្វើទានពេលណាធ្វើភ្លាម មិនព្រួយគិតគូរយូរពេល ព្រោះខ្លួនមានទ្រព្យសល់ពីការប្រើប្រាស់ស្រាប់ ។

ទានបើនិយាយតាមលក្ខណៈខាងផ្លូវចិត្តនោះ នឹងធ្លាក់ទៅជាទាន ទាប កណ្តាល ខ្ពស់ តាមឥន្ទ្រីយ៍ សីលធម៌ និង តាមសេចក្តីគោរព ។ ប៉ុន្តែបើពោលតាមទេយ្យវត្ថុ ( វត្ថុដែលត្រូវឱ្យ ) វិញនោះនឹងធ្លាក់ទៅជា **ទាសទាន** ប្រសិនបើគេយករបស់សំអប់

ឬ របស់ថោកទាបមកធ្វើទាន ។ នឹងទៅជា **សហាយទាន** ប្រសិនបើគេយករបស់សំណប់ ឬ របស់សម្ញាញ់មកធ្វើទាន ។ នឹងទៅជា **សាមីទាន** ប្រសិនបើគេយករបស់ជាកំពូល ឬ របស់បណ្ដូលចិត្តមកធ្វើទាន ។

របស់សំអប់ ឬ ថោកទាប បានដល់របស់ដែលគេមិនចូលចិត្តប្រើ ដោយគេទុកដាក់ថា ជារបស់មិនល្អ ឬជារបស់ល្អដែរ តែគេមិនស្រឡាញ់ ឬជារបស់ដែលគេមិនពេញនិយម ឬជារបស់ដែលកន្ទងហួសសម័យកាល ។

របស់សំណប់ ឬ របស់សម្ញាញ់ បានដល់របស់នោះល្អក៏មាន មិនល្អ ក៏មាន មនុស្សនិយម ក៏មាន មនុស្សមិននិយម ក៏មាន នៅក្នុងសម័យក៏មាន កន្ទងសម័យក៏មាន តែគេចូលចិត្តប្រើ ។

របស់ជាកំពូល ឬ បណ្ដូលចិត្ត បានដល់របស់ដែលគេស្រឡាញ់ហួស ចូលចិត្តហួស ឬជារបស់ទាន់សម័យ គេមិនហ៊ានប្រើ ឬ មិនទាន់ប្រើ ។

ទានបើនិយាយតាមកម្លាំងចិត្ត បុគ្គលពួកគ្មាន និង បុគ្គលក្រ ក្នុងខណៈធ្វើទាន មានចិត្តក្លាហានជាង បុគ្គលអ្នកមានគ្រប់គ្រាន់ និង បុគ្គលអ្នកមានសល់ទុក ព្រោះអ្នកគ្មាន និង អ្នកក្រធ្វើទានអំពីគ្មាន ។ ចំណែកអ្នកមានធ្វើទានអំពីសល់ ។ ដែលថាធ្វើ

ទានអំពីគ្មាន គឺអ្នកក្រខំប្រឹងធ្វើការរកស៊ី ដើម្បីយកលុយមកធ្វើទាន ប្រសិនបើទាននោះធំដុំបន្តិចផង អ្នកក្រខំប្រឹងតស៊ូប្រមូលកម្លាំងរបស់ខ្លួនមាន ៣-៤ ឆ្នាំ ទើបធ្វើបាន។ដែលថាអ្នកមានធ្វើទានអំពីសល់នោះ គឺអ្នកមានចង់ធ្វើពេលណាក៏បាន មិនចាំបាច់ប្រមូលកម្លាំង មិនចាំបាច់តស៊ូធ្វើការងារអ្វីទេ ។

ក្នុងគម្ពីរធម្មបទ បុប្ផវគ្គ រឿងមហាកស្សបត្ថេរ បិណ្ឌបាតទាន ព្រះពុទ្ធឃោសាចារ្យ មាននិយាយអំពីកស្សបត្ថេរថា ព្រះអង្គមានចិត្តអាណិតអ្នកក្រណាស់ ។ ការបិណ្ឌបាតរបស់លោក មានធ្វើចំពោះតែអ្នកក្រ ដោយលោកមានគំនិតថា អ្នកក្រមានចិត្តក្លាហាន មានចិត្តតស៊ូចំពោះបុណ្យកុសលណាស់ ។ មានថ្ងៃមួយមានទេពធីតា ជាច្រើនចុះមកដាក់បាត្រដល់លោក តែព្រះថេរៈមិនព្រមទទួល ។ ក្នុងពេលនោះ លោកនិយាយទៅកាន់ទេពធីតាទាំងឡាយ ថា នាងទាំងអស់គ្នាកុំមកប្លន់សម្បត្តិអ្នកក្រ ។ ដំណឹងនេះមិនបាត់ស្ងាត់ បានលេចឮដល់ព្រះឥន្ទ ។ ការដាក់បាត្រក៏បានសម្រេច ដោយព្រះឥន្ទក្លែងភេទជាអ្នកក្រ ។ តួយ៉ាង នេះសឱ្យឃើញពីការលើកស្ទួយឋានៈ អ្នកក្រក្នុងមុខងារបំពេញទាន គឺអ្នកក្រមានចិត្តក្លាហានជាង តស៊ូជាង លំអោនជាង បានជាទាញចិត្តព្រះអរហន្តឱ្យមានសេចក្តីអាណិតជាងអ្នកមាន ។

ក្នុងគម្ពីរធម្មបទដដែល រឿងលាជទេវធីតា បាននិយាយថា នារីក្នុងត្រកូលកំសត់ម្នាក់ បានដាក់បាត្រព្រះកស្សបៈដោយលាជ ។ បន្ទាប់ពីដាក់បាត្រហើយត្រូវស្លាប់ដោយពស់ចឹកនារីនោះបានចាប់បដិសន្ធិថ្មីក្នុងឋានសួគ៌ ។ យើងត្រូវពិចារណា រឿងនេះមួយទៀតថា លាជជាវត្ថុធុនទាប កណ្ដាល ឬ ខ្ពស់ ។ តាមការពិតលាជជាអាហារធុនទាប មិនជាអាហារថ្នាក់កណ្ដាល ឬ ថ្នាក់ខ្ពស់ទេ ។ នៅក្នុងប្រទេសខ្មែរយើង គេចាត់ថាលាជជាអាហារធុនអន់បំផុត ព្រោះអាហារនេះជារបស់សម្រាប់ខ្មោច ។ តាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញខាងអាហារ ក្នុងប្រទេសឥណ្ឌា សម័យនោះគេថាលាជជាអាហារធុនអន់ ជាអាហារដែលគេបរិភោគបណ្ដោះអាសន្ន ចំឡងពេល មិនមែនជាអាហារប្រចាំថ្ងៃទេ ។ ដូច្នេះនារីនេះបានកើតជាទេពធីតា មិនមែនដោយអំណាចលាជទេ គឺប្រាកដជា ដោយចិត្តតស៊ូក្លាហាន មោះមុត ក្នុងការធ្វើទានរបស់ខ្លួន ប្រកបដោយបសាទៈសទ្ធាជ្រះថ្លា ។

ក្នុងគម្ពីរធម្មបទដដែលទៀត ក្នុងរឿង **ចុល្លេកសាដក-ព្រាហ្មណ៍** មាននិយាយអំពីព្រាហ្មណ៍កំសត់ម្នាក់ មានសំពត់បង់កតែមួយពីរនាក់ ប្ដី ប្រពន្ធ បើម្នាក់ត្រូវការទៅណាមកណា ម្នាក់ត្រូវតែខាន ។ ថ្ងៃមួយព្រាហ្មណ៍ជាស្វាមី ទៅស្ដាប់ធម៌ទេសនា របស់

ព្រះបរមសាស្ដា ដោយធម៌នោះទ្រង់សំដែង លែលកឱ្យល្មមដល់សន្ដានចិត្តរបស់គេ ។ គេពិរោះធម៌ខ្លាំងណាស់ ចង់បូជាធម៌ដោយសំពត់បង់ក ចិត្តរបស់គេចេះតែស្ទាក់ស្ទើរ ម្ដងកាត់ចិត្តឡើងបូជា ម្ដងដកថយ តាំងពីក្បាលព្រលប់លុះដល់ជិតភ្លឺ ទើបចិត្តសទ្ធាឈ្នះចិត្តកំណាញ់បាន ហើយសំរេចដាក់សំពត់ បូជាចំពោះព្រះធម៌ដោយភ្ញាត់ថា **ជិតំ មេៗ** អញឈ្នះហើយៗ ! ។ ចូរយើងពិចារណាមើល ចំបាំងដែលព្រាហ្មណ៍កំសត់នេះ បានធ្វើជាមួយកងទ័ពកំណាញ់អស់រាត្រីមានយាមបី ជាចំបាំងធំប៉ុណ្ណា មានចិត្តតស៊ូប៉ុណ្ណា មានសេចក្ដីក្លាហានមោះមុតប៉ុណ្ណា មានកងពលធម៌គឺ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញាខ្លាំងពូកែប៉ុណ្ណា ។ ផលទាននៃព្រាហ្មណ៍នេះ បានធ្វើឱ្យគាត់ឡើងឋានៈ ជាមហាសេដ្ឋី ក្នុងថ្ងៃ ទីប្រាំពីរ ដោយការតែងតាំងរបស់ព្រះមហាក្សត្រ ព្រះនាមព្រះបាទបសេនទិកោសល តើផលទាននោះ បានសម្រេចដោយសំពត់កញ្ចាស់ ឬ ដោយកម្លាំងចិត្ត ? ។

រឿងទុគ៌តបុរស ក្នុងគម្ពីរធម្មបទដដែលទៀត ដែលយើងធ្លាប់បានស្ដាប់លោកទេសនា ជាញឹកញាប់មកហើយ ។ ដោយស្វាករបស់គាត់ មានភិក្ខុត្រឹមតែមួយអង្គ ចំនួនតិចនេះនាំឱ្យអ្នកចាត់ចែងការប្រទ្បំមិនបានចុះឈ្មោះគាត់ចូលក្នុងបញ្ជី ឬមួយចូល

ក្នុងបញ្ជីហើយភ្លេចក៏មិនដឹង ។ គេបានរុញគាត់ឱ្យទៅ សូមបាត្រ អំពីព្រះបរមគ្រូ ។ ក្នុងពេលគាត់ចូលទៅដល់ ព្រះសម្មាសម្ពុទ្ធ កំពុងត្រូវចោមរោមគាល់ ដោយពួកមហាសេដ្ឋី ។ ប៉ុន្តែព្រះអង្គមិន ទាន់ប្រគល់ទៅឱ្យបុគ្គលណាម្នាក់ នូវបាត្ររបស់ព្រះអង្គទេ ។ លុះ គាត់ចូលទៅដល់ព្រះអង្គទ្រង់ប្រទានបាត្រឱ្យ ។ ពួកមហាសេដ្ឋី បានសុំទិញបាត្រដោយដេញតម្លៃតាំងពី១០០០ កហាបណៈឡើង ទៅដល់ច្រើនពាន់កហាបណៈ គាត់ពុំព្រមលក់ឱ្យ។ គាត់យាងព្រះ ពុទ្ធទៅឆាន់ក្នុងខ្ទមរបស់គាត់ទាល់តែបាន ក្រោយមកផលទាន នេះ បានជួយឱ្យគាត់ឡើងឋានៈជាមហាសេដ្ឋី ។ តើការបានឡើង ជាមហាសេដ្ឋីនៃបុរសនេះ ដោយចង្ហាន់សាមញ្ញ តាមភាពទុគ៌ត នោះឬ ? ឬមួយដោយកម្លាំងចិត្ត ដែលបានច្បាំងឈ្នះកម្លាំងប្រាក់ ដ៏ច្រើនពាន់កហាបណៈ? ។ ប្រហែលដោយកម្លាំងចិត្តនេះទេដឹង ! បានជាអ្នកក្រធ្វើទាន ច្រើនបានផលរហ័សជាងអ្នកមាន ។ ប៉ុន្តែ រឿងនេះ មានទូទៅ ក្នុងគម្ពីរពុទ្ធសាសនា ទាំងផ្នែកបាលី ទាំងផ្នែក សម្រាយ ។ ប៉ុន្តែរឿងនេះមិនមែនជារឿងសម្រេចដាច់ខាតនោះទេ គឺគ្រាន់តែមានភាគច្រើនប៉ុណ្ណោះ ប្រសិនបើអ្នកមានសាងកម្លាំង ចិត្តបានដូចអ្នកក្រដែរនោះ ទានរបស់គេត្រូវតែបានផលច្រើន ។

អ្នកមានទ្រព្យច្រើន សល់ទុកដាក់ចាយមិនអស់ ហើយ

រើសយកតែរបស់អន់ៗ ដែលខ្លួនលែងត្រូវការប្រើប្រាស់ទៅឱ្យជាទាន ដោយគិតថាទុកយូរៗទៅមុខជាចោល ។ ទានដែលមានលក្ខណៈបែបនេះ ហៅថា **ទាសទាន** ។ ផ្ទុយទៅវិញអ្នកក្រខំប្រឹងរកទ្រព្យសម្បត្តិដើម្បីធ្វើទាន ប៉ុន្តែមិនបានរបស់ល្អៗសោះ បានតែរបស់អន់ៗ ហើយយកទៅធ្វើទានដោយគិតថា រកយ៉ាងណាទៅទៀតក៏អស់បានរបស់ល្អហើយ ។ តួយ៉ាង ដូចនារីកំសត់ម្នាក់មានដំណាលក្នុងគម្ពីរធម្មបទ នាងមានចិត្តចង់បូជាព្រះចេតិយ ដែលគេបញ្ចុះព្រះសារីរិកធាតុ តែដោយខ្លួនក្រពេករកគ្រឿងសក្ការៈថ្លៃថ្នូរបូជាមិនបាន ក៏បេះផ្កាននោងព្រៃ ដែលអ្នកផងចាត់ទុកថាជាផ្កាអន់បំផុតយកទៅបូជាព្រះចេតិយ ។ ទានរបស់នាងក៏បានទៅជាទានខ្ពង់ខ្ពស់ ព្រោះចិត្តរបស់នាងខ្ពស់ សេចក្តីគោរពរបស់នាងជិតដល់ ។ ទានមានលក្ខណៈចិត្តខ្ពស់ ក្លាហាន តស៊ូបែបនេះក៏ហៅថា **សាមីទាន** ។

ដើម្បីរៀបចំលំដាប់ថ្នាក់ នៃទានឱ្យបានត្រឹមត្រូវល្អ យើងត្រូវរៀបចំលំដាប់នៃសេចក្តីថ្លៃថ្នូររបស់វត្ថុ និង កម្លាំងក្លាហាននៃចិត្តទាយកអ្នកឱ្យទាន ។

ដើម្បីឱ្យរិតតែងាយយល់ អំពីលក្ខណៈរបស់ទាន ខ្ញុំសូមលើកយកនូវទានទាំង៣ ប្រភេទ តាមលក្ខណៈរបស់ទេយ្យវត្ថុ គឺ

**សាមីទាន សហាយទាន ទាសទាន** មកពន្យល់ដោយសង្ខេបម្តងទៀតដូចតទៅ ៖

១- **សាមីទាន** ការឱ្យប្រគេនជូនថ្វាយ របស់ប្រណីតដែលខ្លួនជាម្ចាស់ទាន មិនហ៊ានបរិភោគប្រើប្រាស់ តែហ៊ានលះបង់ប្រគេនជូន ថ្វាយ បូជាឱ្យឈ្មោះថា **សាមីទាន** គឺទានប្រៀបបានជាម្ចាស់ ដូចជាអ្នកបំរើមានចិត្ត ចង់ជូនរបស់អ្វីមួយដល់ចៅហ្វាយនាយ តែងតែជ្រើសរើសរករបស់ណាដែលគិតថាមានតម្លៃប្រសើរជាងរបស់ដែលខ្លួនមានទើបលះជូន ។ បុគ្គលណាបានបំពេញសាមីទាន បុគ្គលនោះឈ្មោះថា **ទានបតី** ឬ **ទានសាមី** ប្រែថាអ្នកមានទានជាម្ចាស់ ។

២- **សហាយទាន** ការឱ្យវត្ថុដែលខ្លួនមាន បរិភោគប្រើប្រាស់យ៉ាងណា ក៏ចែកចាយចំណាយឱ្យយ៉ាងនោះ ចាត់ថាជា **សហាយទាន** គឺទានប្រៀបបាននឹងមិត្រសម្លាញ់ ។ បុគ្គលណាបានបំពេញសហាយទាន បុគ្គលនោះឈ្មោះថា **ទានសហាយ** ប្រែថា អ្នកមានទានជាសម្លាញ់ ។

៣- **ទាសទាន** ការឱ្យវត្ថុដែលខ្លួនមិនស្រឡាញ់ពេញចិត្ត ដូចជារបស់មិនល្អ មិនគួរដល់ការបរិភោគប្រើប្រាស់ខ្លួនឯង ទើបចាត់ចែងចំណាយឱ្យដល់អ្នកដទៃ ចាត់ថាជា **ទាសទាន** គឺទាន

**អាមិសទាន & ធម្មទាន**

ប្រៀបទៅនឹងអ្នកបំរើ ។ បុគ្គលណាបានបំពេញនូវ **ទាសទាន** បុគ្គលនោះឈ្មោះថា **ទានទាស** ប្រែថា អ្នកមានទានជាទាសៈ។ ក្នុងបណ្ដាទានទាំង ៣ ប្រភេទ ខាងលើនេះ ពុទ្ធបរិស័ទដែលជាទាយកទាយិកា គួរបំពេញសហាយទាន ឡើងលំដាប់ដល់សាមីទាន តាមសមត្ថភាពរបស់ខ្លួន ប៉ុន្តែចៀសវាងកុំបំពេញទាសទាន ព្រោះមានពុទ្ធសាសនសុភាសិតពោលថា ៖

**មនាបទាយី លភតេ មនាបំ**

*អ្នកឱ្យរបស់គាប់ចិត្ត រមែងបានរបស់គាប់ចិត្តវិញ ។*

**សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ**

*អ្នកឱ្យទីឋានដ៏ប្រសើរ រមែងដល់នូវទីឋានដ៏ប្រសើរ ។*

**អគ្គស្ស ទាតា លភតេ បុនគ្គំ**

*អ្នកឱ្យវត្ថុដ៏លើស រមែងបានវត្ថុដ៏លើសវិញ ។*

**អគ្គទាយី វរទាយី សេដ្ឋទាយី ច យោ នរោ**
**ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ ។**

*នរជនណាឱ្យរបស់ដ៏លើស ឱ្យរបស់ល្អ ឱ្យឋានដ៏ប្រសើរ នរជននោះទៅកើតក្នុងភពណាៗ រមែងជាអ្នកមានអាយុវែង មានយស (ក្នុងភពនោះៗ) ។*

# ទានមានផលល្អ

ដូចម្ដេចហៅថាទានមានផលល្អ ? ទានមានផលល្អ គឺទានដែលទាយក ប៉ិនប្រសប់ចេះរៀបចំចាត់ចែង ធ្វើបានត្រឹមត្រូវតាមរបៀបបច្ចេកទេស តាមទំនៀម តាមសម័យនិយម តាមសេចក្ដីប្រាថ្នារបស់អារ្យជន និង តាមការវិវឌ្ឍន៍ខាងសម្ភារៈ ។

ក្បួនបច្ចេកទេស គេចែកទៅតាមមុខរបស់នីមួយៗ ដែលត្រូវបង្កើតឡើងមានជាអាទិ៍ ក្បួនបច្ចេកទេសខាងធ្វើសម្លៀកបំពាក់ ក្បួនបច្ចេកទេសខាងធ្វើម្ហូមអាហារ ក្បួនបច្ចេកទេសខាងនិយាយសរសេរ តែងនិពន្ធ ចងក្រង ឃ្លោងឃ្លា ប្រយោគ ។ ល ។

មនុស្សយើងចេះធ្វើម្ហូបគ្រប់គ្នា តែអ្នកខ្លះធ្វើត្រូវតាមក្បួនបច្ចេកទេស អ្នកខ្លះធ្វើខុសក្បួនបច្ចេកទេស ។ ម្ហូបអាហារដែលគេធ្វើត្រូវតាមក្បួនបច្ចេកទេស ជាម្ហូបអាហារមានសិល្បៈ, ទានរបស់គេក៏មានសិល្បៈ, ផលទានរបស់គេក៏ជាផលមានសិល្បៈ ។

អំពីម្ហូប ដែលយើងហៅថា សម្ល តាមក្បួនបច្ចេកទេសមានរបៀបចិតបន្លែ, ហាន់គ្រឿង, បុកគ្រឿង, កាត់សាច់, ចិញ្ច្រាំសាច់ បញ្ចូលគ្រឿង ឬ ផ្សំគ្រឿងខុសគ្នាតាមមុខសម្ល ។ ការដាក់គ្រឿងចូលមុនក្រោយ, ការប៉ាន់ស្មានចំនួនទឹក ចំនួនគ្រឿង ការដាក់យូរឆាប់ និង ការលៃប្រើកម្លាំងភ្លើង ទាំងអស់នេះសុទ្ធតែមានចែង

ប្រាប់ក្នុងក្បួនបច្ចេកទេស ។

ដូច្នេះអ្នកធ្វើទាន ប្រសិនបើចង់ឱ្យទានរបស់ខ្លួនប្រសើរថ្លៃថ្នូរ ត្រូវចាត់ចែងទេយ្យទានរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមក្បួនបច្ចេកទេសទើបជាទានមានសិល្បៈ ព្រោះបច្ចេកទេសជាហេតុនៃសិល្បៈ ។ ក្នុងពុទ្ធសម័យ អ្នកធ្វើទានធំៗគេច្រើនតែអញ្ជើញមហាឧបាសិកា ឈ្មោះ **វិសាខា** ទៅជួយចាត់ចែង ព្រោះស្ត្រីនេះមានបច្ចេកទេសខាងធ្វើម្ហូបអាហារផង មានបច្ចេកទេសខាងប្រាស្រ័យទាក់ទងភ្ញៀវផង ។

ដើម្បីឱ្យកាន់តែយល់បំណងពុទ្ធសាសនា អំពីរឿងទាននេះ ខ្ញុំសូមលើកយកទក្ខិណាទាន ដែលលោកចាត់ថាជាទានខ្ពង់ខ្ពស់ ពីគម្ពីរទក្ខិណាវិភង្គសូត្រ មកពិពណ៌នាដូចតទៅ ។

## ទក្ខិណាទាន

ទក្ខិណាទាន មានសេចក្ដីបរិសុទ្ធិ ៤ យ៉ាង ហៅថាទក្ខិណាវិសុទ្ធិ គឺ ៖

១- ទាយកបរិសុទ្ធ បដិគ្គាហកៈមិនបរិសុទ្ធ,
២- បដិគ្គាហកៈបរិសុទ្ធ ទាយកមិនបរិសុទ្ធ,
៣- ទាយកក៏មិនបរិសុទ្ធ បដិគ្គាហកៈក៏មិនបរិសុទ្ធ,
៤- ទាយកក៏បរិសុទ្ធ បដិគ្គាហកៈក៏បរិសុទ្ធ ។

ទាយកបរិសុទ្ធ គឺទាយករកទ្រព្យបានតាមផ្លូវត្រូវ ចាត់ចែងទេយ្យទានត្រឹមត្រូវតាមក្បួនបច្ចេកទេស ។ បដិគ្គាហកៈបរិសុទ្ធ គឺបដិគ្គាហកៈមានសីលធម៌សម្រាប់ខ្លួន មានសេចក្តីវៃឆ្លាតចេះប្រើរបស់ដែលគេចាត់ចែងឡើងតាមក្បួនបច្ចេកទេស ។ ទាយកមិនបរិសុទ្ធ គឺ ទាយករកទ្រព្យបានមកតាមផ្លូវខុសចាត់ចែងទេយ្យទានមិនត្រូវតាមបច្ចេកទេស ។ ទាំង ៤ នេះ មានតែទានទី ៤ ទេដែលជាទានល្អបំផុត ព្រោះទាំងសងខាង មានសេចក្តីបរិសុទ្ធិដូចគ្នា ។

គោលបំណងពុទ្ធសាសនា ចង់ឱ្យមនុស្សយើងរកសេចក្តីបរិសុទ្ធិស្វែងរកសេចក្តីចេះដឹងទាំងអស់គ្នា ដើម្បីរស់នៅក្នុងពិភពលោក ដែលចេះតែរករឿងគ្នាមិនមានទីបំផុត ទើបលោកសរសើរទានទី ៤ ថាជាទានល្អ ជាងទានទី ២ និងទី ៣ ។

ពុទ្ធសាសនាបានឃើញទាយកមិនបរិសុទ្ធ និងបដិគ្គាហកៈមិនបរិសុទ្ធនេះហើយ ទើបនិយាយអំពីទក្ខិណាវិសុទ្ធិ ដើម្បីឱ្យទាយក និង បដិគ្គាហកៈ រៀបចំខ្លួនឱ្យបានបរិសុទ្ធ ឱ្យមានសេចក្តីចេះដឹងគ្រប់គ្នា ។ កាលបើយើងធ្វើបរិសុទ្ធកម្ម តាមបំណងព្រះពុទ្ធសាសនា សង្គមមនុស្សក្នុងពិភពលោកយើងនេះ ក៏ប្រាកដជាបានទទួលនូវសេចក្តីសុខចំរើន ឋានសួគ៌ប្រាកដជានឹងបើកទ្វារដោយញញឹមចាំទទួលមនុស្សបរិសុទ្ធទាំងឡាយនោះមិនខានឡើយ ។

**អាមិសទាន & ធម្មទាន**

គួកត់សំគាល់ថា ទក្ខិណាវិសុទ្ធិ សេចក្ដីបរិសុទ្ធិក្នុងការឱ្យទាន និង ការទទួលទាននេះ មិនសំដៅយកត្រឹមតែអាជីវកម្មបរិសុទ្ធ ឬ សីលបរិសុទ្ធប៉ុណ្ណោះទេ គឺ សំដៅយកសេចក្ដីបរិសុទ្ធិខាងផ្លូវចេះដឹង ស្គាល់របៀបបច្ចេកទេសទូទៅ ជាពិសេសស្គាល់វិន័យ បច្ចេកទេស ទាំងខាងអ្នកឱ្យ ទាំងខាងអ្នកទទួល ព្រោះថាបើទាយកមិនស្គាល់បច្ចេកទេសទូទៅ ទានរបស់គេគ្រាន់តែមិនសូវ ល្អ តែបើមិនស្គាល់វិន័យបច្ចេកទេសនោះ ទានរបស់គេក៏មិនកើតជាទានតាមវិន័យឡើយ ។

បើជាកឋិនទានត្រូវតែមានបច្ចេកទេសខាងវិន័យទាំងសងខាង គឺ ខាងទាយកក៏ត្រូវស្គាល់វិន័យបច្ចេកទេស អំពីរឿងកាត់ដេរបោកគក់ ជ្រលក់ចីវរ អំពីរឿងខ័ន្ធនៃចីវរ ដែលគេកាត់ដេរចំណាយស្រាប់ ។ ចំណែកខាងភិក្ខុ គឺ បដិគ្គាហកៈត្រូវតែស្គាល់វិន័យបច្ចេកទេស ខាងក្រាលគ្រងអនុមោទនា ។ ខាងណាមួយមានកំហុសខាងវិន័យបច្ចេកទេស សូម្បីត្រឹមតែបន្តិចបន្តួច ក៏ពុំកើតជាកឋិនឡើយ ។ ដូច្នេះហើយបានជាអត្ថកថាចារ្យ លោកឱ្យន័យពាក្យ កឋិន ថាកម្រ គឺ កម្រនឹងធ្វើឱ្យកើតឡើងជាកឋិនពេញអង្គ តាមពុទ្ធានុញ្ញាត្ត និង ពុទ្ធប្បញ្ញត្តិ ។

សរុបសេចក្ដីមក បើទាយក ទាយិកា បានយល់ដឹងអំពី

*របៀបបច្ចេកទេសនៃការឱ្យទាន ព្រមទាំងអនុវត្តឱ្យបានត្រឹមត្រូវ ដោយយកទក្ខិណាវិសុទ្ធិមកផ្ទុះបញ្ចាំងជាគោល ផល្វានិសង្ឃជាទីមោទនៈនឹងកើតមានឡើងជាប្រាកដ គ្មានអំណាចអ្វីមករារាំងឃាត់ឃាំងបានឡើយ ។*

**ពុទ្ធសាសនសុភាសិតពោលថា ៖**

**អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ**
**យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ ។**

*អ្នកឱ្យគ្រឿងបរិភោគ ឈ្មោះថាឱ្យកម្លាំង, អ្នកឱ្យសំពត់ ឈ្មោះថា ឱ្យពណ៌សម្បុរ, អ្នកឱ្យយាន ឈ្មោះថាឱ្យសេចក្ដីសុខ, អ្នកឱ្យប្រទីប ឈ្មោះថាឱ្យចក្ខុ ។*

**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ**

*អ្នកមានប្រាជ្ញា ជាអ្នកឱ្យនូវសេចក្ដីសុខ ( ដល់អ្នកឯទៀតហើយ ) លោករមែងបាននូវសេចក្ដីសុខ ( នោះមកខ្លួនវិញ ) ។*

**កល្យាណការី កល្យាណំ បាបការី ច បាបកំ**

*អ្នកធ្វើអំពើល្អនឹងបានផលល្អ អ្នកធ្វើអំពីអាក្រក់នឹងបានផលអាក្រក់ ៕*

# ឆឡង្គទាន

**ឆឡង្គទាន** *មកពីពាក្យ* **ឆ** + **អង្គ** + **ទាន** = **ឆឡង្គទាន** *ប្រែថា ទានប្រកបដោយអង្គ៦ ។ អង្គ ៦នោះ គឺ អង្គរបស់ទាយក អ្នកឱ្យ ៣ និង អង្គរបស់បដិគ្គាហក: អ្នកទទួល ៣ ។*

## អង្គរបស់ទាយក ៣ យ៉ាងគឺៈ

*១-* **បុព្វេវ ទានា សុមនោ ហោតិ** *ទាយកអ្នកឱ្យមានចិត្តត្រេកអរក្នុងកាលមុនឱ្យ,*

*២-* **ទទំ ចិត្តំ បសាទេតិ** *ទាយកអ្នកឱ្យញុំាងចិត្តឱ្យជ្រះថ្លាក្នុងកាលកំពុងឱ្យ,*

*៣-* **ទត្វា អត្តមនោ ហោតិ** *ទាយកអ្នកឱ្យមានចិត្តត្រេកអរ ត្រួតថែមតាមទានដែលឱ្យរួចហើយ ។*

*អង្គទាំង ៣ យ៉ាងនេះ នឹងហៅថា* **បុព្វចេតនា១** , **មុញ្ចនចេតនា១**, **អបរាបរចេតនា១** *ដូច្នេះវិញក៏បាន ។*

## អង្គរបស់បដិគ្គាហកៈ ៣ យ៉ាងគឺ ៖

*១-* **វីតរាគា វា ហោន្តិ រាគាវិនយាយ វា បដិបន្នា** *បដិគ្គាហក: អ្នកទទួលទានអស់រាគ: (ពីខន្ធសន្តាន) ហើយ ឬ កំពុងប្រតិបត្តិដើម្បីកំចាត់បង់រាគ: ,*

*២-* **វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិ-**

**បន្ធា** បដិគ្គាហកៈអ្នកទទួលទានអស់ទោសៈ (ពីខន្ធសន្តាន )ហើយ កំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវទោសៈ ,

៣- **វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិ-បន្នា** បដិគ្គាហកៈ អ្នកទទួលទានអស់មោហៈ ( ពីខន្ធសន្តាន ) ហើយ ឬ កំពុងប្រតិបត្តិដើម្បីកំចាត់បង់មោហៈ ។

រួមអង្គទាំងផ្នែកខាងទាយក និង ផ្នែកខាងបដិគ្គាហកៈត្រូវ ជា ៦ ប្រការ ទើបហៅថា ឆឡង្គទាន ប្រែថា ទាន ប្រកបដោយ អង្គ៦ ។ ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរ ឆឡង្គទាននេះថា ទាយក អ្នកធ្វើទាននឹងបានអានិសង្សច្រើនឥតគណនា ។

ការបំពេញទានឱ្យបរិសុទ្ធ តាមរបៀបបច្ចេកទេស ដូច ដែលបានរៀបរាប់នៅទំព័រមុនមកហើយជាកិច្ចដែលបុគ្គលធ្វើបាន ដោយកម្រជាងការរក្សាសីល ។ សីលបើបុគ្គលត្រូវការកាន់រក្សា គ្រាន់តែរៀនសូត្រឱ្យចេះដឹងសិក្ខាបទដែលត្រូវតម ត្រូវវៀរ ហើយ សមាទានសីលនោះពីភិក្ខុ ឬ សាមណេរមកខំប្រឹងប្រតិបត្តិសង្រួម ឱ្យបានត្រឹមត្រូវ ក៏អាចញ៉ាំងកុសលនោះឱ្យសម្រេចបរិសុទ្ធបាន ឬ ថាសីលនេះបុគ្គលគ្រប់ជាន់ថ្នាក់ទាំងអ្នកមាន ទាំងអ្នកមធ្យម ទាំង អ្នកក្រ អាចកាន់រក្សាសមាទានបានដូចគ្នា ដោយមិនចាំបាច់ ចំណាយបង់ទ្រព្យធន ។

ចំណែកការបរិច្ចាគទាន លុះត្រាតែបុគ្គលមានទេយ្យវត្ថុល្អមលះធ្វើកើតផង និង មានបដិគ្គាហកៈអ្នកទទួលផង ។ មិនតែប៉ុណ្ណោះ បុគ្គលត្រូវចាត់ចែងធ្វើទាននោះ តាមបច្ចេកទេសសិល្បៈត្រឹមត្រូវតាមពុទ្ធានុញ្ញាត្ត ទើបនឹងបានផលានិសង្សពេញលេញសមតាមបំណង ហើយមានឈ្មោះថា ជាទានដ៏ប្រពៃ ។

## ទានដ៏ប្រពៃមានស្ថាន ៧ ប្រការ គឺ ៖

១- **តណ្ហាត្តរិយទានំ** ទានដើម្បីឆ្លងចាកតណ្ហា ដែលជាគ្រឿងនាំសត្វឬ បណ្តើរសត្វឱ្យអន្ទោលកើតស្លាប់ក្នុងត្រៃភព ,

២- **ចិត្តីការទានំ** ទានដោយសេចក្តីគោរព គឺ គោរពគ្រប់ទ្វារទាំង៣ ( កាយទ្វារ វចីទ្វារ និង មនោទ្វារ ) ព្រមទាំងទេយ្យវត្ថុដែលត្រូវលះឱ្យ ,

៣- **ហិរោត្តប្បទានំ** ទានដោយសេចក្តីខ្មាសបាប ខ្លាចបាប ខ្ពើមបាប ,

៤- **និរវសេសទានំ** ទានដោយមិនគិតសំចៃទុក មិននឹកស្តាយក្រោយ ,

៥- **ទក្ខិណេយ្យទានំ** ទានចំពោះទក្ខិណេយ្យបុគ្គល ,

៦- **សោមនស្សបរិចារទានំ** ទានដោយសោមនស្ស រីករាយ និង ការពិចារណាឃើញ ប្រយោជន៍ជាក់លាក់ មិនស្រវៃ

ស្រវាន់ដោយវិចិកិច្ឆានីវរណៈ,

៧- **អលង្ការបរិវារទានំ** ទានជាគ្រឿងអលង្ការ និង ជាបរិវារនៃចិត្ត គឺ តាំងចិត្តថានឹងយកការឱ្យទាន មកធ្វើជាគ្រឿងប្រដាប់សម្រាប់អប់រំចិត្ត ជាគ្រឿងលម្អរបស់ចិត្ត ។

បុគ្គលដែលបានធ្វើទានដ៏ប្រពៃ ៧ ប្រការខាងលើនេះមានឈ្មោះថាជាបុគ្គលភ្ញាក់រឮក មានសេចក្តីប្រាថ្នានឹងជិះនាវាត្រៃលក្ខណ៍ឆ្ពោះទៅរកទីស្ថានបរមសុខ គឺ ព្រះនិព្វាន ។ ផ្ទុយទៅវិញ បុគ្គលដែលធ្វើទានទាំងបំពាន ទាំងខ្ជីខ្ជា ដោយមិនចេះដឹងបច្ចេកទេសសិល្បៈនៃការធ្វើទាន ព្រោះអាងកេរ្តិ៍ឈ្មោះយសសក្តិ ទ្រព្យសម្បត្តិ ក៏ធ្វើតាមទំនើងចិត្តចង់ដោយញាណវិប្បយុត្ត មិនអនុវត្តតាមច្បាប់ព្រះពុទ្ធសាសនា ដែលមានមកក្នុងគម្ពីរដីកា មានឈ្មោះថាបុគ្គលជប់ជល់នឹងតណ្ហា ប្រាថ្នាលោកិយសុខ ឬ អាមិសសុខ នាំគ្នាសម្រុកជិះតែនាវាត្រៃលោក ។

នាវាត្រៃលោក បើកវិលវល់ក្នុងសមុទ្រវដ្តសង្សារនៃភពទាំងបី គឺ កាមភព រូបភព និង អរូបភព ដែលព្រះអរិយបុគ្គលទាំងឡាយតែងតែខំចៀសវាង ។ រីឯនាវាត្រៃលក្ខណ៍ផ្ទុកសត្វដែលមានឧបនិស្ស័យចាស់ក្លា បើកយាត្រាឆ្ពោះទៅកាន់ព្រះនិព្វាន ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ៖ **សព្វរសំ ធម្មរសោ ជិនាតិ**

រសធម៌ រមែងឈ្នះអស់រសទាំងពួង ។

ធម្មតារសទាំងអស់ក្នុងលោក មានរសភោជនាហារ ដ៏មានរសជាតិឆ្ងាញ់ពិសា ក្លិនក្រអូបឈ្ងុយឈ្ងប់ ឬ ម្ហូបចំណីសួគ៌ នៃទេវតាទាំងឡាយ រស់ទាំងអស់នេះ គ្រាន់តែជាបច្ច័យសម្រាប់សោយទុក្ខក្នុងសង្សារវដ្តប៉ុណ្ណោះ ។ ចំណែកខាងធម្មរស គឺពោធិបក្ខិយធម៌ ៣៧ ប្រការ និង លោកុត្តរធម៌ ៩ ជារសប្រសើរក្រៃលែង ជាងរសទាំងពួង ព្រោះថា ធម្មរសនេះអាចញុំាងបុថុជ្ជនឱ្យចង់ជិះនាវាត្រៃលក្ខ័ណជាងនាវាត្រៃលោក ។

បូរាណបណ្ឌិតបានពោលថា ការបានកើតជាមនុស្សក្នុងប្រទេសដ៏សមគួរ ទាន់ព្រះពុទ្ធសាសនា ជាហេតុការណ៍មួយដ៏កម្រក្រៃលែង ។ ដូចនេះមិនត្រូវបណ្តោយឱ្យឱកាសដ៏ប្រសើរនេះកន្លងទៅដោយពុំបានក្រេបជញ្ជក់ធម្មរសឡើយ ។ គួរនាំគ្នាត្រាប់តាមសត្វឃ្មុំ ដែលខំហើរស្វះស្វែងមករកក្រេបលំអងផ្កាឈូកផ្កាព្រលិតដុះក្នុងបឹង ។ ចូរកុំត្រាប់កង្កែបដែលហែបបន្ទឹមក្បាលបើកភ្នែកភ្ញឹះៗ ក្បែរផ្កាឈូកធ្វើវាហី មិនខ្វីរវល់អើពើនឹងរសជាតិកេសរផ្កាដែលកមរជាតិកំពុងត្រឹបដោយវិរិយភាព និង អប្បមាទភាព ។

# ទានានិសង្ស

**ទានានិសង្ស** មកពីពាក្យ **ទាន** + **អានិសង្ស** = **ទានានិសង្ស** ប្រែថា ផលនៃការធ្វើទាន ឬ ផល្លានិសង្សនៃការធ្វើទាន ។ ទាន ( អាមិសទាន និង ធម្មទាន ) នេះ លោកចាត់ជាកល្យាណវត្ថុមួយដ៏ប្រសើរ រមែងមាននៅប្រចាំលោក ជាករណីកិច្ចរបស់សប្បុរសដោយពិត តែជាទំនាស់របស់មនុស្សកំណាញ់ ឬ មនុស្សមិនជឿកម្មផល ព្រោះគេយល់ថាទានធ្វើទៅអស់ទ្រព្យ ផលរបស់ទានមានទ្រព្យ ហេតុ និង ផលមិនស្មើគ្នា ។

ទានលោករាប់ថា ជាប្រពៃណីធម៌របស់បុព្វបុរស ឬចាត់ជាបុញ្ញនិធិ ជាទីពឹងពំនាក់របស់សត្វលោក ។ ទានរមែងសម្រេចប្រយោជន៍ឱ្យឃើញជាក់ច្បាស់ ទាំងផ្លូវលោក ទាំងផ្លូវធម៌ គឺ ឥធលោក និង បរលោក ។

ទាយកអ្នកឱ្យទាន ឈ្មោះថា បានឱ្យនូវអាយុ ពណ៌សម្បុរ កម្លាំង សេចក្ដីសុខ សេចក្ដីអង់អាចដល់បុគ្គលដទៃ ។ ការឱ្យទាននេះ ឈ្មោះថា ជាអ្នកចងមិត្ត ប្រមូលកម្លាំងទុកដោយប្រពៃ ព្រោះថា មនុស្សក្នុងលោក រមែងមានកិច្ចធុរៈរវល់ជាធម្មតា ។ កាលបើកិច្ចការធុរៈកើតឡើង បុគ្គលអ្នកឥតមិត្តសម្លាញ់ រមែងរ៉ាប់រងការលំបាកនោះៗ ផ្ទាល់ខ្លួនឯង ។ កាលបើមានមិត្តសម្លាញ់ត្រឹមចំនួន

ណា កម្លាំងក៏មានតាមចំនួននោះដែរ ។

បុរាណាចារ្យលោកបានចាត់ទាន ជាមិត្តសម្លាញ់ ឬជាកម្លាំងដ៏ប្រសើរ ព្រោះជាបច្ច័យជួយជូនដំណើរ ឱ្យជួបប្រទះនូវសេចក្តីសុខចំរើន តាំងពីបច្ចុប្បន្នរៀងដរាបដល់បរលោក ។ រាងកាយមនុស្សយើងត្រូវមានអវយវៈ គឺ ដៃជើងជាមិត្តសម្លាញ់ ឬជាកម្លាំងសម្រាប់សម្រួលដោះស្រាយកិច្ចការធុរៈ យ៉ាងណាមិញ, បុគ្គលអ្នកមានសទ្ធា ត្រេកអរក្នុងការបរិច្ចាគទាន ក៏រមែងបានទាននោះឯងជាមិត្តជាកម្លាំងរបស់ខ្លួនក៏យ៉ាងនោះដែរ ។ រីឯបុគ្គលមិនមានសទ្ធាជាអ្នកកំណាញ់ មានឈ្មោះថា បុគ្គលគ្មានមិត្តសម្លាញ់ ឬ គ្មានកម្លាំងដូចគ្នានឹងរាងកាយដែលកំបុតដៃជើង ។ អានិសង្សរបស់ទានមានច្រើនយ៉ាង តែបើនិយាយរួមចំពោះអានិសង្ស នៃអាមិសទានមាន ៥ យ៉ាង ។

### អានិសង្សនៃអាមិសទាន ៥ យ៉ាងគឺ ៖

១- **បិយោ ហោតិ មនាបោ** រមែងជាទីស្រឡាញ់ពេញចិត្ត នៃជនទាំងឡាយ ,

២- **សប្បុរិសា ភជន្តិ** មនុស្សតែងតែសេពគប់រាប់រក,

៣- **កល្យាណកិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិស័ព្ទរមែងឮល្បីខ្ចរខ្ចាយគ្រប់ទិសានុទិស ,

៤- **វិសារទោ ឧបសង្កមតិ** រមែងមានសេចក្ដីក្លាហានមិនអឹមអៀន ពេលចូលទៅកាន់ទីប្រជុំជន,

៥- **សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** ពេលធ្វើកាលកិរិយានឹងបានទៅកើតក្នុងសុគតិភព ។

អានិសង្សទាំង ៥ យ៉ាង ដូចពោលមកនេះ ចែកចេញជាពីរផ្នែក គឺ អានិសង្ស ៤ ខាងដើមជា **សន្ទិដ្ឋិកផល** គឺផលគួរឃើញជាក់ច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ ។ អានិសង្សមួយខាងចុងជា **សម្បរាយិកផល** គឺផលដែលត្រូវបានជួបប្រសព្វឃើញច្បាស់ក្នុងបរលោក ។

## អានិសង្សនៃធម្មទាន

ធម្មទាននេះ ខ្ញុំបានពន្យល់ក្បោះក្បាយ នៅទំព័រខាងដើមរួចម្ដងមកហើយ ។ ការសំដែងធម្មទេសនាជាសាធារណៈក្ដី ប្រៀនប្រដៅប្រាប់អំពីគុណ ទោស ខុស ត្រូវ ផ្លូវលោក ផ្លូវធម៌ ចំពោះមនុស្សម្នាក់ៗ ឬ ច្រើននាក់ក្ដី បង្ហាត់បង្រៀនធម៌អាថ៌ ចំពោះពួកគណៈសាធារណៈក្ដីហៅថាធម្មទាន។ ធម្មកថិកសំដែងធម៌ទេសនាឈ្មោះថាប្រគល់ចំណេះវិជ្ជាប្រាជ្ញាស្មារតីដល់បុគ្គលដទៃ ព្រោះថាបុគ្គលដែលបានទទួលនូវសេចក្ដីសុខមានភោគសម្បត្តិ មានឋានានុក្រម គឺ តំណែង យសសក្ដិណាមួយ សុទ្ធតែអាស្រ័យការរៀនសូត្រស្ដាប់នេះឯងជាមូលហេតុ ។

**អាមិសទាន & ធម្មទាន**

*ការសិក្សាត្រូវត្រាប់ស្តាប់យកឧបាយ រាប់ថាជាមេគំនិតឬជាដើមពូជនៃសារប្រយោជន៍គ្រប់បែបយ៉ាង ។ បុគ្គលដែលបានសម្រេចមគ្គផលនិព្វាន ក៏ព្រោះអាស្រ័យការស្តាប់ជាបច្ច័យ ។*

*បុគ្គលអ្នកប្រៀនប្រដៅធម៌ ឈ្មោះថា ឱ្យទានព្រះនិព្វានសមដូចពុទ្ធភាសិតថា* **អមតន្ទទោ ច សោ ហោតិ យោ ធម្ម-មនុសាសតិ** *បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះ ឈ្មោះថាឱ្យព្រះនិព្វាន ( ដល់អ្នកដទៃ ) ។* **សព្វទានំ ធម្មទានំ ជិនាតិ** *ធម្មទាន រមែងឈ្នះទានទាំងពួង ។*

*ធម្មទាន ជាទានមានផល្លានិសង្សខ្ពស់ ឈ្នះអាមិសទានទាំងអស់ ព្រោះហេតុថាធម្មទានជាប្រធាន ឬជាជីវិតនៃអាមិស-ទាន ។ ធម្មទានជាអាយុនៃព្រះពុទ្ធសាសនា អាចញុំាងព្រះពុទ្ធ-សាសនាឱ្យមានពន្លឺរស្មីរុងរឿងដរាបរៀងមក ។ ការសំដែងធម៌ដល់អ្នកដទៃ កាលបើអ្នកស្តាប់ទទួលស្តាប់ ដោយគោរព រមែងបានអានិសង្សយ៉ាងប្រសើរ ចំណែកធម្មកថិក លោកអ្នកសំដែងធម៌ ក៏បានទទួលនូវអានិសង្ស ដ៏ថ្លៃថ្លាច្រើនយ៉ាងមកវិញ ។ បើនិយាយរួមអានិសង្សនៃធម្មទានមាន ៥ ប្រការ ។*

**អានិសង្សនៃធម្មទាន ៥ ប្រការ គឺ ៖**

១- **អត្ថប្បដិសំវេទី ធម្មប្បដិសំវេទី** *លោកអ្នកសំដែង*

កាលបើសំដែងធម៌ ដោយផ្ចិតផ្ចង់ តាមអត្ថនៃធម្មកថិកចំពោះព្រះសទ្ធម្ម នឹងរឹងរឹតតែជាអ្នកយល់ដឹងច្បាស់ ជ្រុះថ្លាយក្នុងអត្ថនៃធម៌ដ៏ក្រៃលែងឡើងទៀត ,

២- **បាមោជ្ជំ** សេចក្តីរីករាយក្នុងអត្ថនៃធម៌ រមែងកើតឡើងដោយសោមនស្សជ្រះថ្លាជាទីបំផុត,

៣- **បីតិ** សេចក្តីត្រេកអរឆ្អែតចិត្តក្នុងអត្ថនៃធម៌នោះៗ ក៏រមែងកើតឡើង,

៤- **បស្សទ្ធិ** កាយ និង ចិត្តនៃធម្មកថិក និង អ្នកស្តាប់ស្ងប់រម្ងាប់ចាកអកុសលធម៌ផ្សេងៗ រហូតដល់កើតសង្វេគតក់ស្លុតក្នុងសង្ខារទាំងឡាយ,

៥- **សមាធិ** ចិត្តរបស់លោកដែលកំពុងសំដែងធម៌ ក៏តាំងមាំក្នុងអារម្មណ៍ស្ងប់ស្ងាត់ចាកនីវរណធម៌ ។

អានិសង្សទាំង ៥ យ៉ាងនេះជា **សន្ទិដ្ឋិកផល** គឺផលដែលឃើញច្បាស់ក្នុងបច្ចុប្បន្ននេះក៏មាន ជា **សម្បរាយិកផល** គឺ ផលដែលត្រូវមានជាប់តទៅក្នុងបរលោកក៏មាន ។

## អានិសង្សនៃចតុប្បច្ច័យទាន

ចតុប្បច្ច័យ ឬ បច្ច័យ ៤ ដែលមានចីវរ បិណ្ឌបាត សេនាសនៈ និង គិលានភេសជ្ជៈ ខ្ញុំបានពន្យល់រួចមកហើយនៅទំព័រខាង

ដើមត្រង់អាមិសទាន ។ ប៉ុន្តែដោយយល់ឃើញថា ពុទ្ធបរិស័ទនិយមធ្វើទានបច្ច័យ ៤ ឬ ហៅថាបុណ្យបច្ច័យ៤ ទើបខ្ញុំលើកយកអានិសង្សនីមួយៗនៃចតុប្បច្ច័យទាន មកពណ៌នាឱ្យបានពិស្តារជាងមុនបន្តិចទៀត ដើម្បីឱ្យទាយក ទាយិកា បានយល់ចូលចិត្តមានសទ្ធាជ្រះថ្លាកាន់តែច្រើនឡើងៗ ។

## អានិសង្សនៃចីវរទាន

ពាក្យថា **ចីវរ:** ស្តាប់ទៅដូចជាបានតែខាងស្បង់ ចីវរ ជាបរិក្ខារសម្រាប់បព្វជិតតែមួយមុខប៉ុណ្ណោះ ។ ប៉ុន្តែបើតាមសេចក្តី ( អត្ថ ) ដែលចែងអំពីចីវរប្បច្ច័យនោះ លោកថាសូម្បីតែគ្រឿងស្លៀកពាក់របស់គ្រហស្ថទូទៅ ដែលជារបស់ដេរភ្ជាប់គ្នា ដោយចេស ក៏រាប់ចូលចីវរប្បច្ច័យដែរ ។

មនុស្សគ្រប់រូប ទោះគ្រហស្ថក្តី បព្វជិតក្តី សុទ្ធតែត្រូវការចីវរប្បច្ច័យ ( គ្រឿងស្លៀកដណ្តប់ ) ដូចៗគ្នា ។ បើពុំមានគ្រឿងស្លៀកដណ្តប់ទេ មនុស្សប្រាជកជាមិនអាចរស់នៅបានសុខស្រួលឡើយ ព្រោះតែសេចក្តីអន្តរាយដោយភាពក្តៅ និង ត្រជាក់ជាដើម ។ បើទោះបីជារស់នៅបានក៏បានដោយសេចក្តីវេទនា ដូចជាមនុស្សព្រៃ ឬ សត្វស្វាដែលការពារក្តៅ ឬ ត្រជាក់ដោយសារតែរោមប៉ុណ្ណោះ ។

អាស្រ័យហេតុនេះហើយ បានជាទាយកទាយិកា បានឱ្យចីវរប្បច្ច័យ មានសំពត់ ខោអាវ ដល់មាតាបិតា ដោយបូជាគុណលោក ឬ ដល់គ្រហស្ថ ដោយសង្គ្រោះ និង ប្រគេនត្រៃចីវរចំពោះបព្វជិត ដោយបូជាគុណធម៌របស់លោក ។ ការឱ្យចីវរទានបានទទួលផលានិសង្សច្រើន ទាំងបច្ចុប្បន្នកាល ទាំងអនាគតកាល ។ បដិគ្គាហកៈជាអ្នកទទួលនូវទាន រមែងមានសម្បុរល្អ ក្នុងបច្ចុប្បន្ន ហើយទាយកនឹងមានសម្បុរល្អ និង សម្បូរទៅដោយគ្រឿងស្លៀកពាក់ ក្នុងអនាគតកាល ។

ក្នុង **គម្ពីរសំយុត្តនិកាយ** ត្រង់ **ទេវតាសំយុត្ត** ថែងថាកាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ព្រះជន្មនៅឡើយ មានទេវតាចូលមកទូលសួរព្រះអង្គថា "បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថា ឱ្យពណ៌សម្បុរ ?" ព្រះសាស្ដាទ្រង់ត្រាស់ថា " **វត្ថទោ ហោតិ វណ្ណទោ** ការឱ្យសំពត់ជាទាន បានឈ្មោះថា ឱ្យពណ៌សម្បុរជាទាន គឺបានឈ្មោះថា ឱ្យវណ្ណទានដល់អ្នកទទួលនូវទាន ក្នុងបច្ចុប្បន្នជាតិ ហើយទាយកអ្នកឱ្យទាននោះតែងបានជាអ្នកមានពណ៌សម្បុរល្អ សំបូរគ្រឿងស្លៀកពាក់ និងទ្រព្យសម្បត្តិ ក្នុងអនាគតជាតិ" ។

## អានិសង្សនៃបិណ្ឌបាតទាន

**អាមិសទាន & ធម្មទាន**

ដុំនៃអាមិស គឺ អាហារមានបាយ បបរ នំចំណីជាដើម ដែលដាក់ចូលទៅក្នុងមាត់ ទំពារលេបចូលទៅបាន ភាសាបាលី ហៅថា **បិណ្ឌបាត** ។ យើងអ្នកកាន់ព្រះពុទ្ធសាសនាធ្លាប់សំគាល់ពាក្យនេះតែម្យ៉ាងថា ជាចង្ហាន់របស់ព្រះសង្ឃ ។ ប៉ុន្តែតាមសេចក្តី ( អត្ថ ) ដែលចែងអំពីបិណ្ឌបាតប្បច្ច័យនោះ លោកថាសូម្បីតែអាហាររបស់គ្រហស្ថ ឬ សត្វទូទៅ ដែលជាគ្រឿងលេបចូលទៅតាមមាត់ដូចគ្នា ក៏លោករាប់ចូលក្នុងពួកបិណ្ឌបាតប្បច្ច័យដែរ ។

ធម្មតាមនុស្សសត្វក្នុងលោក សុទ្ធតែត្រូវការបិណ្ឌបាតប្ប-បច្ច័យដូចគ្នាទាំងអស់ បើគ្មានបិណ្ឌបាតប្បច្ច័យជាគ្រឿងអាស្រ័យទេ ពិតជាមិនអាចរស់នៅបានជាដាច់ខាត ។ ព្រះបរមសាស្តាទ្រង់បានសំដែងថា "**សព្វេ សត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយទាំងពួង តាំងជីវិតរស់នៅបានដោយអាហារ" ។ ពាក្យថា អាហារ មិនសំដៅយកតែបាយ បបរ នំចំណីសម្រាប់មនុស្សបរិភោគនោះទេ សូម្បីតែស្មៅ, ឫស, ដើម, ស្លឹកឈើជាដើម ដែលសត្វតូចធំបរិភោគក៏អាចហៅថា អាហារដូចគ្នា។ បើមនុស្សសត្វគ្មានអាហារបរិភោគ ឬក៏មានដែរ តែបរិភោគមិនកើត ព្រោះមានជម្ងឺឈឺថ្កាត់ ក៏ដល់នូវសេចក្តីស្លាប់ ទោះបីជាមិនស្លាប់ ក៏គ្មានកម្លាំងពលំដែរ ។

អាស្រ័យហេតុនេះហើយ បានជាទាយកទាយិកា បាន

ឱ្យបិណ្ឌបាតបច្ច័យ មានចំណីអាហារដល់មាតាបិតា ដោយបូជាគុណលោក ដល់គ្រហស្ថដោយសង្គ្រោះ និង ដល់បព្វជិតដោយបូជាគុណធម៌របស់លោក ។ ការឱ្យបិណ្ឌបាតទាននឹងបានទទួលផលានិសង្សច្រើនអនេកទាំងបច្ចុប្បន្នកាល ទាំងអនាគតកាល ។ បដិគ្គាហកៈអ្នកទទួលនូវទាន មានកម្លាំងមាំមួន ក្នុងបច្ចុប្បន្នកាល ហើយទាយកម្ចាស់ទាន នឹងមានរូបសម្បត្តិល្អ មានកម្លាំងពលំ និងទ្រព្យសម្បត្តិច្រើន ក្នុងអនាគតកាល ។

**គម្ពីរសំយុត្តនិកាយ** ត្រង់ **ទេវតាសំយុត្ត** សំដែងថា កាលព្រះបរមសាស្ដា ទ្រង់គង់ព្រះជន្មនៅឡើយ មានទេវតាចូលទៅទូលសួរព្រះអង្គថា "**ទទោ ពលោ ហោតិ** បពិត្រព្រះដ៏មានបុណ្យដ៏ចំរើន ! ឱ្យរបស់អ្វីជាទាន ទើបបានឈ្មោះថាឱ្យកម្លាំង ? " ព្រះពុទ្ធទ្រង់ត្រាស់ថា "**អន្នទោ ពលទោ ហោតិ** ឱ្យបាយជាទាន បានឈ្មោះថាឱ្យពលទាន គឺ ឱ្យកម្លាំងដល់បដិគ្គាហកៈ អ្នកទទួលនូវទានក្នុងបច្ចុប្បន្នជាតិ ហើយទាយកជាម្ចាស់ទានតែងបានសំបូរទ្រព្យសម្បត្តិ ក្នុងអនាគតជាតិ" ។

## អានិសង្សនៃសេនាសនទាន

ទីជ្រក ទីដេក ទីអង្គុយតាមព្យញ្ជនៈ(តួអក្សរ)នៅក្នុងភាសាបាលីហៅថា **សេនាសនៈ** ។ យើងជាពុទ្ធបរិស័ទធ្លាប់សំគាល់ពាក្យ

នេះថា ជាឈ្មោះទីលំនៅ របស់សង្ឃ មានកុដិ សាលា ព្រះវិហារ បង្គន់ តុ ទូ តាំង ពូក កន្ទេល ខ្នើយជាដើម ។ ប៉ុន្តែតាម ( អត្ថ ) ដែលលោកអធិប្បាយអំពីសេនាសនប្បច្ច័យ ( ក្នុងបច្ច័យ ៤ ឬ ចតុប្បច្ច័យ ) សេនាសនៈ មិនសំដៅត្រឹមតែកុដិ សាលា ព្រះវិហារ បង្គន់ តុតាំង កៅអី ពូកគ្រែ ខ្នើយ របស់ព្រះភិក្ខុសង្ឃប៉ុណ្ណោះទេ សូម្បីផ្ទះសម្បែង ខ្ទម លំហរ កៅអី ពូកគ្រែ...ជាទីនៅ ទីដេក ទីអង្គុយ របស់គ្រហស្ថ ក៏រាប់ចូលក្នុងសេនាសនប្បច្ច័យដែរ ។

ទាំងមនុស្សទាំងសត្វ ដែលកើតមកក្នុងលោកនេះ តែងតែអាស្រ័យដោយសេនាសនប្បច្ច័យជាទីដេកពួន ជ្រកកោន ដូចគ្នា គ្មានជនណាម្នាក់អាចចៀសរួចបាន ។ បើគ្មានសេនាសនប្បច្ច័យជាទីអាស្រ័យទេ មនុស្ស និង សត្វមិនអាចរស់នៅសុខស្រួលបានឡើយ ។ សូម្បីសត្វរស់នៅក្នុងទឹកក្តី លើគោកក្តី សត្វមានជើងក្តី ឥតជើងក្តី ក៏ត្រូវមានទឹក ដី សំបុក រូង រន្ធ ជាទីសេនាសនៈស្នាក់អាស្រ័យតាមស្ថានភាពរបស់ខ្លួនដែរ ទើបអាចរស់នៅបានសុខ ។

អាស្រ័យហេតុនេះហើយ បានជាទាយកទាយិកា បានឱ្យសេនាសនប្បច្ច័យមានផ្ទះ ពូក គ្រែ កន្ទេល ភួយខ្នើយ ដល់មាតាបិតា ដោយបូជាគុណលោក ឱ្យដល់គ្រហស្ថ អ្នកកំសត់ទុគ៌តដោយសង្គ្រោះ និង ដល់បព្វជិតអ្នកមានសីលបរិសុទ្ធ ដោយបូជា

*គុណធម៌របស់លោក ។ បដិគ្គាហកៈអ្នកទទួលនូវទានបានជាទីជ្រកកោននៅយ៉ាងសុខស្រួល ក្នុងបច្ចុប្បន្នកាល ហើយទាយកម្ចាស់ទាននឹងបានជាអ្នកមានទ្រព្យធន មានផ្ទះសម្បែង ប្រាសាទវិមាន រស់នៅជាសុខក្សេមក្សាន្តក្នុងអនាគតកាល ។*

*ក្នុង* **គម្ពីរសំយុត្តនិកាយ** *ត្រង់* **ទេវតាសំយុត្ត** *សំដែងថា កាលព្រះដ៏មានបុណ្យគង់ព្រះជន្មនៅឡើយ មានទេវតាចូលទូលសួរថា៖ "***យោ ទទាតិ ឧបស្សយំ***" ប្រែថា បពិតព្រះអង្គដ៏ចំរើន ! ឱ្យរបស់អ្វី ទើបបានឈ្មោះថាឱ្យគ្រប់មុខ ? " ។*

*ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា៖ "***សោ ច សព្វទទោ ហោតិ យោ ទទតិ ឧបស្សយំ*** "ប្រែថា "អ្នកណាបានឱ្យទីលំនៅជាទាន អ្នកនោះបានឈ្មោះថាបានឱ្យរបស់គ្រប់មុខ " ។*

*ក្នុងគម្ពីរសំយុត្តនិកាយដូចគ្នានេះ ចែងថាមានទេវតាចូលទៅក្រាបទូលសួរព្រះលោកនាថថា៖ "***យេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ***" ប្រែថា "បពិត្រព្រះអង្គដ៏ចំរើន ! បុណ្យតែងចំរើនទាំងយប់ទាំងថ្ងៃសព្វកាលទាំងពួងដល់ពួកជនណា ? "*

ព្រះសម្ពុទ្ធទ្រង់សំដែងថា៖

**"អារាមរោបា វនរោបា យេ ជនា សេតុការកា**

**បបញ្ច ឧទកបានញ្ច យេ ទទន្តិ ឧបស្សយំ**

**តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ**” ។

*ប្រែថា “ម្នាលទេវតា ! ជនទាំងឡាយណា បានដាំសួនឈើផ្កា ដាំសួនឈើមានស្លឹកជាម្លប់ សង់ស្ពាន សង់រោងដាក់ទានទឹក សាងអណ្តូងទឹក និង សាងទីលំនៅជាទាន បុណ្យរបស់ជនទាំងអម្បាលនោះ តែងតែចំរើនទាំងយប់ទាំងថ្ងៃ សព្វកាលទាំងពួង ។ម្យ៉ាងទៀតផលបុណ្យនានា ដែលពួកជនទាំងឡាយបានធ្វើហើយរមែងរង់ចាំទទួលពួកជនដែលធ្វើបុណ្យនោះ ក្នុងលោកខាងនាយដូចញាតិមិត្តដែលស្រឡាញ់គ្នា ហើយទន្ទឹងរង់ចាំទទួលគ្នាយ៉ាងដូច្នោះឯង ”។*

## អានិសង្សនៃគិលានភេសជ្ជទាន

*ថ្នាំសម្រាប់ព្យាបាលរោគគ្រប់ជំពូក ក្នុងភាសាបាលី ហៅថា* **គិលានភេសជ្ជៈ** *ដែលក្នុងបច្ច័យ ៤ ហៅថា គិលានភេសជ្ជ-ប្បច្ច័យ គឺជាឱសថសម្រាប់ព្យាបាលជម្ងឺបានទាំងគ្រហស្ថ ទាំងបព្វជិត និង ទាំងសត្វទូទៅ ។*

*មនុស្សសត្វក្នុងលោក តែងតែមានជម្ងឺជម្កាត់គ្រប់ៗរូបគ្រាន់តែតិច និង ច្រើន ហើយត្រូវការថ្នាំកែរោគជាចាំបាច់ ទើបជម្ងឺនោះ បានជាសះស្បើយឡើងវិញ ។*

*ទាយកទាយិកា មានសទ្ធាជ្រះថ្លាបានឱ្យ ឬ បានប្រគេន*

ភេសជ្ជៈថ្នាំពេទ្យគ្រប់យ៉ាងដល់គ្រហស្ថ និង ព្រះសង្ឃ ដែលមាន ជម្ងឺ ឬ អាពាធ ហៅថា បានធ្វើគិលានភេសជ្ជទាន ។

អាស្រ័យហេតុនេះហើយ បានជាទាយកទាយិកាបានឱ្យ គិលានភេសជ្ជប្បច្ច័យ មានថ្នាំសង្កូវដល់មាតាបិតាឈឺ ចាស់ ជរា ដោយបូជាគុណលោក ឱ្យដល់គ្រហស្ថអ្នកមានជម្ងឺដោយសង្គ្រោះ និង ប្រគេនចំពោះបព្វជិតអាពាធ ដោយគុណធម៌របស់លោក ។ បដិគ្គាហកៈអ្នកទទួលបានជាសះស្បើយពីជម្ងឺ ជម្ងាត់ ឬ អាពាធ ក្នុងបច្ចុប្បន្នកាល ។ ហើយទាយកអ្នកឱ្យនឹងបានជាមនុស្សគ្មាន រោគាព្យាធិ មានសុខភាពល្អទាំងផ្លូវកាយទាំងផ្លូវចិត្តក្នុងអនាគត ។

សរុបសេចក្ដីមក ទាយកជាអ្នកឱ្យនូវបច្ច័យ ៤ គឺ **ចីវរ**, **បិណ្ឌបាត**, **សេនាសនៈ** និង **គិលានភេសជ្ជៈ** ដល់បដិគ្គាហកៈ អ្នកដែលគួរទទួលឈ្មោះថាជាអ្នកឱ្យឋានៈ៥ យ៉ាង ដល់បដិគ្គាហៈ ក្នុងពេលដែលគេទទួលនាបច្ចុប្បន្ននេះ ។ ហើយឋានៈទាំង៥ យ៉ាង នោះនឹងផ្ដល់ឱ្យទាយកនោះវិញក្នុងអនាគតកាល ។

**ឋានៈ ឬ អានិសង្សសាធារណៈ៥ យ៉ាងនោះ គឺ ៖**

១- **អាយុៈ** ការមានអាយុរស់នៅយឺនយូរ ,

២- **វណ្ណៈ** ការមានពណ៌សម្បុរស្បែកល្អគួរឱ្យគយគន់ ,

៣- **សុខៈ** ការមានសេចក្ដីសុខកាយសប្បាយចិត្ត ,

៨- **ពលៈ** *ការមានកម្លាំងកាយ កម្លាំងចិត្ត ,*

៩- **បដិភាណៈ** *ការមានប្រាជ្ញាឆ្លៀវឆ្លាសវាងវៃ ។*

*គួរសង្កេតថាមនុស្សក្នុងសង្គមសព្វថ្ងៃនេះ សូម្បីបានស្តាប់បានយល់ដឹងថា អានិសង្សនៃទានមានសារប្រយោជន៍ សម្រាប់ជីវិតក្នុងបច្ចុប្បន្ន និង បរលោកក៏ដោយ ក៏មិនសូវហ៊ានបរិច្ចាគទ្រព្យសម្បត្តិ ឱ្យជាទានដោយសទ្ធាជ្រះថ្លាដែរ ព្រោះគេកំពុងតែស្រវឹងវ័យ ស្រវឹងទ្រព្យ ស្រវឹងមច្ឆរិយៈ សមដូចពុទ្ធភាសិតថា ៖*

**"មច្ឆេរា ច បមាទា ច ឯវំ ទានំ ន ទយ្យតិ**

**បុញ្ញំ អាកង្ខមានេន ទេយ្យំ ហោតិ វិជានតា"** ។

*ប្រែថា បុគ្គលឱ្យទានមិនបាន ព្រោះហេតុ២យ៉ាង គឺដោយសេចក្តីកំណាញ់១, ដោយសេចក្តីប្រមាទ១, អ្នកមានសេចក្តីចេះដឹងត្រូវការដោយបុណ្យកុសលគួរឱ្យទាន(តាមកម្លាំងរបស់ខ្លួន) ។*

*អធិប្បាយថា របស់ដែលធ្វើមិនឱ្យមនុស្សធ្វើទានកើតមាន ២យ៉ាងគឺ សេចក្តីកំណាញ់ និង សេចក្តីធ្វេសប្រហែសទាំងពីរនេះ បើមិនយ៉ាងណាមួយ ក៏យ៉ាងណាមួយ មិនមែនជាសេចក្តីទ័លក្រឬហេតុដទៃឡើយ ព្រោះបើមិនកំណាញ់មិនស្តាយ ឬ មិនស្រវឹងក្នុងវ័យក្មេង មិនទាន់ចាស់ មិនមានជម្ងឺ ទោះជាយ៉ាងណាក៏ឱ្យទានតាមក្រ ។ ជនដែលជាអ្នកត្រូវការបុណ្យគួរនាំគ្នាធ្វើទាន ៕*

# ទានវិចារណកថា

**ទានវិចារណកថា** *ប្រែថា ការពិចារណាអំពីទាន ឬ ការដោះស្រាយបញ្ហាទានដោយវិចារណញ្ញាណ ។ តាមរយៈការពន្យល់អំពីទានត្រង់ៗ ជាច្រើនវគ្គរួចហើយ មានបញ្ហាកើតឡើងអំពីបាដិបុគ្គលិកទាន និង សង្ឃទាន ដែលសព្វថ្ងៃនេះប្រជាជនយើងនិមយនាំគ្នាធ្វើញឹកញាប់ជាងគេ ។*

*បញ្ហានោះចោទឡើងថា ក្នុងការបរិច្ចាគទាន តើទាយកអ្នកធ្វើទានត្រូវជ្រើសរើសទេយ្យវត្ថុឬទេ ? ត្រូវជ្រើសរើសឋានៈនៃទានឬទេ ?ឆ្លើយថា ទេយ្យវត្ថុត្រូវតែជ្រើសរើស ក្នុងការជ្រើសរើសនោះបុរាណាចារ្យ បានបង្គាប់ថា ត្រូវតែយករបស់ណា ដែលកើតឡើងចាកអាជីវកម្មប្រកបដោយធម៌ ។ លោកបង្គាប់ ឬណែនាំយ៉ាងនេះព្រោះលោកមិនចង់ឱ្យមនុស្សជិះជាន់មនុស្ស ដោយរឿងទានគឺការសង្កត់សង្កិនយកទ្រព្យពីជនពួកមួយ ទៅសង្គ្រោះដល់ជនពួកមួយ ឬបោកប្រាសស៊ីឡឹបលើអំពីជនដទៃយកមកធ្វើទាន ព្រោះទានជាកុសលធម៌ ទ្រព្យសម្បត្តិដែលយកមកធ្វើទាន ក៏ត្រូវបានមកដោយកុសលាជីវកម្ម ( អាជីវកម្មត្រឹមត្រូវ ) ដែរ ។*

*ឋានៈនៃទានក៏ត្រូវជ្រើសរើស ក្នុងការជ្រើសរើស លោកពោលណែនាំថា ក្នុងបណ្ដាលទានទាំងពីរ គឺ សង្ឃទាន និង បាដិ-*

បុគ្គលិកទាន ត្រូវធ្វើសង្ឃទានជាមុន បើធ្វើសង្ឃទានមិនកើត ត្រូវធ្វើបាដិបុគ្គលិកទាន ។

បញ្ហាមានចោទឡើងទៀតថា បុគ្គលដែលធ្វើនូវសង្ឃទាន ត្រូវជ្រើសរើសរូបភិក្ខុ សាមណេរឬទេ ? ឆ្លើយថាមិនត្រូវជ្រើសរើសទេ កាលណាជ្រើសរើស សង្ឃទាននោះ នឹងធ្លាក់ទៅជាបាដិបុគ្គលិកទាន ដោយស្វ័យប្រវត្តិ ។

បញ្ហាមានចោទឡើងទៀតថា បើមិនជ្រើសរើសចុះប្រសិនបើភិក្ខុទាំង ៤ អង្គ ឬច្រើនជាងនេះ ឬ ភិក្ខុមួយអង្គដែលសង្ឃចាត់ទៅក្នុងនាមរបស់សង្ឃនោះជាភិក្ខុទ្រុស្តសីល តើកើតជាសង្ឃទានឬទេ ? ឆ្លើយថាប្រាកដជាកើតជាសង្ឃទាន ប្រសិនទាយកមិនដឹងថាលោកទ្រុស្តសីល ឬ ដឹងដែរ ប៉ុន្តែមិនខ្វីរវល់ អំពីរឿងលោកគិតតែអំពីរឿងព្រះសង្ឃ អំពីរឿងចាត់ចែងទេយ្យទាន អំពីរឿងប្រណិប័តន៍ព្រះសង្ឃឱ្យបានជិតដល់ ។

សង្ឃទានលោកសំដៅយកការគោរពជាធំ។ លោកពុំបានសំដៅយកចិត្តសោមនស្សអរសប្បាយ ចំពោះបដិគ្គាហកៈអ្នកមានសីលធម៌ មានវស្សាច្រើន ជាធម្មាចារ្យបង្រៀនកម្មដ្ឋាន និងវិបស្សនា ឬជាធម្មកថិកាចារ្យ ។ ល ។ ផ្ទុយទៅទៅវិញ ប្រសិនបើទាយកសប្បាយចិត្ត ព្រោះបានព្រះមហាថេរព្រះធម្មកថិក ។ល ។

សង្ឃទានរបស់គេ  ក៏ធ្លាក់ចុះទៅជាបាដិបុគ្គលិកទានដោយស្វ័យប្រវត្តិ ព្រោះហេតុថាសង្ឃទាន ជាទានរបស់សប្បុរស ឬ ជាទានរបស់អ្នកប្រាជ្ញដែលលោកបានឆ្លងកាត់ការអប់រំជាន់ខ្ពស់ គឺលោកបានឆ្លងចាកសោមនស្សសហគតចិត្ត ទៅដល់ឧបេក្ខាសហគតចិត្តដែលជាចិត្តសម្រាប់ប្រើក្នុងកិច្ចការបំពេញកុសលជាន់ខ្ពស់ ។

ដូច្នេះដើម្បីធ្វើទានរបស់យើង ឱ្យមានគុណភាពខ្ពស់ឡើងតាមលំដាប់នោះ មុនដំបូងយើងត្រូវរៀនធ្វើទានដោយពឹងផ្អែកលើសោមនស្សសហគតចិត្ត ហើយខំប្រឹងព្យាយាមលះបង់សោមនស្សសហគតចិត្ត អប់រំខ្លួនឱ្យមានឧបេក្ខាសហគតចិត្ត ព្រោះសោមនស្សសហគតចិត្ត ជាចិត្តនៅមានសេចក្តីគ្រោតគ្រាត នៅមានគុណភាពទន់ខ្សោយជាងឧបេក្ខាសហគតចិត្ត ។

គួរចងចាំថា សោមនស្សសហគតចិត្ត មិនមែនជាចិត្តកើតឡើងដោយការអប់រំទេ គឺជាចិត្តកើតពីធម្មជាតិ ។ ចំណែកឧបេក្ខាសហគតចិត្ត ជាចិត្តកើតអំពីការអប់រំដោយចំរើនសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋានជាដើម ។ សោមនស្សសហគតចិត្ត ជាចិត្តដែលញុំាងទាយកឱ្យធ្វើទានបានត្រឹមតែបាដិបុគ្គលិកទាន ។ ចំណែកឯឧបេក្ខាសហគតចិត្ត ជាចិត្តដែលញុំាងទាយកឱ្យធ្វើទាន បានទាំងបាដិបុគ្គលិកទានផង បានទាំងសង្ឃទានផង ។

**អាមិសទាន & ធម្មទាន**

យើងដឹងច្បាស់ថា សង្ឃទានមានផលានិសង្សច្រើនជាង បាដិបុគ្គលិកទាន ។ យើងមានតួយ៉ាង បញ្ជាក់ថា កាលព្រះនាង បជាបតិគោតមី ជាមាតាចិញ្ចឹមរបស់ព្រះសិទ្ធត្ថ បានថ្វាយសំពត់ សាដកដែលព្រះនាងខំត្បាញយ៉ាងសំរិតសម្រាំងដោយព្រះហស្ត របស់ព្រះនាងផ្ទាល់ចំពោះព្រះបរមសាស្តា តែទ្រង់ពុំបានទទួល ទេ ទ្រង់បានបង្វែរឱ្យព្រះនាងថ្វាយចំពោះសង្ឃសាវ័ករបស់ព្រះ អង្គវិញ ។ ទង្វើនេះ គឺ ព្រះអង្គទ្រង់ឈ្វេងយល់ថា អានិសង្សនៃ សង្ឃទានបានផលច្រើនជាងបាដិបុគ្គលិកទាន សូម្បីថាព្រះនាង បជាបតិគោតមីថ្វាយចំពោះព្រះពុទ្ធអង្គក៏ដោយ ព្រោះការថ្វាយ នេះចំពោះតែបុគ្គល គឺ ចំពោះព្រះអង្គតែប៉ុណ្ណោះ ។ ត្រង់នេះស បញ្ជាក់ច្បាស់ថា ព្រះពុទ្ធទ្រង់បានបង្រៀនព្រះមាតាចិញ្ចឹមឱ្យចេះ ធ្វើសង្ឃទាន ព្រោះសង្ឃទាននេះបុគ្គលធ្វើបានដោយកម្រ ។

ការលំបាកក្នុងការធ្វើសង្ឃទាន មិនគឺអ្វីក្រៅពីការរៀបចំ ចិត្តពីសោមនស្សសហគតចិត្ត ឱ្យទៅជាឧបេក្ខាសហគតចិត្តទេ ។ ព្រះវេស្សន្តរ កាលទ្រង់ដាក់ទានព្រះរាជបុត្រទាំងពីរឱ្យព្រាហ្មណ៍ ចាស់ ព្រះអង្គទ្រង់ដកចិត្តសោមនស្សក្នុងបុត្រ ដកចិត្តទោមនស្ស ក្នុងព្រាហ្មណ៍ ហើយទ្រង់ដម្កល់ចិត្តក្នុងឧបេក្ខាញាណ ទើបព្រះ អង្គញ៉ាំងទាននេះឱ្យប្រព្រឹត្តទៅបាន ។

បញ្ហាមានចោទទៀតថា អ្នកដែលធ្វើបាដិបុគ្គលិកទានតើត្រូវជ្រើសរើសបដិគ្គាហកៈឬទេ ? ឆ្លើយថា ត្រូវជ្រើសរើស ព្រោះទាននេះ ត្រូវបានផលានិសង្សច្រើនអំពីការជ្រើសរើសបដិគ្គាហកៈ មិនមែនដូចសង្ឃទានទាំង ៧ ( បដិគ្គាហកៈ ក្នុងសង្ឃទាន ) ដែលមានផលស្មើៗគ្នានោះទេ ។

ថ្វាយទានព្រះសម្មាសម្ពុទ្ធ បានផលច្រើនជាងព្រះបច្ចេកពុទ្ធ ។ ថ្វាយទានព្រះបច្ចេកពុទ្ធ បានផលច្រើនជាង ព្រះអរហត្តផលបុគ្គល ។ ថ្វាយទានព្រះអរហត្តផលបុគ្គល បានផលច្រើនជាងព្រះអរហត្តមគ្គបុគ្គល ។ ថ្វាយទានព្រះអនាគាមីបុគ្គល បានផលច្រើនជាងព្រះសកទាគាមីបុគ្គល ។ ថ្វាយទានដល់ព្រះសកទាគាមីបុគ្គល មានផលច្រើនជាងសោតាបន្នបុគ្គល ។ ប្រគេនទានភិក្ខុសង្ឃមានសីល មានផលច្រើនជាងភិក្ខុទ្រុស្តសីល ។ ប្រគេនទានភិក្ខុសង្ឃទ្រុស្តសីល មានផលជាងបុថុជ្ជនមានសីល ។ ឱ្យទានដល់បុថុជ្ជនមានសីល មានផលជាងបុថុជ្ជនទ្រុស្តសីល ។ ឱ្យទានដល់បុថុជ្ជនទ្រុស្តសីលបានផលជាងសត្វតិរច្ឆាន ។ ឱ្យទានដល់សត្វតិរច្ឆានមានផលតិចបំផុត ។

បាដិបុគ្គលិកទាន ប្រសិនបើបុគ្គលធ្វើឡើងដោយអាស្រ័យឧបេក្ខាសហគតចិត្ត គឺ អ្នកឱ្យមានឧត្តមគតិថា ជាមនុស្សត្រូវតែ

ជួយរំដោះទុក្ខព្រួយរបស់មនុស្សដូចគ្នា។ អ្នកឱ្យមានវត្ថុបំណងថា ជាមនុស្សត្រូវចេះជួយធ្វើមនុស្ស ឱ្យបានទទួលសេចក្តីសុខចំរើន។ បុគ្គលមានឧត្តមគតិ និង វត្ថុបំណងយ៉ាងនេះ ពេលត្រូវការធ្វើទានម្តងៗ គេតែងតែជ្រើសរើសរកបុគ្គល ដែលគួរដល់ទេយ្យទានរបស់គេ ដូចជាបុគ្គលមានសេចក្តីទុក្ខព្រួយដោយឧទកភ័យ អគ្គីភ័យ ចោរភ័យ ទុព្ភិក្ខភ័យ ព្យាធិភ័យ......បុគ្គលដែលកំពុងមានសេចក្តីខ្វះខាតក្នុងការបំពេញបេសកកម្ម មានការរៀនសូត្រ ការផ្សព្វផ្សាយសាសនា ការផ្សព្វផ្សាយសីលធម៌សង្គមជាដើម ។ បើបុគ្គលបែបនេះមានច្រើន គេគួរតែជ្រើសរើសរកបុគ្គលណាដែលមានគុណូបការៈច្រើនលើខ្លួនរបស់គេ ។ ដូចជាមាតាបិតា គ្រូបាអាចារ្យជាដើម ពុំនោះសោតទេ គេគួរជ្រើសរើសរកបុគ្គល ដែលមានគុណូបការៈច្រើនលើសង្គមមនុស្ស ។ បើបុគ្គលពួកនេះមានច្រើន គេជ្រើសរើសរកបុគ្គលដែលមានគុណធម៌ខ្ពស់ជាងគេ ។

អ្នកមានវត្ថុបំណងល្អ ដែលមានចិត្តជាឧបេក្ខាសហគតជាញាណសម្បយុត្ត គេមិនមែនធ្វើទានដើម្បីសេចក្តីសប្បាយទេ គឺគេធ្វើទានដើម្បីសេចក្តីចំរើន ដើម្បីមនុស្សធម៌ និង ដើម្បីសន្តិភាពនៃសង្គមមនុស្ស ។ បុគ្គលដដែលនេះ ពួកគេមិនចូលចិត្តឱ្យទានដល់មនុស្ស មានរបស់សម្បូរណ៌ស៊ីមិនអស់សល់ទុកសល់ដាក់ ។

គេចូលចិត្តតែធ្វើទានដល់មនុស្សណា ដែលមានសេចក្តីខ្វះខាត ដែលកំពុងត្រូវការរបស់អ្វីមួយជាការចាំបាច់ ។ អ្នកដែលមានចិត្តសប្បុរសប្រកបដោយឧបេក្ខាញាណគេមិនកាន់នូវអំណោយរបស់គេដើរ រំលង ឬ ដើរកាត់មុខមនុស្សអត់ឃ្លាន យកទៅឱ្យអ្នកមានស៊ី មានចាយមិនអស់នោះទេ ។

បាដិបុគ្គលិកទាន ដែលជ្រើសរើសហើយឱ្យ ជាទានមានផលមិនចាញ់សង្ឃទានប៉ុន្មានទេ ប្រសិនបើអ្នកធ្វើទាននេះបានធ្វើប្រកបដោយសម្បទាទាំ ៤ គឺ **ចេតនាសម្បទា**, **បច្ច័យសម្បទា**, **វត្ថុសម្បទា**, **គុណាតិរេកសម្បទា** ។

១- **ចេតនាសម្បទា** គឺមានចេតនាល្អគ្រប់ទាំង បី កាល ហៅថា បុព្វចេតនា កាលមុនឱ្យ, មុញ្ចនចេតនា កាលកំពុងឱ្យ និង អបរាបរចេតនា កាលដែលបានឱ្យរួចហើយ,

២- **បច្ច័យសម្បទា** គឺមានទេយ្យទាន ប្រកបដោយធម៌ ពោលគឺ បច្ច័យទាំងឡាយ ៤ ដែលជាទីពឹងពាក់ពំនាក់អាស្រ័យប្រើប្រាស់របស់បុគ្គលគ្រប់រូបក្នុងលោក,

៣- **វត្ថុសម្បទា** គឺមានបដិគ្គាហកៈជាព្រះអរហន្ត ឬយ៉ាងទាបណាស់ត្រឹមអានាគាមី ,

៤- **គុណាតិរេកសម្បទា** គឺបដិគ្គាហកៈមានសីលាទិគុណ

វិសេសក្រៃលែងដែលទើបចេញចាកនិរោធសមាបត្តិ ។

ទាននេះមានកម្លាំងច្រើន អាចផ្តល់ផលដល់អ្នកធ្វើក្នុងបច្ចុប្បន្នកាលនេះ រហូតដល់អនាគតកាលគ្មានទីបំផុតឡើយ ។

ដើម្បីឱ្យបានផលានិសង្សច្រើន អ្នកធ្វើបាដិបុគ្គលិកទានចាំបាច់ត្រូវជ្រើសរើសបដិគ្គាហកៈ ។ ប៉ុន្តែសូមចាំថា ការជ្រើសរើសមិនមែនមានន័យថា ត្រូវលះបង់មនុស្សទ្រុស្តសីល យកតែបុគ្គលមានសីលទេ គឺ ត្រូវជ្រើសរើសទៅតាមកាលៈទេសៈ បើមនុស្សទាំងពីរ គឺអ្នកទ្រុស្តសីល និង អ្នកមានសីលនៅជិតគ្នា ។

គួរគិតថា អ្នកទ្រុស្តសីលគ្មានអត់បាយជិតនឹងស្លាប់ហើយ តែអ្នកមានសីល មិនទាន់អត់អាហារដាច់ពេលនោះទេ ។ យើងត្រូវយកច្បាប់មនុស្សធម៌ ឬ អភ័យទានលក្ខណៈមកកាត់សេចក្តី គឺតាមច្បាប់មនុស្សធម៌ ឬ អភយ័ទានលក្ខណៈ យើងត្រូវឱ្យបាយទៅអ្នកទ្រុស្តសីល ទើបចាត់ថាជាមនុស្សមានចិត្តសប្បុរស សមជាពុទ្ធសាសនិកមានឧត្តមគតិខ្ពង់ខ្ពស់ ។

ម្យ៉ាងវិញទៀត ពុទ្ធបរិស័ទដែលមានចិត្តភក្តី គោរពបូជាចំពោះព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និង ព្រះមហាករុណាទិគុណនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ គួរនាំគ្នាខិតខំរៀនផ្សាយព្រហ្មវិហារធម៌ ( មេត្តា ករុណា មុទិតា និង ឧបេក្ខា ) ឱ្យបានទូលំ

*ទូលាយដល់សព្វសត្វក្នុងលោក ។*

*ព្រះពុទ្ធសាសនា ជាមាគ៌ានៃជីវិត និង ជាចរិយាសាស្ត្រ សម្រាប់ជីវិត មានគោលបំណងធំតែមួយគត់ គឺ សេចក្តីសុខសន្តិភាពនៃពិភពលោក ។ ព្រះអង្គទ្រង់សំដែងថា ៖*

**អព្យាបជ្ឈំ សុខំ លោកេ**

*ការមិនបៀតបៀនគ្នាជាសុខក្នុងលោក ។*

**នត្ថិ សន្តិ បរំ សុខំ**

*សុខដទៃក្រៅពីសេចក្តីស្ងប់មិនមានឡើយ ។*

*អង្គការសហប្រជាជាតិ យល់តម្លៃព្រះពុទ្ធសាសនាដែលមានពាក្យប្រៀនប្រដៅដ៏មានខ្លឹមសារ គឺធម៌អហឹង្សា ការមិនបៀតបៀនគ្នា ដែលជាមូលដ្ឋាននៃសុខសន្តិភាពរបស់មនុស្សក្នុងពិភពលោក ក៏បានសម្រេចអនុម័តឱ្យធ្វើបុណ្យពិសាខបូជារបស់ព្រះពុទ្ធសាសនានៅទីស្នាក់ការអង្គការសហប្រជាជាតិ តាំងពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៩៩ ( ព-ស ២៥៤៣ ) ។*

# ធ្វើទានបានក្រមួ ?

មនុស្សម្នាក់ៗក្នុងលោកនេះ មានទស្សនៈយល់ដឹងមិនដូចគ្នាទេ ។ ជនពួកមួយប្រើវិចារណញ្ញាណត្រិះរិះរកឃើញការពិតអំពីទាន ក៏មានសទ្ធាជឿផលានិសង្សរបស់ទានតាមពុទ្ធដីកា។ រីឯជនមួយពួកផ្សេងទៀត គេមិនមានជំនឿទេព្រោះគេយល់ថា ទានធ្វើទៅអស់ទ្រព្យ ឯផលរបស់ទានមានទ្រព្យនោះ ហេតុ និង ផលមិនស៊ីគ្នា ។ គេថែមទាំងឃោសនាឱ្យយោបល់ថា ការធ្វើទាន ជាទង្វើរបស់មនុស្សល្ងង់ មិនមែនជាទង្វើរបស់អ្នកមានបញ្ញា ព្រោះអ្នកធ្វើទានយល់ច្រឡំថា ទានមានផលបង្កើតជាទ្រព្យសម្បត្តិ ឱ្យម្ចាស់ទាន មិនព្រមយល់ថា ទានជាអំណោយជាចំហាយ ។ កាលណាធ្វើទាននឹងបានទទួលនូវការអស់ការក្រជាផល ។ ធ្វើតិចអស់តិច ធ្វើច្រើនអស់ច្រើន ។ បើក្នុងជាតិនេះអស់ ជាតិទៅមុខក៏អស់ដូចគ្នា ។ ពាក្យថាធ្វើទានមានទ្រព្យ ជាពាក្យរបស់អ្នកមានបញ្ញាគេរៀបចំដាក់ចូលក្នុងក្បួនបោកស៊ីរបស់គេតែប៉ុណ្ណោះ ។

ចំពោះពាក្យឃោសនាទាំងនេះ យើងត្រូវឆ្លើយតបតាមគតិបណ្ឌិតថា ការធ្វើទានមិនមែនឱ្យផលជាអស់ទេ គឺឱ្យផលជាមានច្រើនឡើងទៀត ប្រសិនបើអ្នកឱ្យមានបញ្ញាយល់ហេតុផលជ្រៅជ្រះ ព្រោះថាទានជាមូលធនដើម នៃសេចក្តីចំរើនខាងផ្លូវចិត្ត

ផង ខាងផ្លូវសម្ភារៈផង សម្រាប់មនុស្សជាតិ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

**ផលទានក្នុងលោកបច្ចុប្បន្ន** ទានបានធ្វើឱ្យពិភពលោកបច្ចុប្បន្នរីកចំរើននោះ យើងនឹងអាចមើលឃើញប្រត្យក្សគ្រប់ៗគ្នាហើយ សាលារៀនមានច្រើននាំឱ្យមនុស្សកើតគំនិតបញ្ញា មន្ទីរពេទ្យព្យាបាលរោគមានច្រើននាំឱ្យមនុស្សមានសុខភាពល្អ ផ្លូវថ្នល់ស្ពាន កំពង់ផែ ចំណត ប្រៃសណីយដ្ឋាន ផ្សារ មានច្រើននាំឱ្យសេដ្ឋកិច្ចរបស់ប្រទេសរីកដុះដាល វត្តអារាមមានច្រើននាំឱ្យសីលធម៌សង្គមមានការរីកចំរើន ។

កាលណាសង្គមបានទទួលសេចក្តីសុខចំរើន ឯកជនដែលរស់នៅក្នុងសង្គម ក៏បានទទួលសេចក្តីសុខចំរើនដែរ ។ នេះគឺជាលទ្ធផលនៃវិភាគទាន របស់មនុស្ស ដែលភ្នែកយើងបានឃើញច្បាស់ក្នុងជីវិតបច្ចុប្បន្ន ។ ដូច្នេះការធ្វើទានមិនមែនឱ្យផលជាអស់ទេ គឺផលជាសុខភាពល្អ ជាគំនិតប្រាជ្ញា ជាវិជ្ជាបច្ចេកទេសខ្ពង់ខ្ពស់ ដែលជាកត្តានាំឱ្យក្លាយទៅជាអារ្យជន ជាធនធានមនុស្សដែលសង្គមថ្លៃថ្នូរ ត្រូវការជាចាំបាច់ ។

**ផលទានក្នុងបរលោក** តាមទ្រឹស្តីពុទ្ធសាសនាអ្នកធ្វើទានអស់ទ្រព្យទៅមែន ក៏ប៉ុន្តែផលរបស់ទានជួយឱ្យទាយក អ្នកធ្វើ

មានចិត្តល្អ ។ កុសលចិត្តជាបច្ច័យឱ្យមានបដិសន្ធិចិត្តល្អទៅក្នុងភពថ្មី ។ លោកចែកបដិសន្ធិជា៤ គឺ **អបាយបដិសន្ធិ, កាមាវចរបដិសន្ធិ, រូបាវចរបដិសន្ធិ** និង **អរូបាវចរបដិសន្ធិ** ។ អ្នកមានចិត្តល្អមិនដែលទៅចាប់បដិសន្ធិក្នុងអបាយភូមិទេ បើអន់ណាស់ក៏គង់ទៅបដិសន្ធិក្នុងកាមសុគតិភព គឺថាបើកើតក្នុងឋានមនុស្សរមែងកើតក្នុងត្រកូលខ្ពង់ខ្ពស់ ឬ ត្រកូលមានទ្រព្យសម្បត្តិដែរ ។

ការដោះស្រាយខាងលើនេះ បានពឹងផ្អែកទៅលើបរមត្ថធម៌ដែលស្ដីអំពីចិត្តទាំងស្រុង ។ ដើម្បីឱ្យកាន់តែយល់អំពីបដិសន្ធិនេះខ្ញុំសូមពន្យល់ត្រួសៗអំពីបដិសន្ធិ ។ បើយើងនិយាយពីភពក្នុងជាតិបច្ចុប្បន្ន ចាប់តាំងពីតូចមកយើងធ្វើបាប ( អកុសលកម្ម ) ខ្លះធ្វើបុណ្យ ( កុសលកម្ម ) ខ្លះជាធម្មតា ។ បាបបុណ្យនេះបង្កើតជាផលរួមគ្នាច្រើនទៅលោកហៅថា វិបាក ឬវិបាកវិញ្ញាណ ។ វិបាកវិញ្ញាណហ្នឹងឯងជាតួបដិសន្ធិរបស់សត្វ ប៉ុន្តែមិនមែនជាតួវិញ្ញាណទេ គឺគ្រាន់តែជាកម្លាំង ដែលអាចជួយរុញច្រានទៅភពមួយទៀតតែប៉ុណ្ណោះ។ ពាក្យថា បដិសន្ធិមានពីរបទគឺបដិ + សន្ធិ បដិ ប្រែថា ឆ្ពោះទៅ ឬ ចំពោះទៅ សន្ធិ ប្រែថា ត ឬ តំណ, ដូច្នេះពាក្យបដិសន្ធិ ប្រែថា ការតជាតិតភពទៅមុខទៀត ។

ចិត្តជាន់ក្រោយបំផុតនៃជីវិត ឈ្មោះថាចុតិចិត្ត ក្នុងពេល

នោះ ក្រសែជីវិតនៅពុំទាន់សាបសូន្យទេ អំណាចកម្ម ( កុសលាកុសលកម្ម ) នឹងរុញច្រានឱ្យអិលឃ្លាតចាកចិត្តនៃភពចាស់ឱ្យទៅចាប់ភពថ្មី ដោយអំណាចបដិសន្ធិចិត្ត ដែលជាចិត្តភ្ជាប់ពីអតីតទៅបច្ចុប្បន្នជាប្រភពនៃជីវិតថ្មី ។

មនុស្សយើងកើតមកមិនដូចគ្នាទេ អ្នកខ្លះមាន អ្នកខ្លះក្រ អ្នកខ្លះកើតក្នុងវិមានប្រាសាទ អ្នកខ្លះកើតក្នុងផ្ទះឈើ ឬខ្ទមស្បូវ ។ សូម្បីតែកើតក្នុងប្រាសាទដូចគ្នា រូបរាងក៏មិនដូចគ្នា ចិត្តថ្លើមចរិយាមារយាទក៏មិនដូចគ្នាទៀត តើអ្នកណាធ្វើឱ្យសត្វលោកខុសប្លែកគ្នាយ៉ាងនេះ? ។ ព្រះពុទ្ធបានត្រាស់ដឹងរឿងអាថ៌កំបាំងនេះ ទ្រង់មានព្រះបន្ទូលថា "**កម្មំ សត្តេ វិភជតិ យទិទំ ហីណប្បណីតតាយ** កម្មរមែងបែងចែកសត្វទាំងឡាយ ឱ្យថោកទាប និង ថ្លៃថ្លា" ។

ដូច្នេះយើងអាចឆ្លើយបញ្ហាបរលោកបានថា បដិសន្ធិចិត្តទាំងឡាយនៃអ្នកធ្វើទានក្នុងបច្ចុប្បន្ននេះ នឹងរមែងឱ្យមានជីវិតថ្មីក្នុងត្រកូលស្តុកស្តម្ភ ក្នុងប្រទេសដែលមានសេចក្តីរុងរឿង ក្នុងភពខ្ពង់ខ្ពស់ដោយគ្មានអ្វីអាចហាមឃាត់បាន ។ បើអ្នកបានធ្វើបុណ្យទានបានយោនយកកំណើតក្នុងត្រកូលខ្ពស់ ប្រទេសចំរើន ភពខ្ពង់ខ្ពស់ តើយើងនឹងហាមឃាត់បុគ្គលនេះ មិនឱ្យមានទ្រព្យសម្បត្តិដូចម្តេចទៅ ! ។ នេះហើយគឺជាការធ្វើទានឱ្យផលក្នុងបរលោក ។

**អាមិសទាន & ធម្មទាន**

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **ពាលា ហវេ នប្បសំសន្តិ ទានំ** បុគ្គលពាលទាំងឡាយមិនសរសើរទានឡើយ។ ធម្មតាមនុស្សពាល មិនដែលសរសើរទាន គឺអំណោយជារបស់ ដល់សប្បុរសជនណាម្នាក់ឡើយ ព្រោះជនជំពូកនេះ ជាអ្នកល្ងង់ខ្លៅ អប្បឥតប្រាជ្ញា គ្មានការពិចារណាឱ្យបានវែងឆ្ងាយថា ទានដែលគេធ្វើហើយ រមែងមានប្រយោជន៍នោះទេ ។ ផ្ទុយទៅវិញបុគ្គលពាលតែងតែយល់ថា អ្នកធ្វើទានជាមនុស្សឥតបេះគិត ពិចារណាចំពោះហេតុផលផ្សេងៗសោះ ចាយវាយទ្រព្យរបស់ខ្លួន ឱ្យអ្នកដទៃទទេៗ គ្មានបានអ្វីមកវិញសោះ ។

ម្យ៉ាងវិញទៀត ជនពាលតែងស្អប់បណ្ឌិត ព្រោះបណ្ឌិតមិនដែលពោលសរសើរចំពោះមនុស្សពាល ដែលមានជីវិតរស់នៅ ខ្វះសតិ ខ្វះវិចារណញ្ញាណ សាបព្រោះតែអំពើអកុសល ។ ជនពាល ជាមនុស្សខ្វះសតិ ខ្វះការហាត់ពត់លត់ដំចិត្ត បណ្ដោយឱ្យចិត្តដឹក តាមទំនើង ។ រីឯបណ្ឌិត ជាបុគ្គលដែលទូន្មានចិត្តខ្លួនឯងបានដោយខន្តី ដែលអ្នកដទៃលំបាកនឹងធ្វើបាន ហើយប្រកបដោយធម៌ ៤ យ៉ាងហៅថា បណ្ឌិតធម៌ គឺ ៖

១- **អត្តសុទ្ធិ** បរិសុទ្ធចំពោះខ្លួនឯង ,

២- **បរបរិសុទ្ធិ** បរិសុទ្ធចំពោះអ្នកដទៃ ,

៣- **សង្គហៈ** ជួយសង្គ្រោះអ្នកដទៃ ,

៤- **កតញ្ញូ** ដឹងគុណឧបការជន ។

ដូច្នេះយើងគប្បីសេពគប់បណ្ឌិត ព្រោះបណ្ឌិតជាសប្បុរសជនដែលបានអប់រំបន្ទុំចរិយាបានដោយប្រពៃ ហើយលែលកធ្វើទានដោយឧបេក្ខាសហគតចិត្ត ។ ក៏ប៉ុន្តែគួរជ្រាបផងដែរថា ការអប់រំទូន្មានខ្លួនត្រាប់តាមបណ្ឌិត ជាការលំបាកនឹងធ្វើបាន សមដូចពុទ្ធភាសិតពោលថា **អត្តា ហិ ករិ ទុទ្ទមោ** លោកថាខ្លួនហ្នឹងហើយ ដែលបុគ្គលទូន្មានបានដោយកម្រ ។

ស្រីហិតោបទេស ភាសាសំស្ក្រឹតនិយាយថា "ការគ្រាន់តែប្រដៅនរជនទាំងឡាយដទៃឱ្យគេបានជាបណ្ឌិត នរណាក៏ធ្វើបានងាយ តែការទូន្មានខ្លួនឯងឱ្យប្រព្រឹត្តទៅតាមគន្លងធម៌ជាការក្រ ធ្វើបានចំពោះតែមនុស្សមានមហាត្ម័ន" ។

ពាក្យថា មហាត្ម័ន ចែកជាពីរបទគឺ មហ: + អាត្ម័ន = មហាត្ម័ន ។ មហ: ប្រែថា ធំ, អាត្ម័ន ជាភាសាសំស្ក្រឹត ស្មើនឹងភាសាបាលីថា អត្ត ប្រែថា ខ្លួន ឬព្រលឹង ។ មនុស្សមានអាត្ម័ន គឺជាអ្នកមានវីរិយៈ ខន្តី មានជំហរខ្ពស់ មានចិត្តតស៊ូយកឈ្នះធម្មជាតិ មិនទន់ជ្រាយ បន្ថោកបន្ទាបអត្តភាពរបស់ខ្លួន មិនផ្សងព្រេង មិនពឹងពាក់ទេវតា ឥន្ទព្រហ្ម ជាអ្នកនិយមឈ្នះលើខ្លួនឯង ។

មនុស្សមានមហាត្ម័នមិនពឹងផ្អែកលើអតីតកម្ម (កម្មចាស់) ពឹងផ្អែកតែទៅលើបច្ចុប្បន្នកម្ម ( កម្មថ្មី ) របស់ខ្លួនគឺតស៊ូក្រាញនទៀល យកជោគជ័យក្នុងឆាកជីវិត ។

ព្រះពុទ្ធទ្រង់សំដែងក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយថា ៖

**"យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**

**ឯកញ្ច ជេយ្យមត្តានំ សវេ សង្គាមជុត្តមោ " ។**

ប្រែថា" សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សរាប់ពាន់នាក់ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ  ក៏មិនប្រសើរជាងការឈ្នះលើខ្លួនឯងតែម្នាក់ឡើយ  បុគ្គលអ្នកឈ្នះខ្លួនឯង  ឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត" ។

**អត្តា ហវេ ជិតំ សេយ្យោ**

ឈ្នះខ្លួនឯងប្រសើរជាងឈ្នះអ្វីៗទាំងអស់ ។

**តណ្ហាក្ខយោ សព្វទុក្ខំ ជិនាតិ**

ការអស់ទៅនៃតណ្ហា រមែងឈ្នះនូវទុក្ខទាំងពួង ។

# ភ័ព្វព្រេងសំណាង

ពាក្យ **ភ័ព្វ** ជាភាសាបាលី ប្រែតាមនិយមន័យខ្មែរយើងថា សំណាង ឬ ព្រេងសំណាង ។ពាក្យថា **សំណាង** ប្រែថា អំពើដែលសាងពីព្រេងនាយ ឬ ភ័ព្វព្រេង ។ ចំណែកពាក្យ វាសនា ខ្មែរយើងច្រើនប្រើសំដៅសេចក្តីថា សំណាង ព្រេងសំណាង ភ័ព្វព្រេង ។ ដូច្នេះពាក្យ ភ័ព្វ ពាក្យ សំណាង និងវាសនា មាននិយមន័យដូចគ្នា ទើបខ្មែរចូលចិត្តនិយាយរួមគ្នាថា ភ័ព្វសំណាង ឬ ភ័ព្វព្រេងសំណាង ថាភ័ព្វវាសនា ឬ ភ័ព្វព្រេងវាសនា ។

មនុស្សលោក ទោះបីជាផ្សេងគ្នាដោយជាតិសាសន៍ ភូមិប្រទេសយ៉ាងណាក៏ដោយ កាលបើកើតមកហើយ ក៏មានសេចក្តីប្រាថ្នាស្មើដូចគ្នាតែម្យ៉ាង ពោលគឺ មានបំណងប៉ងប្រាថ្នា ឱ្យកើតចំលើត្រកូលអភិជនខ្ពង់ខ្ពស់ ប្រកបដោយសក្តិយសបរិវារ ។ ប្រាថ្នាឱ្យមានរូបឆោមលោមពណ៌ល្អស្អាត សុខភាពបរិបូណ៌ អាយុយឺនយូរមានកម្លាំងកាយ កម្លាំងចិត្តក្លាហានស្មារតីរឹងប៉ឹង ។ ជាពិសេសប្រាថ្នាឱ្យមានប្រាជ្ញាឈ្លាសវៃ មានចំណេះចេះដឹងខ្ពង់ខ្ពស់ ទាំងផ្លូវលោកទាំងផ្លូវធម៌ ។ បើនិយាយឱ្យស្រួលស្តាប់ សេចក្តីប្រាថ្នានេះមានន័យថា ភោគសម្បត្តិ រូបសម្បត្តិ និងបញ្ញាសម្បត្តិ។ ទាំងបីនេះ គឺ ជាសេចក្តីប៉ុនប៉ងប្រាថ្នារបស់មនុស្សលោក ក្នុងវដ្តសង្សារនេះ ។

*ក៏ប៉ុន្តែចំពោះគោលបំណងទាំងអស់នោះ ជួនកាលក៏បាន សម្រេច ជួនកាលក៏មិនបានសម្រេច សមដូចពាក្យស្លោកមួយថា "មនុស្សទាំងអស់ គឺជាស្ដាបនិកនៃជោគវាសនា របស់ខ្លួន" ។ ជាការពិតណាស់ថា មនុស្សយើងម្នាក់ៗ កើតមកមិនដូចគ្នាទេអ្នកខ្លះកើតមកក្នុងវិមានក្នុងប្រាសាទ អ្នកខ្លះកើតក្នុងផ្ទះថ្ម ផ្ទះឈើ ឬខ្ទមស្បូវ ។ សូម្បីតែកើតក្នុងប្រាសាទដូចគ្នា រូបសម្បត្តិមិនដូចគ្នា ចរិយាសម្បត្តិក៏មិនដូចគ្នា ប្រាជ្ញាឈ្លាសវៃក៏មិនដូចគ្នាទៀត ទាំងនេះព្រោះហេតុអ្វី? បើពោលទៅតាមន័យ ដែលបានចែងក្នុងព្រះពុទ្ធសាសនាថា មកពីការប្រព្រឹត្តិប្រតិបត្តិ និង ការព្យាយាមខំសន្សំឧបនិស្ស័យមិនស្មើគ្នានោះឯង។ ព្រះភគវាទ្រង់ត្រាស់សំដែងថា "***កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ*** កម្មរមែងបែងចែកសត្វលោកឱ្យថោកទាប ថ្លៃថ្នូរខុស ដោយឡែកពីគ្នា" ។ អំពើ ឬការងារដែលសត្វលោកបានសាងសន្សំមក មិនដូចគ្នា មិនស្មើគ្នា ឬឧបនិស្ស័យមានមកតិចច្រើនខុសប្លែកពីគ្នា ទើបកំណើត និង សេចក្ដីប្រាថ្នារបស់សត្វលោក ពុំអាចបានស្មើដូចគ្នា ។*

*ពាក្យថា* **ឧបនិស្ស័យ** *ជាភាសាបាលី ប្រែជា ភាសាខ្មែរថា កុសលធម៌ ដែលដេកអាស្រ័យនៅក្នុងខន្ធសន្តាន ឬជាកុសលដែលបានអប់រំកសាងសន្សំទុកហើយ ។ ន័យម្យ៉ាងវិញទៀតបាន*

*ដល់ភ័ព្វព្រេងសំណាង ដែលបានកសាងទុកមករហូតជិតដាមដក់ជាប់ជាចំណុចចំណូលចិត្ត ។*

*ឧបនិស្ស័យនេះ បើពោលទៅតាមគម្ពីរព្រះពុទ្ធសាសនាលោកចាត់ថាមាន ៣ យ៉ាងគឺៈ*

*១-* **ទានូបនិស្ស័យ** *ភ័ព្វព្រេងសំណាង ដែលបានសាងទុកមកដោយអំណាចការបរិច្ចាគទ្រព្យទៅជាទាន ,*

*២-* **សីលូបនិស្ស័យ** *ភ័ព្វព្រេងសំណាង ដែលបានសាងទុកមកដោយការរក្សាសីល ,*

*៣-* **ភាវនូបនិស្ស័យ** *ភ័ព្វព្រេងសំណាង ដែលបានសាងទុកមកដោយការបំពេញភាវនា ។*

*ឧបនិស្ស័យ បើពោលតាមន័យ ដូចបានរៀបរាប់មកហើយនោះបានដល់ ទាន សីល ភាវនា ទាំងបីប្រការនេះចាត់ថាជាឧបនិស្ស័យ ដែលសត្វលោកបានសន្សំសាងទុកមក រហូតជិតដាមដក់ជាប់ជាចំណុចចំណូលរបស់ចិត្ត ។*

*សត្វលោកដែលត្រាច់រង្គាត់ក្នុងវាលវដ្តសង្សារ បើមិនទាន់សម្រេចនិព្វានដរាបណា រមែងជួបបញ្ហាទុក្ខសោកច្រើនប្រការ ។ ដូច្នេះដើម្បីរើបម្រះឱ្យផុតបញ្ហាទុក្ខ ប្រាថ្នាសេចក្តីសុខ ត្រូវតែព្យាយាមខំសន្សំបំពេញទាន សីល ភាវនាទាំង បី ប្រការ ទើបបាន*

ឈ្មោះថាជាអ្នកមានឧបនិស្ស័យល្អ គុណធម៌ កុសលធម៌ ឬ បុញ្ញកម្មប្រចាំទុក ដែលជាហេតុបង្កើតបានជា ភ័ព្វព្រេងសំណាងល្អប្រចាំជីវិតក្នុងវាលសង្សារវដ្តនេះ ។

តាមសាមញ្ញាភាសា បើគេឃើញបុគ្គលណាម្នាក់កើតមកហើយចំលើត្រកូលអភិជនមានអំណាចសក្តិយស ទ្រព្យសម្បត្តិបរិវារ មានបញ្ញាស្មារតីភ្លឺស្វាងក្លាហាន មានរូបសម្បត្តិស្រស់សោភា ប្រកបការងារបានសម្រេចសមតាមបំណងប្រាថ្នា គេក៏តែងនាំគ្នាកោតសរសើរចំពោះបុគ្គលនោះថា ម្តេចគេមានភ័ព្វព្រេងសំណាងល្អអស្ចារ្យម៉្លេះហ្ន៎ ! ។ តែបើកើតមកហើយខុសផ្ទុយពីហេតុការណ៍ ដូចបានពោលរួមមកហើយនោះ គេរមែងនាំគ្នានិយាយថា ជាបុគ្គលអភ័ព្វគ្មានព្រេងសំណាងល្អសោះឡើយ ។

ភ័ព្វព្រេងសំណាងពុំមែនកើតឡើងឯងៗ ឬ ដោយព្រះជាម្ចាស់អង្គណាលោកប្រទានឱ្យនោះទេ ព្រេងសំណាងកើតចំពោះតែបុគ្គលណា មានសេចក្តីព្យាយាមឧស្សាហ៍សង្វាត ប្រឹងប្រែងសន្សំឧបនិស្ស័យល្អដោយខ្លួនឯងប៉ុណ្ណោះ ។ បុគ្គលណាបានបំពេញធ្វើទុកហើយ បុគ្គលនោះឈ្មោះថា ជាម្ចាស់លើភ័ព្វព្រេងសំណាងនោះៗ ។

ម្យ៉ាងវិញទៀត ពុទ្ធបរិស័ទជឿជាក់ លើព្រះពុទ្ធសាសនា

មិនគួរប្រើពាក្យ “ព្រហ្មលិខិត” ចំពោះដំណើរជីវិតបច្ចុប្បន្ន ដែលជួបប្រទះភ័ព្វព្រេងសំណាង ឬអភ័ព្វអត់ព្រេងសំណាងនោះឡើយ ព្រោះពាក្យ “ព្រហ្មលិខិត”នេះ ជាពាក្យដែលព្រាហ្មណ៍បរិស័ទត្រូវប្រើតែប៉ុណ្ណោះ ។ ព្រះពុទ្ធទ្រង់ត្រាស់ថា **អត្តាហិ អត្តនោ នាថោ** ខ្លួនទីពឹងខ្លួន ។ ចូរកុំទីពឹងអ្នកដទៃមានទេវតា ឥន្ទព្រហ្មជាដើម ។ សុខ ទុក្ខ មាន ក្រ អាក្រក់ ល្អ កើតមកអំពីទង្វើរបស់ខ្លួនយើង គ្មានអ្នកដទៃណាមកជួយយើងបានឡើយ ។

ដូច្នេះដើម្បីឱ្យបានជាបុគ្គល មានភ័ព្វព្រេងសំណាងពិតៗ ត្រូវខំតាំងចិត្តបំពេញទានឱ្យបានជាទានូបនិស្ស័យ បំពេញសីលឱ្យបានជាសីលូបនិស្ស័យ បំពេញភាវនាឱ្យបានភាវនូបនិស្ស័យទុកជាកម្រៃសម្រាប់ជីវិតគ្រប់ៗជាតិ ។

## ទានូបនិស្ស័យ

**ទានូបនិស្ស័យ** ប្រែថា ភ័ព្វព្រេងសំណាង ដែលបានសាងទុកមក ដោយអំណាចការបរិច្ចាគទ្រព្យទៅជាទាន ។ ពាក្យថាទានជាភាសាសំស្ក្រឹតផង ជាភាសាបាលីផង បើជាភាសាខ្មែរ ប្រែថា អំណោយ ( ការឱ្យ ) ប្រគេន ជូន ថ្វាយនូវបច្ច័យទាំងឡាយឱ្យជាទាន ។ ទាននេះ ខ្ញុំបានពន្យល់ហូរហែរស្ទើរសព្វគ្រប់មកហើយ ខ្ញុំគ្រាន់តែជម្រាបបន្ថែមទៀតថា បុគ្គលដែលអាច

*បំពេញនូវទានឱ្យបានជាឧបនិស្ស័យកើត លុះត្រាតែព្យាយាម ច្បាំងយកជ័យជំនះ លើសត្រូវរបស់ចិត្តពោលគឺ លោភៈ មច្ឆរិយៈ ជាមុនសិន ព្រោះការធ្វើទានទុកដូចជាការធ្វើចំបាំង ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូព្រះអង្គ ទ្រង់មានព្រះតម្រាស់យ៉ាងនេះថា* **ទានញ្ច យុទ្ធញ្ច សមានមាហុ** *ទាន និង ចំបាំងស្មើគ្នា ។*

*ក្នុងន័យនេះ ព្រះអង្គទ្រង់សម្តែងបញ្ជាក់យ៉ាងនេះថា ការបំពេញទាននេះ ប្រហាក់ប្រហែលនឹងការធ្វើចំបាំង ។ ពេលណាប្រទេសជាតិ មានសង្គ្រាមគេតែងតែត្រូវការមេទ័ព និង កងពលទាហាន ដែលមានកម្លាំងខ្លាំងក្លា មានប្រាជ្ញាស្មារតីវាងវៃ មានចិត្តក្លាហាន មានស្បៀងអាហារ និង សព្វាវុធគ្រប់គ្រាន់ស្គាល់កាលវេលា និង ចំណុចខ្សោយខ្លាំងរបស់សត្រូវពិតប្រាកដ ជាអ្នកមានអំណាត់អត់ធន់ តស៊ូប្ដូរផ្ដាច់ ដើម្បីទាមទារយកជ័យជំនះពីខ្មាំងសត្រូវឱ្យបាន យ៉ាងណាមិញ, បុគ្គលដែលអាចបំពេញទានបានក៏ដូច្នោះដែរ លុះត្រាតែព្យាយាមច្បាំងឱ្យបានឈ្នះសត្រូវ របស់ចិត្តជាមុនសិន ទើបអាចបំពេញទានទៅកើត ។*

*សត្រូវរបស់ចិត្តបានដល់លោភៈ និង មច្ឆរិយៈនេះឯង ។ ធម្មតាបុគ្គលដែលមានចិត្តជាប់ជំពាក់ហួងហែង ចង់បានចង់មានហួសកំរិត ចិត្តកំណាញ់ស្វិតស្វាញ កុំថាដល់ទៅហ៊ានលះចាយ*

ចំណាយទ្រព្យធន ដែលខ្លួនមានឱ្យទៅជាទានដល់អ្នកដទៃនោះ ។ សូម្បីតែខ្លួនឯង ក៏ពុំហ៊ានបរិភោគចាយវាយធនធាន ដែលខ្លួនមានទាំងឡាយ ឱ្យបានសមគួរដល់សមត្ថភាពខ្លួនឡើយ ។

បុគ្គលជំពូកនេះ ធ្លាក់ក្នុងតម្រាថា ជាមនុស្សកំណាញ់ស្វិតជាមនុស្សចាញ់ចាល បណ្តោយចិត្តខ្លួនឱ្យឋិតនៅក្រោមអំណាចសត្រូវពោលគឺ លោភៈ និង មច្ឆរិយៈ ។ ចិត្តរមែងសៅហ្មងអន្ទះអន្ទែង ចង់មានបានមិនចេះស្កប់ស្កល់ តែងតែក្រហល់ក្រហាយស្តាយក្រោយ នៅពេលដែលទ្រព្យសម្បត្តិវិនាសបាត់បង់ទៅដោយប្រការផ្សេងៗ មានខ្យល់ព្យុះទឹកជំនន់ជាដើម ។

បុគ្គលប្រភេទនេះ ដែលបណ្តោយចិត្តខ្លួនឱ្យឋិតនៅក្រោមអំណាចនៃលោភៈ និង មច្ឆរិយៈ ទោះបីរស់នៅរាប់រយឆ្នាំក៏មានឈ្មោះថាពុំបានសាងប្រយោជន៍អ្វីសម្រាប់ខ្លួន សម្រាប់សង្គមជាតិសង្គមលោកឡើយ លោកពោលថារស់នៅទម្ងន់ផែនដី ។

ដោយហេតុថា ការធ្វើទាន និង ចំបាំងប្រហាក់ប្រហែលគ្នាទើបព្រះបរមសាស្តា ទ្រង់សំដែងទុកក្នុងអនុបុព្វីកថា អំពីទានជាមុន ហើយទ្រង់សំដែងអំពីសីលតាមលំដាប់ ព្រោះទ្រង់ចង់ឱ្យពុទ្ធ-បរិស័ទយល់អំពីតម្លៃរបស់ទាន និងផលនៃទាន ទ្រង់ចង់ឱ្យរៀនធ្វើបាដិបុគ្គលិកទាន ទ្រង់ចង់ឱ្យចេះធ្វើសង្ឃទាន ដើម្បីដាំផ្សាំបណ្តុះ

ឧបនិស្ស័យ ហៅថា ទានូបនិស្ស័យ ទុកជាបុញ្ញនិធិ ជាក័ព្វព្រេង សំណាងសម្រាប់ឥធលោក និង បរលោក ។

## សីលូបនិស្ស័យ

**សីលូបនិស្ស័យ** ប្រែថាក័ព្វព្រេងសំណាងដែលបានសាង ទុកមកដោយការរក្សាសីល ។ ពាក្យថា សីល ជាភាសាសំស្រ្កឹត ឬ បាលី បើប្រែជាភាសាខ្មែរ បានដល់វិរតិចេតនា វៀរចាកអំពើ អាក្រក់ តាមផ្លូវកាយ វាចា ការមិនប្រព្រឹត្តិកន្លងសិក្ខាបទ ឬ វិន័យ បញ្ញត្តិ ចរិយាសណ្តាប់ធ្នាប់និស្ស័យប្រក្រតីធម្មតា ការសង្រួមមិន ធ្វើអំពើអាក្រក់ទាំងពួង ។

ពាក្យថា **វិរតិ** ប្រែថា ចេតនាវៀរចាក មាន ៣ យ៉ាង គឺ៖

១- **សម្បត្តិវិរតិ** វៀរចាក ដោយការដល់ព្រម ព្រោះ ពិចារណាឃើញច្បាស់នូវគុណធម៌ និង តម្លៃជាតិកំណើត ដែល បានកើតមកជាមនុស្ស ឃើញថាបានមកដោយកម្រជាទីបំផុត ។ ដូច្នេះហើយមិនគួរទៅធ្វើបាបកម្មទាំងពួងសោះឡើយ ទោះបីជា ចំពោះមុខ ឬ កំបាំងមុខអ្នកដទៃក្តី ក៏មិនហ៊ានប្រព្រឹត្ត ដូចជាជួប ប្រទះសត្វមានជីវិត ដែលគួរសម្លាប់ក៏មិនសម្លាប់ ឃើញទ្រព្យ សម្បត្តិអ្នកដទៃ ដែលគួរកាន់យកក៏មិនកាន់យកដូច្នេះជាដើម ។

២- **សមាទានវិរតិ** ការវៀរចាកមិនធ្វើបាបទាំងឡាយ

ដោយបានសមាទានសីល ពីភិក្ខុសាមណេរ ឬ លោកអ្នកមាន សីលរូបណាហើយ ក៏បានព្យាយាមប្រតិបត្តិតាមទ្វារកាយវាចា មិន ហ៊ានប្រព្រឹត្តឱ្យកន្លងចាកសិក្ខាបទ ឬវិន័យបញ្ញត្តិនោះ ដោយមាន ការអៀនខ្មាស និង មានសេចក្ដីក្រែងរអែងខ្លើមចំពោះផលអាក្រក់ លាមកទាំងនោះ ។

៣- **សមុច្ឆេទវិរតិ** ការវៀរចាកដោយដាច់ខាត គឺអំពើ បាបណា ដែលបានវៀរចាកដោយកាយវាចាហើយ អំពើបាបទាំង ឡាយនោះពុំអាចវិលត្រឡប់កើតទៀតបានទេ សំដៅយកការវៀរ ចាករបស់ព្រះអរិយបុគ្គលមានសោតាបន្នជាដើម ។ អំពើបាបណា ដែលទ្រង់បានលះបង់ហើយ គឺជ្រះស្រឡះមិនអាចត្រឡប់កើត វិញបានឡើយ ។ សីលដែលប្រែថា សង្រួម គឺ សង្រួមប្រយ័ត្នបិទ បាំងទ្វារកាយវាចាដោយសតិ មិនបណ្ដោយឱ្យបាបទាំងឡាយ ជ្រៀតជ្រែកចូលមកបាន ។ ព្យាយាមរក្សាកាយវាចាឱ្យជាប្រក្រតី ធម្មតាទាំងចរិយា សណ្ដាប់ធ្នាប់ ក៏ព្យាយាមរក្សាឱ្យបានថ្លៃថ្នូរល្អ ប្រសើរគ្រប់ពេលវេលា ។

## សីលចែកចេញជា ៤ ប្រការ គឺ ៖

១- **និច្ចសីល** បានដល់សីលដែលគួររក្សាជានិច្ច ឬ ហៅថា បញ្ចសីល គឺសីលដែលមានសិក្ខាបទប្រាំ ,

២- **ឧបោសថសីល** *សីលសម្រាប់ដុសខាត់ ជម្រះចិត្តឱ្យបានថ្លាស្អាតជាលំដាប់ឡើងទៅ ឬ ហៅថាសីលប្រាំបី ព្រោះមានសិក្ខាបទប្រាំបី ,*

៣- **ចតុប្បារិសុទ្ធសីល** *សីល ៤* មានបាតិមោក្ខសំវរសីល *ជាដើម ជាសីលសម្រាប់ភិក្ខុសង្ឃអង្គដែលបានបួសក្នុងព្រះពុទ្ធសាសនាលោកសិក្សាគោរពប្រតិបត្តិ ។*

*សម្រាប់ខណៈនេះខ្ញុំសូមលើកយកត្រឹមតែសីលប្រាំ ឬនិច្ចសីលមកអធិប្បាយខ្លះៗប៉ុណ្ណោះ ដើម្បីបញ្ជាក់ពីសីលូបនិស្ស័យឱ្យស្របទៅតាមន័យខាងដើម ។ សត្វលោកដែលកើតមកហើយក្នុងវដ្តសង្សារនេះ តែងជួបប្រទះបញ្ហាទុក្ខសោកជាច្រើនជំពូក ។ បញ្ហាទុក្ខសោកដែលកើតពីសភាវធម៌ គឺបញ្ចក្ខន្ធត្រូវជួបប្រទះនឹងការកើត ចាស់ ឈឺ ស្លាប់ ។ បញ្ហាខ្វះខាតក្នុងការរកដើម្បីបំប៉នបញ្ចក្ខន្ធផង ។ បញ្ហាភ័យខ្លាចតក់ស្លុត ដែលកើតចេញពីសង្គមដូចជាការប្រើអំណាចអាក្រក់ជួរជាតិ កាប់សម្លាប់បៀតបៀន ធ្វើទុក្ខបុកម្នេញ លួចឆ្មក់ឆក់ប្រវ័ញ្ច រំលោភបំពារបំពានបំបាត់សិទ្ធិសេរីភាព ពោលពាក្យសម្តីកុហកបោកប្រាស មួលបង្កាច់ប្រាសចាកពីសភាវពិត មានចិត្តខ្មៅងងឹតវង្វេងភ្លាំងភ្លេចស្មារតី ។ ទាំងនេះសុទ្ធតែជាមហាភ័យ ដែលបង្កចេញជាផ្នត់គំនិតនៃសត្វលោក*

ដែលលោកពោលថា ខូះសីលធម៌នោះឯង ។

ដូច្នេះអ្នកដែលបានរក្សាសីល ឈ្មោះថាជាអ្នករស់នៅក្នុងក្របខ័ណ្ឌនៃច្បាប់ យុត្តិធម៌ មិនបានបង្កការភ័យខ្លាចដល់សង្គម ដូចជានិច្ចសីល គឺសីលដែលត្រូវរក្សា ប្រតិបត្តិដុសខាត់ ឱ្យបានប្រសើរគ្រប់ពេលវេលា ដែលមានសិក្ខាបទប្រាំ ពុទ្ធបរិស័ទបានចងចាំ និង បានសិក្សាចេះដឹងស្ទើរតែគ្រប់គ្នា ។

**សិក្ខាបទ ៥ នោះ គឺ ៖**

១- **បាណាតិបាត** ការសម្លាប់សត្វ បំបាត់ជីវិតគេ,

២- **អទិន្នាទាន** ការលួចទ្រព្យរបស់គេ ,

៣- **កាមេសុមិច្ឆាចារ** ការប្រព្រឹត្តិខុសក្នុងកាម ,

៤- **មុសាវាទ** ការពោលពាក្យកុហក,

៥- **សុរាមេរយ** ការផឹកទឹកស្រវឹង ។

ទាំង៥សិក្ខាបទនេះ ត្រូវសិក្សាឱ្យបានចូលចិត្តថា ជាអំពើអាក្រក់លាមក ។ កាលបើបុគ្គលណាបានប្រព្រឹត្តហើយ ឈ្មោះថាជាបុគ្គលបាប នាំឱ្យសង្គមភ័យខ្លាចតក់ស្លុត ធុញទ្រាន់ខ្ពើមរអើម និង បានឈ្មោះថាជាបុគ្គលទ្រុស្តសីល គឺជាអ្នកគ្មានសីល។ ដូច្នេះដើម្បីឱ្យបានឈ្មោះថា ជាបុគ្គលអ្នកមានសីល គឺត្រូវវៀរចាកមិនប្រព្រឹត្តឱ្យកន្លងសិក្ខាបទទាំង ៥ ខ នេះ ។

ដែលថាត្រូវរក្សាសីល បានដល់ការវៀរចាក មិនសម្លាប់សត្វ មិនលួចទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងកាមេ មិនពោលពាក្យកុហកបោកប្រាស មិនផឹកនូវទឹកស្រវឹង ឬ រក្សាកាយ វាចាឱ្យមានសណ្តាប់ធ្នាប់ល្អថ្លៃថ្នូរ សមគួរដល់ពាក្យថា សីលធម៌ ។

ដែលហៅថានិច្ចសីល គឺជាសីលដែលបុគ្គលម្នាក់ៗ ត្រូវរក្សាប្រតិបត្តិឱ្យបានជាប់ជានិច្ចគ្រប់ពេលវេលា ដើម្បីសេចក្តីសុខក្សេមក្សាន្តក្នុងរង្វង់សង្គមគ្រួសារ សង្គមប្រទេសជាតិ និង ពិភពលោកទាំងមូល ។

និច្ចសីលនេះ ជាច្បាប់សម្រាប់សង្គម ជាធម៌មានប្រចាំលោក ឬថាជាបំណងរបស់មនុស្សសត្វ ជាចាំបាច់គ្រប់ពេលវេលា ទោះបើមានព្រះពុទ្ធត្រាស់ដឹងក្តី មិនមានព្រះពុទ្ធត្រាស់ដឹងក្តី ក៏សង្គមមនុស្សសត្វតែងប៉ងប្រាថ្នាជាចាំបាច់ ដើម្បីសិទ្ធិសេរីភាព សេចក្តីសុខស្រួលក្នុងសង្គម ។

ដូច្នេះបុគ្គលគ្រប់រូប ត្រូវព្យាយាមខំសន្សំអប់រំឱ្យមានសីលជាទម្លាប់ដក់ជាប់ក្នុងចិត្ត ដែលហៅថាសីលូបនិស្ស័យ ព្រោះសីលដែលបុគ្គលរក្សាប្រតិបត្តិល្អហើយនឹងបានជាកម្លាំង៤យ៉ាង ។

**អានុភាពរបស់សីល ៤ យ៉ាង គឺ ៖**

១- **ឧទកសរណសីលគុណោ** សីលមានអានុភាពត្រជាក់

ដូចជាទឹក,

២- **ឧបោសថសមោសីលគុណោ** សីលមានអានុភាពដូចជាឱសថ,

៣- **អាចារសមោសីលគុណោ** សីលមានអានុភាពញុាំងអ្នករក្សាឱ្យប្រព្រឹត្តល្អ ,

៤- **មណីសមោសីលគុណោ** សីលមានអានុភាពដូចជាកែវមណីដ៏មានរស្មីភ្លឺថ្លា ។

បុគ្គលដែលបានរក្សាសីលឱ្យបានបរិសុទ្ធ មិនធ្លុះធ្លាយ មិនធ្លាក់ពពាលរមែងបានអានិសង្ស ៥យ៉ាងគឺ ៖

១- អ្នករក្សាសីល នឹងបានទ្រព្យដ៏ច្រើន មិនមានអធិករណ៍ព្រោះមានសេចក្តីមិនប្រមាទ,

២- អ្នករក្សាសីល នឹងមានកេរ្តិ៍ឈ្មោះពិរោះល្អជាកល្យាណស័ព្ទផុសអណ្តែតឡើងល្បីរន្ទឺគ្រប់ទិសសានុទិស,

៣- អ្នករក្សាសីល កាលនឹងចូលទៅកាន់ទីប្រជុំជន តែងតែរីករាយ មិនអៀនអន់ ដាក់មុខសំយុងចុះ,

៤- អ្នករក្សាសីល វេលានឹងធ្វើកាលកិរិយា មិនវង្វេងស្មារតី,

៥- អ្នករក្សាសីល បន្ទាប់ពីបែកធ្លាយខន្ធទៅ រមែងបានទៅកើតក្នុងសុគតិភព ។

ម្យ៉ាងវិញទៀត សីលនេះលោកប្រៀបដូចជាផែនដី ។ ព្រៃព្រឹក្សាលតាវល្លិ៍ ឬ អ្វីៗទាំងឡាយអាចតាំងនៅបាន ព្រោះមានភពផែនដីជាមូលដ្ឋាន រីឯកុសលធម៌ទាំងឡាយក៏ដូច្នោះដែរ ដែលអាចកើតមាននិងតាំងនៅបាន លុះត្រាតែមានសីលជាមូលដ្ឋាន ។ សីលជាជំហានទីពីរ បន្ទាប់អំពីទានក៏ពិតមែនហើយ អ្នកដែលធ្វើទានក៏ត្រូវតែប្រតិបត្តិតាមសីលដែរ បើសិនជាឱ្យទានតែគ្មានសីល ជាអ្នកទ្រុស្តសីលប្រព្រឹត្តល្មើសសិក្ខាបទដូចជាលួចប្លន់ ឆក់បំបាត់កេងប្រវ័ញ្ច បោកបញ្ឆោត កាប់សម្លាប់ យកទ្រព្យ យកជីវិតគេមកបំពេញទានបានបុណ្យដែរ តែលាយបាប ឃើញថាបុណ្យនោះមិនបានបរិសុទ្ធស្អាតទេ ។

ដូច្នេះការបំពេញទាន ត្រូវតែមានសីល ទើបបានផលានិ-សង្សពិតប្រាកដ ។ ការពោលរាប់រៀបមកនេះ បញ្ជាក់ឱ្យឃើញច្បាស់ថា សីលជាគុណធម៌ដ៏ប្រសើរ ជាទីតាំងនៃកុសលដទៃធ្វើឱ្យកុសលធម៌ទាំងពួងកើតតាំងនៅ និង ចំរើនបាន និង ជាជំហានឈានចូលដល់ភាវនា ដែលជាឧបនិស្ស័យជាន់ខ្ពស់ទៀតផង ។

សាធុជន ជាអ្នកមានសេចក្តីប្រាថ្នា ចង់បានភ័ព្វព្រេងសំណាងល្អ បានប្រតិបត្តិតាមលំដាប់ថ្នាក់ទាន ឈានចូលមកដល់ថ្នាក់សីល ត្រូវព្យាយាមខិតខំសន្សំបំពេញសីល ឱ្យបានជា

ឧបនិស្ស័យ ហៅថា សីលូបនិស្ស័យ ។

## ភាវនូបនិស្ស័យ

**ភាវនូបនិស្ស័យ** ប្រែថា ភ័ព្វសំណាង ដែលបានសាងទុកមកហើយដោយការបំពេញភាវនា ។ **ភាវនា** នេះជាភាសាបាលី ឬ សំស្ក្រឹត ប្រែថា ការចំរើនការនឹកត្រង់ចំពោះអារម្មណ៍ល្អតែមួយ ដដែលៗច្រើនដងជារឿយៗនឹកហើយនឹកទៀតរំពឹងស្មឹងស្មាធ៏ ។

ភាវនា ដែលប្រែថា ការចំរើននោះ គឺសម្រាប់ប្រើជាមួយនឹងពាក្យដទៃ ដូចជាសមាធិភាវនា ការចំរើនសមាធិបញ្ញា ឬ វិបស្សនាភាវនា ការចំរើនបញ្ញា មេត្តាភាវនា ការចំរើនមេត្តា ឬក៏ចំរើនសតិ បានដល់ការរឭកដឹងជារឿយៗញយដង ។

ភាវនា បើពោលឱ្យងាយស្តាប់ងាយយល់ បានដល់ការអប់រំចិត្ត ឱ្យស្ថិតនៅក្នុងអារម្មណ៍មូលស្ងប់ល្អតែមួយ ប្រាសចាកនីវរណធម៌បង្កើតបញ្ញា ដើម្បីចាក់ធ្លុះត្រៃលក្ខណធម៌ មាន អនិច្ចំ ទុក្ខំ អនត្តា ។ ភាវនានេះ ជាធម៌ថ្នាក់ខ្ពស់ក្នុងព្រះពុទ្ធសាសនា ។ លោកអ្នកប្រាថ្នាសេចក្តីសុខចំរើនក្នុងសង្សារវដ្ត ឬ ប្រាថ្នារំដោះខ្លួនឱ្យរួចផុតចាកជីវិតអន្ទោលកើតស្លាប់ ត្រូវខំព្យាយាមសន្សំបំពេញភាវនាធម៌ មានសមថភាវនា និង វិបស្សនាភាវនាជាដើម ឱ្យកើតបានជាឧបនិស្ស័យបច្ច័យ ព្រោះជាគុណធម៌សម្រាប់អប់រំ

ទូន្មានចិត្តឱ្យស្ថិតនៅក្នុងកុសលធម៌ទាំងពួង ។ព្រះពុទ្ធបរមសាស្ដា ទ្រង់ត្រាស់សំដែង ក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយយ៉ាងនេះថា **មនោ បុព្វង្គមា ធម្មា** ធម៌ទាំងឡាយមានចិត្តជាខាងដើម ។

តាមព្រះពុទ្ធដីកានេះ បញ្ជាក់បានថា ធម៌ជាកុសលក្ដី ជាអកុសលក្ដី រមែងមានចិត្តជាដែនកើត មានចិត្តជាប្រធាន ។ ដើម្បីចំរើនភាវនាឱ្យបានផលប្រយោជន៍ពិតប្រាកដ គេត្រូវកំណត់ដឹងស្គាល់យល់អំពីពាក្យថា **ចិត្ត** ជាមុនសិន ។

ក្នុងគម្ពីរអភិធម្ម ព្រះពុទ្ធដីកា មានន័យល្អិតជ្រាលជ្រៅ ដែលព្រះអង្គទ្រង់សំដែងធម៌ ៤ ប្រការ ១- **ចិត្ត** ២- **ចេតសិក** ៣- **រូប** ៤- **និព្វាន** ។ ធម៌ទាំង ៤ ប្រការនេះ មានន័យល្អិតសុខុម ដែលលោកអ្នកប្រាជ្ញទាំងឡាយ មិនងាយនឹងលើកមក សម្ដែងពន្យល់ដល់អ្នកស្ដាប់ឱ្យចេះចាំយល់បានដោយងាយៗនោះទេ ។

ពាក្យថា **ចិត្ត** ជាអរូបធម៌ ពុំអាចមើលឃើញដោយភ្នែកឬចាប់ពាល់កាន់ត្រូវដោយដៃបានទេ ។ ចិត្តជានាមធម៌មានត្រឹមតែឈ្មោះសម្រាប់កំណត់ហៅឱ្យដឹងថាគ្រាន់តែជាចិត្តប៉ុណ្ណោះ ។

ចិត្តជាធាតុសោយនូវអារម្មណ៍ ជាធាតុទទួលដឹងត្រិះរិះពិចារណាសន្សំនូវអារម្មណ៍ ជួនកាលលោកហៅថា មនោធាតុ ឬវិញ្ញាណធាតុ មានចេតសិកជាធាតុកើតរលត់នៅរួមជាមួយ ។ ចិត្ត

និង ចេតសិកនេះជាអរូបធាតុ តែងអាស្រ័យនៅនឹងរូបធាតុ មានរូបរាងកាយ ជាទីជម្រកជាប្រទេសអាស្រ័យនៅ ។ រូបរាងកាយនៃមនុស្ស សត្វទាំងឡាយ ជាប្រទេស ជាជម្រករបស់ចិត្ត ។

រូបរាងកាយជាធាតុ មិនយល់មិនដឹង គ្រាន់តែជាទីជម្រករបស់ចិត្តប៉ុណ្ណោះ ។ ចិត្តមិនមែនជ្រកនៅ ឬ ត្រាច់ចរតែក្នុងរាងកាយទេ តែងនឹកវេទោរទន់បង្អោនទៅកាន់អារម្មណ៍ផ្សេងៗ ខាងក្រៅទោះជាទីជិត ឬ ឆ្ងាយចិត្តតែងអណ្តែតត្រសែតនឹករកអារម្មណ៍គ្រប់ពេលវេលា ។ ពាក្យថា **អារម្មណ៍** បានដល់ធម្មជាតិដែលចិត្តតែងនឹករកឬថាជានុយជាចំណីរបស់ចិត្ត។ អារម្មណ៍ជាចំណីរបស់ចិត្តមានច្រើនយ៉ាងណាស់ រាប់មិនអស់ តែបើពោលដោយខ្លីមានត្រឹម ៦ យ៉ាង ១- រូបារម្មណ៍ អារម្មណ៍បានដល់រូប ២- សទ្ទារម្មណ៍ អារម្មណ៍បានដល់សម្លេង ៣- គន្ធារម្មណ៍ អារម្មណ៍បានដល់ក្លិន ៤- រសារម្មណ៍ អារម្មណ៍បានដល់រសជាតិ ៥- ផោដ្ឋព្វារម្មណ៍ អារម្មណ៍បានដល់ការប៉ះពាល់ ៦- ធម្មារម្មណ៍ អារម្មណ៍បានដល់វត្ថុ ឬ អ្វីដែលចិត្តរមែងនឹករកជាអតីត អនាគត បច្ចុប្បន្នក្តី ។ រូប សម្លេង ក្លិន រស សម្ផស្ស ធម្មានេះហើយ ដែលចិត្តតែងសោយតែងនឹករកមិនដាច់ ។

អារម្មណ៍ទាំងប្រាំមួយនេះ តែងកើតឡើង ឬ ត្រាច់ចរចុះ

*ឡើងតាមចន្លោះទ្វារប្រទេស នៃរូបកាយប្រាំមួយដែរ ១- ចក្ខុទ្វារ ទ្វារភ្នែក ២-សោតទ្វារ ទ្វារត្រចៀក ៣- ឃានទ្វារ ទ្វារច្រមុះ ៤-ជីវ្ហាទ្វារ ទ្វារអណ្តាត ៥- កាយទ្វារ ទ្វារកាយ មនោទ្វារ ទ្វារចិត្ត ។ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ មនោ លោកចាត់ជាទ្វារ ព្រោះជាចន្លោះប្រហោងចេញចូលនៃអារម្មណ៍ ហៅថា អាយតនៈ ប្រែថា អណ្តូង សម្រាប់ផ្ទុកអារម្មណ៍ ជាអណ្តូងយ៉ាងសែនជ្រៅ ព្រោះមិនចេះពេញដោយអារម្មណ៍ទាំងឡាយសោះឡើយ ។*

**អារម្មណ៍ចែកចេញជា ២ ប្រភេទ គឺ ៖**

១- **ឥដ្ឋារម្មណ៍** *អារម្មណ៍ជាទីប្រាថ្នា,*

២- **អនិដ្ឋារម្មណ៍** *អារម្មណ៍មិនជាទីប្រាថ្នា ។*

*កាលបើរូប សម្លេង ក្លិន រស សម្ផស្ស ធម្មា បានប៉ះពាល់ ឬកើតឡើងតាមផ្លូវភ្នែកត្រចៀកច្រមុះអណ្តាត កាយ មនោវិញ្ញាណ គឺ ដឹងស្គាល់ថា រូបស្អាត សម្លេងពិរោះ ក្លិនក្រអូប រសជាតិឈ្ងុយឆ្ងាញ់ សម្ផស្សទន់ភ្លន់ ធម្មា ឬវត្ថុហេតុការណ៍នាអតីតបច្ចុប្បន្ន ជាទីគាប់គួរសមបំណង ក៏កើតសេចក្តីប្រាថ្នាពេញចិត្ត សោមនស្សត្រេកអរ សប្បាយរីករាយដោយកាម គឺចង់ឱ្យកើតរាគៈ តម្រេកត្រេកត្រអាល ភ្លើតភ្លើនស្រើបស្រាល ចំពោះអារម្មណ៍ដែលជាទីប្រាថ្នានោះ ។ អារម្មណ៍បែបនេះ ឈ្មោះថា ឥដ្ឋារម្មណ៍ ។*

ផ្ទុយទៅវិញ កាលបើជួបប្រទះអារម្មណ៍ដូចជា រូប សម្លេង ក្លិន សម្ផស្ស ធម្មា ជាទំនាស់មិនជាទីគាប់គួរ មិនសមប្រាថ្នា ក៏កើតទោមនស្ស និង ស្អប់បដិឃៈថ្នាំងថ្នាក់ក្វាម ចំពោះអាម្មណ៍ទាំងនោះ ។ អារម្មណ៍បែបនេះ ឈ្មោះថា អនិដ្ឋារម្មណ៍ ។

ចិត្តឥតមានរូបទេ តែគេអាចដឹងបាន សម្គាល់បាន ត្រង់ចលនារបស់ចិត្ត ដែលតែងគិតសន្សំរេរទៅកាន់អារម្មណ៍គ្រប់ពេលវេលា ។ ចិត្តជាធាតុដឹងអាចបញ្ជារាងកាយ ជាធាតុមិនដឹងឱ្យមានចលនាប្រព្រឹត្តអំពើជាបាប បុណ្យ គុណទោស ខុសត្រូវ កុសល អកុសល គ្រប់បែបយ៉ាង ដោយមានចេតសិក ដែលជាអរូបធម៌ដូចគ្នា រមែងកើតរលត់ជាមួយគ្នា បើជាអកុសលចេតសិក ក៏ជម្រុញបញ្ជាចិត្តឱ្យទៅជាអកុសលទៅ បើជាកុសលចេតសិក ក៏ជម្រុញបញ្ជាចិត្តឱ្យទៅជាកុសលទៅ ។

ដូច្នេះ ដើម្បីឱ្យបានគុណប្រយោជន៍អំពីចិត្ត គេត្រូវខិតខំព្យាយាមអប់រំទូន្មានចិត្តដោយទាញប្រគងលើកចិត្ត ឱ្យឋិតនៅក្នុងកុសលធម៌ជានិច្ច ព្រោះចិត្តនេះបើគេមិនបានទូន្មានអប់រំទេ រមែងរេទៅកាន់អារម្មណ៍ជាទីប្រាថ្នាខ្លះ មិនជាទីប្រាថ្នាខ្លះ នៅពេលប៉ះប្រទះអារម្មណ៍ទាំងនោះហើយ បើគ្មានសតិរឭកនឹកដឹង បញ្ញាពិចារណា ឱ្យឃើញគុណទោសទេនោះ ចិត្តរមែងគិតយល់ខុស

ប្រកាន់ខុស ជាហេតុធ្លាក់ចុះទៅក្នុងជ្រោះ ពោរពេញទៅដោយសេចក្ដីសៅហ្មង កាលបើចិត្តប្រកបដោយមន្ទិលសៅហ្មងហើយ សេចក្ដីទុក្ខនឹងកើតមានពិតប្រាកដ ដូចពុទ្ធភាសិតក្នុងមូលបណ្ណាសកមជ្ឈិមនិកាយពោលថា "**ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា** កាលបើចិត្តសៅហ្មងហើយ ទុគតិនឹងកើតឡើងប្រាកដ" ។

ពាក្យថា ភាវនា បានដល់ការចំរើន ការនឹកត្រង់ចំពោះអារម្មណ៍ដ៏ល្អតែមួយនឹកហើយនឹកទៀត ។ ពាក្យនឹក ឬ រលឹកសំដៅយកសតិបានដល់ការចម្រើនសតិឱ្យរឿយៗច្រើនដង។ សតិប្រែថា ការរឭកបានជាគូ និងសម្បជញ្ញៈ ប្រែថា សេចក្ដីដឹងខ្លួន ។

ធម៌ទាំង ២ ប្រការនេះ គឺ សតិ និង សម្បជញ្ញៈជាធម៌មានឧបការច្រើន ជាកុសលចេតសិកកើតឡើងជាមួយចិត្ត ញុំាងចិត្តឱ្យប្រព្រឹត្តទៅ ក្នុងគុណប្រយោជន៍ជានិច្ច ។ ពាក្យថាសេចក្ដីរឭកគឺរឭកមុនពេលធ្វើ មុនពេលនិយាយស្ដី គិតប្រកបកិច្ចការអ្វីៗមានស្មារតីមិនភ្លេចភ្លាំង ។ សម្បជញ្ញៈ គឺសេចក្ដីដឹងខ្លួនក្នុងពេលដែលកំពុងធ្វើ កំពុងពោលស្ដី ប្រកបកិច្ចការគ្រប់បែបយ៉ាង ។ ការមានធម៌ទាំង ២ ប្រការនេះ រមែងញុំាងឱ្យបានសម្រេចផលប្រយោជន៍ទាំងខាងផ្លូវលោកទាំងខាងផ្លូវធម៌ តាំងតែពីថ្នាក់ទាបថ្នាក់កណ្ដាល រហូតទៅដល់ថ្នាក់ខ្ពស់បាន ។

*ការពោលរៀបរាប់យ៉ាងខ្លីមកនេះ បញ្ជាក់ឱ្យឃើញពីគុណប្រយោជន៍ ដែលកើតអំពីភាវនា គឺការចំរើនទូវសតិថ្នាក់ទាប ថ្នាក់កណ្តាល ។ ការចំរើនសតិរឭកពិចារណាទូវធម៌ ៤ ប្រការ គឺកាយ វេទនា ចិត្ត ធម៌ ជាព្រះពុទ្ធដីកាក្នុងសតិបដ្ឋានសូត្រ ទើបចាត់ថាជាការចំរើនសតិថ្នាក់ខ្ពស់ អាចរំដោះសត្វឱ្យឆ្លងផុតចាកសង្សារវដ្ត ។*

*ព្រះសម្មាសម្ពុទ្ធបរមនាថ ព្រះអង្គទ្រង់ត្រាស់យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ មានតែសតិបដ្ឋាននេះទេ ដែលជាខប្រតិបត្តិកំចាត់បង់ទុក្ខទោសទាំងពួង និង ជាមាគ៌ាសម្រាប់ធ្វើដំណើរឆ្ពោះទៅកាន់ទីរំលត់ទុក្ខ " ។ បើចង់ជ្រាបច្បាស់ពីសតិបដ្ឋាន សូមមេត្តាអានព្រះត្រៃបិដកភាគទី ១៧ ទំព័រ ២៤៤ បន្ថែមទៀតចុះ ។*

*ការចំរើនសតិបដ្ឋានក្តី ការចំរើនសមាធិវិបស្សនាក្តី មានន័យ និង គោលដៅតែមួយដូចគ្នា គឺជាមាគ៌ាសម្រាប់អប់រំផ្លូវចិត្តឱ្យប្រព្រឹត្តទៅក្នុងកុសលធម៌ ដើម្បីសាងចិត្តដែលធ្លាប់តែត្រាច់ចរតាមទំនើង ដែលធ្លាប់តែងងឹតវង្វេង ដោយអំណាចកិលេសឱ្យទៅជាចិត្តថ្លាបរិសុទ្ធស្អាត គួរដល់ការផ្សារជាគុណប្រយោជន៍តាំងពីថ្នាក់ទាប កណ្តាល និង ខ្ពស់បាន ។*

*សូមជ្រាបថា ទាន សីល ភាវនា ទាំង ៣ ប្រការនេះ រមែងអាស្រ័យជាជំនួយដល់គ្នា ។ ទាន គឺ ការចែករំលែក ជួយបំពេញ*

ដល់អ្នកដែលមានសេចក្តីត្រូវការខ្វះខាត ស្រេកឃ្លាន ជាជំហាន ជួយឧបត្ថម្ភដល់សង្គមមនុស្សសត្វ ឱ្យប្រព្រឹត្តទៅបានសុខស្រួល។ សីល គឺប្រពៃណីច្បាប់ សណ្តាប់ធ្នាប់ ចរិយាប្រពៃថ្លៃថ្នូរល្អប្រសើរ ការគោរពសិទ្ធិគ្នា ក្នុងសង្គមគ្រួសារ ដោយឱ្យតម្លៃទៅលើជីវិត ទ្រព្យសម្បត្តិ ប្តីប្រពន្ធ កូន មិនបៀតបៀន ប៉ះពាល់រំលោភសិទ្ធិគ្នា កាយវាចានិយាយស្តី ឈរលើស្មារតីប្រកាន់លើយុត្តិធម៌ ។ ភាវនា ជាធម៌ថ្នាក់ខ្ពស់ក្នុងព្រះពុទ្ធសាសនា អាចនាំបុគ្គលអ្នកប្រតិបត្តិឱ្យ ឆ្ងង់ផុតទុក្ខទោស ដោយមានបញ្ញាជាពន្លឺកំចាត់បង់មោហៈ អវិជ្ជា មិច្ឆាទិដ្ឋិ ធ្វើចិត្តឱ្យមានការសណ្តោសប្រោសប្រណីមេត្តាអាណិត ដោយមានទឹកចិត្តសង្វេគតក់ស្លុតពីជីវិត ដែលកំពុងតែប្រព្រឹត្ត ទៅនៅក្នុងសង្សារវដ្តនេះ ។ ភាវនាធម៌នេះ អាចជួយឃុំគ្រងទាន សីល ឱ្យប្រព្រឹត្តទៅកាន់តែប្រសើរឡើងទៀត ។ អ្នកធ្វើទាន មាន ភាវនាចិត្តជាជំនួយ គេតែងឱ្យដោយចិត្តសង្វេគផ្តេកអារម្មណ៍ទៅ លើធម៌ ៣ ប្រការគឺ អនិច្ចំ ទុក្ខំ អនត្តា មានសេចក្តីអាណិតគិត ប្រាថ្នាឱ្យអ្នកទទួលបានសុខសប្បាយ រួចផុតពីសេចក្តីទុក្ខកង្វល់ ដោយការខ្វះខាត អត់ឃ្លានទាំងនោះ មិនបានគិតពីកិត្តិយសកេរ្តិ៍ ឈ្មោះ ព្រោះអំណាចទាននោះទេ ។ គេបំពេញទានដើម្បីបំពេញ សេចក្តីត្រូវការ និង ជួយសម្រាលសេចក្តីទុក្ខសោក របស់មនុស្ស

សត្វក្នុងលោក និង ដើម្បីរំដោះខ្លួនគេ ចេញចាកពីអន្ទង់ទុក្ខសោក ក្នុងលោកនេះផង ។

អ្នករក្សាសីលប្រកបដោយភាវនាចិត្ត តែងគិតអាណិតជួយសង្គ្រោះជីវិតមនុស្សសត្វ ឱ្យរួចផុតវិបត្តិភ័យពៀរវេរា ដោយគ្មានគិតពីកិត្តិយសលើកកំពស់ ឬ ចង់បានពាក្យពោលសរសើរពីអ្នកដទៃណាម្នាក់ឡើយ ។

សីលជាជំនួយដល់ទាន ។ អ្នកបំពេញទានត្រូវមានសីល គឺរក្សាសីលឱ្យបានបរិសុទ្ធស្អាត ទើបធ្វើទានទៅមានផលានិសង្ស ប្រាកដទៅបាន បើពុំនោះសោតទេ នឹងមានឈ្មោះថាធ្វើបាបលាយបុណ្យ ឬថាយកបាបទៅរំលែកបុណ្យនាំឱ្យខាតទុនបាត់បង់កម្រៃផល ដូចអ្នកដែលលួចឆក់កេងប្រវ័ញ្ចទ្រព្យសម្បត្តិ អ្នកដទៃយកទៅធ្វើទានដោយចង់បានអំណាច បានកេរ្តិ៍ឈ្មោះមុខមាត់ ឬ សម្លាប់ជីវិតសត្វក្តី ភូតភរកុហកបោកប្រាសក្តី ទោះបីបំពេញទានមានចិត្តធ្វើបុណ្យ ក៏ឈ្មោះថាមិនបរិសុទ្ធដែរ ។

សីលជាជំនួយដល់ភាវនា ។ សមាធិភាវនាក្តី វិបស្សនាភាវនាក្តី ដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសីលបរិសុទ្ធជាខាងដើម ។ ដូច្នេះ សីលជាជំនួយដល់ទាន ជាជំនួយដល់ភាវនា ។ ចំណែកទាន ជាជំនួយដល់សង្គមជាចាំបាច់ និង ជាជំនួយដល់

សីលភាវនាដែរ ។ លោកអ្នកដែលរក្សាឧបោសថសីល រហូតដល់ចតុប្បារិសុទ្ធិសីល បំពេញភាវនា ក៏ដោយសារមានអ្នកបំពេញទាន ជួយទំនុកបំរុងនោះឯង ។ ដូច្នេះ ទើបពោលថា ធម៌ ៣ ប្រការនេះ គឺទាន សីល ភាវនា ត្រូវអាស្រ័យគ្នា ។

ម្យ៉ាងវិញទៀត លោកចាត់ទុកថាជាឧបនិស្ស័យ ព្រោះទានសីលភាវនានេះ សត្វលោកត្រូវព្យាយាមខំសន្សំ ខំបំពេញឱ្យបានជាស្នាមគំនូសជិតដក់ជាប់ក្នុងចិត្តឱ្យជាទម្លាប់របស់ចិត្ត គឺឱ្យមានឈ្មោះថាអ្នកចេះធ្វើទាន ចេះរក្សាសីល ជាអ្នកមានភាវនាធម៌ ។ បើគ្មានឧបនិស្ស័យទាំង៣ប្រការនេះទេ មនុស្សលោកមិនអាចជាអ្នកចេះចែករំលែក ជាអ្នកមានចិត្តលោភលន់ កំណាញ់ជាប់ជំពាក់ ជាអ្នកមានចរិយាសណ្តាប់ធ្នាប់មិនល្អ មិនគួររាប់រកជាអ្នកប្រទូស្ត ធ្វើទុក្ខបុកម្នេញ ដល់សង្គម មានចិត្តដំងងឹតងងល់ខ្វះពន្លឺរស្មីក្នុងជីវិត ព្រោះត្បិតសេចក្តីវង្វេង ។

មនុស្សដែលមានបុណ្យភ័ព្វព្រេងសំណាង បានសាងមកពីអតីតជាតិមានកំណើតបានឃើញពន្លឺលោកនេះ ប្រកបដោយសេចក្តីសុខពេញលក្ខណៈ ជាមនុស្ស ជាទេវតា ជាព្រហ្ម ដោយសារមានឧបនិស្ស័យទាំង៣ប្រការនេះឯង។ ដូច្នេះត្រូវព្យាយាមខំសន្សំបន្តទៀតកុំប្រមាទភ្លាំងភ្លេចឱ្យស្នាមគំនូសនេះ រលប់រលាយ

សូន្យបាត់ពីចិត្តឡើយ ។ បើសិនជាគេបណ្តោយឱ្យស្នាមគំនូសនេះរលប់បាត់អស់នោះ ទោះបីជាគេកើតក្នុងសម័យពុទ្ធកាលទាន់ព្រះសម្មាសម្ពុទ្ធ ពោរពេញទៅដោយលោកអ្នកប្រាជ្ញទាំងឡាយ មានព្រះបច្ចេកពុទ្ធ ព្រះអរហន្តាខីណាស្រពយ៉ាងណាក៏ដោយ ក៏គេមិនអាចបំពេញទាន មានថ្វាយចង្ហាន់ដល់ព្រះសម្ពុទ្ធបរមគ្រូព្រមទាំងព្រះអរិយសាវ័កទាំងឡាយ សូម្បីតែបាយមួយវែក បបរមួយបោយក៏គ្មានសោះឡើយ ដូចជាតោទេយ្យព្រាហ្មណ៍ គ្មានសីលព្រោះជាអ្នកប្រទូស្តស្អប់ខ្ពើម ព្រះពុទ្ធអង្គ ជាមនុស្សមិច្ឆាទិដ្ឋិយល់ឃើញខុសពីសេចក្តីពិត វង្វេងងងឹតឥតពន្លឺ ព្រោះការហួងហែងជាប់ជំពាក់ ដោយខ្វះទាន សីល ភាវនា ជាឧបនិស្ស័យ ។

ក្នុងសាកលលោកនេះ ទោះបីជាវិទ្យាសាស្ត្របច្ចេកទេសរីកចំរើនដល់កំរិតណា ក៏គេមិនអាចកែច្នៃសំណ ឬ ស្ពាន់ឱ្យក្លាយទៅជាមាស ហើយពុំអាចច្នៃមាស ឱ្យក្លាយទៅជាដុំពេជ្រមានពន្លឺចែងចាំងបានឡើយ យ៉ាងណាមិញ, បុគ្គលដែលគ្មានបុណ្យព្រេងសំណាង ទោះបីជាលើកដាក់ឱ្យអង្គុយលើបល្ល័ង្ក តែងតាំងឱ្យមានអំណាចមុខតំណែងតួនាទីដ៏ខ្ពស់ខ្ពង់ ក៏មិនអាចរក្សាបល្ល័ង្កនោះឱ្យគង់វង់បិតបេរបានសោះឡើយ ។

សេចក្តីព្យាយាម ធ្វើឱ្យសំរេចជោគជ័យគ្រប់បែបយ៉ាងបាន

*តែបើគ្មានបុណ្យក៏ព្វព្រេងសំណាងសាងមកជាជំនួយផងទេ គេតែងប្រទះឧបសគ្គវិបត្តិយ៉ាងនេះ យ៉ាងនោះ រហូតដល់ពេលខ្លះមានការខកខូចតូចចិត្ត ត្បិតតែមិនបានសម្រេច ទៅតាមសេចក្តីបំណងប៉ងប្រាថ្នានោះ ។*

*ព្រះពុទ្ធដីកា ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃលោក ទ្រង់បានត្រាស់សំដែងធម៌ទេសនា ទូន្មានសត្តនិករ មានច្រើនប្រការណាស់ តែបើពោលបំព្រួញដោយខ្លី មានត្រឹមតែ ៣ យ៉ាង គឺ ៖*

១- **សព្វបាបស្ស អករណំ** *មិនត្រូវធ្វើបាបគ្រប់យ៉ាង ,*

២- **កុសលស្សូបសម្បទា** *ត្រូវបំពេញបុណ្យកុសល,*

៣- **សចិត្តបរិយោទបនំ** *ត្រូវជុសខាត់ជម្រះចិត្តរបស់ខ្លួនបានឱ្យស្អាត ។*

*ព្រះពុទ្ធសាសន៍ទាំងបីនេះ ពុំមែនជាព្រះពុទ្ធដីកា របស់ព្រះពុទ្ធសមណគោត្តមតែមួយព្រះអង្គឯងនោះទេ គឺជាពុទ្ធវចនៈរបស់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គ ។*

*ដូច្នេះការបំពេញទាន រក្សាសីល ចំរើនភាវនា ឃើញថាជាការគ្រប់គ្រាន់ណាស់ទៅហើយ ព្រោះទានអាចកំចាត់បង់លោភៈនិង មច្ឆរិយៈ សីលអាចកំចាត់បង់ទោសៈ ភាវនាអាចកំចាត់បង់មោហៈ ។ លោភៈ ទោសៈ មោហៈ ទាំង ៣ ប្រការនេះ ចាត់ជា*

*អកុសលមូល គឺឫសគល់នៃអំពើបាបអកុសលទាំងឡាយ ។ ចុះបើឫសគល់នៃអំពើបាបទាំងនោះ ត្រូវបានកំចាត់បង់អស់ទៅហើយ តើមែកជាងស្លឹកផ្លែផ្កា នៃអំពើបាបអកុសលទាំងនោះ នឹងកើតមកពីណាទៀត ? ។*

*បុគ្គលដែលមានសេចក្ដីព្យាយាម បំពេញទានសីលភាវនា ឱ្យបានជាឧបនិស្ស័យ ឈ្មោះថា ជាអ្នកបានសាងភ័ព្វព្រេងវាសនា បុណ្យបារមី និង ឈ្មោះថា បានដុសខាត់សំអាតចិត្ត ឱ្យបរិសុទ្ធផូរផង់ តាមឱវាទរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ រួចស្រេចទៅហើយ ។*

**ឧបនិស្ស័យ ៣ ប្រការ មានផល្លានិសង្សផ្សេងៗគ្នា គឺ ៖**

១- **ទានូបនិស្ស័យ** *បុគ្គលអ្នកមានទានូបនិស្ស័យនឹងកើតក្នុងត្រកូលប្រកបដោយភោគសម្បត្តិ ជាអ្នករកទទួលទានមានបានធ្វើអាជីវកម្ម រមែងសម្រេចតាមសេចក្ដីប្រាថ្នា ឥតមានឧបសគ្គណាមករារាំង ធ្វើឱ្យខូចខាតបាត់បង់គុណប្រយោជន៍នោះទេ ។*

២- **សីលូបនិស្ស័យ** *បុគ្គលអ្នកមានសីលូបនិស្ស័យនឹងបានកើតក្នុងត្រកូលខ្ពង់ខ្ពស់ ប្រកបដោយកិត្តិយស តំណែងតួនាទីល្អមានរូបសម្បត្តិឆើតឆាយ សំឡេងពិរោះ សុខភាពបរិបូណ៌ អាយុយឺនយូរឥតមានរោគាពាធ បៀតបៀនឱ្យដល់នូវទុក្ខវេទនា ។*

៣- **ភាវនូបនិស្ស័យ** *បុគ្គលអ្នកមានភាវនូបនិស្ស័យ នឹង*

បានជាអ្នកមានប្រាជ្ញាឆ្លាតវៃ មានស្មារតីចិត្តគំនិតរឹងប៉ឹងក្លាហាន ប្រកបការងារសិក្សារៀនសូត្រ ឆាប់ចេះចាំដឹង យល់ស្គាល់ច្បាស់ហេតុការណ៍ តាមសភាពពិតៗ ។

ការរៀបរាប់អានិសង្សទាន សីល ភាវនា ដោយសង្ខេបខ្លី គឺដើម្បីបញ្ជាក់ន័យឡើងវិញ អំពីពាក្យថា "ភ័ព្វព្រេងសំណាងល្អ នេះឯង ។ អ្វីដែលហៅថា ភ័ព្វព្រេង សំណាងល្អ ? ភ័ព្វព្រេងសំណាងល្អ គឺជាភោគសម្បត្តិ រូបសម្បត្តិ បញ្ញាសម្បត្តិ ដែលកើតបានពីបុណ្យព្រេងសំណាង ខំសន្សំបំពេញទាន សីល ភាវនា ឱ្យបានជាឧបនិស្ស័យ ដូចពោលរួចមកហើយ ។

សរុបសេចក្តីមក រូបសម្បត្តិក្តី ភោគសម្បត្តិក្តី បញ្ញាសម្បត្តិក្តី សុទ្ធតែជាវត្ថុប្រាថ្នា របស់សត្វលោក ក្នុងឋានមនុស្ស ទេវតា ព្រហ្ម ដែលត្រូវបានទៅតាមឧបនិស្ស័យ និង ការព្យាយាមខំសន្សំកសាង ។ ប៉ុន្តែភ័ព្វព្រេងសំណាងល្អ ក្នុងកំណើតមនុស្ស ទេវតា ព្រហ្ម ពុំបានស្មើគ្នានោះទេ ព្រោះនៅមានការប្រណាំងប្រជែង គឺនៅមានឋានៈ ទាបខ្ពស់ ខុសដោយឡែកពីគ្នា បើស្មើគ្នាវិញនោះ គឺស្មើដោយភាពអន្ទោលវិលកើត ចាស់ ឈឺ ស្លាប់ ឬ ស្មើដោយត្រៃលក្ខណធម៌ទាំងបី គឺ អនិច្ចំ ទុក្ខំ អនត្តា ។ រាល់តែកំណើតដែលមាននៅក្នុងកាមភព រូបភព អរូបភព មិនអាចគេចផុតរត់រួច

ពីសភាពមិនទៀង ( អនិច្ចំ )សភាពជាទុក្ខ ( ទុក្ខំ ) និង សភាពសូន្យ ទទេ ឬ ហាមមិនបាន ( អនត្តា ) ជាដាច់ខាត ។

លោកអ្នកបានបំពេញទាន សីល ភាវនា ឱ្យបានជាឧបនិស្ស័យស្មើដូចគ្នា បើកើតក្នុងឋានមនុស្ស រមែងបានជួបគ្នាដោយក្ដីសុខ មនោរម្យ ជាគូស្វាមីភរិយា បងប្អូនកូនចៅផៅញាតិ មាតាបិតា មិត្តភក្ដិ ឬធ្វើការរួមគ្នាជាសមាគមអ្វីមួយ តែងប្រព្រឹត្តទៅនៅក្នុងគោលដៅ ចេះបែងចែករំលែក ឱ្យអភ័យ ជួយគ្នាមានចិត្តស្មោះត្រង់ ចរិយាអធ្យាស្រ័យទន់ភ្លន់មិនបៀតបៀនគ្នា គោរពសិទ្ធិ មិនគិតកេងប្រវ័ញ្ចយកឈ្នះចាញ់គ្នា មានចិត្តមេត្តាអាណិតអាសូរចែករំលែកគុណប្រយោជន៍ដល់គ្នា ប្រកបដោយតម្លាភាព មានតម្រិះប្រាជ្ញា ពិចារណាហេតុផល យល់ច្បាស់ពិតប្រាកដ ។

អាស្រ័យហេតុនេះ បើចង់ឱ្យមានឈ្មោះថា ជាអ្នកមានភ័ព្វព្រេងសំណាងល្អ ប្រកបដោយភោគសម្បត្តិ រូបសម្បត្តិ បញ្ញាសម្បត្តិ ពុទ្ធបរិស័ទទាំងឡាយ ដែលមានជំនឿក្នុងសទ្ធា ៤ យ៉ាង គឺ ១- កម្មសទ្ធា ការជឿលើកម្ម គឺអំពើឯណានីមួយ ដែលសត្វបានធ្វើ, ២- វិបាកសទ្ធា ការជឿផល គឺផលនៃកុសល និង អកុសកម្ម, ៣- កម្មស្សកតាសទ្ធា ការជឿថា សត្វទាំងឡាយ មានកម្មដែលខ្លួនធ្វើហើយជារបស់ខ្លួន, ៤- តថាគតពោធិសទ្ធា ជឿការត្រាស់ដឹង

*របស់តថាគត គួរគប្បីរៀនធ្វើទាន រក្សាសីល ចំរើនភាវនា ឱ្យបានខ្ជាប់ខ្ជួន បានជាមនុស្សមានសីល ទាន ភាវនា ជាកល្យាណការី ព្រោះថាបើបច្ចុប្បន្នជាតិនេះល្អហើយ អនាគតជាតិក៏នឹងល្អដែរ ។ បច្ចុប្បន្នជាតិនេះ នឹងក្លាយជាអតីតជាតិ របស់អនាគតជាតិ ។*

*ទ្រឹស្តីកម្មផលនិយាយថា អ្វីៗដែលយើងមានក្នុងបច្ចុប្បន្នជាតិ ដូចជាអាក្រក់ ល្អ មាន ក្រ ស ខ្មៅ ឆ្លាត ល្ងង់ ។ ល ។ អាស្រ័យមកពីផលនៃកម្ម របស់យើងពីអតីតជាតិ ហើយផលនៃកម្មក្នុងបច្ចុប្បន្នជាតិនេះស្តាបនាជីវិតយើងនាអនាគតជាតិ ។*

*យើងគួរចាប់អារម្មណ៍ថា ថ្វីបើអ្វីៗ យើងមានក្នុងបច្ចុប្បន្ន-ជាតិ គឺជាផលនៃកម្មបន្តមកអំពីអតីតជាតិ ប៉ុន្តែអតីតជាតិ និងបច្ចុប្បន្នជាតិ មិនដូចគ្នាទាំងស្រុងទេ ។ គឺដូចគ្នាខ្លះ ខុសពីគ្នាខ្លះ ដែលដូចគ្នាត្រង់បច្ចុប្បន្នជាតិ ជាផលនៃកម្មពីអតីតជាតិ ដែលខុសគ្នាត្រង់បច្ចុប្បន្នជាតិ យើងមានការសិក្សា កសាង អប់រំបណ្តុះបណ្តាលថ្មីទៀត ដោយន័យថា ក្នុងបច្ចុប្បន្នជាតិនេះ យើងមានឱកាសកែច្នៃរចនាជីវិតយើង ឱ្យបានចំរុងចំរើនរុងរឿង សម្រាប់អនាគតជាតិ ។*

# រឿងតោទេយ្យព្រាហ្មណ៍

ក្នុងពុទ្ធសម័យ ព្រះសមណគោត្តមបរមគ្រូទ្រង់គង់ធរមាននៅឡើយ មានព្រាហ្មណ៍ម្នាក់ឈ្មោះតោទេយ្យព្រាហ្មណ៍ ជាអ្នកមានទ្រព្យសម្បត្តិច្រើន ប៉ុន្តែគាត់បានក្លាយទៅជាមនុស្សអភ័ព្វគ្មានជឿបុណ្យ បាប គុណទោស ព្រេងសំណាងអ្វីសោះ ។

ព្រាហ្មណ៍នេះជាមនុស្សកំណាញ់ស្វិត ឥតហ៊ានចាយវាយបរិភោគប្រើប្រាស់ខ្លួនគាត់ ឬចែកចាយចំណាយដល់កូនចៅញាតិមិត្រសាច់សារលោហិតណាក៏ទេដែរ ។ កាលគាត់មានជីវិតរស់នៅគាត់ខំលបលួចយកទ្រព្យមានមាសពេជ្រកែវកង ទៅកប់ទុកនៅក្រោមជណ្តើរផ្ទះ មិនឱ្យអ្នកណាម្នាក់ដឹង សូម្បីតែកូនប្រុស បង្កើតរបស់គាត់ក៏ពុំឱ្យដឹងដែរ ។

រាល់ព្រឹកព្រះសម្មាសម្ពុទ្ធ មួយអន្លើដោយព្រះអានន្ទព្រមទាំងភិក្ខុសង្ឃទាំងឡាយ ទ្រង់និមន្តបិណ្ឌបាត នៅចំពោះមុខផ្ទះគាត់ ក៏ព្រាហ្មណ៍ពុំអើពើនឹងដាក់បាត្របាយមួយវែក ឬ បបរមួយបោយសោះឡើយ ។ មិនតែប៉ុណ្ណោះ ព្រាហ្មណ៍ទុយ៌ស មានចិត្តស្អប់ខ្ញើមធុញទ្រាន់ចំពោះព្រះសម្មាសម្ពុទ្ធជាខ្លាំងថែមទៀតផង ។

រាល់ព្រឹកឱ្យតែឃើញព្រះអង្គនិមន្តទៅដល់ ព្រាហ្មណ៍តាំងស្រែកជេរតិះដៀលថា " ឃីអើ ! សមណគោត្តមអង្គនេះមិនចេះធ្វើ

ការរកស៊ីអ្វីនឹងគេសោះ មួយថ្ងៃៗគិតតែពីដើរសូមទានគេ”។ គាត់ស្រែកជេរ ដោយសំដីជេរៗ ជារៀងរាល់ព្រឹក រហូតដល់ព្រះអានន្ទ ជាឧបដ្ឋាករបស់ព្រះអង្គ មានការធុញទ្រាន់ ទើបទូលសូមអង្វរព្រះសម្មាសម្ពុទ្ធយ៉ាងនេះថា“បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គកុំនិមន្តបិណ្ឌបាតមុខផ្ទះតោទេយ្យព្រាហ្មណ៍ទៀតអី នាំតែគេជេរព្រះអង្គទេ ក្រាបទូល”។ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រាស់សួរទៅអានន្ទវិញថា “ម្នាលអានន្ទ បើដូច្នោះតើយើងនឹងទៅខាងណាទៀតអានន្ទ”?។ អានន្ទ តបទូលព្រះពុទ្ធដីកាថា“ទៅផ្លូវផ្សេងទៀត”។ ព្រះសម្ពុទ្ធទ្រង់ត្រាស់សួរទៅកាន់អានន្ទទៀតថា “ចុះបើមានគេជេរយើងទៀត តើយើងទៅខាងណាទៀតអានន្ទ?” ។ អានន្ទ ទូលថា “ចេះតែទៅផ្លូវឯទុំះផ្សេងទៀតព្រះអង្គ ” ។

ព្រះពុទ្ធអង្គ ទ្រង់មានព្រះភក្ត្រញញឹម ព្រមទាំងមានព្រះតម្រាស់ទៅកាន់អានន្ទ យ៉ាងនេះថា “ម្នាលអានន្ទ ក្នុងលោកនេះទោះបីនៅក្នុងទីណាក៏ដោយ អ្នកដែលគេមិននិន្ទានោះ ឥតមានសោះឡើយ ( **នត្ថិ លោកេ អនិន្ទិតោ** ) ហើយនៅក្នុងលោកនេះក៏គ្មានទីណាឱ្យស្ងាត់កំបាំងដែរ ( **នត្ថិ លោកេ រហោនាម** )” ។ ព្រះអង្គតែងតែនិមន្តបិណ្ឌបាត រាល់ៗព្រឹក ជាប្រចាំនៅពីមុខផ្ទះតោទេយ្យព្រាហ្មណ៍ ដ៏មហាសែនកំណាញ់ស្វិត ។

ក្រោយមក តោទេយ្យព្រាហ្មណ៍ ធ្លាក់ខ្លួនមានជម្ងឺឈឺដល់ស្លាប់ បានទៅចាប់កំណើតជាសត្វឆ្កែនៅក្រោមផ្ទះ របស់គាត់នោះឯង ។ លុះដល់កូនឆ្កែធំឡើង ដោយអំណាចចិត្តជាប់ជំពាក់នឹងទ្រព្យសម្បត្តិ ជារៀងរាល់ថ្ងៃ តែងតែទៅដេកក្រោមជណ្ដើរ ដោយមានចិត្តនឹកខ្លាចក្រែងគេមកជណ្ដើមយកកំណាប់ទ្រព្យសម្បត្តិ ។

រាល់ពេលព្រឹកឱ្យតែព្រះពុទ្ធបរមសាស្ដា ព្រះអង្គនិមន្តដល់មុខផ្ទះ ឆ្កែតោទេយ្យព្រាហ្មណ៍ ស្ទុះចេញមកឈរសម្លឹងមើល ព្រះភក្ត្រព្រះអង្គ ហើយព្រុសឥតឈប់ ។ នៅពេលព្រឹកមួយ ព្រះបរមសាស្ដាទ្រង់មានព្រះភក្ត្រញញឹម ទើបទ្រង់ត្រាស់ទៅកាន់ឆ្កែ តោ-ទេយ្យព្រាហ្មណ៍ថា "ម្នាលតោទេយ្យព្រាហ្មណ៍ កាលអ្នកនៅជាតិជាមនុស្ស អ្នកស្អប់ខ្ពើមតថាគតណាស់ ។ អ្នកមិនដែលធ្វើបុណ្យទាន ប្រគេនចង្ហាន់ដល់តថាគត ឬ ព្រះសង្ឃអង្គណា សូម្បីតែបាយមួយវែកក៏គ្មានដែរ មិនតែប៉ុណ្ណោះ អ្នកថែមទាំងស្អប់តថាគតស្រែកជេរតថាគត រាល់ពេលវេលា ។ ឥឡូវនេះ អ្នកបានស្លាប់ទៅចាប់កំណើតជាសត្វឆ្កែហើយ ក៏នៅតែស្អប់ខ្ពើមតថាគតទៀត " ។

ក្នុងពេលដែលព្រះអង្គមានព្រះតម្រាស់ ចំពោះឆ្កែយ៉ាងនេះ កូនប្រុសតោទេយ្យព្រាហ្មណ៍ស្ដាប់ឮ មានការថ្នាំងថ្នាក់អាក់អន់ចិត្តជាខ្លាំង ទើបទូលសួរព្រះសម្ពុទ្ធ អំពីហេតុការណ៍នោះ ។

ព្រះពុទ្ធសំដែងពន្យល់ព្រាហ្មណ៍បុត្រថា "ម្នាលព្រាហ្មណ៍បុត្រ ! អ្នកអត់បានយល់ដឹងទេថា ឪពុកអ្នកជាមនុស្សកំណាញ់ស្វិត ជាមនុស្សមានចិត្តជាប់ជំពាក់នឹងទ្រព្យសម្បត្តិ មិនដែលចេះលះបង់ចែកចាយចំណាយជួយអ្នកដទៃ សូម្បីតែបន្តិចបន្តួចឡើយ ទាំងខ្លួនឯងសោតទៀតក៏មិនហ៊ានចាយបរិភោគដែរ ។ ដោយអំណាចការជាប់ជំពាក់នឹងទ្រព្យសម្បត្តិ និង សេចក្តីកំណាញ់ស្វិតស្វាញ ទើបធ្វើឱ្យគាត់ស្លាប់ទៅកើតជាសត្វឆ្កែ ដេកចាំថែរក្សាទ្រព្យដោយខ្លាចមានគេមកដណ្តើមយក ។ បើអ្នកមិនជឿទេ អ្នកទៅជីកនៅក្រោមជណ្តើរ អ្នកនឹងឃើញមាសប្រាក់កែវកងនោះហើយ" ។

ព្រាហ្មណ៍បុត្រ ប្រញាប់នាំអ្នកបំរើទៅជីកក្រោមជណ្តើរ ឃើញមាសពេជ្រកែវកងយ៉ាងច្រើនសន្ធឹកសន្ធាប់ ទើបលាន់មាត់ថា "ឱ ! ឪពុកយើងជាមនុស្សល្ងង់ណាស់ ឥតហ៊ានចាយវាយបរិភោគទ្រព្យសម្បត្តិខ្លួនឯងផង ទាំងឥតបានចំណាយទ្រព្យធនបំពេញបុណ្យទានឱ្យបានជាផលប្រយោជន៍ផង ថែមទាំងបំផ្លាញជាតិកំណើតជាមនុស្សស្មូន្យសោះ ក្លាយទៅជាកំណើតតិរច្ឆានវិញយ៉ាងនេះ ។ ដូច្នេះយើងនឹងខិតខំបំពេញទាន ឱ្យបានជាផលប្រយោជន៍កើតពីទ្រព្យសម្បត្តិទាំងឡាយតរៀងទៅ" ។

អំណឹះតមក ព្រាហ្មណ៍បុត្រ បានជាពុទ្ធសាសនិកដ៏ឆ្នើមខំ

*ព្យាយាមបំពេញទាន រក្សាសីល ចំរើនភាវនា តាមព្រះពុទ្ធដីកា យ៉ាងខ្ជាប់ខ្ជួន ឥតមានធ្វេសប្រហែសឡើយ ។*

*រឿងនិទានខាងលើនេះ បញ្ជាក់ឱ្យឃើញថា អ្នកមានទ្រព្យសម្បត្តិ ដ៏មហាសាលយ៉ាងណាក៏ដោយ តែបើបណ្តោយចិត្តឱ្យស្ថិតនៅក្រោមអំណាចលោភៈមច្ឆរិយៈហើយ ក៏ពុំអាចបំពេញទានកើតដែរសមដូចព្រះពុទ្ធដីកា ក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយសម្តែងថា "***មច្ឆេរំ ទទតោ មលំ*** *សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឱ្យ (ទាន)" ។ម្យ៉ាងវិញទៀត អ្នកដែលមានចិត្តលោភលន់ជាប់ជំពាក់ហួងហែងចំពោះភោគសម្បត្តិ ដោយខ្វះប្រាជ្ញាពិចារណាឱ្យឃើញគុណទោស ដែលកើតមានអំពីទ្រព្យសម្បត្តិនោះៗ ទុកដូចជាមនុស្សសម្លាប់ខ្លួន ឬ បានបំផ្លាញខ្លួនព្រោះតែភោគទ្រព្យ មានតួយ៉ាងដូចជាតោទេយ្យព្រាហ្មណ៍យ៉ាងនេះឯង បានជាព្រះពុទ្ធអង្គទ្រង់សំដែងបញ្ជាក់យ៉ាងនេះទៀតថា ៖*

"**ភោគា តណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តានំ** " ។

*"មនុស្សអាប់ឥតប្រាជ្ញា តែងតែសម្លាប់ខ្លួនឯង ដូចសម្លាប់អ្នកដទៃព្រោះចង់បានភោគសម្បត្តិ " ។*

*ដូច្នេះ ដើម្បីប្រឆាំងឱ្យឈ្នះចិត្តលោភលន់ កំណាញ់បាន យើងត្រូវប្រើវិចារណញ្ញាណ ទៅតាមព្រះពុទ្ធដីកា ដែលទ្រង់មាន*

ព្រះតម្រាស់បញ្ជាក់ទៀតថា "កាលបើផ្ទះត្រូវភ្លើងឆាបឆេះហើយ ទ្រព្យសម្បត្តិណា ដែលគេប្រញាប់ជញ្ជូនចេញផុតមកបាន ទ្រព្យសម្បត្តិនោះ នឹងបានទៅជាប្រយោជន៍របស់គេ យ៉ាងណាមិញ, អត្តភាពរាងកាយនៃសត្វទាំងឡាយ កាលបើត្រូវភ្លើង គឺជរា ព្យាធិ មរណៈ ឆាបឆេះហើយ, ទ្រព្យសម្បត្តិទាំងឡាយ ក៏ត្រូវតែវិនាសអន្តរាយទៅជាមួយនឹងរូបរាងកាយនោះដែរ ។ ដូច្នេះដើម្បីឱ្យបានប្រយោជន៍អំពីទ្រព្យសម្បត្តិ គប្បីជញ្ជូនទ្រព្យសម្បត្តិចេញ ឱ្យផុតពីអត្តភាព ពោលគឺរូបរាងកាយដោយការខ្វល់ខ្វាយបំពេញទាន។ ទានដែលគេបានបរិច្ចាគហើយ ឈ្មោះថាគេបានច្បាំងឈ្នះសត្រូវ ពោលគឺ លោភៈ មច្ឆរិយៈ ផង ឈ្មោះថា គេបានជញ្ជូនសម្បត្តិឱ្យផុតពីភ្លើងឆេះផង និង បានធ្វើទ្រព្យសម្បត្តិ ដែលឥតខ្លឹមសារ ឱ្យមានខ្លឹមសារផង" ។

ព្រះពុទ្ធបរមគ្រូ ទ្រង់ត្រាស់បន្ថែមថា ៖

"**ភោគោ អសារោ សារមោ ទាតព្វោ** " ។

ភោគៈទាំងឡាយឥតខ្លឹមសារ តែអ្នកមានប្រាជ្ញាអាចធ្វើឱ្យមានខ្លឹមសារបាន" ។

# ព្រះបោឋិលត្ថេរ

សម័យមួយ ព្រះទសពលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចំពោះបោឋិលត្ថេរ ជាអ្នកមានប្រាជ្ញាវាងវៃ ចេះចាំចប់ព្រះត្រៃបិដក ជាធម្មាចារ្យដ៏ឆ្នើម បង្រៀនធម៌ដល់ភិក្ខុទាំងឡាយ ។

គ្រាមួយ ព្រះបោឋិលៈ បានឮព្រះបរមសាស្តា ត្រាស់ហៅខ្លួនថា "**ភិក្ខុមានគម្ពីរទទេ**" ក៏កើតមានសេចក្តីតក់ស្លុតយ៉ាងខ្លាំង ហើយបានចូលទៅអាស្រ័យជាមួយនឹងពួកភិក្ខុ ដែលសុទ្ធសឹងតែជាព្រះអរហន្តមានប្រមាណ៣០អង្គនៅក្នុងព្រៃស្ងាត់មួយកន្លែង ។ ដំបូងព្រះបោឋិលៈបានចូលទៅរកព្រះថេរៈ ដែលជាប្រធានមុនគេ សុំយកព្រះថេរៈធ្វើជាគ្រូបង្រៀនវិបស្សនា របស់ខ្លួន ប៉ុន្តែព្រះថេរៈជាប្រធានបានបដិសេធមិនព្រមទទួល ។

បន្ទាប់មក ព្រះបោឋិលៈ បានចូលទៅរកព្រះថេរៈដទៃៗទៀតធ្វើជាគ្រូ តែត្រូវព្រះថេរៈទាំងនោះបដិសេធដដែល ។ ទីបំផុតក៏បានចូលទៅរកសាមណេរអាយុ ៧ ឆ្នាំ ។ សាមណេរបានគង់ធ្វើព្រងើយដូចជាមិនចង់ទទួលព្រះបោឋិលៈធ្វើជាសិស្ស ។

ព្រះបោឋិលៈ បានសុំអង្វរករសាមណេរ ជាច្រើនលើកច្រើនគ្រា, លុះសាមណេរនោះ ដឹងថា ព្រះបោឋិលៈ លះទិដ្ឋិមានះខ្លះហើយ លោកក៏បានប្រាប់ថា" លោកអាចារ្យ ដំបូកមួយ មានរន្ធ

ដល់ទៅ ៦, សត្វទន្សោង ចូលទៅនៅខាងក្នុងបាន តាមរន្ធតែមួយ, ឯបុគ្គលដែលប្រាថ្នាចង់ចាប់សត្វទន្សោងនោះ ត្រូវតែញ៉ុករន្ធទាំង៥ ហើយ ចាំចាប់វានៅក្បែរមាត់រន្ធ ដែលទន្សោងនោះចូលទៅ យ៉ាងណាមិញ, លោកគ្រូអាចារ្យ ត្រូវបិទទ្វារទាំង ៥ ហើយត្រូវកំណត់ការងារក្នុងមនោទ្វារ ក៏យ៉ាងនោះឯង" ។

ព្រះបោឋិលៈ បានស្តាប់យ៉ាងដូច្នេះហើយ កើតមានបញ្ញាយល់ជាក់ច្បាស់ ឥតមានសេចក្តីសង្ស័យ ព្រោះលោក ជាពហុស្សូត្រ ហើយបានចាប់ផ្តើមប្រារព្ធបំពេញនូវសមណធម៌ ។

ព្រះបរមគ្រូ ទ្រង់បានបញ្ចេញព្រះរស្មីទៅ បីដូចជាប្រថាប់គង់នៅក្នុងទីចំពោះមុខ ហើយត្រាស់ព្រះគាថានេះថា ៖

"**យោគា វេ ជាយតេ អយោគា ភូរិសង្ខយោ** ,

**ឯតំ ទ្វេធាបថំ ញត្វា ភវាយ វិភវាយ ច តថត្តានំ និវេសេយ្យ យថា ភូរិ បវឌ្ឍតិ** "។

បញ្ញាកើតឡើងបាន ព្រោះការប្រកបពិត, ការអស់ទៅនៃបញ្ញា ព្រោះការមិនប្រកប, បណ្ឌិតស្គាល់ផ្លូវទាំង ២ យ៉ាង, (គឺផ្លូវ) នៃសេចក្តីចំរើន និង សេចក្តីវិនាសនោះហើយ គប្បីតម្កល់ខ្លួនដោយហេតុដែលបញ្ញានឹងកើតឡើងបាន"។

ក្នុងព្រះពុទ្ធសាសនា លោកចែងថាមនុស្សយើងមានបញ្ញា ៣ យ៉ាង សម្រាប់បណ្តុះបណ្តាលផ្ទាល់ខ្លួននាបច្ចុប្បន្នកាល ។

បញ្ញាទាំង ៣ យ៉ាងនោះគឺៈ

១- **សុតមយបញ្ញា** បញ្ញាបានមកពីការស្តាប់ធម្មទេសនា ស្តាប់បាឋកថា ស្តាប់គ្រូបង្រៀន អានសៀវភៅ សិក្សាបរិយត្តិធម៌ ជាដើម,

២- **ចិន្តមយបញ្ញា** បញ្ញាបានមកពីការសញ្ជឹងគិត ការត្រិះរិះរកហេតុផលតាមធម្មតារបស់មនុស្ស ឬ ពិចារណាអ្វីៗដែលបានរៀនបានអាន បានស្តាប់មកហើយជាដើម ,

៣- **ភាវនាមយបញ្ញា** គឺបញ្ញាបានមកពីការចំរើន ការបតិបត្តិ ការយកបរិយត្តិធម៌ដែលបានរៀន បានអាន បានត្រិះរិះមកបតិបត្តិ ( អនុវត្ត ) ផ្ទាល់ខ្លួនមានជាអាទិ៍ គឺៈ ការចំរើនភាវនាសមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋាន ឬ សតិបដ្ឋាន ។

បញ្ញា នៅក្នុងគាថាខាងលើនេះ ព្រះពុទ្ធទ្រង់សំដៅយកភាវនាមយបញ្ញា ដែលជាបញ្ញាកើតឡើង បានដោយសារការប្រកបពិត ហើយព្រះអង្គទ្រង់ឱ្យតម្លៃខ្ពស់បំផុត ។ រីឯសុតមយ-បញ្ញា និង ចិន្តមយបញ្ញាដែលជាបញ្ញាខ្ចីពីអ្នកប្រាជ្ញដទៃនោះ ព្រះអង្គមិនសូវពេញព្រះទ័យប៉ុន្មានឡើយ ។ ដូច្នេះហើយបានជាទ្រង់ត្រាស់ហៅព្រះបោឋិលៈ ដែលរៀនចេះចាំព្រះត្រៃបិដករហូតបានជាធម្មាចារ្យថា "ភិក្ខុមានគម្ពីរទទេ" ។ ព្រះតម្រាស់ថា "ភិក្ខុមាន

គម្ពីរទទេ” គឺ ព្រះភគវា ទ្រង់បំផុសន័យថា “ភិក្ខុមានតែទ្រឹស្ដី ខ្វះការបដិបត្តិ” ។

គួរជ្រាបថាសម័យពុទ្ធកាលជាសម័យចិត្តនិយម គឺសម័យដែលមនុស្សរាប់អានការហាត់ពត់ចិត្តជាធំ ។ គេព្យាយាមហ្វឹកហ្វឺនចិត្តឱ្យបានដល់កំរិតជាចិត្តខ្ពស់ឯក។ ចិត្តដែលគេហ្វឹកហ្វឺនល្អបរិសុទ្ធហើយ អាចឱ្យគេបានសម្រេចមគ្គផលដល់ថ្នាក់ខ្ពស់បំផុត គឺសម្រេចអរហត្តបដិសម្ភិទា ជាព្រះខីណាស្រព ប្រកបដោយឫទ្ធិដូចព្រះមហាមោគ្គល្លាន ជាទុតិយសាវ័កនៃព្រះសម្ពុទ្ធជាដើម ។

ក្រោយព្រះពុទ្ធបរិនិព្វាន ការអប់រំចិត្តដោយចំរើនសមថ-កម្មដ្ឋាន វិបស្សនាកម្មដ្ឋាន ឬសតិបដ្ឋានជាដើម ត្រូវបានសាវ័កធ្វេសប្រហែស ឬ ស្ទើរតែបំភ្លេចចោល នាំគ្នាខ្វល់ខ្វាយតែខាងបរិយត្តិធម៌តែម្យ៉ាង ។ ដូច្នេះហើយបានជាលំដាប់ខាងក្រោយមកទល់គ្នានឹងបច្ចុប្បន្ននេះ គេពុំធ្លាប់ជួបប្រទះព្រះអរិយបុគ្គលគឺព្រះព្រះសោតាបន្ន, ព្រះសកទាគាមី, ព្រះអនាគាមី និង ព្រះអរហន្តសោះឡើយ ។

# អវសានកថា

ទានជាកល្យាណប្រពៃណី ជាទំនៀមមួយដ៏វិសេស របស់សប្បុរសជន មានជាប់តាំងពីមុនពុទ្ធសម័យមកម៉្លេះ ហើយក៏ជាចរិយាដ៏វិសេសនៃបណ្ឌិតទាំងឡាយ មានព្រះពោធិសត្វជាដើម ដែលលោកតែងបំពេញទុកជាឧបនិស្ស័យ ហៅថា ទានូបនិស្ស័យ ជារៀងរាល់ជាតិ មិនដែលរំលងខកខាន ។

ជនជាតិខ្មែរយើង តែងតែធ្វើទាន ដោយករុណាអាណិតអាសូរផង ដោយអនុគ្រោះចំពោះការខ្វះខាតផង ដោយការបូជាគុណធម៌ផង ដោយតបស្នងសងគុណូបការៈផង ។ ជាពិសេសជាតិខ្មែរយើងនិយមធ្វើទានដល់បព្វជិតក្នុងពុទ្ធសាសនា ជាងដល់ជនដទៃទៀត ដរាបដល់ក្មេងគិតមាតាបិតាក៏សឹងមាន មកពីយល់ឃើញថាពួកបព្វជិត តែងមានការខ្វះខាត គួរអនុគ្រោះផង មានគុណធម៌គួរដល់ការគោរពបូជាផង ។

ការធ្វើទានដល់ពួកបព្វជិតនេះ ជាមធ្យោបាយជួយពង្រីកសេចក្ដីសុខចំរើន ឱ្យរីកធំទូទៅដល់សព្វសត្វឥតរើសមុខ ព្រោះពួកបព្វជិតជាអ្នកបម្រើព្រះពុទ្ធសាសនា ដោយធ្លាប់មានប្រពៃណីធ្វើទានតាំងពីបុរាណកាល ទោះបីស្រុកទេសធ្លាក់ក្នុងវិបត្តិធំៗ ខ្សត់អ្នកប្រាជ្ញខ្សត់គម្ពីរក្បួនខ្នាត ដូចក្នុងសម័យខ្វះ មានសម័យក្រុង

លផ្សេងៗជាដើម ជនជាតិខ្មែរក៏នៅតែរក្សាប្រពៃណីធ្វើទានជរាប ។

ចំណែកជនជាតិនៅបស្ចិមប្រទេសវិញ ដែលកាន់ពាហិរ-សាសនា ( សាសនាផ្សេងពីព្រះពុទ្ធ ) និមយធ្វើទាន ដោយមានចិត្តជាសាកល គឺ មិនធ្វើចំពោះតែក្នុងវង្សជាតិសាសន៍ របស់គេប៉ុណ្ណោះទេ គេថែមទាំងចូលចិត្តធ្វើរវាងជាតិ និង ជាតិ(អន្តរជាតិ) រវាងប្រទេស និង ប្រទេស ( អន្តរប្រទេស ) រវាងទ្វីប និង ទ្វីប ( អន្តរទ្វីប ) ទៀតផង ។ ឧទាហរណ៍ ជាក់ស្តែងមានអង្គការកម្មវិធីស្បៀងអាហារពិភពលោក ( World Food Program ) អង្គការជំនួយពិភពលោក ( World Relief Organization ) អង្គការកាកបាទក្រហមអន្តរជាតិ ( International Red Cross ) និង អង្គការផ្សេងៗជាច្រើន ដែលតែងតែផ្តល់ជំនួយ ជាអំណោយមនុស្សធម៌ដល់ប្រទេសក្រីក្រកំពុងអភិវឌ្ឍនានា ក្នុងពិភពលោកក្នុងគ្រាមានទុរភិក្ស ជម្ងឺឆ្លងកាចសាហាវ គ្រោះភយន្តរាយធម្មជាតិ ដូចជាទឹកជំនន់ ព្យុះសង្ឃរា រញ្ជួយផែនដី ភ្នំភ្លើងផ្ទុះជាដើម ព្រោះគេយល់ច្បាស់ថា ទានជាសង្គហកម្មមួយដ៏ប្រពៃ ចំពោះមនុស្សជាតិលើពិភពលោកយើងនេះ ។

ពុទ្ធសាសនា អធិប្បាយថា ទានមាន ២ ប្រការ គឺ អាមិសទាន និង ធម្មទាន ។ អាមិសទាន បានដល់ការឱ្យបច្ច័យ ៤ និង

ទានវត្ថុ ( វត្ថុសម្រាប់ឱ្យទាន ) ១០ យ៉ាងជាទាន ។ រីឯធម្មទាន បានដល់ការឱ្យនូវធម៌ជាទាន ។ បណ្ដាទានទាំង ២ ប្រការនេះ ធម្មទានជាទានប្រសើរជាងអាមិសទាន ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងញែក អាមិសទាន តាមលក្ខណៈ កិច្ចរបស់ទានជាច្រើនប្រការ មានជាអាទិ៍ បាដិបុគ្គលិក-ទាន ( អសាធារណទាន ) សង្ឃទាន និង សាធារណទាន ។ បាដិបុគ្គលិកទានបានដល់ទានដែលគេឱ្យចំពោះរូបបុគ្គល គ្រួសារ ឬបក្សពួកមួយៗ ។ សង្ឃទាន បានដល់ទានដែលគេប្រគេនចំពោះព្រះសង្ឃដោយគោរព និង តាំងចិត្តជ្រះថ្លា។ សាធារណទានបានដល់ទានដែលគេឱ្យចំពោះមនុស្សទូទៅ មិនប្រកាន់ជាតិ សាសន៍ពណ៌សម្បុរ ។ សង្ឃទាន និង សាធារណទាន រមែងបានផលជាងបាដិបុគ្គលិកទាន ឬ អសាធារណទាន ។

សាធារណទាន បានផលប្រហាក់ប្រហែលគ្នានឹងសង្ឃ-ទានដែរ ខុសប្លែកត្រង់សាធារណទាន ងាយស្រួលធ្វើជាងសង្ឃទាន ។ ដែលថាសាធារណទានងាយធ្វើនោះ គឺទាយកងាយនឹងក្រាលចិត្តចំពោះសាធារណប្រយោជន៍ ដូចសាងសង់អាគារសិក្សាមន្ទីរពេទ្យ មណ្ឌលកុមារកំព្រា មជ្ឈមណ្ឌលវិបស្សនា កុដិ សាលាព្រះវិហារ ។ ល ។ ដើម្បីជាផលប្រយោជន៍ដល់សិស្ស អ្នកជម្ងឺ ក្មេង

កំព្រាអនាថា វិបស្សនាជន ព្រះសង្ឃមិនរើសមុខ ។ ដែលថាសង្ឃទាន លំបាកនឹងធ្វើនោះ គឺថាទាយកលំបាកនឹងធ្វើប្រកបដោយឧបេក្ខាសហគតចិត្ត ព្រោះថាបើទាយកទាយិកា ធ្វើប្រកបដោយសោមនស្សសហគតចិត្ត ឬ ទោមនស្សសហគតចិត្តនោះ ទានរបស់គេនឹងធ្លាក់ទៅជាបាដិបុគ្គលិកទាន ដោយស្វ័យប្រវត្តិ ។

ទស្សនពុទ្ធនិយមបង្ហាញថា ផលនៃការឱ្យទាននេះ រមែងបណ្ដាលឱ្យពួកទាយកបានជាទីពេញចិត្ត នៃសាធុជនទាំងឡាយ មានមនុស្សល្អនិយមសេពគប់រាប់រក មានសេចក្ដីក្លាហានមិនអឹមអៀន ពេលចូលទៅកាន់ទីប្រជុំជន មានកិត្តិស័ព្ទល្បីខ្ចរខ្ចាយ គ្រប់ទិសានុទិស ហើយមានកំណើតដ៏ល្អក្នុងសុគតិភព បន្ទាប់អំពីធ្វើមរណកាល លាចាកលោកនេះទៅ ។

គឺនៅក្នុងញាណទស្សនៈថា ការបរិច្ចាគទាន មានសារប្រយោជន៍ដល់ជីវិតបច្ចុប្បន្ន និង អនាគតដូច្នេះឯង ទើបព្រះពុទ្ធបរមគ្រូ ទ្រង់ខិតខំស្រាវជ្រាវសំដែងពន្យល់ពុទ្ធបរិស័ទ អំពីទាន និង របៀបធ្វើទានឱ្យបានបរិសុទ្ធយ៉ាងល្អិតល្អន់សព្វគ្រប់ សឹងមានប្រាកដក្នុងស្ពានធម៌ផ្សេងៗ ដូចជាក្នុងអនុបុព្វីកថា បារមីធម៌ សប្បុរិសបញ្ញត្តិ បុញ្ញកិរិយាវត្ថុ ទសពិធរាជធម៌ អរិយទ្រព្យ អធិដ្ឋាន សង្គហធម៌ ឧបនិស្ស័យ ។ល។

ក្នុងអនុបុព្វីកថា ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងអំពីទាន ជាមុន ទើបទ្រង់សម្តែងអំពីសីល ភាវនាជាក្រោយ ។ ព្រះលោកនាថទ្រង់ចាត់ទានជាកម្មវត្ថុដំបូង ព្រោះទ្រង់ចង់ពន្យល់ដល់សត្វលោកឱ្យបានដឹងយល់អំពីភាពខ្សត់ អត់ឃ្លាន កង្វះខាត សេចក្តីត្រូវការតែងចោទជាបញ្ហា សម្រាប់មនុស្សសត្វតាំងពីសម័យណា ក៏ដូចជាសម័យណាដែរ ហើយឱ្យលះបង់លោភៈ មច្ឆរិយៈ រៀនធ្វើទានសន្សំឧបនិស្ស័យមុននឹងឈានទៅដល់សីល និង ភាវនា ។

ពុទ្ធបរិស័ទ ដែលប្រាថ្នាចង់បានសេចក្តីសុខចំរើន គួរតែខំព្យាយាមសន្សំបំពេញទាន តាមសមត្ថភាព ដែលអាចធ្វើទៅបានដើម្បីបណ្តុះឧបនិស្ស័យពីបច្ចុប្បន្នជាតិ រៀងរហូតទៅតាមលំដាប់ជាតិ ព្រោះទានទុកដូចជាស្បៀង ឬ ជាកំណប់ទ្រព្យជាប់តាមខ្លួនជានិច្ច ។ អ្នកមានទានូបនិស្ស័យពីអតីតជាតិ ឈ្មោះថាជាអ្នកមានកំណប់ព្រេង ឬថាមានភ័ព្វសំណាងល្អ ជាប់តាមមកក្នុងបច្ចុប្បន្ន ។ អ្នកដែលសាងទានក្នុងបច្ចុប្បន្ន បានឈ្មោះថាជាអ្នកមានភ័ព្វព្រេងសំណាងល្អទៅអនាគត ។

ជាការពិតណាស់ មនុស្សយើងម្នាក់ៗ ជានិច្ចកាលប្រាថ្នានូវសម្បត្តិ ៣ ប្រការគឺ ភោគសម្បត្តិ រូបសម្បត្តិ និង បញ្ញាសម្បត្តិ ។ សម្បត្តិទាំង ៣ ប្រការនេះ កើតមានឡើងអាស្រ័យពីការសន្សំឧប-

និស្ស័យ ៣ យ៉ាងដែរ គឺទាន សីល ភាវនា ។ ដូច្នេះដើម្បីឱ្យបាន ប្រកបដោយសម្បត្តិ ៣ ប្រការ ឬ ពាក្យសាមញ្ញថាព្រេងសំណាង ល្អនោះ គួរនាំគ្នាហាត់រៀនធ្វើទាន រក្សាសីល ចំរើនភាវនា តាម ដែលអាចធ្វើទៅបាន កុំធ្វេសប្រហែស កុំស្រវឹងនឹងវ័យ ឈ្ងក់ វង្វេងនឹងទ្រព្យសម្បត្តិ ដូចពាក្យស្លោកបុរាណថា "ស្រវឹងទ្រព្យ ភ្លេចបុណ្យ ស្រវឹងប្រពន្ធភ្លេចម្ដាយ ស្រវឹងកាយភ្លេចចាស់ "។

កំប៉ុន្តែគួរជ្រាបថា ការធ្វើទាន រក្សាសីល ការប្រតិបត្តិដុស ខាត់សំអាតចិត្ត ពិតជាពុំមែនងាយស្រួល ដូចពោលពាក្យជា លោកវោហារ តាមការចេះចាំ យល់ដឹងពីទ្រឹស្ដីនោះសោះឡើយ សមដូចពាក្យស្លោកថា "និយាយងាយជាងធ្វើ " ។ ព្រោះហេតុ នេះ បានជាព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សម្ដែងធម៌ស្របទៅ តាមឧបនិស្ស័យរបស់សត្វ ។ ព្រះអង្គសម្ដែងអំពីទានជាលំដាប់ ថ្នាក់ខាងដើម ជាលំហាត់ដែលបុគ្គលគ្រប់ប្រភេទ ងាយស្រួលក្នុង ការបំពេញ ។ បន្ទាប់មក សីល គឺជាថ្នាក់កណ្ដាល ទើបភាវនា គឺ ជាថ្នាក់ខ្ពស់សម្រាប់អប់រំចិត្ត ឱ្យបរិសុទ្ធផូរផង់ ជាលំដាប់តទៅ ។

ក្នុងលោកនេះ ទោះបីជានៅក្នុងភូមិប្រទេសណាក៏ដោយ សាសនាដែលគេមិនរិះគន់និន្ទានោះឥតមានសោះឡើយ ពីព្រោះ មនុស្សយើងម្នាក់ៗ មានទស្សនៈគំនិតយោបល់ផ្សេងៗគ្នា ។ ទាក់

ទងនឹងឧបនិស្ស័យ ឬ ភ័ព្វព្រេងសំណាង ជនស្រុករក្រោយមួយពួកមានយោបល់ថា ពុទ្ធសាសនាអប់រំមនុស្ស ឱ្យពឹងផ្អែកខ្លួនលើព្រេងសំណាង ដែលជាហេតុមួយនាំឱ្យមនុស្សខ្ជិលធ្វើការងារ ។

គួរឱ្យអស់សំណើច ព្រោះយោបល់នៃពួកនេះ ជាយោបល់កើតឡើងតាមអារម្មណ៍ មិនមែនកើតឡើង តាមវិចារណញ្ញាណផ្អែកទៅលើវត្ថុបំណងដ៏ពិតប្រាកដ នៃពុទ្ធសាសនាឡើយ ។ ការពិត ពុទ្ធសាសនា មិនបានបង្រៀនមនុស្សឱ្យអង្គុយត្របោមក្បាលជង្គង់ យកដៃទ្រចង្ការង់ចាំព្រេងវាសនាដួសបាយបញ្ចុកទេ ។ ផ្ទុយទៅវិញ ពុទ្ធសាសនាបង្រៀនមនុស្សម្នាក់ៗឱ្យទទួលខុសត្រូវចំពោះជោគវាសនារបស់ខ្លួន បានន័យថាជោគវាសនារបស់មនុស្សម្នាក់ៗស្ថិតនៅក្នុងកណ្តាប់ដៃរបស់ខ្លួនឯង ពុំមែនស្ថិតនៅក្នុងកណ្តាប់ដៃរបស់ព្រះអាទិទេព ឥន្ទ ព្រហ្មឡើយ ។

គួរជ្រាបថា ពុទ្ធសាសនាជាញាណទស្សនវិជ្ជានៃកម្មនិយម ជាសាសនាបង្រៀនមនុស្សឱ្យធ្វើការ ( កម្ម )ពុំដែលបង្រៀនមនុស្សឱ្យដេកផ្សងព្រេងម្តងណាឡើយ ប៉ុន្តែពន្យល់ថា មនុស្សមានភ័ព្វវាសនារមែងមានកំណើតល្អ ធ្វើការងារធាប់បានសម្រេចផល ។

ព្រះពុទ្ធបរមសាស្តានៃយើង មិនមែនមានភារកិច្ចត្រឹមតែក្រើនរំលឹកឱ្យមនុស្សធ្វើការប៉ុណ្ណោះទេ ព្រះអង្គថែមទាំងបានដៅ

បញ្ជាក់ថា "**វីរិយេន ទុក្ខមច្ចេតិ** ប្រែថា ដោយសេចក្តីព្យាយាម មនុស្សអាចឆ្លងពីទុក្ខទោសគ្រប់យ៉ាងបាន"។ អធិប្បាយថាសេចក្តីទុក្ខរបស់មនុស្សដែលនឹងអស់ទៅបាន ក៏ដោយសារសេចក្តីខំប្រឹងព្យាយាមរបស់មនុស្សទាំងឡាយ ។

ដូច្នេះឃើញថា ព្រះពុទ្ធសាសនាមិនមែនជាសាសនាសាងសេចក្តីសុខ និងរំលត់រំលាយសេចក្តីទុក្ខដោយការផ្សងព្រេងទេ ។ ប៉ុន្តែមនុស្សកំជិលបេះតែនាំគ្នាដេកផ្សងព្រេង លុះធ្លាក់ខ្លួនទៅជាមនុស្សក្រខ្សត់ ក៏តាំងចោទពុទ្ធសាសនាថា បង្រៀនខ្លួនឱ្យដេកផ្សងព្រេងទៅវិញ ។

គួរឱ្យសោកស្តាយ មានពុទ្ធបរិស័ទមួយចំនួន មានចិត្តរើរវាយមានសទ្ធាដូចទឹកលើស្លឹកឈូក ពុំព្រមចង់ប្រើប្រាស់ប្រាជ្ញាពិចារណាថា "មនុស្សទាំងឡាយមានសមត្ថភាពនៅក្នុងខ្លួនរបស់ខ្លួន សម្រាប់រចនាកែច្នៃជីវិតរបស់ខ្លួនតាមប្រឡាយឆន្ទៈ" ។ ពួកគាត់បែរជានាំគ្នាចុះចាញ់វិរិយភាព ខ្វះសេចក្តីក្លាហាន បន្ថោកបន្ទាបអត្តភាពរបស់ខ្លួន សុខចិត្តទៅធ្វើជាអាយ៉ងរបស់ព្រះព្រហ្មបណ្តោយឱ្យព្រះព្រហ្មចារព្រេងវាសនារបស់ខ្លួនតាមព្រះទ័យ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងសុភាសិតថា **អត្តាហិ អត្តនោ នាថោ** ខ្លួនទីពឹងខ្លួន ទេវតា ឥន្ទព្រហ្ម ពុំមែនជាទីពឹងរបស់យើង

ទេ ។ នៅក្នុងមហានិព្វានសូត្រ ព្រះអង្គសម្តែងដល់សាវ័កព្រះអង្គ ថា៖ "**ភិក្ខវេ អត្តទីបា វិហរថ អត្តសរណា អនញ្ញសរណា**" ប្រែថា "ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយចូរយកខ្លួនជាកោះពឹងខ្លួនឯង ចូរយកខ្លួនជាទីពឹង ចូរកុំយកអ្នកដទៃមកធ្វើជាទីពឹងខ្លួនឡើយ " ។

ជាអវសាន ខ្ញុំសូមឱ្យមិត្រអ្នកអាន បានជួបប្រទះនូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ ។

សូមឱ្យព្រះពុទ្ធសាសនា គង់វង្សស្ថិតស្ថេរ នៅបានយឺនយូរគ្រប់កំណត់ ៥.០០០ ព្រះវស្សា ដើម្បីជាម្លប់សាខាត្រជាក់ត្រជុំដល់សត្តនិករ ក្នុងត្រៃភព ។

សូមឱ្យព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្នុងសុខសន្តិភាព ប្រាសចាកសង្គ្រាមជានិច្ចនិរន្តរ៍ ។ សូមឱ្យវឌ្ឍនភាព សុខុមាលភាព សុភមង្គល កើតមានដល់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។ សូមឱ្យជម្ងឺកាចសាហាវផ្សេងៗដែលកំពុងរាតត្បាតពិភពលោក និងគ្រោះថ្នាក់ធម្មជាតិទាំងឡាយ បរវៀសចៀសឆ្ងាយពីដែនដីខ្មែរ ។

**សព្វេ សត្តា អវេរិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយទាំងពួង កុំឱ្យមានពៀរនឹងគ្នា,

**សព្វេ សត្តា ខេមិនោ ហោន្តុ**

**អាមិសទាន & ធម្មទាន**

*សូមសត្វលោកទាំងឡាយទាំងពួង    បានដល់នូវសេចក្តីក្សេមក្សាន្ត ,*

**សព្វេ សត្តា សុខិនោ ហោន្តុ**

*សូមសត្វលោកទាំងឡាយទាំងពួង    បានប្រកបដោយសេចក្តីសុខជានិច្ចនិរន្តរ៍ ។*

# ចប់ដោយសន្តិ

សរសេរចប់នៅឡុងប៊ិច រដ្ឋកាលីហ្វញ៉ា ស. អ.រ.

**Long Beach, California U. S. A.**

ថ្ងៃ ៣ រោជ ខែអស្សុជ ឆ្នាំ ខាលទោស័ក ព.ស.២៥៥៤

ត្រូវនឹងថ្ងៃទី២៦ ខែ តុលា គ.ស ២០១០

***October 26, 2010***

# ឈុន- គឹមអៀត

**មនុស្សជាស្ថាបនិកនៃជោគវាសនារបស់ខ្លួន**

*Every man is the architect of his own fate .*

# ឈ្មោះសៀវភៅដែលខ្ញុំបានដកស្រង់

មង្គលត្ថទីបនីប្រែ ភាគ ១ - ៤ ភិក្ខុវិនយធរោ យិន នឿន

គាថាធម្មបទប្រែ ភិក្ខុវិនយធរោ មហា យិន នឿន

ទានកថា ព្រះបាឡាត់ឃោសនាគ ហែម ចៀវ

ទានទស្សនៈ ភិក្ខុធម្មបាល ខៀវ ជុំ

ពន្លឺធម្មទេសនា រៀបរៀងដោយ ជយានន្ទោ ជួន ចិន្តា

// ចន្ទត្ថេរោ ខួន សារ៉ុន

ឧបនិស្ស័យ ដោយ មិញ សារ៉ាន

សាសនសុភាសិត ភាគ ១- ២-៣ ពុទ្ធសាសនណ្ឌិត្យ

អត្ថាធិប្បាយ សាសនសុភាសិត សែម សូរ

ទ្រឹស្តីកម្មផល ដោយ ឈុន គឹមអៀត

ព្រះពុទ្ធដីកា // ឈុន គឹមអៀត

បុណ្យប្រពៃណី ដោយ ធឹង ផាន់ សុផុន

ពន្លឺពុទ្ធសាសនា ដោយ សោម ង៉ន

ពុទ្ធសាសនា ២៥០០ ដោយ ពុទ្ធសាសនបណ្ឌិត្យ

Buddhism By Richard .A. Gard

Buddha the Intelligent Heart By Alistair Shearer

# សេចក្តីជូនដំណឹង

*បើពុទ្ធបរិស័ទត្រូវការសៀវភៅ* **អាមិសទាន & ធម្មទាន** *នេះ ចែកជាធម្មទាន សូមទាក់ទងជាមួយនឹង:*

-*ភិក្ខុមហា* **ឃិន ឡឿន** *វត្តសាន់តាអាណា*

2630 N Grand Ave. Santa Ana, CA 92705 ( U.S.A. )

*ទូរស័ព្ទ:* ( 714 ) 744-2834

-*លោក* **ខ៉ូវ តា** *ផ្ទះលេខ:* 256 *ក្រុមទី ១ ភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។*

*ទូរស័ព្ទ*: 012-726-856

-*លោក* **ហុង ម៉ូហ៊ីន** *ផ្ទះលេខ:* 13 FE. *ផ្លូវលេខ* 146 *សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា ភ្នំពេញ ។*

*ទូរស័ព្ទ:* 012-245-476 .

*សៀវភៅ* **អាមិសទាន** & **ធម្មទាន** *នេះ មានចុះផ្សាយក្នុងគេហទំព័រ*: http: // Dhamma4 Khmer 2.org .

# បញ្ជីរាមនាមពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លា ចូលបច្ច័យ បោះពុម្ពផ្សាយ ចែកចាយជាធម្មទាន នៅលើកទី១ នេះ

| | |
|---|---|
| លោក ឈុន -គឹមអៀត និង អ្នកស្រី តូ - ប៊ុនឡាំ | ៥០០ ដុ |
| ឯកឧត្តម ហុង -ទូហាយ និង លោកជំទាវ តាន់ - គឹមស៊ន់ | ៥០០ ដុ |
| ឧបាសក ឈុន -ស៊ឺ ឧបាសិកា គី - ឈីវអ៊ី ព្រមទាំងបុត្រ | ៣០០ ដុ |
| ឧបាសក សេក - ម៉ូវ និង ឧបាសិកា សារិទ្ធ -ធំម | ៣០០ ដុ |
| លោក នូ - សំបាន និង អ្នកស្រី នូសំបូរ | ៣០០ ដុ |
| លោកហុង - កុកហ៊្វរ និង អ្នកស្រី ទី -ហុងសាម៉ុន | ៣០០ ដុ |
| លោក ភាត - សុខុម និង អ្នកស្រី កុល -មល្លិកា | ៣០០ ដុ |
| លោក ង៉ូវ - គា និង អ្នកស្រី ឈុន - គឹមអេង | ៣០០ ដុ |
| លោក ឈុន - សុភាន និង អ្នកស្រី សំ- ផល្លី | ២០០ ដុ |
| លោក ឈួន - ច័ន្ទ ធាយា និង អ្នកស្រី សេង - សំណាង | ២០០ ដុ |
| លោក ដាញ់ - វិរ៉ាវុឌ្ឍ និង អ្នកស្រី ឡេង - សម្ព័ណ | ២០០ ដុ |
| ឧបាសក ឡូ - ប៊ុនឡេង និង ឧបាសិកា អៀប - ផៃគីម | ២០០ ដុ |
| អ្នកស្រី ហុង - គីមហ៊ោ ព្រមទាំងបុត្រ | ២០០ ដុ |
| លោក យិន - គាត និង អ្នកស្រី ចាន់ - សានិត | ១០០ ដុ |
| ឧបាសិកា ម៉ៅ - កាក់ ព្រមទាំងបុត្រ | ១០០ ដុ |
| លោក ង៉ូវ - វេងគង់ និង អ្នកស្រី ឈុន - ថារេត | ១០០ ដុ |
| លោក លឹម - សេប៉ាង និង អ្នកស្រី អ៊ីវ - ប៉ុកនី | ១០០ ដុ |

**អាមិសទាន & ធម្មទាន**

ភិក្ខុមហា យិន នឿន ១០០ ដុ

ឧបាសិកា អៀប - ឆៃហុង ១០០ ដុ

លោក អ៊ី - លី និង អ្នកស្រី ទ្រី - ចន្ទ្រា ១០០ ដុ

លោក តាន់ - កុកហ៊ុន អ្នកស្រី តោ -គីមប៉ាវ និង បុត្រ ១០០ ដុ

លោក ហាក់ - មេង និង អ្នកស្រី តាំង - ស៊ូគាង ១០០ ដុ

លោក លឹម - សៀកអាំង និង អ្នកស្រី លឹម - សុខង៉ោ ១០០ ដុ

លោក BOB និង អ្នកស្រី ហុង - គីមហ៊ូរ ព្រមទាំងបុត្រ ១០០ ដុ

លោក សេង -យន់ អ្នកស្រី គីម - ហាន់ ព្រមទាំងបុត្រ ១០០ ដុ

លោក ធន - គឹមហាន់ និង អ្នកស្រី គីម - ឈឿង ១០០ ដុ

ឧបាសិកា ឃិន - សារ៉ាត ព្រមទាំងបុត្រ ១០០ ដុ

លោក លឹម - វ ស៊ាង ១០០ ដុ

លោក ខៀវ - ស៊ីណារេត និង អ្នកស្រី ឡាង - រ៉ាន់នីសា ១០០ ដុ

លោក តោប៊ុន - ហ៊ុយ និង អ្នកស្រី សុខ - ថាន ១០០ ដុ

ឧបាសក ថោ - ឃៀម ឧបាសិកា ខ្ទៅ - កែវ និង បុត្រ ១០០ ដុ

លោក សៅ -សាត អ្នកស្រី ហង្ស - សុខលីន និង បុត្រី ១០០ ដុ

លោក គឹម - ពិសិដ្ឋ និង អ្នកស្រី ចៅ - សារ៉ាន ១០០ ដុ

លោក ឱក - គឹមអាន និង អ្នកស្រី ម៉ឹង - ផល្លា ៧០ ដុ

លោក គូ - ស៊ុំរាំងសាន និង អ្នកស្រី ប៉េង - ណារី ៥០ ដុ

| | |
|---|---|
| អ្នកស្រី ឡុក - ម៉ៅ ព្រមទាំងបុត្រ | ៥០ដុ |
| ឧបាសិកា តាន់ - ឡើយ ព្រមទាំងបុត្រ | ៥០ ដុ |
| អ្នកស្រី ចាន់ - កែម ព្រមទាំងបុត្រ | ៥០ ដុ |
| ឧបាសក ពា - ប៉ាវស៊្រុ និង ឧបាសិកា នូវ - ឡុក | ៥០ ដុ |
| លោក អ៊ាប - ហៃសាន និង អ្នកស្រី ឡឹក - ពេញចិត្ត | ៥០ ដុ |
| លោក ហ៊ិល - ប៉ុណ្យ និង អ្នកស្រី ទេស - ទៀន | ៥០ ដុ |
| លោក ហួត - យូហេង និង អ្នកស្រី ហួត - ជីតា | ៥០ ដុ |
| លោក ហួត - អេងលី និង អ្នកស្រី អេង - ទិតឡេង | ៥០ ដុ |
| ឧបាសិកា សំ - សោភ័ណ ព្រមទាំងបុត្រ | ៥០ ដុ |
| វិជ្ជបណ្ឌិត ឈឹម - ប៉េម៉ី អ្នកស្រី សូ - វណ្ណថា ហៅមុំ | ៥០ ដុ |
| លោក នូ - យុទ្ធារៈ និង អ្នកស្រី ហុង - គឹមណា | ៥០ ដុ |
| លោក អ៊ឹង - កុសល និង អ្នកស្រី ហុង - គឹមនី | ៥០ ដុ |
| លោក Lance និង អ្នកស្រីហុង- គឹមណាន | ៥០ ដុ |
| លោក ង៉ូវ - វេងអាង | ៥០ ដុ |
| កញ្ញា ង៉ូវ - វេងណាង | ៥០ ដុ |
| ឧបាសក មុត -មឿន ឧបាសិកា ជា -យន | ៥០ ដុ |
| លោក ជា -កែវ បូរិន និង អ្នកស្រី សាន -សុខា | ៥០ ដុ |
| គឹម - ឡាង ព្រមទាំងបុត្រ | ៤០ ដុ |

**អាហារាមិសទាន & ធម្មទាន**

| | |
|---|---|
| សូ - ណាម ព្រមទាំងបុត្រ | ៣០ ដុ |
| អ៊ឹង - តាំងហ៊ាង ព្រមទាំងបុត្រ | ៣០ ដុ |
| អ្នកស្រី អ៊ុក - ចន្ទថេត | ២៥ ដុ |
| អ្នកស្រី គួច -មុយ ហ្គេច ព្រមទាំងបុត្រ | ២០ ដុ |
| រស់ - ផឹងវត្តី ព្រមទាំងបុត្រ | ២០ ដុ |
| គឹម -អ៊ុល ព្រមទាំងបុត្រ | ២០ ដុ |
| ឧបាសិកា ងី - ឆេ | ២០ ដុ |
| អ្នកស្រី ហួត - សារិន ព្រមទាំងបុត្រ | ២០ ដុ |
| លោក ហេង -យូឡា និង អ្នកស្រី លីម - អ៊ាប | ២០ ដុ |
| លោក វុន - ស្រមោល និង អ្នកស្រី សៀង - ចន្ធូ | ២០ ដុ |
| លោក សេក - ពុទ្ធិរិទ្ធ និង អ្នកស្រី បុន្នីដា | ២០ ដុ |
| លោក ជុំ - ង៉ិ និង អ្នកស្រី វន | ២០ ដុ |
| ឧបាសក ចក់ - ម៉ន និង ឧបាសិកា ឡុង - វី | ១៥ ដុ |
| អ្នកស្រី សយ - ឡូម ព្រមទាំងបុត្រ | ១០ ដុ |
| អ្នកស្រី សយ - សារឿត ព្រមទាំងបុត្រ | ១០ ដុ |

សូមសប្បុរសជន អនុមោទនាផលានិសង្ស ដែលកើតឡើងពីធម្មទាននេះ ដោយចិត្តប្រាមោទ្យ ជ្រះថ្លា ប្រាថ្នាយ៉ាងណា សូមបានសម្រេចដូចគោលបំណង ៕

| | |
|---|---|
| សូ-ណាម ព្រមទាំងបុត្រ | ៣០ដុ |
| អ៊ីង-តាំងហ៊ាង ព្រមទាំងបុត្រ ព្រមទាំងបុត្រ | ៣០ដុ |
| អ្នកស្រី អ៊ុក-ចន្ទថេត | ២៥ដុ |
| អ្នកស្រី គួច-មុយហ្គេច ព្រមទាំងបុត្រ | ២០ដុ |
| រស់-ផឹងវត្តី ព្រមទាំងបុត្រ | ២០ដុ |
| គឹម-អ៊ុល ព្រមទាំងបុត្រ | ២០ដុ |
| ឧបាសិកា ង៉ី-ឆេ | ២០ដុ |
| អ្នកស្រី ហួត-សារិន ព្រមទាំងបុត្រ | ២០ដុ |
| លោក ហេង-យូឡា និង អ្នកស្រី លីម-អ៊ាប | ២០ដុ |
| លោក វុន-ស្រមោល និងអ្នកស្រី សៀង-ចន្ទូ | ២០ដុ |
| លោក សេក-ពុទ្ធិរិទ្ធ និង អ្នកស្រី បុន្នីដា | ២០ដុ |
| លោក ជុំ-ង៉ិ និង អ្នកស្រី វន | ២០ដុ |
| ឧបាសក ចក់-ម៉ន និង ឧបាសិកា ឡុង-រី | ១៥ដុ |
| អ្នកស្រី សយ-ឡុម ព្រមទាំងបុត្រ | ១០ដុ |
| អ្នកស្រី សយ-សារឿត ព្រមទាំងបុត្រ | ១០ដុ |

សូមសប្បុរសជន ទទួលនូវផលានិសង្សដែលកើតឡើងពីធម្មទាននេះ ដោយចិត្តប្រាមោទ្យ ជ្រះថ្លា ប្រាថ្នាយ៉ាងណា សូមឲ្យបានសម្រេចដូចបំណង ។

សូមសេរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរ កើតមានឡើង ដល់អស់លោកអ្នក ជាពុទ្ធបរិស័ទ ជានិច្ចនិរន្តរ៍ រហូតកាលាវសាន ។

**សព្វទានំ ធម្មទានំ ជិនាតិ**

*ធម្មទាន ឈ្នះអស់ទានទាំងពួង ។*

**មនាបទាយី លភតេ មនាបំ**

*អ្នកឲ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្តវិញ ។*

**សេដ្ឋន្ទទោ សេដ្ឋមុបេតិ ឋានំ**

*អ្នកឲ្យទីឋានដ៏ប្រសើរ រមែងចូលទៅដល់ទីឋានដ៏ប្រសើរ ។*

**នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា**

*កាលបើចិត្តជ្រះថ្លាហើយ ទក្ខិណាទានមិនឈ្មោះថាតិចតួចឡើយ។*

**វិចេយ្យ ទានំ សុគតប្បសត្ថំ**

*ពិចារណាហើយឲ្យ ព្រះសុគតទ្រង់សរសើរ ។*

# ដំណឹងពិសេស

*សៀវភៅនេះត្រូវអានថតសម្លេងបញ្ចូលក្នុងបន្ទះស៊ីឌី* CD *សម្រាប់ចែកជាធម្មទានសូមទាក់ទង លោក* **លឹម រស៊ាង** *នៅ* U S A *តាមទូរសព្ទ លេខ* (714) 580-5339

## សព្វទានំ ធម្មទានំ ជិនាតិ
## ធម្មទានឈ្នះអស់ទានទាំងពួង

**The gift of Dhamma surpasses all other gifts.**

**សព្វរសំ ធម្មរសោ ជិនាតិ**

រសធម៌រមែងឈ្នះរសទាំងពួង

**សព្វរតឹ ធម្មរតិ ជិនាតិ**

អំណរក្នុងធម៌ រមែងឈ្នះអំណរទាំងពួង

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ**

ការអស់តណ្ហា រមែងឈ្នះទុក្ខទាំងពួង

**ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជិយ្យតិ**

ជំនះណាត្រឡប់ចាញ់វិញ ជំនះនោះជាជំនះមិនល្អឡើយ

**តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជីយ្យតិ**

ជំនះណាមិនត្រឡប់ចាញ់វិញ ជំនះនោះឯងជាជំនះល្អ

**សីលជាស្ពាន ទានជាស្បៀង**
**ភាវនាជាថ្មសំលៀង បញ្ញាជាអាវុធ ។**

ស្រវឹងទ្រព្យភ្លេចបុណ្យ ស្រវឹងប្រពន្ធភ្លេចម្ដាយ ស្រវឹងកាយភ្លេចចាស់